# ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sports


**វិទ្យាស្ថានជាតិអប់រំ**

National Institute of Education


# និក្ខេបបទ

# ទស្សនៈគណៈគ្រប់គ្រង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនពីការប្រើប្រាស់វិធីសាស្រ្តបង្រៀន និងរៀនបែបរិះរកនៅសាលាមធ្យមសិក្សាទុតិយភូមិក្នុងខេត្តកណ្តាល

PERSPECTIVES OF PRINCIPALS, TECHNICAL TEAM LEADERS AND TEACHERS ON THE USE OF INQUIRE-BASED LEARNING AT HIGH SCHOOL IN KANDAL PROVINCE


**ធឿង ឃន**

THOEUNG KHORN


**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៨**

**ឯកទេសៈ គ្រប់គ្រងអប់រំ**

**ឆ្នាំសិក្សា ២០១៩-២០២១**

ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sports

វិទ្យាស្ថានជាតិអប់រំ

National Institute of Education


# និក្ខេបបទ

## ទស្សនៈគណៈគ្រប់គ្រង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនពីការប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនបែបរិះរកនៅសាលាមធ្យមសិក្សាទុតិយភូមិក្នុងខេត្តកណ្ដាល

## Perspectives of Principals, Technical Team Leaders and Teachers on the Use of Inquire-Based Learning at High School in Kandal province


**ធឿង ឃន**

THOEUNG KHORN


**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៨**

**ឯកទេស: គ្រប់គ្រងអប់រំ**

**ឆ្នាំសិក្សា ២០១៩-២០២១**

# សេចក្តីអះអាងរបស់បេក្ខជន

ខ្ញុំបាទសូមបញ្ជាក់ថានិក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា «ទស្សនៈគណៈគ្រប់គ្រងប្រធានបច្ចេកទេស និងគ្រូបង្រៀនស្តីពី ការប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនបែបរិះរកនៅសាលាមធ្យមសិក្សាទុតិយភូមិក្នុងខេត្តកណ្តាល» សម្រាប់បំពេញបរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំគឺជាស្នាដៃរបស់ខ្ញុំបាទទាំងស្រុង។ ស្នាដៃនេះពុំទាន់បានប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសិក្សា សម្រាប់ទទួលបានសញ្ញាបត្រនៅវិទ្យាស្ថានជាតិអប់រំ សាកលវិទ្យាល័យ ឬវិទ្យាស្ថាននានា ដែលមានសញ្ញាបត្រស្មើឡើយ។ ក្នុងការសរសេរអត្ថបទស្រាវជ្រាវនេះពុំមានសេចក្តីដកស្រង់ ឬខ្លឹមសារមួយណាដែលត្រូវបានប្រើប្រាស់ដោយគ្មានការអនុញ្ញាតិពីអ្នកនិពន្ធ ឬចុះបញ្ជីក្នុងឯកសាយោងឡើយ។

និក្ខេបបទខាងលើនេះពិតជាត្រូវបានស្រាវជ្រាវ និងចងក្រងឡើងដោយខ្ញុំបាទផ្ទាល់ពិតប្រាកដមែន។

ថ្ងៃ...............ខែ.............ឆ្នាំ..........ពុទ្ធសករាជ ២៥៦៥

រាជធានីភ្នំពេញ,ថ្ងៃទី............ខែ.........ឆ្នាំ២០២១

**ហត្ថលេខា**

**ឡឿង ឃន**

# លិខិតបញ្ជាក់

**លោក ឡុច ចាន់ថន គ្រូដឹកនាំបង្គោល**

**បណ្ឌិត នី រដ្ឋា គ្រូដឹកនាំរង**

## សូមបញ្ជាក់ និងទទួលស្គាល់ថា

លោក ធឿង ឃន ជានិស្សិតបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៨ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា «ទស្សនៈគណៈគ្រប់គ្រង ប្រធានបច្ចេកទេស និងគ្រូបង្រៀនស្តីពី ការប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនបែបរិះរក នៅសាលាមធ្យមសិក្សាទុតិយភូមិក្នុងខេត្តកណ្ដាល» ពិតប្រាកដមែន។

ថ្ងៃ..............................ខែ.....................ឆ្នាំ..............ពុទ្ធសករាជ ២៥៦៥

រាជធានីភ្នំពេញ,ថ្ងៃទី...........ខែ........ឆ្នាំ២០២១

.................................... ....................................

**លោក ឡុច ចាន់ថន**
មន្ត្រីដេប៉ាតឺម៉ង់គ្រប់គ្រង និងផែនការ

**បណ្ឌិត នី រដ្ឋា**
ប្រធានការិយាល័យសិក្សា

# លិខិតឧទ្ទេនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខៈ ៣២០៥ អយក. ១ ១៨

(ការសម្ងាត់)

**លិខិតឧទ្ទេសនាម**

យោង ៖ -លិខិតលេខ១៤៣៤ អយក.ឧទន ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១។
-បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។
-ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៨ និងទី៩ ឆ្នាំសិក្សា២០២០-២០២១ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២១។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទ** ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៨ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី១៤-១៥ ខែវិច្ឆិកា ឆ្នាំ២០២១ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តមបណ្ឌិត | ជ័យ សារិន | អគ្គាធិការដ្ឋាន | ប្រធាន |
| ២-ឯកឧត្តមបណ្ឌិត | សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៣-ឯកឧត្តមបណ្ឌិត | ឌី ខាំបូលី | វិទ្យាស្ថានជាតិអប់រំ | អនុប្រធាន |
| ៤-លោកបណ្ឌិត | ឈូក ច័ន្ទធាយា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៥-ឯកឧត្តម | នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ៦-លោក | ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៧-លោកបណ្ឌិត | នូវ វីរ៉ា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-លោកស្រី | ប៊ុន សុផានី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៩-លោក | ថៃ ហេង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១០-លោកបណ្ឌិត | សំអោ អង្គារតន៍ | អគ្គ.គផក | សមាជិក |
| ១១-ឯកឧត្តមបណ្ឌិត | ម៉ុក សារ៉ុម | អគ្គ.អប់រំ | សមាជិក |
| ១២-លោក | ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោកបណ្ឌិត | នី រដ្ឋា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៤-លោក | ម៉ៅ សារឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៥-លោក | ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៦-លោក | លឹម វ៉ាន់ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៧-លោកបណ្ឌិត | ម៉ម ចាន់សៀន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៨-លោកបណ្ឌិត | ឈាង សង្វាត | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៩-លោកបណ្ឌិត | អាន វ៉ូប្រាវ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២០-លោកបណ្ឌិត | កាង ស៊ុងឆាង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២១-លោក | ប៉ូ ប៊ុន្នន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

| | | | |
|---|---|---|---|
| ២២-លោកស្រី | ខែក សំណាង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៣-លោក | សៀង វាសនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៤-លោកស្រី | នូ ចន្នី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៥-លោក | ឡុច ចាន់ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៦-លោក | លន លីណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៧-លោក | ចាន់ ធឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៩-ល.ស | សុខ វណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៨-លោក | ជាង ចាន់ណាក់ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៣០-លោក | អ៊ុច ផលរដ្ឋ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតពីថ្ងៃទី១៤-១៥ ខែវិច្ឆិកា ឆ្នាំ២០២១ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ ពុធ ៥កើត ខែកត្តិក ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ១០ ខែ វិច្ឆិកា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**កន្លែងទទួល៖**

-អគ្គនាយដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
-ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
"ដើម្បីជ្រាបជាព័ត៌មាន"
-គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ
"ដើម្បីជ្រាបជាព័ត៌មាន"
-សាមីខ្លួន "ដើម្បីអនុវត្ត"
-កាលប្បវត្តិ -ឯកសារ វជអ

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **ជឿង យន** ជានិស្សិតបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៨ នៃវិទ្យាស្ថានជាតិអប់រំ ឆ្នាំសិក្សា ២០១៩-២០២១ ពិតជាមានសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ដោយបានបញ្ចប់ការស្រាវជ្រាវនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ដោយជោគជ័យ។ ជាមួយនឹងលទ្ធផលដ៏ត្រចេះត្រចង់នេះ ខ្ញុំបាទមិនភ្លេចផងដែរ ចំពោះការជួយជ្រោមជ្រែងគាំទ្រ និងយកចិត្តទុកដាក់ពីមជ្ឈដ្ឋានជាច្រើន។ ខ្ញុំបាទសូមគោរពថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះ៖

- លោកអ្នកមានគុណទាំងពីរគឺលោកឪពុក **ផាំង ថន** និងអ្នកម្តាយ **ប្រេវ អាំង** ដែលបានផ្តល់កំណើត ផ្តល់ដំបូន្មានល្អ ខិតខំចិញ្ចឹមបីបាច់ថែរក្សា និងតស៊ូផ្គត់ផ្គង់ឱ្យកូនបានសិក្សារហូតមកដល់ពេលនេះ។
- ភរិយា **មឿន សុខចាន់** ដែលបានផ្តល់ពេលវេលា គាំទ្រទាំងកម្លាំងចិត្ត និងថវិកាក្នុងការសិក្សា
- បងៗ និងប្អូនៗ ទាំងប្រាំមួយនាក់ដែលបានផ្តល់ការលើកទឹកចិត្ត និងថវិកាខ្លះគាំទ្រដល់ការសិក្សារៀនសូត្រ ដើម្បីលើកកិត្តិយសគ្រួសារ។
- ក្រសួងអប់រំ យុវជន និងកីឡា វិទ្យាស្ថានជាតិអប់រំ និងដៃគូពាក់ព័ន្ធទាំងអស់ក្នុងវិស័យអប់រំ។
- គណៈកម្មការគ្រប់គ្រងការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ នៃវិទ្យាស្ថានជាតិអប់រំ ព្រមទាំងលោកសាស្ត្រាចារ្យទាំងអស់ដែលបានខិតខំចំណាយពេលវេលាដ៏មានតម្លៃមកបង្ហាត់បង្រៀន និងពន្យល់ផ្ទាល់គ្រប់មេរៀនដល់ខ្ញុំបាទទាំងអស់គ្នាដោយមិនគិតពីការលំបាកនឿយហត់ឡើយ។
- លោក **ឡុច ចាន់ថន** គ្រូដឹកនាំបង្គោល និងលោក**បណ្ឌិត នី រដ្ឋា** គ្រូដឹកនាំរង ដែលតែងតែចំ ណាយពេលដ៏មានតម្លៃដើម្បីណែនាំ ពន្យល់ និងផ្តល់អនុសាសន៍ល្អដល់រូបខ្ញុំតាំងពីដើមរហូត មកទើបធ្វើឱ្យការសិក្សាស្រាវជ្រាវរបស់ខ្ញុំបាទទទួលបានជោគជ័យនៅពេលនេះ។
- គ្រូបង្រៀនដែលបានបង្ហាត់បង្រៀនខ្ញុំតាំងពីបឋមសិក្សារហូតដល់បរិញ្ញាបត្រជាន់ខ្ពស់។

- មិត្តភក្តិទាំងអស់ ក៏ដូចជាមិត្តរួមថ្នាក់ រួមជំនាន់ទី ៨ទាំងអស់ ដែលតែងតែផ្តល់កម្លាំងចិត្ត និងចែករំលែកឯកសារក៏ដូចជាចំណេះដឹងដល់រូបខ្ញុំបាទ។
- លោកនាយក/នាយិកា គ្រូបង្រៀន និងសិស្សានុសិស្សសាលាគោលដៅទាំងអស់ ដែលបានជួយបំពេញកម្រងសំណួរខ្ញុំបាទ។
- លោកនាយក នាយករង នៃវិទ្យាល័យ ហ៊ុន សែន អង្គស្នួល ដែលបានរៀបចំសម្រួលកាលវិភាគឱ្យមានភាពងាយស្រួលដល់រូបខ្ញុំបាទដើម្បីបន្តការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់នេះ។

សូមគោរពប្រសិទ្ធិពរជ័យជូនចំពោះ លោកឪពុក អ្នកម្តាយ ភរិយាជាទីស្រលាញ់ ឯកឧត្តម សាស្ត្រាចារ្យ លោក លោកស្រី ទាំងអស់មានសុខភាពល្អ កម្លាំងមាំមួន សមប្រកបតាមបំណងប្រាថ្នា ដែលបានប៉ុនប៉ងសច្ចា ដើម្បីបន្តដឹកនាំ កសាងធនធានមនុស្សទៅថ្ងៃអនាគត។

# មូលន័យសង្ខេប

រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញយុទ្ធសាស្ត្រចតុកោណដំណាក់ទី៤ដោយកំណត់ **ការអភិវឌ្ឍធនធានមនុស្ស និងការអប់រំ** គឺវិស័យអាទិភាពក្នុងចំណោមវិស័យផ្សេងៗទៀតនៃយុទ្ធសាស្ត្រចតុកោណ។ ក្នុងនោះដែរ ក្រសួងអប់រំ យុវជន និងកីឡាបានប្ដេជ្ញាចិត្តសម្រេចឱ្យបាននូវមុំទី១នៃចតុកោណទី១ លើ « **ការអភិវឌ្ឍធនធានមនុស្ស**» បានចែងថា «ការពង្រឹងគុណភាពវិស័យអប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា»។ មូលដ្ឋានគ្រឹះនៃការពង្រឹងគុណភាពអប់រំគឺត្រូវផ្ដើមចេញពី **ការប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនដែលអនុវត្តដោយគ្រូបង្រៀនគ្រប់កម្រិតសិក្សាទាំងអស់ ឱ្យសមស្របទៅនឹងតម្រូវការជាក់ស្ដែងរបស់សិស្ស និងដំណើរការបច្ចុប្បន្នភាពស្ដីពីការបង្រៀន និងរៀននៃសតវត្សទី២១នេះ**។

ការបង្រៀន ជាមាគ៌ាក្នុងការផ្ដល់ចំណេះដឹងដល់សិស្សតាមរយៈការប្រើប្រាស់វិធីសាស្ត្រ ល្បិចកិចកល ដើម្បីឱ្យសិស្សមានការអភិវឌ្ឍផ្នែកបញ្ញាស្មារតី និងរាងកាយ។ វិធីសាស្ត្របង្រៀន គឺជាល្បិច ជាមធ្យោបាយធ្វើឱ្យការងាររបស់គ្រូបង្រៀន និងសិស្សក្រោមការដឹកនាំរបស់គ្រូ សិស្សទទួលបាននូវចំណេះដឹង ចំណេះធ្វើ និងបំណិន ចេះរស់នៅជាមួយគ្នា ព្រមទាំងពង្រីកសតិបញ្ញាស្មារតីសិស្សសំដៅទៅលើកម្ពស់ការប្រតិបត្តិគ្រប់ភារកិច្ចនៃការបង្រៀន។ គ្រូបង្រៀនដ៏អស្ចារ្យម្នាក់មិនធ្វើរឿងអ្វីមួយដោយគ្មានគោលបំណងឡើយ។ គ្រប់សកម្មភាពរាល់ការបង្រៀន រាល់កំណត់ត្រា មានហេតុផលច្បាស់លាស់។ យុទ្ធសាស្ត្រទាំងនេះត្រូវបានកំណត់មួយផ្នែកលើខ្លឹមសារនៃមេរៀនដែលត្រូវបង្រៀន និងមួយផ្នែកទៀតផ្អែកលើធម្មជាតិរបស់អ្នកសិក្សា។

សម្រាប់វិធីសាស្ត្របង្រៀនជាក់លាក់មួយសមស្រប និងមានប្រសិទ្ធភាពត្រូវតែទាក់ទងទៅនឹងចរិតលក្ខណៈរបស់អ្នកសិក្សា និងប្រភេទនៃការរៀនដែលសិស្សម្នាក់ៗមាន។ ដើម្បីរៀបចំ និងជ្រើសរើសវិធីសាស្ត្របង្រៀនគ្រូបង្រៀនមិនត្រឹមតែគិតពីលក្ខណៈនៃខ្លឹមសារមេរៀនប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងគិតអំពីរបៀបដែលសិស្សរៀនទៀតផង។ ការលើកទឹកចិត្តឱ្យមានការច្នៃប្រឌិត និងការអភិវឌ្ឍធនធានមនុស្សកើតឡើងតាមរយៈការត្រិះរិះរកហេតុផល។ ការត្រិះរិះរកហេតុផល និងការបញ្ចេញទស្សនៈគឺជាការបង្កើនការច្នៃប្រឌិត។ ដើម្បីសម្រេចបាននូវការប្រើប្រាស់វិធីសាស្ត្របង្រៀនមួយសមស្រប និងមានប្រសិទ្ធភាពខ្ពស់

ទាមទារឱ្យគណៈគ្រប់គ្រង ស្ថាប័នអប់រំគ្រប់កម្រិត ជាពិសេសគឺនាយកសាលា និងប្រធានក្រុមបច្ចេកទេស ត្រូវមានចំណេះដឹង និងយល់ច្បាស់អំពីវិធីសាស្ត្របង្រៀន និងរៀន សម្រាប់ចង្អុលបង្ហាញដល់គ្រូបង្រៀន ក៏ដូចជាសិក្សានុសិស្សឱ្យមានប្រសិទ្ធភាពខ្ពស់ក្នុងការអនុវត្ត។

ដោយមើលឃើញពីសារៈសំខាន់នៃការប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀន ទើបអ្នកសិក្សាស្រាវជ្រាវសម្រេចជ្រើសរើសប្រធានបទសម្រាប់សរសេរនិក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា **«ទស្សនៈគណៈគ្រប់គ្រង ប្រធានបច្ចេកទេស និងគ្រូបង្រៀនពីការប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនបែបរិះរកនៅសាលាមធ្យមសិក្សាទុតិយភូមិក្នុងខេត្តកណ្តាល»**។

ការសិក្សាស្រាវជ្រាវនេះមានគោលបំណងស្វែងយល់ពីទស្សនៈរបស់គណៈគ្រប់គ្រង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនពីការប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនបែបរិះរក និងពិនិត្យមើលបញ្ហាប្រឈមនានាក្នុងការប្រើប្រាស់«វិធីសាស្ត្របង្រៀន និងរៀនបែបរិះរក» នេះនៅសាលាមធ្យមសិក្សាទុតិយភូមិ។ ជាមួយគ្នានេះដែរ ដើម្បីចូលរួមដោះស្រាយ និងជម្រុញឱ្យការប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនបែបរិះរកឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់បន្ថែមទៀត។

តាមលទ្ធផលនៃការសិក្សានេះបានបង្ហាញថា ទស្សនៈយល់ឃើញរបស់គណៈគ្រប់គ្រង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនពុំសូវមានលក្ខណៈខុសគ្នាប៉ុន្មាននោះទេ។ ពួកគាត់ទាំងអស់យល់ឃើញថា ការប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនបែបរិះរក របស់គ្រូបង្រៀនពុំទាន់មានលក្ខណៈទូលំទូលាយ និងផុសផុលនោះទេ ពីព្រោះកម្រិតយល់ដឹងលើការប្រើប្រាស់វិធីសាស្ត្រនេះនៅមានកម្រិតទាបនៅឡើយ។

គ្រូបង្រៀនមួយចំនួនពុំទាន់បានឆ្លងកាត់វគ្គបណ្តុះបណ្តាលស្តីពីវិធីសាស្ត្របង្រៀន និងរៀនតាមបែបរិះរកនៅឡើយ ហើយគ្រូបង្រៀនមួយចំនួនទៀត ទោះបីជាធ្លាប់ឆ្លងកាត់វគ្គបណ្តុះបណ្តាលក៏ដោយក៏ពួកគាត់មិនអាចប្រើវិធីសាស្ត្រនេះឱ្យបានទូលំទូលាយដែរ។ គ្រូបង្រៀនមួយចំនួនទៀត ខ្វះឆន្ទៈក្នុងការប្រើប្រាស់ ពួកគាត់ទាំងនោះអនុវត្តទៅតាមទម្លាប់ដែលធ្លាប់បានធ្វើពីមុនៗមក។

ចំពោះនាយក/នាយិកា នាយករង/នាយិការង ប្រធានក្រុមបច្ចេកទស និងគ្រូបង្រៀនមានទស្សនៈបន្ថែមថា បើទោះបីជាគាត់បានបំពេញភារកិច្ចស្របទៅតាមឯកទេស ជំនាញ ទេពកោសល្យ និងគុណវុឌ្ឍ

របស់ខ្លួនភាគច្រើនក៏ដោយក៏ពួកគាត់មិនបានធ្វើការពិភាក្សាគ្នាឱ្យបានស៊ីជម្រៅរវាងគ្រូបង្រៀនគ្នាឯង ប្រធានក្រុមបច្ចេកទេស និងគណៈគ្រប់គ្រងដែរ។

រីឯទស្សនៈយល់ឃើញរបស់គណៈគ្រប់គ្រង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនទៅលើបញ្ហាប្រឈមវិញគឺពាក់ព័ន្ធជាមួយការខ្វះសម្ភារៈឧបទ្ទេសសម្រាប់ប្រើប្រាស់នៅក្នុងការបង្រៀន និងរៀន ជាពិសេសនៅពេលគ្រូបង្រៀនប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនបែបរិះរក។ គ្រូបង្រៀនមួយចំនួនទៀតយល់ឃើញថា បរិយាកាសថ្នាក់ក៏ជាផ្នែកមួយដ៏សំខាន់នៅក្នុងការអនុវត្តវិធីសាស្ត្រនេះឱ្យមានប្រសិទ្ធភាពខ្ពស់ តែថ្នាក់រៀននីមួយៗមានសិស្សច្រើន ថ្នាក់រៀនពុំមានផាសុកភាព សិស្សមានភាពចម្រុះគ្នា កង្វះការលើកទឹកចិត្ត កង្វះការត្រួតពិនិត្យតាមដាន វាយតម្លៃ និងខ្វះអ្នកជំនាញផ្នែកវិធីសាស្ត្រនេះ ដើម្បីចូលរួមកែលម្អជាប្រចាំ។

ការសិក្សានេះក៏បានបង្ហាញពីបញ្ហាប្រឈមចំបងៗពាក់ព័ន្ធជាមួយការយល់ដឹង អំពីខ្លឹមសារ និងគរុសល្យ ការគ្រប់គ្រងថ្នាក់រៀន និងការរៀបចំកិច្ចតែងការបង្រៀនឱ្យបានត្រឹមត្រូវតាមលក្ខណៈបច្ចេកទេសផងដែរ។ ជាមួយគ្នានេះដែរបញ្ហាចម្បងផ្សេងទៀតទាក់ទងជាមួយការប្រើប្រាស់សម្ភារៈបច្ចេកវិទ្យា និងមានភាពអាក់អួល ព្រោះគ្រូបង្រៀនមួយចំនួនមិនចេះប្រើប្រាស់កុំព្យូទ័រ និងបច្ចេកវិទ្យាទំនើបផ្សេងៗទៀតដូចជា ការប្រើប្រាស់តេឡេក្រាម ហ្វេសបុក អ៊ីម៉ែល និងសម្ភារៈប្រើប្រាស់នានាសម្រាប់បង្រៀនតាមអនឡាញ ដូចជា Google Classroom, Google Zoom, និង Google Meet ជាដើម។ សម្ភារៈទាំងនេះលោកគ្រូ/អ្នកគ្រូត្រូវការជាចាំបាច់ ដើម្បីគាំទ្រ និងបម្រើឱ្យការបង្រៀនរបស់ខ្លួនក្នុងយុគ្គសម័យនៃការរាតត្បាតជម្ងឺកូវីដ-១៩នេះ ជាពិសេសការរាតត្បាតនៃកូវីដ-១៩បំលែងថ្មីដែលគេហៅថា Delta។

## ABSTRACT

The Royal Government of Cambodia has launched the Fourth Rectangular Strategy, defining human resource development and education as priority areas among other areas of the Rectangular Strategy. The Ministry of Education, Youth and Sports is committed to achieving the first angle of the first rectangle**, "Human Resource Development",** which states that "strengthening the quality of education, science and technology."

The foundation of improving the quality of education is to start by using the teaching methods of teachers at all levels to suit the specific needs of students and the current process of teaching and learning in the 21st century. Teaching is a way to impart knowledge to students through the use of tricks to enable students to develop mentally and physically. Teaching methods are tricks as a way to make the work of teachers and students under the guidance of teachers, students acquire knowledge, skills, know how to live together, and expand the students' memory, refers to the performance of all tasks.

A great teacher does not do anything without a purpose. Every activity, every teaching, every record has a clear reason. These strategies are determined in part by the content of the lesson to be taught and in part by the nature of the learner. For a particular teaching method to be appropriate and effective, it must relate to the character of the learner and the type of learning that each student has. To design and select teaching methods, consider not only the nature of the lesson content, but also how students learn. innovative encourage and human resource development occurs through reasoning. Reasoning and expression are creative. Achieving an appropriate and effective teaching

method requires the management of educational institutions at all levels, especially principals and technical team leaders, to have a clear knowledge of teaching and learning methods to point out to teachers which methods are highly effective in practice.

Recognizing the importance of using teaching methods in all levels of educational institutions, the researchers decided to select the topic of the research dissertation entitled "Perspectives of principals, technical principals and teachers on the use of teaching and learning methods at High school." In order to (1) to anticipate the views of principals, technical team leaders and teachers on the use of teaching and learning methods (IBL). (2) Look for challenges in using the above teaching and learning methods to participate in solving and promoting the use of this teaching and learning method more effectively.

The results of this study show that the views of principals/vice-principals, technical team leaders and teachers are not very different. They all feel that the use of Inquiry-Based Learning (IBL) by teachers is not yet widespread and revived because the level of understanding of this method is still low. Some teachers have not yet undergone training on Inquiry-Based Learning (IBL). Some other teachers, even though they have been through training, do not use that method widely. Some teachers lack the will to use them, following the habits they used to do what they have had in the past. The Principals/Vice-principals, Technical Team Leader and teachers added that although they performed their duties in accordance with most of their specializations, skills, talents and qualifications, they lacked in-depth discussions between the individual teachers, the technical team leaders and principals/vice-principle.

The perception of principals/vice-principles, technical team leaders and teachers on the challenge is that there is a lack of teaching materials to use in teaching and learning when teachers use Inquiry-Based Learning (IBL). Some teachers feel that the classroom environment is also an important part of implementing this approach effectively because each classroom has many students. The class is not comfortable. The students are diverse and there is lack of motivation and lack of control. There also are lack of experts to monitor and evaluate the implementation of this method to participate in regular improvements.

The study also identified key challenges related to the understanding of pedagogical content and teaching, classroom management, and the preparation of lesson plans in the technical sense of Inquiry-Based Learing. It also shows the main problems with the use of technology, most of which are inconvenient, some teachers do not know how to use computers, as well as modern technology such as the use of telegrams, Facebook, e-mail and some online teaching materials such as Google Classroom, Google Zoom, and Google Meet, which teachers need to teach students in this age of the Kovid-19 pandemic, and especially the new Kovid-19 pandemic called the Delta.

# មាតិកា

ទំព័រ


សេចក្តីអះអាងរបស់បេក្ខជន ........ iii

លិខិតបញ្ជាក់........ iv

លិខិតឧទ្ទេនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ ........ v

សេចក្តីថ្លែងអំណរគុណ........ vii

មូលន័យសង្ខេប........ ix

មាតិកា........ xv

**ជំពូក ១៖ សេចក្តីផ្តើម ........ 2**

១.១ សាវតានៃការស្រាវជ្រាវ........ 2

១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ ........ 6

១.៣ គោលបំណងនៃការសិក្សាស្រាវជ្រាវ ........ 9

១. ៤ សំណួរនៃការស្រាវជ្រាវ........ 9

១. ៥ សារៈសំខាន់នៃការស្រាវជ្រាវ........ 9

១. ៦ ដែនកំណត់នៃការស្រាវជ្រាវ........ 10

១. ៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ........ 11

**ជំពូកទី២៖ រំឭកទ្រឹស្តី........ 14**

២.១ និយមន័យបញ្ញត្តិគន្លឹះ ........ 14

២.២ វិធីសាស្រ្តបង្រៀន និងរៀនបែបរិះរក (IBL)........ 24

**ជំពូកទី៣៖ វិធីសាស្រ្តស្រាវជ្រាវ........ 46**

៣.១ ព័ត៌មានទូទៅនៃគម្រោងស្រាវជ្រាវ ........ 46

៣.២ ទីកន្លែងសិក្សាស្រាវជ្រាវ........ 46

៣.៣ ក្រុមគោលដៅ........ 48

៣.៤ ទំហំ និងភាគសំណាកនៃការស្រាវជ្រាវ........ 52

៣.៥ វិធីសាស្ត្រស្រាវជ្រាវ ......53
៣.៦ ការជ្រើសរើសភាគសំណាក ......54
៣.៧ ឧបករណ៍ស្រាវជ្រាវ ......54
៣.៨ ការប្រមូលព័ត៌មាន ......57
៣.៩ ការវិភាគទិន្នន័យ ......59
៣.១០ ក្រមសីលធម៌ស្រាវជ្រាវ ......59
**ជំពូកទី៤៖ លទ្ធផល និងការពិភាក្សា ......62**
៤.១ ព័ត៌មានទូទៅអំពីគ្រូ ......62
៤.២ ទស្សនៈយល់ឃើញអំពីវិធីសាស្ត្របង្រៀន និងរៀនបែបរិះរក (IBL) ......66
**ជំពូកទី៥៖ សេចក្តីសន្និដ្ឋាន និងសំណូមពរ ...... 100**
៥.១ សេចក្តីសន្និដ្ឋាន ......100
៥.២ សំណូមពរ ......105
**ឯកសារយោង ......108**
ក. ឯកសារជាភាសាខ្មែរ ......108
ខ.ឯកសារជាភាសាបរទេស ......109
**ឧបសម្ព័ន្ធ ......110**

# ជំពូកទី១

# សេចក្តីផ្តើម

# ជំពូកទី១៖ សេចក្តីផ្តើម

## ១.១ សាវតានៃការស្រាវជ្រាវ

ប្រព័ន្ធអប់រំនៅប្រទេសកម្ពុជាបានផ្លាស់ប្តូរច្រើនលើកច្រើនសារ ដោយសារតែមនោគមន៍វិជ្ជា និងឥទ្ធិពលនយោបាយរវាងប្លុកកុំម្មុយនីស និងប្លុកសេរី ដែលបានប្រគួតប្រជែង ដណ្តើមកិត្យានុភាពគ្នាក្នុងការគ្រប់គ្រងពិភពលោក។ និន្នាការនយោបាយទាំងកម្រិតតំបន់ និងកម្រិតពិភពលោកបានជះឥទ្ធិពលអាក្រក់មកដល់សង្គមកម្ពុជាជាច្រើនលើកច្រើនសារ ជាហេតុធ្វើឱ្យប្រទេសដ៏តូចមួយនេះធ្លាក់ចូលក្នុងរបបវាលពិឃាត កម្ពុជាប្រជាធិបតេយ្យក្រោមការដឹកនាំ និងគ្រប់គ្រងដោយ ប៉ុល ពតដែលជ្រកក្រោមឆ័ត្របែបកុំម្មុយនីស។

នៅពេលនោះប្រព័ន្ធអប់រំរបស់ប្រទេសកម្ពុជាបានធ្លាក់ដល់កម្រិតសូន្យ ចាប់ពីឆ្នាំ១៩៧៥ ដល់១៩៧៩។ ទោះបីជាយ៉ាងណាក៏ដោយ បន្ទាប់ពីដួលរលំរបបប្រល័យពូជសាសន៍ **ពុល ពត** ប្រព័ន្ធអប់រំក៏បានចាប់កំណើតឡើងវិញ និងបានធ្វើកំណែទម្រង់របស់ខ្លួនជាបន្តបន្ទាប់ ដើម្បីបំពេញតម្រូវការនៃការអភិវឌ្ឍទាំងផ្នែកសេដ្ឋកិច្ច និងសង្គម(Mak, 2006)។ ជាមួយគ្នានេះដែរ វិធីសាស្ត្របង្រៀនក៏ត្រូវបានអ្នកអប់រំយកមកប្រើប្រាស់តាមវិធីខុសៗគ្នា ជាពិសេសពីរបបដឹកនាំរដ្ឋមួយ ទៅរបបដឹកនាំរដ្ឋមួយទៀត។

បើក្រឡេកមើលពីការសិក្សាអប់រំនៅសម័យអាណានិគមនិយមបារាំង គឺមិនសូវមានការរីកចម្រើនប៉ុន្មានទេ ដោយនៅពេលនោះបារាំងបាននាំយកប្រព័ន្ធអប់រំថ្មីមួយមកបំពាក់ លើការសិក្សាអប់រំបែបប្រពៃណីរបស់ខ្មែរ។ ទោះបីជាការអប់រំនៅពេលនោះគឺធ្វើឡើងនៅក្នុងសាលារៀនក៏ដោយ ក៏ប៉ុន្តែការបួសរៀននៅក្នុងវត្តអារាមក៏នៅតែបន្តជាដរាប។ ការបួសរៀននៅក្នុងវត្តអារាមបានរួមចំណែកជួយ និងសង្គ្រោះកូនខ្មែរឱ្យរួចចាកផុតពីភាពអវិជ្ជា និងបានរក្សាអក្សរសាស្ត្រជាតិឱ្យនៅគង់វង្ស រួចចាកផុតពីការព្យាយាមលុបបំបាត់របស់ពួកបារាំងសេស្ញីផងដែរ។ ចំណែកឯព្រះសង្ឃខ្មែរក៏នៅតែបន្តតួនាទីជាគ្រូអាចារ្យដ៏សំខាន់ក្នុងការជួយបង្ហាត់បង្រៀនកូនខ្មែរព្រមទាំង រក្សាការពារ វប្បធម៌ ប្រពៃណី និងអក្សរសាស្ត្រខ្មែរបានល្អទៀតផង។

ចំពោះលោក David Chandler (២០០៥-១៦៨) បានលើកឡើងនៅក្នុងសៀវភៅរបស់លោកថា "នៅក្នុងសម័យអាណានិគមនិយមបារាំង ការចេះអាន និងចេះសរសេរភាសាខ្មែរគឺស្ថិតនៅក្នុងការគ្រប់

គ្រងរបស់ព្រះសង្ឃសឹងតែទាំងស្រុង"។ ថ្វីដ្បិតតែបារាំងបានត្រួតត្រាប្រទេសខ្មែរតាំងពីឆ្នាំ១៨៦៣ក៏ដោយ ក៏គេមិនឃើញមានសកម្មភាពក្នុងការជួយពង្រឹង និងពង្រីកវិស័យអប់រំរបស់ខ្មែរឱ្យបានខ្លាំងក្លាដែរ។ តែទោះបីជាយ៉ាងនេះក្តីក៏គេសង្កេតឃើញថា ចាប់ពីឆ្នាំ១៨៨៤មក រាជការបារាំងបានធ្វើកំណែទម្រង់រចនាសម្ព័ន្ធគ្រប់គ្រងប្រទេស និងវិស័យសិក្សាអប់រំរបស់ខ្មែរផងដែរ ដែលជាហេតុនាំឱ្យការអប់រំនេះចាប់ផ្តើមមានការប្រែប្រួលបន្តិចម្តងៗ។ ជាពិសេសគឺចាប់ពីទសវត្សឆ្នាំ១៩០០ ការកែទម្រង់នេះបានលេចចេញជារូបរាងច្បាស់ឡើងជាងមុន ហើយការសិក្សាចំណេះដឹងទូទៅបានទទួលអាទិភាពជាពិសេសផងដែរ។ ហេតុនេះទើបការសិក្សាបែបទំនើបចាប់កំណើតឡើង ដោយពេលនោះមានបង្កើតសាលាបឋមសិក្សាបារាំងនៅតាមឃុំ និងបានកែប្រែសាលាវត្តឱ្យមានរបៀបបង្រៀនតាមបែបទំនើបឡើង។

ជាងនេះទៅទៀត អាណានិគមបារាំងក៏បានជួយផ្តួចផ្តើម និងផ្តល់ថវិកាដល់រដ្ឋាភិបាលខ្មែរ ដើម្បីឱ្យស្ថាបនាសាលារៀន សម្រាប់ឱ្យកុលបុត្រកុលធីតាខ្មែរបានសិក្សារៀនសូត្រ។ សាលារៀនដែលគេស្ថាបនានៅពេលនោះមាន២ផ្នែកគឺសាលាវត្ត និងសាលារៀនក្រៅវត្តដែលគេហៅថា សាលារាជការ។ សាលារាជការនេះសម្រាប់តែកូននាម៉ឺន និងកូនអ្នកមាននៅតាមទីក្រុងប៉ុណ្ណោះទើបអាចចូលរៀនបាន។ ចំណែកឯកូនអ្នកក្រវិញអាចចូលសិក្សារៀនសូត្របាននៅសាលាវត្ត(សៅ ឆាត ១៩៩៣)។ ហេតុនេះហើយទើបការសិក្សាបួសរៀនតាមផ្នែកផ្លូវធម៌ ឬព្រះពុទ្ធសាសនានៅតែបន្ត តែនៅពេលនោះ បារាំងក៏នៅតែឆ្លៀតយកវត្តអារាមធ្វើជាកន្លែងសម្រាប់បណ្តុះបណ្តាលតាមបែបទំនើបផងដែរ។ ដូចនេះការសិក្សា និងការអប់រំនៅពេលនោះគឺប្រព្រឹត្តទៅនៅកន្លែងសំខាន់ៗ គឺវត្ត(ផ្នែកធម៌) សាលាវត្ត ឬសាលាបឋមសិក្សាជាន់ដំបូង និងសាលារៀនរាជការឬសាលាបារាំង (ឃឹន សុខ ២០០៣)។

នៅសម័យបារាំងគ្រប់គ្រង ការប្រើប្រាស់វិធីសាស្ត្របង្រៀនគឺផ្តោតលើ វិធីសាស្ត្របង្រៀនបែបឧទ្ទេស និងវិធីសាស្ត្របង្រៀនបែបចង្អុលបង្ហាញ។ វិធីសាស្ត្របង្រៀនបែបឧទ្ទេសគឺជាវិធីសាស្ត្រដែលគ្រូបង្រៀនប្រើប្រាស់ជាពាក្យសម្តី ដើម្បីបកស្រាយបញ្ញត្តិ ភេទ ក្រឹត្យក្រមនានា និងរបៀបប្រើប្រាស់ក្រឹត្យក្រមទាំងនោះ។ វិធីសាស្ត្រនេះគឺជាការរៀបរាប់អំពីបញ្ហាមួយ ដើម្បីបំពេញ ឬបង្គ្រប់ទៅលើចំណេះដឹងរបស់សិស្សដែលមានភាពស្មុគស្មាញ អរូបី និងត្រូវបានធ្វើទូទៅកម្មនៅក្នុងរយៈពេលមួយដ៏ខ្លី។ រីឯវិធីសាស្ត្រ

បង្រៀនបែបចង្អុលបង្ហាញគឺជាការធ្វើបទបង្ហាញ ដើម្បីបញ្ជាក់ និងតម្រូវឱ្យអ្នកសិក្សាបង្ហាញទៅកាន់អ្នកចូលរួមអំពីរបៀបធ្វើអ្វីមួយជាដើម។ ការប្រើប្រាស់វិធីសាស្ត្របង្រៀនបែបចង្អុលបង្ហាញគឺសំដៅដល់ការមើលឃើញនឹងភ្នែក បង្ហាញពីការអនុវត្តជារួម និងមានលក្ខណៈជាការពិភាក្សាផងដែរ។ ការប្រើប្រាស់វិធីសាស្ត្រនេះមានលក្ខណៈសមស្របជាមួយគោលបំណង និងខ្លឹមសារមេរៀនទាំងឡាយណាដែលមានភាពទូលំទូលាយព្រោះវាមានទម្រង់ជាក់លាក់ជាងវិធីសាស្ត្របង្រៀនបែបចង្អុលបង្ហាញ។

ការអប់រំនៅប្រទេសកម្ពុជាមានការរីកចម្រើនគួរឱ្យកត់សម្គាល់នាសម័យសង្គមរាស្ត្រនិយម និងមានលក្ខណៈខុសផ្លែកពីពេលមុនៗ ព្រោះក្មេងប្រុសត្រូវទៅសិក្សារៀនសូត្រនៅតាមសាលាវត្ត ចំណែកក្មេងស្រីត្រូវចូលម្លប់ ដើម្បីរៀនវិជ្ជាមេផ្ទះ និងអក្សរសាស្ត្របន្តិចបន្តួច។ ជាមួយគ្នានេះដែរ ទោះបីវិស័យអប់រំនៅសម័យសង្គមរាស្ត្រនិយមមានការរីកចម្រើនក៏ដោយ ក៏វិធីសាស្ត្របង្រៀនដែលគ្រូបង្រៀនប្រើនៅពេលនោះគឺផ្អែកលើទ្រឹស្តី និងការសិក្សាដែលមានទិសដៅគ្រាន់តែបណ្តុះបណ្តាលក្របខ័ណ្ឌសម្រាប់ការគ្រប់គ្រង និងមិនបានផ្តល់ជាទុនសម្រាប់ការលូតលាស់ផ្នែកសង្គម-សេដ្ឋកិច្ចខ្លាំងក្លាឡើយ។

នៅសម័យសាធារណរដ្ឋកម្ពុជា(១៩៧០-១៩៧៥) វិធីសាស្ត្រនៃការបង្រៀនក៏ពុំទាន់មានការផ្សព្វផ្សាយ ឱ្យបានទូលំទូលាយថា វិធីសាស្ត្របង្រៀនណាមួយដែលល្អជាងគេនោះដែរ ពោលគឺគ្រូបង្រៀនគ្រប់រូបធ្វើការបង្រៀន របស់ខ្លួនដោយអនុលោមទៅតាមការណែនាំពីគ្រូចាស់ៗ(គ្រូចេញមុន)តែប៉ុណ្ណោះ។

ចំពោះនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យវិញ វិស័យអប់រំបានដួលរលំ ដោយពួកប្រល័យពូជសាសន៍បានសម្លាប់អ្នកចេះដឹង និងគ្រូបង្រៀនចោលស្ទើតែគ្មានសល់។ ការអប់រំនៅពេលនោះគឺ«**ជាមុខងារនៃបរិយាកាសនយោបាយ និងសង្គមដ៏ស្មុគស្មាញ។** ក្រសួងអប់រំនៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យមិនទទួលបានជោគជ័យសម្រាប់ការងារអប់រំរបស់ខ្លួនទេ ពោលគឺមានត្រឹមតែគ្រោងឆ្អឹង និងតម្រូវការសម្រាប់តែបំពេញការងារប៉ុណ្ណោះ» (Anatomy of Crisis, Education, Development, and the State in Cambodia, 1953-1998)។

បន្ទាប់ពីរបប ប៉ុល ពតដួលរលំ ការអប់រំក៏បានស្តារឡើងវិញ។ វិស័យអប់រំសិក្សាធិការត្រូវបក្ស និងរដ្ឋយកចិត្តទុកដាក់ខ្លាំងបំផុតតាមពាក្យស្លោកថា«**វប្បធម៌ អក្សរសាស្ត្រលត់ នោះជាតិរលាយ**»។ នៅក្នុង

ផែនការរបស់រដ្ឋដំបូងគឺលុបបំបាត់ភាពមិនចេះអក្សរឱ្យអស់ពីមជ្ឈដ្ឋានប្រជាជន ព្រោះអវិជ្ជាជាសត្រូវចំពោះបដិវត្តន៍ ពោលគឺបើគ្មានសាលារៀនគឺគ្មានកម្មាភិបាល គ្មានបញ្ញវ័ន្ត គ្មានវិទ្យាសាស្ត្របច្ចេកទេស និងគ្មានការលូតលាស់ *(សៀវភៅប្រវត្តិនៃការអប់រំនៅកម្ពុជា៖ ការអប់រំសម័យសាធារណរដ្ឋប្រជាមានិតកម្ពុជា ឆ្នាំ១៩៧៩-១៩៩៤)*។

ភារកិច្ចចម្បងរបស់ក្រសួងអប់រំនៅពេលនោះគឺ គិតគូរយ៉ាងខ្លាំងទៅលើសៀវភៅសិក្សាគោល កម្មវិធីសិក្សា និងរចនាសម្ព័ន្ធអប់រំថ្មី។ ទន្ទឹមនឹងនេះដែរក៏មានការហ្វឹកហ្វឺនផ្នែកនយោបាយ និងគរុកោសល្យដល់គ្រូបង្រៀនផងដែរ។ នៅក្នុងគោលការណ៍អប់រំជាមូលដ្ឋានគឺក្រសួងអប់រំចាប់ផ្តើមបង្កើតសាលាមតេយ្យ សាលាបឋម សាលាមធ្យម សាលាបបច្ចេកទេស-វិជ្ជាជីវៈ និងឧត្តមសិក្សា។ តែទោះជាយ៉ាងនេះក្តីក៏គេមិនអាចភ្លេចបានជាដាច់ខាតចំពោះការសិក្សាអប់រំមនុស្សចាស់ ព្រោះមនុស្សចាស់ក៏ជាកូនសោមួយយ៉ាងណាសំខាន់សម្រាប់អភិវឌ្ឍន៍ប្រទេសនាពេលនោះផងដែរ។ នៅក្នុងភូមិសិក្សានីមួយៗមានការកែប្រែច្រើន ទាំងផ្នែករចនាសម្ព័ន្ធអប់រំ និងសិក្សាអធិការជាតិ ទាំងផ្នែកខ្លឹមសារ និងកម្មវិធីបង្រៀន។ បញ្ហាចម្បងរបស់ប្រព័ន្ធអប់រំថ្មីនៅពេលនោះគឺណែនាំមនុស្សពេញវ័យ និងវ័យជំទង់ឱ្យឆ្ពោះទៅរកការងារបង្កបង្កើនផលក្នុងរយៈពេលខ្លី តាមសកម្មភាព និងការប្រតិបត្តិ ដែលមានចាប់ពីកម្រិតបឋមរហូតដល់កម្រិតឧត្តមសិក្សា។ នៅក្នុងដំណាក់កាលនេះជាដំណាក់កាលនៃការរស់ឡើងវិញ និងជាដំណាក់កាលនៃការពង្រីកបរិមាណ។ ជាមួយគ្នានេះដែរ រដ្ឋបានធ្វើការប្រមែរប្រមូលមនុស្សឱ្យមកសិក្សា និងគ្រូបង្រៀនដែលសេសសល់ពីសង្គមចាស់មកធ្វើជាដើមទុនសម្រាប់ការអប់រំថ្មីនេះ។ នៅក្នុងដំណាក់កាលនៃការរៀបចំប្រព័ន្ធអប់រំថ្មីនេះក៏មានលក្ខណៈពេញលេញ តែពុំទាន់សុក្រឹតនៅឡើយ។ ជ័យជំនះនៃការរៀបចំក្នុងដំណាក់កាលនេះ ស្តែងឡើងនៅគ្រប់កម្រិតសិក្សា ពោលគឺទាំងមតេយ្យសិក្សា បឋមសិក្សា មធ្យមសិក្សា ឧត្តមសិក្សា និងសិក្សាឯកទេស រហូតដល់ការអប់រំមនុស្សចាស់។

នៅឆ្នាំ១៩៩៣ ជាដំណាក់កាលនៃព្រះរាជាណាចក្រទី២ បន្ទាប់ពីមានការរៀបចំការបោះឆ្នោតដោយអង្គការសហប្រជាជាតិ តាមស្មារតីកិច្ចព្រមព្រៀងសន្តិភាពទីក្រុងប៉ារីស(២៣ តុលា ឆ្នាំ ១៩៩១) នៅខែឧសភា ឆ្នាំ១៩៩៣នោះមក។ នៅពេលនោះ បាវចនានៃព្រះរាជាណាចក្រកម្ពុជាគឺ "ជាតិ សាសនា ព្រះ

មហាក្សត្រ”។ ចំពោះក្រសួងអប់រំ យុវជន និងកីឡា ត្រូវបានរាជរដ្ឋាភិបាលប្រគល់ "បេសកកម្មឱ្យដឹកនាំ និងគ្រប់គ្រងវិស័យអប់រំ នៃព្រះរាជាណាចក្រកម្ពុជា” ។ ក្រសួងអប់រំ មានមុខងារ និងភារកិច្ច "កំណត់នយោបាយអប់រំរបស់ខ្លួន ដោយផ្អែកលើមូលដ្ឋានកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលដែលសំដៅអភិវឌ្ឍធនធានមនុស្ស”ឱ្យបានទាន់ពេលវេលា។

នៅឆ្នាំ១៩៩៥-៩៦ ជារបត់នៃកំណែទម្រង់ប្រព័ន្ធអប់រំ កម្មវិធីសិក្សា សៀវភៅសិក្សាគោល និងបានផ្លាស់ប្តូរ វិធីសាស្ត្របង្រៀនបែបគ្រូមជ្ឈមណ្ឌលមកជាសិស្សមជ្ឈមណ្ឌលវិញ ហើយនៅឆ្នាំ២០០៣ ក៏មានការកែលម្អថ្មីបន្ថែមទៀតលើទម្រង់កម្មវិធីសិក្សា សៀវភៅសិក្សាគោល និងវិធីសាស្ត្របង្រៀន តាមគោលវិធីសិស្សមជ្ឈមណ្ឌល ដោយរក្សាតាមប្រព័ន្ធអន្តរជាតិ។ ចក្ខុវិស័យនៃការអប់រំនៅពេលនេះគឺបណ្តុះបណ្តាលសិស្សានុសិស្សឱ្យក្លាយជាមនុស្សពេញលេញ ជាពលរដ្ឋល្អ ពលរដ្ឋថ្លៃថ្នូរ និងជាពលករជំនាញដែលជាប្រភពធនធាននៃការអភិវឌ្ឍជាតិ*(បណ្ឌិត ធយ អួន,៣១ ខែសីហា ឆ្នាំ១៩៩៨)*[1]។

ដោយសារសង្គមមានការរីកចម្រើន និងជឿនលឿនទាំងផ្នែកបច្ចេកវិទ្យា និងផ្នែកចំណេះដឹង ទើបគ្រូបង្រៀនបានជ្រើសរើសវិធីសាស្ត្របង្រៀន និងរៀននានាមកបង្ហាត់បង្រៀនសិស្សានុសិស្ស កាន់តែមានភាពល្អប្រសើរឡើងៗ។ ការជ្រើសរើសវិធីសាស្ត្របង្រៀន និងរៀនមានប្រសិទ្ធភាពខ្ពស់ និងពេញនិយមគឺអាចជួយសិស្សានុសិស្សឱ្យទទួលបានលទ្ធផលចំណេះដឹងល្អប្រសើរ និងត្រចះត្រចង់។ ជាមួយគ្នានេះដែរ ក្នុងចំណោមវិធីសាស្ត្រនានាដែលគ្រូបង្រៀនលើកយកមកបង្រៀនសិស្សានុសិស្សក្នុងសម័យទំនើបនេះ ក៏មានវិធីសាស្ត្របង្រៀន និងរៀនបែបរ៉ូរកផងដែរ។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជាបានចាត់ទុកការវិនិយោគមូលធនមនុស្សក្នុងវិស័យអប់រំគឺជាទិសដៅដ៏សំខាន់មួយសម្រាប់អភិវឌ្ឍប្រទេសប្រកបដោយចីរភាព។ ការអប់រំដើរតួនាទីយ៉ាងសំខាន់ក្នុងការបណ្តុះបណ្តាលធនធានមនុស្ស និងធ្វើឱ្យសម្រេចបាននូវការអភិវឌ្ឍទាំងផ្នែកសង្គម និងសម្ភារៈ ស្មារតី បញ្ញាញាណ សីល

[1] *(ប្រវត្តិក្រសួងអប់រំ យុវជន និងកីឡា ផ្នែកទី១និងទី២ (នាយកដ្ឋានបុគ្គលិក) រៀបចំឡើងនៅ ខែសីហា ឆ្នាំ១៩៩៨ ចុះហត្ថលេខាដោយ បណ្ឌិត ធយ អួន អគ្គនាយករង នៃអគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ នៅថ្ងៃទី ៣១ ខែសីហា ឆ្នាំ១៩៩៨)*។

ធម៌ សោភ័ណ វប្បធម៌ វិទ្យាសាស្ត្រ និងការអភិវឌ្ឍបច្ចេកវិទ្យាសម្រាប់វឌ្ឍនភាពប្រជាពលរដ្ឋ សេដ្ឋកិច្ច និងសង្គមរបស់ខ្លួន ស្របតាមគោលដៅអប់រំជាតិ ការឯកភាពជាតិ ប្រជាធិបតេយ្យ ដើម្បីវឌ្ឍនភាពសេដ្ឋកិច្ច សន្តិសុខ និងសុវត្ថិភាពសម្រាប់ប្រជាជនកម្ពុជា។

បើយោងទៅតាមលោក **ខុង ជឺ** ការអប់រំមិនមានវណ្ណៈឡើយ។ មនុស្សជាតិទាំងអស់អាចបង្រៀន និងរៀនឬអាចកែលម្អបាន ហើយអ្នកដែលចង់បានការអប់រំគួរតែទទួលបានការអប់រំស្របតាមឆន្ទៈរបស់គេ។ "ការដាំដុះមនុស្សគឺត្រូវសំរេចទៅតាមរយៈមាគ៌ា និងដំណើរការនៃការអប់រំ ពោលគឺត្រូវធ្វើតាមរយៈជេន (មនុស្សធម៌)" (Pohl 1999,ទំព័រ ៨៥)[2]។ ដើម្បីឱ្យប្រព័ន្ធអប់រំមានការរីកចម្រើនប្រកបដោយគុណភាព និងមានប្រសិទ្ធផលខ្ពស់ក៏ទាមទារឱ្យមានការចូលរួមពីគ្រប់ភាគីពាក់ព័ន្ធនៅក្នុងវិស័យនេះ ពោលគឺទាំងអ្នកបច្ចេកទេស អ្នករៀបចំកម្មវិធីសិក្សា អ្នករៀបចំគោលនយោបាយអប់រំ ក៏ដូចជាវិស័យសេដ្ឋកិច្ច និងនយោបាយផងដែរ។

ជាមួយគ្នានេះដែរ ការប្រើប្រាស់វិធីសាស្ត្របង្រៀនឱ្យបានត្រឹមត្រូវគឺជាចលករដ៏សំខាន់មួយនៅក្នុងដំណើរនៃការបង្រៀន និងរៀន ហើយក៏រួមចំណែកយ៉ាងសកម្មដល់ការពង្រឹង និងពង្រីកគុណភាពសិក្សា បណ្តុះសមត្ថភាពត្រិះរិះពិចារណា ការគិតស៊ីជម្រៅ និងធ្វើឱ្យសិស្សមានឥរិយាបថល្អ ជាពលរដ្ឋល្អ តាមរយៈអន្តរកម្មសង្គម។ ដោយវិធីសាស្ត្របង្រៀនគឺជាឧបករណ៍សំខាន់មួយដែលមិនអាចខ្វះបានសម្រាប់ដំណើរការបង្រៀន និងរៀន ដូចនេះការយល់ដឹងច្បាស់លាស់ពីរបៀបនៃការប្រើប្រាស់វិធីសាស្ត្របង្រៀននីមួយៗគឺជាកត្តាជម្រុញ និងលើកទឹកចិត្តឱ្យការរៀន និងបង្រៀនកាន់តែមានគុណភាពខ្ពស់ថែមទៀតនៅគ្រប់ភូមិសិក្សា។

យ៉ាងណាមិញ ការប្រើប្រាស់វិធីសាស្ត្របង្រៀនឱ្យបានត្រឹមត្រូវស្របតាមបរិបទ និងតម្រូវការជាក់ស្តែងរបស់សិស្សានុសិស្សនៅគ្រប់ភូមិសិក្សា ទាំងអស់នៃប្រទេសកម្ពុជាក៏នៅមានចំណុចអសកម្មមួយចំនួនផងដែរ។ ជាក់ស្តែងគ្រូបង្រៀននៅតាមវិទ្យាល័យមួយចំនួននៅតែប្រើប្រាស់វិធីសាស្ត្របង្រៀនបែបប្រពៃណី និងយកមកអនុវត្តតៗគ្នា ដោយពុំបានយល់អំពីវិធីសាស្ត្រថ្មីៗ និងទំនើបដែលគេនិយមក្នុងការ

[2] the Doctrine of the Mean, Pohl (1999)

ប្រើប្រាស់នៅឡើយ។ វិធីសាស្ត្របង្រៀនថ្មីៗទាំងនោះមានដូចជា៖ វិធីសាស្ត្របង្រៀន និងរៀនបែបរិះរក (IBL) វិធីសាស្ត្របង្រៀន និងរៀនបែបដោះស្រាយបញ្ហា វិធីសាស្ត្របង្រៀននិងរៀនបែបពិភាក្សា ឬវិធីសាស្ត្របង្រៀននិងរៀនបែបសហការជាដើម។ ជាងនេះទៅទៀត គ្រូបង្រៀនមួយចំនួនទៀតពុំបានធ្វើការសិក្សាស្រាវជ្រាវអំពីវិធីសាស្ត្របង្រៀនថ្មីៗទាំងនោះនៅឡើយ។

ចំពោះបញ្ហាចម្បងមួយចំនួនទៀតគឺកង្វះការបណ្តុះបណ្តាល ឬបំប៉នបន្ថែមលើកការប្រើប្រាស់ និងផ្សព្វផ្សាយវិធីសាស្ត្របង្រៀន និងរៀនថ្មីៗដល់គ្រូបង្រៀននៅទូទាំងប្រទេស ជាពិសេសគ្រូបង្រៀននៅកម្រិតមធ្យមសិក្សាទុតិយភូមិដែលបានរៀបចំឡើងដោយវិទ្យាស្ថានជាតិអប់រំ និងអនុម័តឱ្យប្រើប្រាស់ដោយក្រសួងអប់រំ យុវជន និងកីឡា។ ម្យ៉ាងវិញទៀត ដោយសារខ្វះអ្នកឯកទេស និងអ្នកជំនាញផ្នែកវិធីសាស្ត្របង្រៀន និងរៀន កង្វះសម្ភារៈឧបទ្ទេសសម្រាប់គាំទ្រ និងបម្រើឱ្យវិធីសាស្ត្របង្រៀនទាំងនោះ ក៏ដូចជាខ្វះការសហការ និងការចូលរួមពីថ្នាក់ដឹកនាំ គ្រូឧទ្ទេស និងសហគមន៍នៅជុំវិញសាលារៀនផងដែរ។

ជាមួយគ្នានេះដែរ នៅពេលមានវគ្គបណ្តុះបណ្តាលម្តងៗ ការចាត់ចែងអ្នកចូលរួមក្នុងវគ្គបណ្តុះបណ្តាលក៏ពុំសូវមានតម្លាភាព ជាហេតុធ្វើឱ្យការបណ្តុះបណ្តាលខុសគោលដៅ និងមិនស្របតាមជំនាញជាដើម។ ដោយអង្កេត និងមើលឃើញបញ្ហាដូចបានរៀបរាប់ខាងលើ ទើបអ្នកសិក្សាស្រាវជ្រាវសម្រេចជ្រើសរើសប្រធានបទស្តីពី **«ទស្សនៈគ្រប់គ្រង ប្រធានបច្ចេកទេស និងគ្រូបង្រៀនលើការប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនបែបរិះរកនៅសាលាមធ្យមសិក្សាទុតិយភូមិ»** មកសិក្សាស្រាវជ្រាវ និងដើម្បីបញ្ចប់វគ្គ បណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ ក្នុងឆ្នាំសិក្សា ២០២០ ២០២១នេះផងដែរ។ ម្យ៉ាងវិញទៀតគឺ ដើម្បីឈ្វេងយល់ពីទស្សនៈមួយចំនួនលើការប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនបែបរិះរកនេះ ថាតើវាមានលក្ខណៈដូចម្តេចខ្លះនៅសាលាគោលដៅដែលអ្នកស្រាវជ្រាវរំពឹងទុកនោះ។ ជាពិសេសទៅទៀតនោះគឺចង់ដឹងពីចំណុចវិជ្ជមាន និងអវិជ្ជមានលើការប្រើប្រាស់វិធីសាស្ត្រនេះ ដើម្បីកែលម្អឱ្យការបង្រៀន និងការរៀនកាន់តែមានគុណភាពខ្ពស់ មានលទ្ធផលល្អប្រសើរឡើងមួយកម្រិតទៀត ហើយអាចប្រកួតប្រជែងជាមួយបណ្តាប្រទេសក្នុងតំបន់ និងសកលលោកបាន។

## ១.៣ គោលបំណងនៃការសិក្សាស្រាវជ្រាវ

ការស្រាវជ្រាវនេះមានគោលបំណងសំខាន់ពីរគឺ៖

១. ស្វែងយល់ពីទស្សនៈរបស់គណៈគ្រប់គ្រង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនពីការប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនបែបរិះរក

២. ពិនិត្យមើលបញ្ហាប្រឈមនានាក្នុងការប្រើប្រាស់«វិធីសាស្ត្របង្រៀន និងរៀនបែបរិះរក» នៅសាលាមធ្យមសិក្សាទុតិយភូមិ

## ១. ៤ សំណួរនៃការស្រាវជ្រាវ

ប្រធានបទនៃការស្រាវជ្រាវនេះមានសំណួរសំខាន់ៗចំនួនពីរគឺ៖

១.តើគណៈគ្រប់គ្រង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនយល់ឃើញបែបណាពីការប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនបែបរិះរកនៅសាលាមធ្យមសិក្សាទុតិយភូមិ?

២.តើការប្រើប្រាស់វិធីបង្រៀន និងរៀនបែបរិះរកមានបញ្ហាប្រឈមអ្វីខ្លះនៅសាលាមធ្យមសិក្សាទុតិយភូមិ?

## ១. ៥ សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវប្រធានបទអំពី **«ទស្សនៈគណៈគ្រប់គ្រង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនលើការប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនបែបរិះរកនៅសាលាមធ្យមសិក្សាទុតិយភូមិ»**នេះមានសារៈសំខាន់ណាស់សម្រាប់គ្រូបង្រៀនក៏ដូចជាការសិក្សារៀនសូត្ររបស់សិស្ស។ ការប្រើប្រាស់វិធីសាស្ត្រនេះជួយអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន សមត្ថភាពគរុកោសល្យ និងបច្ចេកទេសក្នុងការផ្ទេរចំណេះដឹងដល់អ្នកសិក្សា ឱ្យទទួលបានលទ្ធផលល្អប្រសើ និងមានគុណភាព។ ជាមួយគ្នានេះដែរ ការចង្អុលបង្ហាញរបស់គណៈគ្រប់គ្រង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនអំពីវិធីសាស្ត្របង្រៀន និងរៀនបែបរិះរកនេះមានលក្ខណៈវិទ្យាសាស្ត្រ និងស្របតាមជំហាននានារបស់វាផងដែរ។

ម្យ៉ាងវិញទៀត ការកំណត់យកប្រធានបទខាងលើមកសិក្សាស្រាវជ្រាវគឺស្របតាមឆន្ទៈ និងមុខងារបច្ចុប្បន្នរបស់អ្នកសិក្សាស្រាវជ្រាវ ព្រោះអ្នកសិក្សាស្រាវជ្រាវក៏ជាគ្រូបង្រៀននៅកម្រិតមធ្យសិក្សាទុតិយភូមិផងដែរ។ ការប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនដែលស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល

និងគោលយោបាយអប់រំរបស់ក្រសួងអប់រំ យុវជន និងកីឡាគឺជាការចាំបាច់ និងត្រូវបានចាត់ទុកថាជាការអប់រំយុគ្គសម័យឌីជីថលទៀតផង។ មួយវិញទៀត ការសិក្សាស្រាវជ្រាវនេះមានសារៈសំខាន់ ធ្វើការឆ្លុះបញ្ចាំងពីចំណុចខ្លាំង និងចំណុចខ្សោយនៃការប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនបែបរិះរករបស់លោកគ្រូអ្នកគ្រូនៅតាមសាលាវិទ្យាល័យទាំងនោះ ហើយក៏ជាឯកសារចាំបាច់សម្រាប់ជួយណែនាំគ្រូបង្រៀនជំនាន់ក្រោយៗទៀត ឱ្យមានភាពងាយស្រួលក្នុងការបង្ហាត់បង្រៀនក៏ដូចជាជួយពង្រឹង និងពង្រីកសមត្ថភាពចំណេះដឹងកូនចៅខ្មែរជំនាន់ក្រោយឱ្យកាន់តែរឹងមាំ និងអាចប្រកួតប្រជែងជាមួយបណ្តាប្រទេសនានានៅក្នុងតំបន់ និងនៅលើឆាកអន្តរជាតិ។

## ១.៦ ដែនកំណត់នៃការស្រាវជ្រាវ

ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវជាចំណុចសំខាន់ និងជាទិសដៅបង្ហាញផ្លូវ ដើម្បីកុំឱ្យអ្នកសិក្សាស្រាវជ្រាវដើរចាកឆ្ងាយពីប្រធានបទ ឬដើរមិនចំគោលដៅនៃប្រធានបទដែលត្រូវស្រាវជ្រាវ។ ដែនកំណត់ និងវិសាលភាពនៃការសិក្សាស្រាវជ្រាវនេះគឺផ្តោតជាសំខាន់លើទស្សនៈយល់ឃើញ និងបញ្ហាប្រឈមមួយចំនួនរបស់គណៈគ្រប់គ្រង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀន នៅពេលប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនបែបរិះរកនៅសាលាមធ្យសិក្សាទុតិយភូមិតែប៉ុណ្ណោះ។

ការសិក្សាស្រាវជ្រាវនេះផ្តោតលើការប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនបែបរិះរក នៅសាលាមធ្យមសិក្សាចំណេះទូទៅទុតិយភូមិ នៅក្នុងក្រុង/ស្រុកចំនួនប្រាំនៃខេត្តកណ្តាលៈ (១)ក្រុងតាខ្មៅ (២)ស្រុកកោះធំ (៣)ស្រុកពញាឮ (៤)ស្រុកអង្គស្នួល និង(៥)ស្រុកកណ្តាលស្ទឹង។

ការសិក្សានេះប្រព្រឹត្តិទៅដោយផ្តោតលើសាលាមធ្យសិក្សាទុតិយភូមិជាគោលដៅចំនួន១៤ដែលស្ថិតនៅក្នុងក្រុង/ស្រុកទាំង៥ខាងលើ។ នៅក្នុងក្រុងតាខ្មៅមានសាលាវិទ្យាល័យចំនួនពីរគឺៈ(១)វិទ្យាល័យ ហ៊ុន សែន សេរីភាព និង(២)វិទ្យាល័យ ហ៊ុន សែនតាខ្មៅ។ នៅក្នុងស្រុកកោះធំមានសាលាវិទ្យាល័យចំនួនបីគឺៈ(១) វិទ្យាល័យ ហ៊ុន សែន កោះធំ (២)វិទ្យាល័យ វិទ្យាល័យ ហ៊ុន សែន ព្រែកតាដួង និង(៣)វិទ្យាល័យ ហ៊ុន សែន សំពៅពូន។ នៅស្រុកពញាឮមានសាលាវិទ្យាល័យបីគឺៈ (១)វិទ្យាល័យ ហ៊ុន សែន ព្រះធម្មស្រះ (២)វិទ្យាល័យ វិទ្យាល័យ ហ៊ុន សែន អូកុង និង(៣)វិទ្យាល័យ ហ៊ុន សែន កោះចិន។ នៅស្រុក

អង្គស្នួលមានសាលាវិទ្យាល័យចំនួនបីគឺ៖ (១)វិទ្យាល័យ ហ៊ុន សែន អង្គស្នួល (២)វិទ្យាល័យ ហ៊ុន សែន ថ្នល់ទទឹង និង(៣)វិទ្យាល័យអង្គពពាយ។ រីឯនៅស្រុកកណ្តាលស្ទឹងមានសាលាវិទ្យាល័យចំនួនបីដែរគឺ៖ (១)វិទ្យាល័យកំពង់កន្ទួត (២)វិទ្យាល័យព្រែកស្លែង និង(៣)វិទ្យាល័យ ប៊ុន រ៉ានី ហ៊ុន សែន ដើមឬស្ស។

ជាមួយគ្នានេះដែរ អ្នកសិក្សាស្រាវជ្រាវបានជ្រើសរើសភាគសំណាកជានាយក/នាយិកា នាយករង/នាយិការង ប្រធានក្រុមបច្ចេកទស និងគ្រូបង្រៀន នៃសាលាគោលដៅដែលបានរៀបរាប់ខាងលើសរុបទាំងអស់ចំនួន ២៣៨នាក់ ដើម្បីបំពេញកម្រងសំណួរស្រាវជ្រាវ តាមរយៈកម្មវិធីអនឡាយ (Google Form)។ ចំនួនភាគសំណាកទាំងអស់ដែលបានរៀបរាប់ខាងលើមាន៖ នាយក/នាយិកាចំនួន១៤នាក់ នាយករង/នាយិការងចំនួន២៨នាក់ ប្រធានក្រុមបច្ចេកទេសចំនួន៧០នាក់ និងគ្រូបង្រៀនចំនួន១២៦នាក់។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះចែកចេញជាប្រាំជំពូក។ នៅក្នុងជំពូកទី១គឺជាសេចក្តីផ្តើមដែលផ្តោតជាសំខាន់លើលំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ សំណួរស្រាវជ្រាវ សារៈសំខាន់ និងដែនកំណត់នៃការស្រាវជ្រាវ និងរចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវផងដែរ។ ចំពោះជំពូកទី២គឺជាការរំលឹកទ្រឹស្តី។ នៅក្នុងជំពូកនេះអ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់ទិន្នន័យបឋម សម្រាប់ប្រមូលព័ត៌មាន ឯកសារ និងបញ្ហាពាក់ព័ន្ធនានាសម្រាប់ធ្វើជាអំណះអំណាង ដើម្បីឆ្លុះបញ្ចាំង និងស្វែងយល់ពីការប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនបែបរិះរក សម្រាប់ធ្វើជាមូលន័យ ជាត្រីវិស័យ ឬជាទឡ្ហីករណ៍នៃការស្រាវជ្រាវនេះ និងសម្រាប់រៀបចំកម្រងសំណួរសម្ភាសលើភាគសំណាកដែលបានកំណត់នៅក្នុងដែនកំណត់នៃការស្រាវជ្រាវនេះផងដែរ។

ចំណែកនៅក្នុងជំពូកទី៣គឺផ្តោតជាសំខាន់លើការប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវ របៀបស្រាវជ្រាវ របៀបវិភាគទិន្នន័យ របៀបប្រមូលទិន្នន័យ ជាពិសេសបន្ទាប់ពីការផ្តល់ចំលើយលើកម្រងសំណួរដែលភាគសំណាកផ្តល់ជូនរួចរាល់។ នៅក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវក៏បានបង្ហាញពីរបៀបនៃការសិក្សាស្រាវជ្រាវ ការប្រមូលសំណាក ការប្រមូលព័ត៌មាន ការវិភាគព័ត៌មាន ការប្រើប្រាស់ឧបករណ៍ ស្ថិតិ ការប្រើប្រាស់រូបមន្តសម្រាប់គណនា និងការជ្រើសរើសវិធីសាស្ត្រសម្រាប់ប្រមូលទិន្នន័យផងដែរ។ ចំពោះនៅ

ក្នុងជំពូកទី៤គឺ ផ្តោតជាសំខាន់លើលទ្ធផលនៃការស្រាវជ្រាវ ការបកស្រាយទិន្នន័យ ការបង្ហាញទិន្នន័យជាក់ស្តែង ដូចជាក្រាប ជាតារាង និងការពិភាក្សាទៅលើទស្សនៈយល់ឃើញរបស់ភាគសំណាកទាំងអស់អំពីការប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនបែបរិះរកនេះ ដោយយោងទៅលើទ្រឹស្តី និងកម្រងសំណួរស្រាវជ្រាវដែលអ្នកស្រាវជ្រាវផ្តល់ជូន។ ចំណែកនៅក្នុងជំពូកទី៥គឺជាសេចក្តីសន្និដ្ឋាននិងសំណូមពរ។

នៅក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវបានសង្ខេបខ្លឹមសារ និងបញ្ហាប្រឈមនានានៃការសិក្សាស្រាវជ្រាវបន្ទាប់មកទាញជាសេចក្តីសន្និដ្ឋាន លើចំណុចដែលបានវិភាគ និងផ្តល់យោបល់គ្រឡប់ ឬសំណូមពរទៅលើចំណុចដែលត្រូវកែលម្អ ជាពិសេសគឺបញ្ហាប្រឈមដែលលោកគ្រូអ្នកគ្រូជួបប្រទះនៅក្នុងការប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនបែបរិះរកនេះ។

# ជំពូកទី២

# រំពូកទ្រឹស្តី

# ជំពូកទី២៖ រំឭកទ្រឹស្តី

## ២.១ និយមន័យបញ្ញត្តិគន្លឹះ

ប្រធានបទនៃការស្រាវជ្រាវដែលមានចំណងជើងថា «**ទស្សនៈគណៈគ្រប់គ្រង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀន ពីការប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនបែបវិះរក នៅសាលាមធ្យមសិក្សាទុតិយភូមិ**» មានពាក់ព័ន្ធជាមួយតួអង្គអប់រំសំខាន់ៗមួយចំនួនដូចជា នាយក/នាយិកា នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនដែលកំពុងបង្រៀននៅសាលាមធ្យមសិក្សាទុតិយភូមិក្នុងក្រុង/ស្រុក ចំនួន៥ នៃខេត្តកណ្តាលគឺ៖ (១)ក្រុងតាខ្មៅ (២)ស្រុកកោះធំ (៣)ស្រុកពញាឮ (៤)ស្រុកអង្គស្នួល និង (៥)ស្រុកកណ្តាលស្ទឹង។

១.គណៈគ្រប់គ្រង៖ មាននាយកសាលា និងនាយករង។ បើផ្អែកនិងយោងលើឯកសារបង្រៀនស្តីពីការបំពេញភារកិច្ចក្នុងសាលារៀន បានបញ្ជាក់ថា «តួនាទី និងភារកិច្ច» របស់នាយកសាលាសំដៅដល់ថ្នាក់ដឹកនាំសាលារៀន។ នាយកជាមនុស្សតែម្នាក់គត់ដែលត្រូវដឹងព័ត៌មានគ្រប់បែបយ៉ាងនៅក្នុងសាលារៀនដែលក្នុងនោះមានដូចជា ដំណើរការប្រព្រឹត្តទៅនៅក្នុងសាលា បញ្ហាប្រឈមនានាដែលកើតមាននៅក្នុងសាលារៀន។ នាយកសាលាត្រូវធ្វើការងារជាច្រើនទាក់ទងជាមួយការដឹកនាំ និងគ្រប់គ្រងអង្គភាពរបស់ខ្លួន។ ការដឹកនាំគ្រប់គ្រងរដ្ឋបាល ការបង្រៀន និងរៀន(លទ្ធផលការសិក្សារបស់សិស្ស) ការគ្រប់គ្រងបុគ្គលិក និងហិរញ្ញវត្ថុ ការប្រកបមុខវិជ្ជាជីវៈ ការរក្សាស្វ័យភាព គណនេយ្យភាព តម្លាភាព និងមានភាពទន់ភ្លន់ ឬបត់បែនតាមស្ថានភាពជាក់ស្តែង(បណ្ឌិត នីរដ្ឋា, ២០២០)។

ជាមួយគ្នានេះដែរ នាយកសាលាត្រូវមានគុណសម្បត្តិសំខាន់៣យ៉ាងក្នុងការបំពេញ កិច្ចការ និងការទទួលខុសត្រូវរបស់ខ្លួនដូចជា ត្រូវមាន**ឆន្ទៈម្ចាស់ការ ភក្តីភាព និងមនសិការវិជ្ជាជីវៈ**។ **នាយកសាលាជាបេះដូងរបស់សាលារៀន** ដូចនេះនាយកសាលាត្រូវយល់ដឹងឱ្យបានច្បាស់អំពីតួនាទី និងភារកិច្ចសំខាន់ៗជាសារវន្តរបស់ខ្លួន ហើយត្រូវប្រឹងប្រែងធ្វើខ្លួនឱ្យក្លាយជា **បេះដូងរបស់សាលារៀន** សម្រាប់សិស្សានុសិស្ស មាតាបិតាសិស្សក៏ដូចជាសហគមន៍ និងសង្គម។ ដើម្បីសម្រេចបាននូវការងារនេះ នាយកសាលាដើរតួនាទី

**ជាអាជ្ញាធរអប់រំ មន្ត្រីរដ្ឋបាល ទីប្រឹក្សាគរុកោសល្យ អធិការអេចន្ទ្រៃយ៍ អ្នកចរចារ អ្នកអប់រំ អ្នកផ្តល់សេវាកម្ម អ្នកពិគ្រោះយោបល់ និងជាភ្នាក់ងារអភិវឌ្ឍរបស់សហគមន៍**(បណ្ឌិត នីរដ្ឋា,២០២០)។

បើយោងទៅតាមសៀវភៅគោលនយោបាយស្តីពី «ក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន» បានចែងថា គណៈគ្រប់គ្រងសាលារៀនត្រូវបានរៀបចំឡើងសម្រាប់នាយក និងនាយករងដែលមានឧបនិស្ស័យក្នុងការដឹកនាំ និងគ្រប់គ្រងសាលារៀន និងត្រូវបានគេបែងចែកជាបីកម្រិតដូចជា៖

**ក. នាយកឈានមុខ៖** សំដៅទៅលើនាយកដែលឈានមុខគេ មានគុណផលដឹកនាំ និងគ្រប់គ្រងសាលារៀន ធ្វើឱ្យប្រសើរឡើងនូវគុណផលសិក្សារបស់សិស្សតាមរយៈការគ្រប់គ្រង ការអនុវត្តកម្មវិធីសិក្សា ការបង្រៀន ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស និងធ្វើការអភិវឌ្ឍវិជ្ជាជីវៈបង្រៀនរបស់ខ្លួនជាប្រចាំនៅកម្រិតសាលារៀននោះ។

**ខ. នាយកគំរូ៖** សំដៅទៅលើនាយកសាលាដែលដើរតួជាគំរូគេ មានគុណផលដឹកនាំ និងគ្រប់គ្រងសាលារៀន ធ្វើឱ្យការអនុវត្តកម្មវិធីសិក្សាប្រសើរឡើង ទាំងការបង្រៀន ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស និងត្រូវធ្វើការអភិវឌ្ឍវិជ្ជាជីវៈបង្រៀនរបស់ខ្លួនជាប្រចាំផងដែរទាំងនៅកម្រិតស្រុក ឬខេត្ត។

**គ.នាយកឆ្នើម៖** ជានាយកដែលមានគុណផលដឹកនាំ និងគ្រប់គ្រងសាលារៀន ដោយធ្វើឱ្យប្រសើរឡើងនូវគោលនយោបាយ និងការអនុវត្តនានាពាក់ព័ន្ធជាមួយការអនុវត្តកម្មវិធីសិក្សា ការបង្រៀន ការវាយតម្លៃលទ្ធផលសិក្សារបស់សិស្ស និងធ្វើការអភិវឌ្ឍវិជ្ជាជីវៈបង្រៀនរបស់ខ្លួនជាប្រចាំនៅកម្រិតជាតិ។

២.ប្រធានក្រុមបច្ចេកទេស៖ សំដៅលើគ្រូបង្រៀនជាន់ខ្ពស់នៅក្នុងសាលារៀន ជាអ្នកដឹកនាំ និងគ្រប់គ្រងក្រុមគ្រូបង្រៀនផ្នែកឯកទេសរបស់ខ្លួនតាមមុខវិជ្ជានីមួយ។ ប្រធានក្រុមបច្ចេកទេសទទួលខុសត្រូវក្នុងការគ្រប់គ្រង និងធ្វើឱ្យប្រាកដថា អ្វីៗគ្រប់យ៉ាងកំពុងដំណើរការយ៉ាងរលូនពីមួយថ្ងៃទៅមួយថ្ងៃជាពិសេសនៅក្នុងដំណើរការរៀន និងបង្រៀន នៅក្នុងសាលារៀនរបស់ខ្លួន។ ជាមួយគ្នានេះដែរ ប្រធានក្រុមបច្ចេកទេសដើរតួនាទីយ៉ាងសំខាន់ក្នុងការចាត់ចែងការបង្រៀន និងរៀន ដោយចំណាយពេលវេលា ធ្វើការចែករំលែកបទពិសោធន៍ វិធីសាស្ត្របង្រៀនថ្មីៗដល់សមាជិក ជួយបំពេញបន្ថែមលើសមត្ថភាព ជំនាញតាមរយៈការសិក្សាស្រាវជ្រាវ និងការបណ្តុះបណ្តាលនានាដល់គ្រូបង្រៀននៅក្នុងសាលាឬក្នុងមុខវិជ្ជាជីវៈ

របស់ខ្លួន។ ជាងនេះទៅទៀត គាត់ត្រូវធ្វើការលើកទឹកចិត្ត គ្រប់គ្រងបុគ្គលិក និងសិស្សានុសិស្សក្នុងដំណើរការបង្រៀន និងរៀនឱ្យបានល្អ និងមានប្រសិទ្ធភាពផងដែរ(Stevepeacocke, Job Description and Resume Examples, 2021)។

បញ្ញត្តិអំពីប្រធានក្រុមបច្ចេកទេសសំដៅលើក្រុមមនុស្សដែលគ្រប់គ្រង លើអ្នកធ្វើការងាររដ្ឋបាល គ្រូបង្រៀន និងបុគ្គលិក ឬជាសមាជិកផ្សេងៗទៀត ដើម្បីងាយស្រួលធ្វើការសម្រេចចិត្ត លើការងារអភិបាលកិច្ចសំខាន់ៗនៅក្នុងសាលារៀន និង/ឬជាអ្នកដឹកនាំ និងជាអ្នកសម្របសម្រួលគំនិតផ្តួចផ្តើមនានាដើម្បីឱ្យការងារទាំងនោះមានវឌ្ឍនភាពល្អប្រសើរឡើង។ ប្រធានក្រុមបច្ចេកទេសមានតួនាទី និងដើរតួជាគំរូមួយចំនួនដូចជា៖ អភិវឌ្ឍ សម្របសម្រួល ដឹកនាំ មានគំនិតផ្តួចផ្តើមដើម្បីវឌ្ឍនភាពសាលារៀន និងវិភាគទិន្នន័យដែលទាក់ទងនឹងសមត្ថភាពរបស់សិស្ស គ្រូបង្រៀន ព្រមទាំងលើកឡើងនូវយុទ្ធសាស្ត្រជាក់លាក់ស្របតាមកម្មវិធីសិក្សា ឬសៀវភៅសិក្សាគោល និងតម្រូវការបង្រៀន(*Stevepeacocke,* Job Description and Resume Examples, 2021)។

ជាងនេះទៅទៀត ប្រធានក្រុមបច្ចេកទេសត្រូវលើកទឹកចិត្ត សម្របសម្រួល និងគាំទ្រលើកិច្ចការសហការ និងស្និទ្ធស្នាលក្នុងចំណោមគ្រូបង្រៀនដូចគ្នា។ ត្រួតពិនិត្យ និងធ្វើឱ្យប្រសើរឡើងនូវ ឱកាសអភិវឌ្ឍវិជ្ជាជីវៈសម្រាប់គ្រូបង្រៀន សមាជិក និងបុគ្គលិកផ្សេងៗទៀត។ ជ្រើសរើស កែតម្រូវ ឬធ្វើទំនើបកម្មកម្មវិធីសិក្សា សៀវភៅសិក្សាគោល និងបច្ចេកទេសនៃការបង្រៀន និងរៀន។ ដោះស្រាយបញ្ហាដែលពាក់ព័ន្ធ ទំនាក់ទំនងក្នុងការសិក្សានិងវប្បធម៌សិក្សា វប្បធម៌សង្គម និងវិជ្ជាជីវៈនៅក្នុងសាលារៀន។ ប្រធានក្រុមបច្ចេកទេសអាចផ្តល់គោលការណែនាំទៅលើការសម្រេចចិត្តនៃការចាយវាយថវិកាសាលារៀន ដែលជាជំនួយកម្មវិធី និងជាធនធានសម្រាប់លើកតម្លើងការសិក្សារបស់សិស្ស ព្រមទាំងធ្វើប្រសើរឡើងនូវទំនាក់ទំនងផ្ទៃក្នុងជាមួយបុគ្គលិកសិក្សាដូចគ្នា និងត្រូវមានទំនាក់ទំនងផ្ទៃក្រៅ ជាពិសេសរវាងសាលារៀន និងសហគមន៍ឱ្យបានល្អផងដែរ *(Stevepeacocke,* Job Description and Resume Examples, 2021) ។

៣.គ្រូបង្រៀន៖ ជាសិក្ខាបនជារី ជាកម្លាំងអប់រំចម្បងក្នុងការជួយសិស្សានុសិស្សដោយផ្ទាល់ ដើម្បីឱ្យសិស្សអាចសម្រេចកិច្ចរៀនសូត្ររបស់ពួកគេ និងជាភារកិច្ចស្នួលរបស់សាលារៀនផងដែរ។ ថ្នាក់រៀននីមួយៗត្រូវមានកម្មវិធីសិក្សាប្រចាំឆ្នាំ ប្រចាំឆមាស ប្រចាំខែ តាមមុខវិជ្ជានីមួយៗ និងមានម៉ោងសម្គាល់មានវិធីសាស្ត្របង្រៀន មានវត្ថុបំណងនៃមេរៀន មានលំហាត់សម្រាប់អនុវត្ត ដែលក្រសួងអប់រំ យុវជន និងកីឡាដាក់ចេញ។ ថ្នាក់រៀននីមួយៗតែងមានសិស្សានុសិស្សចម្រុះគ្នា និងមានចំនួនច្រើនចាប់ពី៣០ទៅ៤៥នាក់ជាដើម ជាមួយគ្នានេះដែរសិស្សទាំងនោះមានចិត្តសាស្ត្រមិនដូចគ្នា និងមានស្ថានភាពគ្រួសារមិនដូចគ្នាផងដែរ (បណ្ឌិត នី វដ្ឋា, ឆ្នាំ២០២០)[3]។

គ្រូបង្រៀនដើរតួនាទីជាអ្នកបច្ចេកទេស ជាអ្នករៀបចំការបង្រៀន និងរៀនលើមុខវិជ្ជា និងជំនាញឯកទេសរបស់ខ្លួន ទៅតាមវិធីសាស្ត្រនានាដែលក្រសួងអប់រំ យុវជន និងកីឡាបានទទួលស្គាល់។ គ្រូបង្រៀនមិនអាចអភិវឌ្ឍសម្បទាចិត្ត-គរុកោសល្យរបស់ខ្លួនបានទេ ប្រសិនបើមិនបង្រៀនតាមវិធីសាស្ត្របង្រៀនដែលទទួលបានពីការបណ្ដុះបណ្ដាលដោយស្ថាប័នគរុកោសល្យអប់រំជាតិ ឬវិទ្យាស្ថានជាតិអប់រំ។ គ្រូបង្រៀនគឺជាអ្នកសិក្សាពេញមួយជីវិត ព្រោះចំណេះដឹងថ្មីតែងកើតមានឡើងជាបន្តបន្ទាប់ ដូចនេះគ្រូបង្រៀនត្រូវតែទទួលចំណេះដឹងថ្មី សិក្សាស្រាវជ្រាវរកអ្វីដែលថ្មី រកអ្វីដែលមានប្រយោជន៍សម្រាប់សិស្ស សហគមន៍ និងសង្គម។ គ្រូបង្រៀនជាអ្នកត្រួសត្រាយផ្លូវ ជាអ្នកដឹកនាំការរៀននិងបង្រៀន។ ហេតុនេះហើយទើបមានល្បះដំបូន្មានគរុកោសល្យមួយបានបំភ្លឺឡើងថា គ្រូបង្រៀន«**ជម្រុញសិស្សខ្សោយដោយមិនពន្យឺតសិស្សពូកែ**»(បណ្ឌិត នី វដ្ឋា, ឆ្នាំ២០២០)។

ដើម្បីឱ្យការបង្រៀនរបស់ខ្លួនសម្រេចបានផលផ្លែផ្កា គ្រូបង្រៀនត្រូវមានលក្ខណៈសម្បត្តិសំខាន់៣យ៉ាងដូចខាងក្រោម៖

១.**ចំណេះដឹងវិជ្ជាជីវៈ**៖ ជាសមត្ថភាពដែលមានលក្ខណៈបុគ្គល និងទទួលបានតាមរយៈការសិក្សារៀនសូត្រ និងការបណ្ដុះបណ្ដាលពីមជ្ឈដ្ឋានអប់រំត្រឹមត្រូវ ព្រមទាំងមានការទទួលស្គាលស្ថាប័នជាតិ រួមទាំងមជ្ឈដ្ឋានសង្គម សហគមន៍ និងសិស្សានុសិស្ស។

---

[3] ផ្អែកលើឯកសារអំពីតួនាទី និងភារកិច្ចរបស់នាយកសាលា លើកការគ្រប់គ្រងការបំពេញភារកិច្ចក្នុងសាលារៀន

២.**ប្រតិបត្តិវិជ្ជាជីវៈ**៖ មានលក្ខណៈជានិយ័តភាពក្នុងការបំពេញការងារ តួនាទី ភារកិច្ច ការរៀបចំផែនការបង្រៀន ការគ្រប់គ្រង និងរៀបចំរដ្ឋបាលថ្នាក់ និងការប្រើប្រាស់កិច្ចតែងការបង្រៀនជាដើម។

៣.**សីលធម៌វិជ្ជាជីវៈ**៖ ជាសីលធម៌បុគ្គល ស្មារតីយុត្តិធម៌ ការស្រលាញ់អាជីពរបស់ខ្លួន ការថ្នាក់ថ្នមសិស្ស ភាពម៉ឺងម៉ាត់ ចិត្តទូលាយ ទឹកមុខស្រស់ស្រាយ មានភក្តីភាព និងមនសិការវិជ្ជជីវៈ(បណ្ឌិត នី រដ្ឋា, ឆ្នាំ២០២០)។

ជាមួយគ្នានេះដែរ បើផ្អែកលើសៀវភៅគោលនយោបាយស្តីពី «ក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន» បានឱ្យដឹងថា គ្រូបង្រៀនត្រូវបានបែងចែងទៅតាមឧបនិស្ស័យបង្រៀនសិស្សនៅក្នុងថ្នាក់រៀន និងបែងចែកជាបីកម្រិតគឺ៖

១) **គ្រូឈានមុខ៖** ជាគ្រូបង្រៀនដែលមានគុណផលការងារ និងធ្វើឱ្យប្រើសើរឡើងនូវការអនុវត្តកម្មវិធីសិក្សា ការបង្រៀន ការវាយតម្លៃ និងគុណផលសិក្សារបស់សិស្សនៅកម្រិតសាលារៀន។

២) **គ្រូគំរូ៖** ជាគ្រូបង្រៀនឈានមុខដែលមានគុណផលការងារ និងធ្វើឱ្យប្រើសើរឡើងនូវ ការអនុវត្តកម្មវិធីសិក្សា ការបង្រៀន ការវាយតម្លៃ និងគុណផលសិក្សាសិស្សនៅកម្រិតស្រុក ឬខេត្ត។

៣) **គ្រូឆ្នើម៖** ជាគ្រូបង្រៀនឆ្នើមដែលមានគុណផលការងារខ្ពស់ និងធ្វើឱ្យប្រសើរឡើងដល់គោលនយោបាយ និងអន្តរាគមន៍ ពាក់ព័ន្ធនឹងការអនុវត្តកម្មវិធីសិក្សា ការបង្រៀន ការវាយតម្លៃគុណផលសិក្សាសិស្ស និងគុណផលសាលារៀននៅកម្រិតជាតិ *(ក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន, ៧ មិថុនា ២០១៨)*។

៤.ការបង្រៀន៖ ជាមាគ៌ានៃការផ្តល់ចំណេះដឹងដល់សិស្សានុសិស្ស តាមរយៈការប្រើប្រាស់វិធីសាស្ត្របង្រៀន ល្បិចកិច្ចកល្ប បច្ចេកទេស ដើម្បីឱ្យសិស្សអភិវឌ្ឍបញ្ញាស្មារតី និងរូបរាងកាយ (ប៉ូ ប៊ុន្នន, ឡុច ចាន់ថន និង ឃិន វណ្ណី ឆ្នាំ២០១៩)[4]។ បើយោងទៅតាមវចនានុក្រមសម្តេចសង្ឃរាជ្យ **ជួន ណាត** បានពន្យល់ថា **ការបង្រៀន**គឺ ការញ៉ាំងឱ្យអ្នកដទៃរៀន ប្រៀនឱ្យចេះ ឱ្យចំណេះ ដោយការបង្ហាត់ ការ

[4] វិធីសាស្ត្របង្រៀន,គ្រឹះស្ថានបោះពុម្ពឯកសារខ្មែរ,ប្រាក់ពៅ,ឃិន វណ្ណី, បាន កក្កដា, ២០១៩,គេហទំព័រ, www.khmerbooks.net

បង្ហាញឱ្យចេះ។ល។ ជាឧទាហរណ៍៖ បង្រៀនអក្សរ បង្រៀនលេខ បង្រៀនច្បាប់។ ការបង្រៀននេះពឹងផ្អែកលើអ្នកមានចំណេះ មានបទពិសោធន៍ និងទទួលបានការអប់រំទោះបីជាតាមរយៈសាសនាក្តី ឬសង្គមក្តី។

បើយោងតាមទស្សនាវដ្តីទិនានុប្បវត្តិអប់រំអន្តរជាតិ[5] ដែលបានមានចំណងជើងថា «បញ្ញត្តិនៃការអប់រំ» និងអ្នកជំនាញអប់រំមួយចំនួនបានលើកឡើងនូវទស្សនៈផ្សេងៗគ្នាលើបញ្ហានេះ។ ចំពោះលោក Edmund Amidson បានផ្តល់និយមន័យលើការបង្រៀនថា ជាដំណើរការ ជាអន្តរកម្ម តែជាដំបូងពាក់ព័ន្ធជាមួយការជជែកគ្នានៅក្នុងថ្នាក់រៀន រវាងគ្រូ និងសិស្ស ដោយកើតឡើងតាមរយៈសកម្មភាពណាមួយពិតប្រាកដ។ លោកក៏បន្តលើកឡើងទៀតថា ការបង្រៀនគឺជាទំនាក់ទំនងដ៏ស្និទ្ធស្នាល រវាងបុគ្គលិកលក្ខណៈដែលមានការរីកចម្រើនច្រើន និងបុគ្គលិកលក្ខណៈដែលមានការរីកចម្រើនតិច ដោយរៀបចំឡើងដើម្បីបន្ថែមការអប់រំដល់បុគ្គលិកលក្ខណៈដែលមានការរីកចម្រើនតិច។

បើតាម លោក ម៉ូរីសុន (Morrison,1934) និងលោក ឌូវី(Dewey,1934)បានបញ្ជាក់ និងបង្ហាញអំពីទស្សនៈនៃការអប់រំរបស់ខ្លួនគាត់ថា«**ការបង្រៀនគឺជាការរៀន រីឯការលក់គឺជាការទិញ**»។ នេះមានន័យថា ការបង្រៀន និងរៀនមានដំណើរស្របគ្នា មានអន្តរកម្មជាមួយគ្នា។ ការបង្រៀនត្រូវមានភាពទាក់ទាញ និងមានចំណាប់អារម្មណ៍ពីអ្នករៀន ទើបការបង្រៀនអាចទទួលបានផលផ្លែផ្កា។ តែបើតាម ចន ប្រូប៊ែកឃើ(John Brubacher,1939) មានទស្សនៈដោយពីនេះ ដោយគាត់បានអះអាងថា «ការបង្រៀនគឺជាការរៀបចំ និងសញ្ជឹងគិតអំពីស្ថានភាពដែលមានចន្លោះប្រហោង ឬឧបសគ្គ ដែលបុគ្គលម្នាក់ៗនឹងយកឈ្នះ និងត្រូវរៀនតាមរយៈការប្រតិបត្តិ»។ ចំពោះ ប៊ីអូ សម្មីត (B.O.Smith) បានផ្តល់និយមន័យលើការបង្រៀនថា ជាប្រព័ន្ធនៃសកម្មភាពដែលមានគោលបំណងដើម្បីបញ្ជ្រាបការរៀន។ ចំពោះ ហ្គិច(Gage, 1963) វិញបានពោលថា «ការបង្រៀនគឺជាទម្រង់មួយដែលមានឥទ្ធពល មានអន្តរកម្ម មានគោលបំណងក្នុងការផ្លាស់ប្តូរឥរិយាបថបុគ្គលម្នាក់ៗ»។ ចំណែក ស្មីត(Smith in 1963)បានផ្តល់និយមន័យបន្ថែមលើបញ្ញត្តិនៃការបង្រៀនថា ជាប្រព័ន្ធនៃសកម្មភាព ពាក់ព័ន្ធនឹងភ្នាក់ងារមួយ គំនិតគោលដៅ និងស្ថានភាពមួយ។ ការរួមបញ្ចូលគ្នានូវវិនិច្ឆ័យពីរនេះគឺជាភ្នាក់ងាយដែលមិនស្ថិតនៅក្រោមការគ្រប់គ្រង ដែលក្នុងនោះ

[5] International Journal of Education, Concept of Education

មានដូចជា ទំហំថ្នាក់រៀន ចរិកលក្ខណៈរបស់សិស្ស រួមទាំងបរិក្ខារូបជាច្រើនទៀត និងភ្នាក់ងារដែលអាចបង្ហាញបាន ដូចជា បច្ចេកទស និងយុទ្ធសាស្ត្រនៃការបង្រៀនជាដើម។

និយាយរួម ការបង្រៀនមានលក្ខណៈសំខាន់ៗជាច្រើន ដែលក្នុងនោះមានដូចជា៖ ១)ការបង្រៀនគឺជាអន្តរកម្មមានប្រសិទ្ធភាពរវាងគ្រូ និងសិស្ស។ ២)ការបង្រៀនគឺជាសិល្បៈ និងជាវិទ្យាសាស្ត្រ។ ៣)ការបង្រៀនគឺជាសិល្បៈ ព្រោះវាទាមទារឱ្យប្រើប្រាស់សកម្មភាពប្រកបដោយទេពកោសល្យ និងគំនិតច្នៃប្រឌិត។ ៤)ការបង្រៀនជាវិទ្យាសាស្ត្រពីព្រោះវាពាក់ព័ន្ធជាមួយការសម្តែងប្រកបដោយបច្ចេកទេស និតិវិធី និងជំនាញ ដែលអាចត្រូវបានសិក្សា ពិពណ៌នា និងរីកចម្រើនតាមលក្ខណៈជាប្រព័ន្ធ។ ៥)ការបង្រៀនមានទម្រង់ផ្សេងៗគ្នា។ វាមានលក្ខណៈជាទម្រង់ផ្លូវការ ឬមិនផ្លូវការដោយសារការបង្រៀនផ្អែកលើស្ថានភាព និងមជ្ឈដ្ឋានខុសៗគ្នា ឬការបង្រៀនតាមបែបសាសនាជាដើម។ ៦)ការបង្រៀនគ្របដណ្តប់ទៅដោយជំនាញ និងទំនាក់ទំនង។ ៧)ការបង្រៀនមានប៉ូលបីយ៉ាងគឺ វត្ថុបំណងនៃការអប់រំ បទពិសោធន៍នៃការរៀន និងការផ្លាស់ប្តូរឥរិយាបថ។ ៨)ការបង្រៀនគួរតែធ្វើផែនការបង្រៀនឱ្យបានល្អប្រសើរ។ ៩)ការបង្រៀនគឺជាការផ្តល់ជំបូន្មាន តែមិនមែនជាការទន្ទេញចាំមាត់ទេ។ ១០)ការបង្រៀនល្អមានលក្ខណៈប្រជាធិបតេយ្យ គ្រូបង្រៀនគោរព និងលើកទឹកចិត្តសិស្ស ក្នុងការសួរសំណួរ ឆ្លើយសំណួរ និងពិភាក្សាអ្វីៗជាមួយសិស្ស។ ១១)ការបង្រៀនផ្តល់គោលការណ៍ណែនាំ គោលដៅ និងការលើកទឹកចិត្តសិស្ស។ ១២)ការបង្រៀនគឺជាសកម្មភាពសហការ។ គ្រូបង្រៀនជម្រុញសិស្សឱ្យចូលរួមសកម្មភាពថ្នាក់រៀនផ្សេងៗដូចជា ការរៀបចំ ការគ្រប់គ្រង ការពិភាក្សា ការកែលំអរ និងការវាយតម្លៃលទ្ធផល។ ១៣)ការបង្រៀនមានលក្ខណៈសមានចិត្តល្អ។ គ្រូបង្រៀនល្អ អភិវឌ្ឍលំនឹងអារម្មណ៍ក្នុងចំណោមសិស្សានុសិស្សទាំងអស់គ្នា។ ១៤)ការបង្រៀនគឺជាដំណោះស្រាយ។ គ្រូបង្រៀនល្អត្រូវដោះបញ្ហាអំពីការរៀនរបស់សិស្ស។ ១៥)ការបង្រៀនគឺជាសកម្មភាពប្រកបដោយវិជ្ជាជីវៈនាំមកនូវការអភិវឌ្ឍសុខដុមនីយកម្ម។ ១៦)ការបង្រៀនជម្រុញអំណាចសិស្សក្នុងការគិត និងនាំផ្លូវពួកគេទៅកាន់ការរៀនដោយខ្លួនឯង។ ១៧)ការបង្រៀនអាចត្រូវធ្វើឡើងតាមរយៈការអង្កេត វិភាគ និងវាយតម្លៃ។ ១៨)ការបង្រៀនគឺជាភារៈកិច្ចឯកទេស និងជាសំណុំនៃជំនាញ។

៥.ការរៀន៖ យោងតាមឯកសារដែលផ្ដល់ដោយសាស្ត្រាចារ្យបណ្ឌិត **នូ វ៉ា** បង្រៀនមុខវិជ្ជា **ការអភិវឌ្ឍកម្មវិធីសិក្សា** សម្រាប់និស្សិតបរិញ្ញាបត្រជាន់ខ្ពស់ជំនាន់ទី៨ ឆ្នាំទី២ ឆមាសទី២ បានពន្យល់អំពីបញ្ញត្តិនៃ «**ការរៀន**» មានអត្ថន័យចំនួន៣យ៉ាងគឺ៖ ១)ការរៀនគឺជាលំនាំមួយដែលនាំឱ្យមានការផ្លាស់ប្ដូរ ហើយការផ្លាស់ប្ដូរនោះបានមកពីការអនុវត្ត ឬបានមកពីបទពិសោធន៍ដែលអ្នករៀនបានជួបប្រទះ។ ២) ការរៀនគឺជាការផ្លាស់ប្ដូរអប្បកិរិយា ឬឥរិយាបថជាវិជ្ជមាន ហើយជាអចិន្ត្រៃយ៍។ ៣) ការរៀនគឺជាការផ្សារភ្ជាប់នូវបទពិសោធរបស់បុគ្គលម្នាក់ៗ ហើយការរៀននេះវាទាក់ទងទៅនឹងទេពកោសល្យ បញ្ញា ចិត្តចលករ ឬភាពឧស្សាហ៍ព្យាយាមរបស់បុគ្គលម្នាក់ៗ។

ជាមួយគ្នានេះដែរ ដើម្បីបង្កើនប្រសិទ្ធភាពក្នុងការរៀន អ្នករៀនត្រូវមានបច្ចេកទេសរៀនមួយចំនួនដូចខាងតទៅ៖ (១)ត្រូវរៀនតាមរយៈធ្វើផែនការរៀនសូត្រឱ្យបានច្បាស់លាស់ (២)ត្រូវរៀនតាមរយៈមតិផ្ដល់យោបល់ត្រឡប់ (៣)ត្រូវរៀនតាមរយៈការរួមបញ្ចូលគ្នា (៤)ត្រូវរៀនតាមរយៈការធ្វើពិសោធន៍ជាក់ស្ដែង និង(៥)ត្រូវរៀនតាមរយៈការរំលឹកឡើងវិញជាញឹកញាប់។

៦.វិធីសាស្ត្របង្រៀន៖ គឺជាល្បិច ឬជាមធ្យោបាយធ្វើឱ្យការងារគ្រូបង្រៀន និងការងារសិស្សអាចសម្រេចបានក្រោមការដឹកនាំរបស់គ្រូ។ សិស្សអាចទទួលបានចំណេះដឹង ចំណេះធ្វើ បំណិនប្រសប់ និងចេះរស់នៅជាមួយអ្នកដទៃ ព្រមទាំងអាចពង្រីកសតិបញ្ញាស្មារតីខ្លួនសំដៅលើកកម្ពស់ការប្រតិបត្តិគ្រប់ភារកិច្ចនៃការបង្រៀន(ប៉ូ ប៊ុន្នួន,ឡុច ចាន់ថន និង ឃិន វណ្ណី, ឆ្នាំ២០២០)។ ប្រព័ន្ធនៃវិធីសាស្ត្របង្រៀនគឺជាគោលវិធីនៃការបង្រៀនដែលអ្នកអប់រំស្គាល់ថា«គោលវិធីគ្រូមជ្ឈមណ្ឌល និងសិស្សមជ្ឈមណ្ឌល»។

ចំណែកឯវិធីសាស្ត្របង្រៀនវិញគេបានបែងចែកជាពីរគឺ វិធីសកម្ម និងវិធីអកម្ម។ វិធីសកម្មគឺជាវិធីសាស្ត្រដែលត្រូវបានគេសង្កេតឃើញថាសិស្សមានសកម្មភាពរស់រវើកនៅក្នុងការសិក្សា ទាំងក្នុងថ្នាក់រៀន និងក្រៅថ្នាក់រៀន។ វិធីបែបសកម្មគឺជាវិធីដែលសិស្សអាចសិក្សាតាមបែបតថភាពនិយម ជាវិធីដែលធ្វើឱ្យសិស្សចេះសិក្សាស្រាវជ្រាវដោយខ្លួនឯង ចេះរៀបចំ និងធ្វើពិសោធន៍ ជាវិធីដែលធ្វើឱ្យសិស្សមានគំនិតច្នៃប្រឌិត ក្រោយពីការប្រតិបត្តិ និងការហ្វឹកហ្វឺនរបស់ខ្លួន។ វិធីអសកម្មគឺជាវិធីសាស្ត្រដែលគេមើលឃើញថាសិស្សធ្វើសកម្មភាពតិច ប្រើប្រាស់បញ្ញាស្មារតីតិច និងរងចាំតែការផ្ដល់ទឡ្ហីករណ៍ ឬចម្លើយពីគ្រូបង្រៀន។

វិធីអសកម្មមានលក្ខណៈជាការសិក្សាតាមបែបគម្ពីរនិយម ជាការបង្រៀនតាមបែបពណ៌នា ឬបង្រៀនតាមបែបឧទ្ទេស ដោយគ្រូជាអ្នកបកស្រាយពន្យល់ និងជាការបង្រៀនតាមបែបអត្ថាធិប្បាយជាដើម (ប៉ូ ប៊ុន្នឡុច ចាន់ថន និង ឃិន វណ្ណី, ឆ្នាំ២០១៩)[6]។

យោងតាមសៀវភៅស្តីពី "អ្វីដែលគ្រូត្រូវដឹង" បានសម្មតវិធីសាស្ត្របង្រៀនថា ជាលក្ខណៈនៃសំណុំគោលការណ៍ និតិវិធី ឬយុទ្ធសាស្ត្រដែលត្រូវបានអនុវត្តដោយគ្រូបង្រៀនដើម្បីសម្រេចបានលទ្ធផលសិក្សាមួយសមស្របតាមបំណងប្រាថ្នារបស់សិស្ស(យ៉េ & Sri, 2007)។ នៅក្នុងសព្វវចនាធិប្បាយគុកកោសល្យដែលបោះពុម្ពផ្សាយនៅឆ្នាំ១៩៦៥បានផ្តល់និយមន័យអំពីវិធីសាស្ត្របង្រៀនថា ជាវិធីសាស្ត្រនៃកិច្ចការងារបង្រៀនរបស់គ្រូ និងសិស្ស ដោយមានជំនួយពីជំនាញនៃចំណេះ ដឹងជំនាញ និងសមត្ថភាព ហើយត្រូវធ្វើយ៉ាងណាឱ្យសម្រេចបានទស្សនវិស័យពិភពលោករបស់សិស្ស និងនិស្សិត ចំណែកសមត្ថភាពរបស់ពួកគេត្រូវបានអភិវឌ្ឍឡើងជាលំដាប់។

យោងតាមសៀវភៅ«វិធីសាស្ត្របង្រៀនសំខាន់ៗសម្រាប់ការអប់រំឥរិយាបថ និងវិទ្យាសាស្ត្រ ឆ្នាំ២០១៧»[7] បានកំណត់ពីវិធីសាស្ត្របង្រៀនថាជាបច្ចេកទេសនៃការបង្រៀន ដែលត្រូវអនុវត្តចំពោះមុខវិជ្ជាផ្សេងៗគ្នា ដោយអាចរៀន និងអនុវត្តបានដោយគ្រូបង្រៀនម្នាក់ៗ។ វិធីសាស្ត្រនេះមានសារៈសំខាន់នៅក្នុងស្ថានភាពនៃការរៀន និងការបង្រៀន។ វិធីដែលគ្រូបង្រៀនប្រើគឺបង្ហាញមេរៀនទៅដល់សិស្សានុសិស្សដែលអាចធ្វើឱ្យគេចូលចិត្តឬមិនចូលចិត្តចំពោះមុខវិជ្ជារបស់គ្រូបង្រៀនម្នាក់នោះ។ ហេតុដូច្នេះហើយ វិធីសាស្ត្របង្រៀនពិតជាអាចជម្រុញឱ្យសិស្សចូលចិត្តសាលារៀន ឬឃ្លាតឆ្ងាយពីសាលារៀនបាន។ ដោយសារតែវិធីសាស្ត្របង្រៀនមានសារៈសំខាន់ ហេតុនេះហើយ ទើបគ្រូបង្រៀនមិនត្រឹមតែគិតអំពីវិធីសាស្ត្រនៃការបង្រៀនទូទៅប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងត្រូវគិតពីវិធីបង្រៀនពិសេសណាមួយសម្រាប់មុខវិជ្ជាដែលមានលក្ខណៈផ្សេងៗគ្នានោះទៀតផង។ នៅពេលវិធីសាស្ត្របង្រៀនមួយចំនួនត្រូវបានគេប្រើប្រាស់ជាច្រើនឆ្នាំកន្លងរួចមកហើយ ចំណែកវិធីសាស្ត្របង្រៀនខ្លះទៀតគេទើបតែបានប្រើប្រាស់នាពេលថ្មីៗនេះប៉ុណ្ណោះ។

---

[6] វិធីសាស្ត្របង្រៀន,គ្រឹះស្ថានបោះពុម្ពឯកសារខ្មែរ,ប្រាក់ពៅ,ឃិន វណ្ណី, បាន កក្កដា, ២០១៩,គេហទំព័រ, www.khmerbooks.net

[7] Essential Teaching Methods for Education and Behavioral Science, 2017

ហេតុនេះហើយទើបនៅក្នុងដំណើរការនៃការរៀន និងបង្រៀនត្រូវបានអ្នកអប់រំប្រើប្រាស់វិធីសាស្ត្រផ្សេងៗគ្នា ដើម្បីសម្រេចវត្ថុបំណង ឬខ្លឹមសារមេរៀនដែលខ្លួនត្រូវបង្រៀន ឬដើម្បីចែករំលែក និងផ្ទេរចំណេះដឹងទៅឱ្យសិស្សទាំងនោះក៏មិនដូចគ្នាដែរ។ គ្រូបង្រៀនត្រូវតែប្រើប្រាស់វិធីសាស្ត្រផ្សេងៗគ្នានៅក្នុងដំណើរការនៃការបង្រៀនរបស់ខ្លួន ហើយវិធីសាស្ត្រដែលប្រើប្រាស់មួយចំនួនគឺជាវិធីបង្រៀនបែបចំរុះ។ គ្រូបង្រៀនតែងតែផ្លាស់ប្តូរវិធីសាស្ត្របង្រៀនមួយ ទៅវិធីសាស្ត្របង្រៀនមួយផ្សេងទៀត ដោយសម្របទៅតាមដំណាក់កាលនៃសកម្មភាពរៀន និងបង្រៀននោះ។ គោលការណ៍ និងនិតិវិធីនេះត្រូវបានកំណត់ដោយផ្អែកលើមុខវិជ្ជាដែលត្រូវបង្រៀន និងមួយផ្នែកទៀតផ្អែកលើទំនុកចិត្ត និងទ្រឹស្តីថា តើសិស្សត្រូវរៀនបែបណា ឬរៀនយ៉ាងដូចម្តេច។

នៅក្នុងដំណើរការរៀន និងបង្រៀននាយុគ្គសម័យទំនើបនេះ បញ្ញត្តិរិះរក(Inquiry)ត្រូវបានអ្នកអប់រំ ក៏ដូចជាអ្នកវិទ្យាសាស្ត្រនិយមប្រើប្រាស់ ដោយចាត់ទុកបញ្ញត្តិរិះរកថាជាដំណើរការផ្លូវការមួយក្នុងការស្វែងរកបុព្វហេតុនៃអ្វីមួយឬស្វែងរកព័ត៌មានអំពីអ្វីមួយ(វចនានុក្រម Oxford Advanced Learner's Dictionary, 1 January 2020)[8]។ ក្នុងន័យប្រហាក់ប្រហែលគ្នានេះដែរ តាមវចនានុក្រមសម្តេចសង្ឃរាជជួន ណាត បានពន្យល់បញ្ញត្តិ **«រិះរក» =«រិះ»+«រក»** ។ ពាក្យ «រិះ» សំដៅទៅលើការគិតពិចារណា គិតគ្នេរគិតច្រើន គិតកាញ់ ល្អិតល្អោចច្រើនពេក។ «រិះ» មើលទាល់តែឃើញពិត ខ្វះខាតអ្វីត្រូវទាយកមក វិញ។ រីឯពាក្យ«**រក**»មានន័យថា សង្វាត ឬស្វែងរកឱ្យជួប ឱ្យប្រទះ ឱ្យឃើញ ឱ្យបានដូចបំណង។ តាម រយៈអត្ថន័យនៃពាក្យទាំងពីរយើងអាចសម្មតបញ្ញត្តិ«រិះរក»ថា ជាការស្វែងរកដោយការគិតពិចារណាឱ្យបានល្អិតល្អន់ ដើម្បីរកឱ្យឃើញ ឱ្យប្រទះ និងឱ្យបានដូចបំណង។

បើយោងតាម Sharon Friesen[9] អំពីប្រធានបទ «ផ្តោតលើការរិះរក» បានផ្តល់និយមនៃបញ្ញត្តិ«ការរិះរក»ថា ជាការអង្កេតដ៏សាមញ្ញ មានលក្ខណៈជាប្រព័ន្ធចំពោះបញ្ហា ហេតុផលបញ្ហា ប្រធានបទ និង

[8] (Oxford Advanced Learner's Dictionary)

[9] Sharon Friesen បានចែកការរិះរកចេញជាបីគំរូគឺ៖ ១) (Universal Inquiry Model), ២) (Minimally Guided Inquiry) និង៣) (Disciplined-Base Inquiry)

បញ្ញត្តិផ្សេងៗ។ ជាមួយគ្នានេះដែរ លោកបានចែកការរិះរកចេញជា៣គំរូគឺ៖១)ការរិះរកបែបសកល។ ២) ការរិះរកដែលមានការណែនាំតិចតួច និង៣)ការរិះរកដោយផ្អែកលើគោលការវិន័យ។

## ២.២ វិធីសាស្ត្របង្រៀន និងរៀនបែបរិះរក (IBL)

### ២.២.១ និយមន័យ និងប្រវត្តិទ្រឹស្តី

វិធីសាស្ត្របង្រៀន និងរៀតាមបែបរិះរក(IBL)គឺជាវិធីសាស្ត្របែបសិស្សមជ្ឈមណ្ឌល។ នៅក្នុងវិធីសាស្ត្រនេះ ដំណើរការរៀន និងបង្រៀនផ្តោតជាសំខាន់លើសកម្មភាពសិស្ស ដោយអនុញ្ញាតឱ្យសិស្សចោទ ឬលើកជាសំណួរ បន្ទាប់មកធ្វើការសិក្សាស្រាវជ្រាវតាមរយៈសំណួរដែលបានលើកឡើងឬចោទសួរនោះ តាមការចង់ចេះចង់ដឹងរបស់សិស្ស។ នៅពេលនោះ គ្រូបង្រៀនដើរតួជាអ្នកសម្របសម្រួល ជាអ្នកដឹកនាំសកម្មភាពសិក្សារបស់សិស្ស និងធ្វើយ៉ាងណាឱ្យលទ្ធផលសិក្សារបស់អាចសម្រេចបានតាមការចង់ចេះចង់ដឹងរបស់សិស្ស និងស្រមតាមវត្ថុបំណងរបស់មេរៀនផងដែរ។ **ការរិះរក**គឺជាបញ្ញត្តិដែលគេបានប្រើប្រាស់នៅក្នុងការអប់រំ និងក្នុងជីវិតប្រចាំថ្ងៃ តែបើការអប់រំវិញ គេសំដៅទៅលើការស្វែងរក ការពន្យល់ និងការរកព័ត៌មានផ្សេងៗ តាមរយៈសំណួរដែលសិស្សបានលើកឡើង(Harlem, 2013)។

បើផ្អែកលើ«ទិនានុប្បវត្តិនៃការរិះរក និងសកម្មភាពក្នុងការអប់រំ»[10] ឆ្នាំ២០១៩បានពន្យល់អំពីវិធីសាស្ត្របង្រៀន និងរៀនបែបរិះរកថា ជាការអនុវត្ត ជាការបង្រៀនដោយឱ្យសិស្សប្រើប្រាស់បទពិសោធន៍ និងម្ចាស់ការលើការរៀនដោយខ្លួនឯង តាមរយៈការបង្កើត អង្កេត និងឆ្លើយសំណួរ (Carwell&LaBrie, 2017)។ វិធីសាស្ត្រនេះត្រូវបានគេចាត់ទុកថា ជាទម្រង់នៃការរៀនដែលសិស្សត្រូវដឹកនាំខ្លួនឯងផ្ទាល់ (self-directed learning) និងទទួលខុសត្រូវលើការរៀនរបស់ខ្លួន(Spronken-Smith& Walker .2010)។ ចំណែក Bell, Smetana, and Binns (2005)បានប្រើប្រាស់ជាឃ្លាមួយ និងបានកំណត់ពីវិធីសាស្ត្រនេះថាជា «ដំណើរការនៃការរៀនសកម្ម»។ ការរៀននេះសំដៅទៅលើធម្មជាតិនៃការរិះរក ហើយគេរំពឹងថាសិស្សឆ្លើយសំណួរនោះបាន តាមរយៈការស្រាវជ្រាវ ការវិភាគទិន្នន័យ និងការផ្លាស់ប្តូរព័ត៌មានគ្នាក្នុងចំណោមក្រុមរបស់ពួកគេ។ វិធីសាស្ត្របង្រៀន និងរៀនតាមបែបរិះរកត្រូវបានគេមើលឃើញថា ជា

[10] Journal of Inquiry & Action in Education, 10(2),2019

ប្រព័ន្ធនៃការរៀនដែលគាំទ្រដល់ការអភិវឌ្ឍចំណេះដឹង ឱ្យសិស្សចេះពីរបៀបនៃការដោះស្រាយបញ្ហា និងមានជំនាញគិតស៊ីជម្រៅ(Maxwell, Lambeth &Cox, 2015)។

ជាមួយគ្នានេះដែរ Saunders-Stewart, Gyles, and Shore (2012) ក៏បានពិចារណារលើទម្រង់ជាច្រើននៃវិធីសាស្ត្របង្រៀន និងរៀនបែបរិះរកនេះ ហើយបានលើកឡើងថា វិធីសាស្ត្រនេះមានដាក់បញ្ចូលនូវ ការវិភាគ ដំណោះស្រាយបញ្ហា ការស្រាវជ្រាវ និងការគិតស៊ីជម្រៅ។ ទោះបីជាការរៀនបែបរិះរកផ្តោតជាសំខាន់ទៅលើសិស្សក៏ដោយក៏លោក Zangori, Forbes, and Biggers (2012)បានអះអាងដោយហេតុផលមួយផ្សេងទៀត និងបានបញ្ជាក់ថា គ្រូបង្រៀនអាចដឹកនាំសិស្សនៅពេលណាមួយ អំឡុងដំណើរការនៃការរៀន ពីព្រោះសិស្សមួយចំនួនដែលទើបតែចាប់ផ្តើមរៀន តាមវិធីសាស្ត្រនេះអាចត្រូវការការបង្រៀន និងការពន្យល់ពីគ្រូច្រើនជាងការដាក់កិច្ចការឱ្យសិស្សរៀន ដើម្បីឱ្យពួកគេមានជំនាញក្នុងការរិះរកនេះ។

ចំពោះ Guido (2017)បានពោលបញ្ជាក់ថា ការបង្រៀននេះគឺជាការត្រួតពិនិត្យលើការរិះរក អំពីទស្សនៈរបស់គ្រូ និងសិស្ស។ ដោយដកចេញពីទស្សនៈរបស់សិស្ស វិធីសាស្ត្របង្រៀន និងរៀនបែបរិះរកផ្តោតលើការអង្កេតបញ្ហា និងសំណួរទម្រង់បើក ចំណែកដកចេញពីទស្សនៈរបស់គ្រូវិញគឺផ្តោតទៅលើការជម្រុញសិស្សឱ្យចង់ដឹងចង់ចេះ ដោយចាប់ផ្តើមពីជំនាញមូលដ្ឋាន បន្ទាប់មកទើបឈានទៅដល់ការយល់ដឹងកម្រិតខ្ពស់ និងការគិតស៊ីជម្រៅ។

ម៉្យាងវិញទៀត វិធីសាស្ត្របង្រៀន និងរៀនបែបរិះរកក៏ស្ថិតនៅក្នុងវិធីសាស្ត្របង្រៀនបែបស្ថាបនានិយមផងដែរ។ ទ្រឹស្តីនេះបានចែងថា«មនុស្សស្ថាបនានូវចំណេះដឹង និងអត្ថន័យផ្ទាល់ខ្លួនចេញពីបទពិសោធន៍ផ្ទាល់ខ្លួនរបស់ពួកគេ(Tamim & Grant, 2013)។ ដូច្នេះហើយ នៅក្នុងករណីនេះ ចំណេះដឹងគឺត្រូវបានកសាងឡើងដោយសិស្សជាងការចែករំលែកពីគ្រូ។

លោក ចន ឌូវី(John Dewey)ជាអ្នកស្ថាបនានិយម និងជាអ្នកគាំទ្រវិធីសាស្ត្របែបស្ថាបនានិយម បានលើកឡើងថា សិស្សគួរតែចូលរួមយ៉ាងសកម្មនៅក្នុងដំណើរការនៃការរៀន។ លោកបានពន្យល់ថា« ប្រសិនបើអ្នកមានការសង្ស័យថាតើការរៀនកើតឡើងយ៉ាងម៉េច ពាក់ព័ន្ធនឹងការរិះរកដូចម្តេច ចូរសិក្សា

និងពិចារណានូវលទ្ធភាពដែលអ្នកអាចជ្រើសរើសបាន និងត្រូវមានជំនឿជាក់ទៅលើភស្តុតាងទាំងអស់នេះ (Dewey, 1998, as cited in Mapes, 2009)។ John Dewey ជឿជាក់យ៉ាងមោះមុតថា សិស្សត្រូវតែជាអ្នកដោះស្រាយបញ្ហាដោយខ្លួនឯង និងមានភាពបត់បែន(Santrock,2017)។

រីឯលោក Jerome Bruner ក៏បានចែករំលែកទស្សនទានចំពោះវិធីសាស្ត្របង្រៀនបែបស្ថាបនានិយមនេះផងដែរ ដោយលោកមានការព្រួយបារម្ភជាបឋម អំពីការអប់រំដែលពាក់ព័ន្ធជាមួយនឹងតម្រូវការរបស់សិស្សនៅក្នុងដំណាក់កាលនីមួយៗ។ គាត់មានជំនឿជាក់ថា គ្រូបង្រៀនគួរតែសម្រេចឱ្យបាននូវបញ្ហានេះដោយអនុញ្ញាតឱ្យសិស្សចូលរួមយ៉ាងសកម្មក្នុងដំណើរការរៀន។ ទ្រឹស្តីរបស់លោកទាំងពីរជាការរៀនបែបរុករក និងជាទម្រង់មួយនៃវិធីសាស្ត្របង្រៀន និងរៀនបែបរិះរក ហើយគាត់បានសំអាងថា សិស្សទំនងជាយល់ និងចងចាំនូវគំនិតដែលពួកគេរកឃើញ នៅក្នុងអំឡុងពេលធ្វើអន្តរកម្មជាមួយនឹងបរិយាកាសនៅជុំវិញខ្លួន(Roblyer & Doering, 2013)។

ចំពោះលោក Lev Vygotsky ស្នាដៃរបស់លោកត្រូវបានគេស្គាល់ថា ជាទ្រឹស្តីស្ថាបនានិយមសង្គមបានធ្វើការបកស្រាយថា អន្តរកម្មសង្គម និងការគិតស៊ីជម្រៅគឺជាគ្រឿងផ្សំពីរដ៏សំខាន់របស់ដំណើរការនៃការរៀន(Liu&Chen,2010)។ លោកក៏បានពិពណ៌នាបន្ថែមទៀតថា «វិធីសាស្ត្របង្រៀន និងរៀនបែបរិះរកគឺជាផ្នែកមួយនៃការបង្កើតថ្នាក់រៀនបែបស្ថាបនាសង្គមនិយម»(Powell & Kalina, 2009)។

វិធីសាស្ត្របង្រៀន និងរៀនបែបរិះរកអាចត្រូវបានអនុវត្តនៅកម្រិតសិក្សាផ្សេងៗគ្នា (Duran & Dökme, 2016)។ បើតាម Mackenzie (2016) បានរកឃើញពី«ភាពខុសគ្នា»រវាងការរិះរកចំនួន៤ប្រភេទរបស់សិស្ស ហើយការរិះរកទាំងនោះមានដូចជា៖ ១)រៀបចំរចនាសម្ព័ន្ធ ២)ត្រួតពិនិត្យ ៣)ដឹកនាំ និង៤)សេរីភាព។ **គំរូរិះរកតាមរចនាសម្ព័ន្ធ៖** សិស្សអនុវត្តតាមការដឹកនាំរបស់គ្រូសំដៅទៅលើការចូលរួមរបស់ថ្នាក់ទាំងមូលដោយធ្វើការរិះរករួមគ្នា។ **ការរិះរកតាមរយៈការត្រួតពិនិត្យ៖** គ្រូជ្រើសរើសប្រធានបទ និងបញ្ជាក់ពីប្រភពទដែលសិស្សនឹងប្រើប្រាស់ដើម្បីឆ្លើយសំណួរ។ **ការរិះរកតាមរយៈការដឹកនាំ៖** គ្រូជ្រើសរើសប្រធានបទ និងសំណួរ ហើយសិស្សត្រូវរៀបចំផលិតផល ឬដំណោះស្រាយលើប្រធានបទ និងសំណួរ

នោះ។ **ការរិះរកដោយសេរី៖** សិស្សជ្រើសរើសប្រធានបទដោយពុំមានឯកសារយោងចំពោះលទ្ធផល ដែលអាចធ្វើបាន ឬធ្វើមិនបាន។

ជាមួយគ្នានេះដែរ លោកក៏បានពន្យល់បន្ថែមថា គ្រូបង្រៀនជាធម្មតាចាប់ផ្តើមឆ្នាំសិក្សាក្នុងគំរូរិះរកតាមរចនាសម្ព័ន្ធ ហើយបន្តទៅកាន់ការរិះរកដោយត្រួតពិនិត្យ បន្ទាប់មកទៀត ការរិះរកតាមរយៈការដឹកនាំ ហើយប្រសិនបើទាំងអស់នេះដំណើរការទៅបានល្អ គ្រូបង្រៀនអាចបញ្ចប់ឆ្នាំសិស្ស និងអាចធ្វើការរិះរកដោយសេរី។

ចំណែក Marshall (2013) បានរកឃើញអំពីការរិះរក ដែលកើតឡើងជាបន្តបន្ទាប់ និងបានស្នើសុំដល់អ្នកអានឱ្យធ្វើការស្រមើស្រមៃទៅលើគោលដៅមួយ ដែលគ្រូបង្រៀនជាអ្នកប្រាប់អំពីព័ត៌មាន និងទៅលើគោលដៅផ្ទុយពីអ្វីដែលគ្រូបានប្រាប់។ ដូចនេះវាមានន័យថាជាការរិះរកដោយចំហ។ ជាមួយគ្នានេះដែរ លោកបានសំដៅទៅលើពាក្យគន្លឹះខាងក្រោម ដើម្បីពិពណ៌នាអំពីការរិះរកទាំងបួនប្រភេទគឺ៖ គ្រូជាអ្នកប្រាប់ ការរិះរកតាមបញ្ហា ការរិះរកតាមការដឹកនាំ និងការរិះរកដោយចំហ។ សិស្សចូលរួមក្នុងការរិះរកតាមបញ្ហាជាធម្មតាធ្វើអ្វីបានតិចតួច និងពុំមានការគិតស៊ីជម្រៅទេ។ នេះជាហេតុផលដែលគួរតែជាករណីលើកលែងជាជាងនិតិវិធីទូទៅ។ម្យ៉ាងវិញទៀត ពេលបង្រៀនក៏ដាក់បញ្ចូលការរិះរកបែបដឹកនាំដ៏មានប្រសិទ្ធភាពដែរ ហើយការរៀនរៀបនេះគឺមានភាពសំបូរបែប និងមានការប្រកួតប្រជែងសមត្ថភាព ចំពោះសិស្សគ្រប់កម្រិត (Marshall, 2013)។

### ២.២.២ ក្របខ័ណ្ឌសម្រាប់វិធីសាស្ត្របង្រៀន និងរៀនបែបរិះរក

ការរិះរកមានដំណាក់កាលផ្សេងៗគ្នានៅក្នុងការអប់រំ (Pedaste et al., 2015)។ ចំពោះលោក Marshall (2013) បានចាត់ថ្នាក់ការរិះរកជាបួនដំណាក់កាលគឺ៖ ចូលរួម (Engage) រុករក (Explore) ពន្យល់ (Explain) និងពង្រីក (Extend) និងមានបញ្ចូលនូវការវាយតម្លៃ (Formative assessment) និងការអនុវត្តដើម្បីធ្វើការឆ្លុះបញ្ចាំងពីដំណាក់កាលនីមួយៗ។ ចំណែក (Bybee et al, 2006), បានចាត់ថ្នាក់ការរិះរកជាប្រាំដំណាក់កាលទៅវិញ គឺការចូលរួម (Engagement) ការរុករក (Exploration) ការពន្យល់ (Explanation) ការពន្យល់ពិស្តារ (Elaboration) និងការវាយតម្លៃ (Evaluation)។

ទោះបីជាយ៉ាងណាក៏ដោយ វិធីសាស្ត្របង្រៀន និងរៀនបែបរិះរកគឺមិនមែនជាដំណើរការលីនេអ៊ែ និងដំណើរការតាមតែបទបញ្ជានោះទេ (Pedaste et al, 2015)។ Peter and Stout (2011) បានបែងចែកការរិះរកជាគំរូ៦អ៊ី ដែលមានលក្ខណៈប្រហាក់ប្រហែលនឹងគំរូ៥អ៊ីដែរ(Bybee et al, 2006) ប៉ុន្តែវាបន្ថែមសមាសធាតុមួយទៀតទៅលើគំរូ៥អ៊ី ដោយក្នុងនោះមានដូចជា៖ ការចូលរួម (Engagement) ការរុករក (Exploration) ការពន្យល់ (Explanation) ការពន្យល់ពិស្តារ (Elaboration) ការវាយតម្លៃ (Evaluation) និងការសិក្សាពីចម្ងាយ (E-learning) ។

២.២.៣ ការប្រើប្រាស់វិធីសាស្ត្របង្រៀនតាមមុខវិជ្ជា

ក្នុងបច្ចុប្បន្នសម័យនេះ គ្រូបង្រៀននៅលើពិភពលោក ជាទូទៅបានស្គាល់អំពី«គោលវិធីសិស្សមជ្ឈមណ្ឌល»។ បើមិនស្គាល់ពីវិធីសាស្ត្របង្រៀនទេ យ៉ាងហោចណាស់ក៏អាចស្គាល់ឈ្មោះរបស់វាដែរ។ ទោះបីយ៉ាងណាក៏ដោយ ក៏នៅតែមានការយល់ច្រឡំដែរក្នុងចំណោមគ្រូបង្រៀនទាំងនោះ។ គ្រូបង្រៀនភាគច្រើនយល់ថា ការបង្រៀនរបស់ពួកគាត់បានអនុវត្តតាមគោលវិធីសិស្សមជ្ឈមណ្ឌលហើយ។ គ្រូមួយចំនួនបាននិយាយថា «ខ្ញុំឱ្យសិស្សធ្វើការជាក្រុមរៀងរាល់ម៉ោងបង្រៀន» ឬ«ខ្ញុំតែងតែសួរសំណួរជាច្រើនទៅសិស្សរបស់ខ្ញុំ ដើម្បីឱ្យពួកគេមានការគិតច្រើន» ឬ«ខ្ញុំផ្តល់ឱកាសច្រើន ដើម្បីឱ្យសិស្សអនុវត្ត» ឬ«ខ្ញុំធ្វើការពិសោធន៍ជាញឹកញាប់»។ តើយើងអាចនិយាយបានថាការបង្រៀនរបៀបនេះជាការបង្រៀបតាមគោលវិធីសិស្សមជ្ឈមណ្ឌលដែរឬទេ?។

ដូចនេះ លោកគ្រូអ្នកគ្រូដឹងរួចមកហើយថា ចម្លើយអំពីសំណួរនេះគឺពិតណាស់«ទេ»។ វិធីសាស្ត្រដែលគ្រូបង្រៀនប្រើខាងលើមិនបានឈានទៅរកការសិក្សាតាមបែបគោលវិធីសិស្សមជ្ឈមណ្ឌល និងមានលក្ខណៈពេញលេញនោះទេ។ ជារឿយៗ យើងមើលឃើញថា៖

**ចំពោះការងារជាក្រុម៖** នៅក្នុងការងារក្រុមនេះមានសិស្សតែពីរបីនាក់ប៉ុណ្ណោះដែលបានគិត និងបានចូលរួមធ្វើសកម្មភាព ហើយសិស្សដ៏ទៃទៀតបានតែអង្គុយមើល ដោយមិនបានជួយអ្វីទាំងអស់ ឬនៅពេលគ្រូដាក់សំណួរឱ្យសិស្សតាមក្រុមនីមួយៗ ជាទូទៅមានសិស្សពូកែតែម្នាក់ឬពីរនាក់ប៉ុណ្ណោះ ដែលជាអ្នកឆ្លើយនឹងសំណួរនោះ។

**ចំពោះការធ្វើពិសោធន៍៖** នៅក្នុងការបង្រៀនជាទូទៅ គ្រូបង្រៀនជាអ្នកធ្វើពិសោធន៍ ក៏ប៉ុន្តែ (១)វាមិនបានផ្តល់ឱ្យសិស្សនូវចំណេះដឹង និងជំនាញថ្មីៗដែលទាក់ទងនឹងផ្នែកវិទ្យាសាស្ត្រទេ (២)លទ្ធផលដែលទទួលបានវាមិនសម្រេចតាមគោលបំណងនៃមេរៀននោះឡើយ (៣)ការសន្និដ្ឋានរបស់សិស្សបានមកពីការរកឃើញនៅក្នុងសៀវភៅពុម្ព មិនមែនបានមកពីលទ្ធផលនៃការធ្វើពិសោធន៍នោះទេ *(ប្រាក់ ពៅ, ឃិន វណ្ណី និង បាន កក្កដា, ឆ្នាំ ២០១៩)*។

ក្នុងករណីដូចបានជម្រាបជូនខាងលើនេះមានន័យថា ដំណើរការនៃការបង្រៀន និងរៀនស្ថិតនៅដាក់ឆ្ងាយពីគោលវិធីសិស្សមជ្ឈមណ្ឌល ឬយើងអាចនិយាយបានថាវាមានលក្ខណៈមិនទាន់ពេញលេញ។ បើដូចនេះ តើអ្នកគិតថា មានហេតុផលអ្វីដែលនាំឱ្យមានការសន្និដ្ឋានបែបនេះ? គំនិតភាគច្រើនយល់ថាគោលវិធីសិស្សមជ្ឈមណ្ឌលដែលផ្តោតលើការអប់រំវិទ្យាសាស្ត្រ គណិតវិទ្យា ភាសា និងវិទ្យាសាស្ត្រសង្គមពុំទាន់មានការណែនាំឱ្យបានល្អិតល្អន់ដល់គ្រូបង្រៀន និងឱ្យប្រើប្រាស់គោលវិធីសិស្សមជ្ឈមណ្ឌលនេះនៅឡើយទេ*(ប្រាក់ ពៅ, ឃិន វណ្ណី និង បាន កក្កដា, ឆ្នាំ ២០១៩)*។

«ការរិះរក» គឺជាវិធីសាស្ត្របង្រៀនមួយដែលស្ថិតនៅក្នុងគោលវិធីសិស្សមជ្ឈមណ្ឌល ដោយផ្តោតទៅលើការអប់រំវិទ្យាសាស្ត្រ និងវិទ្យាសាស្ត្រសង្គម។ ការណែនាំអំពីគោលវិធីនេះបានផ្តល់ឱ្យគ្រូបង្រៀននូវរបៀបនៃការបង្រៀនតាមបែបវិទ្យាសាស្ត្រ និងតាមបែបវិទ្យាសាស្ត្រសង្គមក្នុងទិដ្ឋភាពមួយច្បាស់លាស់។ «**ការរិះរក**» មានន័យថា «ការរកចំណេះដឹងតាមរយៈសំណួរ»។ ដូច្នេះ ការបង្រៀន និងរៀនតាមបែបរិះរកគឺជាការបង្រៀនដែលលើកទឹកចិត្តសិស្សឱ្យធ្វើការជាមួយគ្នា ស្វែងរកចម្លើយនៃសំណួរជាមួយគ្នា ជាជាងការប្រាប់ចម្លើយ និងបង្រៀនដោយផ្ទាល់ពីគ្រូ និងធ្វើអ្វីៗតាមតែគ្រូប្រាប់។ ការងាររបស់គ្រូបង្រៀននៅក្នុងវិធីសាស្ត្រនេះគឺមិនមែនផ្តល់ចំណេះដឹងទៅឱ្យសិស្សនោះទេ ប៉ុន្តែជួយសិស្សឱ្យរកបាននូវចំណេះដឹងណាមួយដោយខ្លួនពួកគេផ្ទាល់*(ប្រាក់ ពៅ, ឃិន វណ្ណី និង បាន កក្កដា, ឆ្នាំ ២០១៩)*។

ការរៀន និងបង្រៀនតាមវិធីសាស្ត្ររិះរកតម្រូវឱ្យសិស្ស ចេះសង្កេត ចេះវិភាគបាតុភូតវិទ្យាសាស្ត្រ ឬវិទ្យាសាស្ត្រសង្គម ដើម្បីបង្កើតសំណួរគន្លឹះ រៀបចំផែនការ ធ្វើពិសោធន៍ ឬធ្វើការស្រាវជ្រាវ ដើម្បីឆ្លើយតបទៅនឹងសំណួរគន្លឹះ ដែលបានលើកឡើង និងទាញសេចក្តីសន្និដ្ឋានមួយសមស្រប តាមរយៈលទ្ធផល

នៃការធ្វើការពិសោធន៍ ឬតាមរយៈការសិក្សាស្រាវជ្រាវ ដោយផ្អែកលើទិន្នន័យ ឬភស្តុតាងដែលប្រមូលបាន។ នៅក្នុងដំណើរការនេះ សិស្សយល់ដឹងអំពីខ្លឹមសារមេរៀនបានកាន់តែច្បាស់ និងកាន់តែស៊ីជម្រៅ ដោយទទួលបានជំនាញ និងចំណេះដឹងបែបវិទ្យាសាស្ត្រយ៉ាងពិតប្រាកដពីលទ្ធផលនៃសិក្សាស្រាវជ្រាវរបស់ពួកគេនោះ។

នៅពេលសិស្សរៀនមុខវិជ្ជាវិទ្យាសាស្ត្រ ឬវិទ្យាសាស្ត្រសង្គមនៅក្នុងថ្នាក់ តាមវិធីសាស្ត្របង្រៀន និងរៀនបែបរិះរកគឺមានន័យថា សិស្សក្លាយជា«អ្នកវិទ្យាសាស្ត្រពាក់កណ្ដាល»រួចទៅហើយ ពីព្រោះពួកគេប្រើប្រាស់វិធីសាស្ត្រនេះដូចគ្នាទៅនឹងអ្នកវិទ្យាសាស្ត្រដែលបានធ្វើការសិក្សាស្រាវជ្រាវដែរ។ ដំណើរការដែលសិស្សត្រូវធ្វើសកម្មភាពនៅក្នុងការបង្រៀន និងរៀនតាមបែបរិះរកគឺមានលក្ខណៈដូចខាងក្រោម៖

*រូបភាពទី១៖ ដំណើរការបង្រៀន និងរៀនបែបរិះរក(ប្រាក់ ពៅ, យិន វណ្ណី និង បាន កក្កដា,ឆ្នាំ ២០១៩)*




នៅក្នុងការបង្រៀន និងរៀនតាមបែបរិះរកគ្រូបង្រៀនក៏អាចទទួលបានបទពិសោធន៍អំពីការសិក្សាផ្នែកវិទ្យាសាស្ត្រ និងផ្នែកវិទ្យាសាស្ត្រសង្គម តាមបែបគោលវិធីសិស្សមជ្ឈមណ្ឌលផងដែរ បើទោះបីជាវិធីសាស្ត្រនៃការបង្រៀននិងរៀនតាមបែបរិះរកនេះទាមទារឱ្យគ្រូបង្រៀនមានចំណេះដឹងខ្ពស់ ខាងផ្នែកវិទ្យាសាស្ត្រ និងផ្នែកវិទ្យាសាស្ត្រសង្គម និងត្រូវមានជំនាញក្នុងការបង្រៀនខ្ពស់ជាងវិធីសាស្ត្រផ្សេងៗទៀត។

### ២.២.៤ ប្លង់មេរៀនតាមបែបរិះរក

#### ក. សមាសភាគក្នុងការបង្រៀន និងរៀនបែបរិះរក

ដូចជាការបង្រៀននៅក្នុងថ្នាក់រៀនធម្មតាដែរ ការបង្រៀន និងរៀនតាមបែបរិះរក មានវត្ថុបំណងមេរៀន និងសកម្មភាពដែលត្រូវបម្រើឱ្យវត្ថុបំណងនោះ។ តារាងទី២ខាងក្រោមនឹងបង្ហាញពីទំនាក់ទំនង រវាងសមាសភាគនៃការបង្រៀន និងរៀនតាមបែបរិះរក ដោយក្នុងនោះមានដូចជា ទំនាក់ទំនងវត្ថុបំណងមេរៀន ការបង្ហាញបាតុភូត សំណួរគន្លឹះ ការស្រាវជ្រាវ និងការសន្និដ្ឋាន។

## ខ.ការបង្កើតសំណួរគន្លឹះ

សំណួរគន្លឹះមានលក្ខណៈសំខាន់បំផុត និងធ្វើឱ្យការបង្រៀន និងរៀនតាមបែបរិះរក ខុសពីការបង្រៀន និងរៀនតាមបែបផ្សេងៗទៀត ជាពិសេសត្រង់ការបង្កើត«**សំណួរគន្លឹះ**»ឬ«សំណួរចាំបាច់» ដែលមានតួនាទីសំខាន់ក្នុងការបង្រៀន និងរៀននេះ។ ដូចដែលបានបង្ហាញនៅក្នុងតារាងខាងក្រោម «សំណួរគន្លឹះ»ត្រូវបានបង្កើតឡើងដោយផ្អែកតាម ការសង្កេត និងការពិភាក្សារបស់សិស្ស ទៅលើបាតុភូតវិទ្យាសាស្ត្រ និងបាតុភូតសង្គម ដែលគ្រូបានផ្តល់ឱ្យ ឬអាចជាការលើកឡើងរបស់សិស្ស។ បន្ទាប់មកទៀត សិស្សត្រូវពិភាក្សា និងបង្កើតសម្មតិកម្ម ដោយផ្អែកលើហេតុផលច្បាស់លាស់ ដើម្បីរៀបចំផែនការសកម្មភាព ធ្វើផែនការស្រាវជ្រាវ ប្រមូលទិន្នន័យសម្រាប់យកមកវិភាគ និងដើម្បីទាញសេចក្តីសន្និដ្ឋាន មួយដែលឆ្លើយតបទៅនឹងវត្ថុបំណងនៃមេរៀន។




រូបភាពទី២៖ ទម្រង់នៃការបង្រៀន និងរៀនតាមបែបរិះរក

### គ. ការស្រាវជ្រាវនៅក្នុងការបង្រៀន និងការរៀនបែបរិះរក

**«ការស្រាវជ្រាវ»** ជាកិច្ចការដែលសិស្សត្រូវធ្វើដោយខ្លួនឯង និងមានការសម្របសម្រួលដោយគ្រូបង្រៀនផ្ទាល់ ជាពិសេសនៅក្នុងដំណើរការរៀន និងបង្រៀនទាំងស្រុង។ កិច្ចការដែលសិស្សត្រូវធ្វើមានដូចជា៖ រៀបចំផែនការ ស្វែងរក ឬសង្កេត ការពិសោធន៍ និងការវិភាគ។ កិច្ចការទាំងនេះត្រូវរៀបចំឱ្យបានល្អ ដើម្បីឆ្លើយតបទៅនឹង «**សំណួរគន្លឹះ**» និងអាចទាញបាននូវ «**សេចក្ដីសន្និដ្ឋាន**» មួយដូចការរំពឹងទុក និងសមស្របជាមួយវត្ថុបំណងមេរៀន។ ជារឿយៗកំហុសតែងកើតមានចំពោះគ្រូបង្រៀនដែលទើបចាប់ផ្ដើមបង្រៀន និងប្រើប្រាស់វិធីសាស្ត្រនេះ ដោយសារតែគាត់មិនទាន់ថ្មិក និងស្ទាត់ជំនាញលើការប្រើប្រាស់វិធីសាស្ត្រនេះជាដើម។ បញ្ហាទាំងនោះមានដូចជា៖ ការរៀបចំ បទពិសោធន៍មិនសូវទាក់ទងទៅនឹងសំណួរគន្លឹះ ឬវត្ថុបំណងមេរៀន។ ព័ត៌មាន ឬខ្លឹមសារមេរៀនដែលទទួលបានតាមរយៈការស្វែងរក នៅក្នុងក្រុមពិភាក្សានីមួយៗមិនទាក់ទងទៅនឹងសំណួរគន្លឹះ ឬវត្ថុបំណងមេរៀនជាដើម។ មានការយកចិត្តទុកដាក់តិចតួចចំពោះលទ្ធផលដែលសិស្សរកឃើញ និងខុសឆ្ងាយពីលទ្ធផល រំពឹងទុក វត្ថុបំណងមេរៀន ឬអាចមានចំណុចផ្សេងៗទៀត(ប្រាក់ ៧, ឃិន វណ្ណី និង បាន កក្កដា, ឆ្នាំ ២០១៩)។

បញ្ហាដែលកើតមានខាងលើអាចបណ្ដាលមកពីគ្រូបង្រៀន មានបទពិសោធន៍តិចតួច មានចំណេះដឹងមុខវិជ្ជាឯកទេសមិនរឹងមាំ ឬខ្សោយឯកទេសតែម្ដង។ ជាងនេះទៅទៀត មានការយល់ដឹង និងប្រើប្រាស់វិធីសាស្ត្របង្រៀនបែបនេះមិនទាន់មានភាពជាក់លាក់ជាដើម។ ម្យ៉ាងវិញទៀត អាចបណ្ដាលមកពីការរៀបចំធ្វើពិសោធន៍ ឬការរៀបចំឯកសារ ឬប្រមូលឯកសារមិនច្បាស់លាស់ និងមិនទាន់បានគ្រប់គ្រាន់នៅឡើយ។ បើដូចនេះ ដើម្បីអនុវត្តការបង្រៀន និងរៀនតាមបែបរិះរកប្រព្រឹត្តទៅបានល្អ ទាមទារឱ្យគ្រូបង្រៀនសិក្សាស្រាវជ្រាវ ពង្រឹងសមត្ថភាពឱ្យបានរឹងមាំ ជាពិសេសអំពីខ្លឹមសារមេរៀនដែលត្រូវបង្រៀន។

### ឃ. សេចក្ដីសន្និដ្ឋានពីការបង្រៀន និងរៀនបែបរិះរក

ចំពោះការបង្រៀន និងរៀនតាមបែបរិះរក«ការសន្និដ្ឋាន»ទាមទារឱ្យគ្រូបង្រៀនមានបម្រុងប្រយ័ត្នខ្ពស់។ គ្រូបង្រៀនមិនគួរធ្វើសេចក្ដីសន្និដ្ឋានឆាប់ពេកនោះទេ ក៏ប៉ុន្តែវាជាកិច្ចការដែលសិស្សត្រូវធ្វើសេចក្ដីសន្និដ្ឋាននោះខ្លួនឯងឬតាមរយៈក្រុម ដោយផ្អែកលើសកម្មភាពស្រាវជ្រាវ ឬលទ្ធផលពិសោធរបស់ពួកគេ។

ទោះបីជាយ៉ាងណាក៏ដោយ ចំពោះបញ្ហានេះ លទ្ធផលនៃការធ្វើពិសោធន៍ ឬលទ្ធផលស្រាវជ្រាវមួយចំនួនពិតជានឹងមានកំហុស ឬមានភាពល្អៀងខ្លះៗ ជាហេតុនាំឱ្យការសន្និដ្ឋានអាចខុសពីការរំពឹងទុកជាក់ជាមិនខានឡើយ។ លទ្ធផលទាំងនោះអាចបណ្ដាលមកពីជំនាញនៃការវាស់វែង ឬមកពីការស្រាវជ្រាវរបស់សិស្សពុំទាន់បានត្រឹមត្រូវ។ ចំណែកបញ្ហាមួយចំនួនទៀតគឺជាកំហុសដែលមិនអាចជៀសផុត ហើយតែងតែកើតឡើងនៅក្នុងការធ្វើពិសោធឬស្រាវជ្រាវនោះតែម្ដង។ ជាមួយគ្នានេះដែរគ្រូបង្រៀនត្រូវតែពិនិត្យឱ្យបានគ្រប់ដំណាក់កាលទាំងអស់នៃដំណើរការនៃការធ្វើពិសោធ ឬការស្រាវជ្រាវរបស់សិស្ស និងជួយសិស្សធ្វើការពិសោធន៍ឱ្យបានត្រឹមត្រូវទៅតាមក្បួនច្បាប់។ ប្រសិនបើមានការសន្និដ្ឋានផ្សេងៗគ្នា នៅក្នុងចំណោមក្រុមសិស្សផ្សេងៗគ្នា នោះគ្រូបង្រៀនត្រូវតែសម្រេចចិត្តថា តើពួកគេត្រូវបន្តការពិភាក្សាតទៅទៀត ឬត្រូវសម្រុះសម្រួល ហើយឱ្យសិស្សទាញសេចក្ដីសន្និដ្ឋានមួយសមស្រប ហើយសិស្សភាគច្រើនអាចទទួលយកបាន ប៉ុន្តែបញ្ហានេះមិនត្រូវបង្ខំពេកទេ។ ម្យ៉ាងទៀតគ្រូអាចជ្រើសរើសមេរៀនណាមួយផ្សេងទៀត ដែលមានខ្លឹមសារពាក់ព័ន្ធគ្នា មកបង្រៀនសម្រាប់ធ្វើជាអំណះអំណាងដើម្បីបញ្ជាក់ និងធ្វើឱ្យការសន្និដ្ឋាននោះមានភាពត្រឹមត្រូវ និងអាចទទួលយកបានទាំងអស់គ្នា(ប្រាក់ ៣, ឃិន វណ្ណី, បាន កក្កដា, ឆ្នាំ ២០១៩)។

ជាងនេះទៅទៀត គ្រូបង្រៀនផ្នែកវិទ្យាសាស្ត្រពិត និងផ្នែកវិទ្យាសាស្ត្រសង្គមភាគច្រើន មានការយល់ច្រឡំរវាង«ការសន្និដ្ឋាន»និង«លទ្ធផលពិសោធ ឬលទ្ធផលស្រាវជ្រាវ»តែតាមការពិតទស្សនៈទាំងពីរនេះមានលក្ខណៈខុសគ្នាទាំងស្រុង(តារាងទី២)។ លទ្ធផលពិសោធ ឬលទ្ធផលស្រាវជ្រាវ មានន័យថាជាព័ត៌មានដែលទទួលបានក្រោយពីការធ្វើពិសោធន៍ ឬស្រាវជ្រាវនោះ។ ចំណែកការសន្និដ្ឋានបានមកពីការវិភាគទៅលើលទ្ធផលពិសោធ ឬលទ្ធផលនៃការស្រាវជ្រាវនោះ។ ម្យ៉ាងទៀតវាមិនត្រឹមតែផ្តល់ចម្លើយចំពោះសំណួរគន្លឹះប៉ុណ្ណោះទេ ប៉ុន្តែវាថែមទាំងបានឆ្លើយតបទៅនឹងវត្ថុបំណងនៃមេរៀនទៀតផង។

### ២.២.៥ បាតុភូតវិទ្យាសាស្ត្រ បាតុភូតសង្គម ឬព្រឹត្តិការណ៍សង្គមចំពោះការរិះរក

#### ក. «ការបង្ហាញពីបាតុភូត ឬព្រឹត្តិការណ៍» និង«សំណួរគន្លឹះ»

ការបង្ហាញពីបាតុភូត ឬព្រឹត្តិការណ៍គឺជាសកម្មភាពមួយនៅដើមមេរៀន។ នៅក្នុងចំណុចនេះ គេតម្រូវឱ្យគ្រូបង្រៀនផ្តោតការយកចិត្តទុកដាក់ជាមួយសិស្ស ជាពិសេសលើខ្លឹមសារមេរៀន ហើយជួយសិស្ស

ឱ្យចេះ ឬអាចបង្កើត«សំណួរគន្លឹះ»បានដោយខ្លួនឯងផ្ទាល់។ ជាទូទៅ«ការបង្ហាញពីបាតុភូត ឬព្រឹត្តិការណ៍» ចាប់ផ្តើមពីការសង្កេត ទៅលើបាតុភូតធម្មជាតិ និងព្រឹត្តិការណ៍សង្គមនានាជាយថាហេតុ ឬជាការអង្កេតរូបភាព ឬវីដេអូដែលទាក់ទងជាមួយខ្លឹមសារមេរៀន។ ដំណើការនេះ បន្តពិភាក្សាពីសំណាក់សិស្សតាមរយៈការផ្តើមសំណួរដោយប្រើពាក្យ«ហេតុអ្វី»ឬ«មានអ្វីប្រសិនបើ»ឬអ្វីមួយដែលជម្រុញសិស្សឱ្យមានការគិតជាដើម។ ឆ្លងតាមរយៈសកម្មភាពនេះ គេត្រូវចាប់ផ្តើមបង្រួមទំហំនៃការគិតរបស់សិស្សឱ្យកាន់តែតូចទៅៗ ដើម្បីឱ្យគេផ្តោតជាសំខាន់ទៅលើសំណួរគន្លឹះរបស់មេរៀន។ ជាមួយគ្នានេះដែរ គួរចងចាំថា«ការបង្ហាញពីបាតុភូត ឬព្រឹត្តិការណ៍» មិនចាំបាច់ធ្វើឡើងគ្រប់មេរៀននោះទេ តែគេអាចលុបចោលខ្លះប្រសិនបើមេរៀនថ្ងៃនេះទាក់ទងដោយផ្ទាល់ទៅនឹងមេរៀនម៉ោងមុន ឬមេរៀនមុខជាដើម(ប្រាក់ ៣, ឃិន វណ្ណី និង បាន កក្កដា, ឆ្នាំ ២០១៩)។

គ្រូបង្រៀនអាចបង្ហាញអំពីបាតុភូត ឬព្រឹត្តិការណ៍នានាមុនឈានទៅដល់ការបង្កើតសំណួរគន្លឹះដែលទាក់ទងជាមួយមេរៀនប្រចាំថ្ងៃ ឬអាចលើកជាឧទាហរណ៍បញ្ជាក់អំពី**បាតុភូតរូប ឬព្រឹត្តិការណ៍រូប**ទាំងនោះ។ គ្រូបង្រៀនអាចលើកឡើងពីបញ្ហាសង្គម សេដ្ឋកិច្ច នយោបាយ ច្បាប់ ការប្រើប្រាស់គ្រឿងញៀន បញ្ហាធម្មជាតិ ឬបញ្ហាវិទ្យាសាស្ត្រជាដើម។ គ្រូបង្រៀនអាចលើកឡើងអំពីភាពផុយស្រួយរបស់សង្គមដែលធ្វើឱ្យអ្នកទន់ខ្សោយទទួលរងគ្រោះកាន់តែច្រើនឡើងៗ។ បន្ទាប់មកគ្រូឱ្យសិស្សធ្វើការសម្មតឬទស្សន៍ទាយ ថាតើនឹងមានរឿងអ្វីកើតឡើងនៅក្នុងសង្គម ប្រសិនបើអ្នករងគ្រោះស៊ូស្លាប់ នាំគ្នាចេញមកប្រឆាំងដើម្បីការពារសិទ្ធិ និងការរំលោភបំពានមកលើខ្លួន។ ជាមួយគ្នានេះដែរ គ្រូឱ្យសិស្សពន្យល់ហេតុផលពីការទស្សន៍ទាយរបស់ពួកគេ។ បន្ទាប់ពីសិស្សបង្ហាញមតិយោបល់របស់ខ្លួន និងមានការសម្របសម្រួលពីគ្រូបង្រៀន បន្ទាប់មកគ្រូអាចបង្ហាញលទ្ធផលអំពីការតស៊ូរបស់ជនរងគ្រោះ បន្ថែមទៅលើមតិយោបល់សិស្ស។ នៅពេលនេះសិស្សអាចលើកឡើង ឬបង្កើតជាសំណួរគន្លឹះបានដូចជា៖ ហេតុអ្វីបានជាមានបដិវត្តកើតឡើង? ហេតុអ្វីបានជាមានការជិះជាន់សង្កត់សង្កិនមកលើប្រជាពលរដ្ឋ? តើការប្រើប្រាស់អំណាចសុទ្ធតែទទួលបានផលវិជ្ជមានដែរឬទេ? (ប្រាក់ ៣, ឃិន វណ្ណី, បាន កក្កដា, ឆ្នាំ ២០១៩)។

ចំពោះ**ការប្រើប្រាស់រូបភាព**ក៏ជាកត្តាសំខាន់ ដែលអាចជួយសិស្សឱ្យចេះបង្កើតសំណួរគន្លឹះផងដែរ ដោយគ្រូបង្ហាញរូបភាពអំពីមនុស្សណាម្នាក់ រួចលើកជាសំណួរថា តើប្អូនៗធ្លាប់ឃើញអ្នកណាម្នាក់អង្គុយម្នាក់ឯង មានទឹកមុខក្រៀមក្រំ ឬនិយាយតែម្នាក់ឯងដែរឬទេ? បន្ទាប់មកទៀត គ្រូបង្ហាញរូបភាពអំពីមនុស្សដែលមានភាពតានតឹងចិត្ត ដោយលើកឡើងនូវសំណួរដូចជា តើប្អូនៗធ្លាប់មានការតានតឹងចិត្តដែរឬទេ? ជាមួយគ្នានេះដែរ គ្រូក៏អាចទាញអារម្មណ៍សិស្សឱ្យផ្តោតទៅលើសំណួរគន្លឹះផ្សេងទៀតដូចជា៖ ហេតុអ្វីបានជាមានការតានតឹងចិត្តកើតឡើង?

ក្នុងករណីមួយទៀត គ្រូបង្រៀនអាចលើកឡើងអំពីបាតុភូតនៃភ្លើងឆេះព្រៃឱ្យសិស្សពិភាក្សា និងបង្កើតជាសំណួរគ្លឹះ។ នៅពេលនេះ គ្រូអាចបង្ហាញរូបភាពអំពីភ្លើងឆេះព្រៃ ហើយដឹកនាំពួកគេឱ្យធ្វើការពិភាក្សា អំពីមូលហេតុនៃភ្លើងឆេះព្រៃនោះ។ ជាមួយគ្នានេះដែរ សិស្សអាចលើកសំណួរគ្លឹះមួយចំនួនតាមការយល់ដឹងរបស់ពួកគេដូចជា៖ ហេតុអ្វីជាមានភ្លើងឆេះព្រៃ? តើភ្លើងឆេះព្រៃបណ្តាលមកពីកត្តាមនុស្សដែរទេ? តើភ្លើងឆេះព្រៃបណ្តាលមកពីផែនដីឡើងកំដៅដែរទេ? ឬបណ្តាលមកពីកត្តាអ្វីផ្សេងៗទៀត?

**ខ.របៀបបង្កើត «សំណួរគន្លឹះ»**

សំណួរគន្លឹះនៅក្នុងមេរៀន និងការរៀនតាមបែបរិះរកគឺមានទំនាក់ទំនងយ៉ាងជិតស្និទ្ធ ទៅនឹងវត្ថុបំណងនៃមេរៀនទាំងមូល។ សំណួរគន្លឹះត្រូវគេបង្កើតឡើងដើម្បីសម្រេចបានវត្ថុបំណងមេរៀន តាមរយៈការឆ្លើយសំណួរគន្លឹះរបស់សិស្ស។ ជាឧទាហរណ៍៖ ប្រសិនបើវត្ថុបំណងមេរៀននិយាយអំពីត្រីទឹកសាបនៅកម្ពុជា គ្រូបង្រៀនអាចឱ្យសិស្សពន្យល់ពីមូលហេតុដែលបណ្តាលឱ្យទិន្នផលត្រីទឹកសាបនៅកម្ពុជាថយចុះ។ ហេតុនេះ គេអាចបង្កើតសំណួរគន្លឹះបានដូចជា «តើមានមូលហេតុអ្វីខ្លះបានជាទិន្នផលត្រីទឹកសាបនៅប្រទេសកម្ពុជាបច្ចុប្បន្នធ្លាក់ចុះ?»។ ក្នុងមេរៀននេះ សិស្សនឹងធ្វើការស្រាវជ្រាវ និងស្វែងរកកត្តាទាំងឡាយដែលធ្វើឱ្យទិន្នផលត្រីទឹកសាបនៅប្រទេសកម្ពុជាធ្លាក់ចុះ។ វាកាន់តែល្អប្រសើរថែមទៀត ប្រសិនបើសិស្សអាចបង្កើតសំណួរគន្លឹះបែបនេះដោយខ្លួនឯង នៅក្នុងពេលរៀនមេរៀននោះ ពីព្រោះពួកគេកាន់តែមានឆន្ទៈខ្ពស់ ចង់ដោះស្រាយបញ្ហា ឬរកឱ្យឃើញបញ្ហាតាមរយៈការឆ្លើយសំណួរគន្លឹះរបស់ពួកគេ ប្រសិនបើសំណួរនោះសួរចេញពីខ្លួនពួកគេផ្ទាល់។ ដូច្នេះ គ្រូបង្រៀនត្រូវគិតពីរបៀបដឹកនាំសិស្ស ឱ្យចេះរក

សំណួរគន្លឹះ តាមរយៈការបង្ហាញពីបាតុភូតវិទ្យាសាស្ត្រ បាតុភូតសង្គម ឬព្រឹត្តិការណ៍នានាដែលទាក់ទង ទៅនឹងជីវភាពរស់នៅប្រចាំថ្ងៃរបស់សិស្ស ហើយដែលសិស្សនឹងត្រូវធ្វើការបកស្រាយ នៅជំហានបន្តបន្ទាប់ទៀត(ប្រាក់ ពៅ, ឃិន វណ្ណី និង បាន កក្កដា, ឆ្នាំ ២០១៩)។

### ២.២.៦ ការវាយតម្លៃការបង្រៀន និងរៀនតាមបែបរិះរក

### ក.គោលបំណង

ជាទូទៅគ្រូបង្រៀនតែងលើកឡើងនូវសំណួរមួយចំនួនដូចជាតើគ្រូបង្រៀនចាំបាច់ត្រូវមានចំណេះដឹងផ្នែកវិទ្យាសាស្ត្រពិត ចំណេះដឹងផ្នែកវិទ្យាសាស្ត្រសង្គម និងចំណេះដឹងផ្នែករិះរកកម្រិតណា ដើម្បីអាចបង្រៀនមេរៀនមុខវិជ្ជាវិទ្យាសាស្ត្រពិត និងវិទ្យាសាស្ត្រសង្គមតាមបែបរិះរកបាន?

ជាការពិតណាស់ គ្រូបង្រៀនមានចំណេះដឹងកាន់ច្រើនកាន់តែប្រសើរ ប្រសិនបើគ្រូបង្រៀនមានចំណេះដឹងច្រើនអំពីការរិះរក ចំណេះដឹងលើមុខវិជ្ជាវិទ្យាសាស្ត្រពិត និងមុខវិជ្ជាវិទ្យាសាស្ត្រសង្គម នោះការបង្រៀន និងរៀនតាមបែបរិះរក នឹងរឹតតែមានប្រសិទ្ធភាពខ្ពស់ថែមទៀត។ ដូច្នេះហើយ គ្រូបង្រៀនត្រូវបានលើកទឹកចិត្តឱ្យបន្តការសិក្សា និងស្រាវជ្រាវបន្ថែមគ្រប់ពេលវេលា ដោយមិនត្រឹមតែចូលរួមក្នុងវគ្គបំប៉ននានាប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចធ្វើការចែករំលែកបទពិសោធន៍របស់ខ្លួនជាមួយគ្រូបង្រៀនដទៃទៀតដែលជាសហការី ឬជាសិស្សានុសិស្សផងដែរ។ គ្រូបង្រៀនដែលគិតថា ខ្លួនល្អគ្រប់គ្រាន់ហើយគឺជាសត្រូវនឹងការធ្វើឱ្យប្រសើរឡើង និងវឌ្ឍនភាពរបស់មនុស្ស និងសង្គម។ ម្យ៉ាងទៀត គ្រូបង្រៀនដែលផ្តោតការយកចិត្តទុកដាក់តែទៅលើកម្រិតនៃការបង្រៀនតាមបែបរិះរកក៏តែងចោទជាសួរសំណួរមួយចំនួនដូចខាងក្រោមនេះផងដែរ។

តើសិស្សត្រូវធ្វើការរិះរកកម្រិតណានៅក្នុងការសិក្សាមេរៀនតាមវិធីសាស្ត្របែបរិះរកនេះ? ការសួរសំណួរបែបនេះអាចមានចម្លើយមិនច្បាស់លាស់ទេ ថែមទាំងអាចមានការយល់ច្រឡំទៀតផង ជាពិសេសក្នុងចំណោមគ្រូបង្រៀនដូចគ្នា។ ដោយសារការបង្រៀមានកម្រិតមិនដូចគ្នាទេ និងអាស្រ័យលើខ្លឹមសារមេរៀន ព្រមទាំងកម្រិតនៃការយល់ដឹងរបស់សិស្ស ទំហំថ្នាក់រៀន ឬស្ថានភាពនៃការរៀន និងបង្រៀនដែល

មានក្ខណៈសមស្រប ឬមិនសមស្របជាដើម។ បើមេរៀនរបស់ខ្ញុំ និងមេរៀនរបស់អ្នកមានកម្រិតរិះកមិនដូចគ្នា តើយើងអាចហៅមេរៀនទាំងពីរនេះថា ជាមេរៀនបែបរិះរកបានដែរឬទេ?។ល។

ការរៀន និងបង្រៀនតាមវិធីសាស្ត្របែបរិះរកត្រូវបានគេទទួលស្គាល់ថា ពិតជាមានកម្រិតនៃការរិះរកច្រើន និងទូលំទូលាយ។ នៅខណៈពេលដែលអ្នកនិពន្ធជាច្រើនផ្តល់នូវគំនិតខុសៗគ្នា ដូចនេះយើងសូមលើកយកទស្សនៈរបស់ លោក Fay និង Bretz(២០០៨) ស្តីពីកម្រិតនៃការបង្រៀនតាមបែបរិះរកមកបង្ហាញ ពីព្រោះវាហាក់ដូចជាងាយយល់ និងអាចអនុវត្តន៍បាននៅក្នុងប្រទេសកម្ពុជាយើង។

**ខ.កម្រិតនៃការរិះរក**

លោក ហ្វេ (Fay) និង ប្រេតហ្ស៍ (Bretz, 2008) បានលើកឡើងអំពីកម្រិតនៃការបង្រៀនតាមបែបរិះរកថាមានលក្ខណៈមិនដូចគ្នាទេ(តារាងទី១)។ លោកទាំងពីរបានផ្តោតទៅលើចំណុចសំខាន់ៗចំនួនបីទាក់ទងនឹងសកម្មភាពនៃការស្រាវជ្រាវ និងសកម្មភាពសម្រាប់មន្ទីរពិសោធន៍គឺៈ ១) បញ្ហា ឬសំណួរដែលសិស្សត្រូវធ្វើការដោះស្រាយ។ ២) ដំណើរការ ឬវិធីសាស្ត្រដែលសិស្សត្រូវប្រើសម្រាប់ធ្វើការសង្កេត។ ៣) ចម្លើយ ឬសេចក្តីសន្និដ្ឋានដែលសិស្សត្រូវបង្កើតឡើងនៅទីបញ្ចប់នៃការពិភាក្សា។ នៅក្នុងតារាងទី១ និងទី២ ខាងក្រោមនឹងផ្តល់ជូននូវសេចក្តីលម្អិតអំពីកម្រិតនៃការរិះរកនីមួយៗ។

**តារាងទី១៖ កម្រិតនៃការរិះរក**

| **កម្រិត** | **បញ្ហា ឬសំណួរគន្លឹះ** | **ដំណើរការ ឬវិធីសាស្ត្រ** | **សេចក្តីសន្និដ្ឋាន** |
|---|---|---|---|
| ០ | ផ្តល់ឱ្យសិស្ស | ផ្តល់ឱ្យសិស្ស | ផ្តល់ឱ្យសិស្ស |
| ១ | ផ្តល់ឱ្យសិស្ស | ផ្តល់ឱ្យសិស្ស | |
| ២ | ផ្តល់ឱ្យសិស្ស | | |
| ៣ | ... | | |

(ប្រភព៖ ប្រាក់ ពៅ ឃិន វណ្ណី បាន កក្កដា, វិធីសាស្ត្របង្រៀន, ឆ្នាំ២០១៩)

**តារាងទី២៖ សេចក្ដីលម្អិតនៃកម្រិតរិះរកនីមួយៗ**

| កម្រិត | ការបរិយាយ |
|---|---|
| ០ | សំណួរគន្លឹះ ដំណើរការ និងសេចក្ដីសន្និដ្ឋានត្រូវបាន**ផ្ដល់ឱ្យសិស្ស**។ សិស្សធ្វើការស្រាវជ្រាវ ឬពិសោធន៍ និងផ្ទៀងផ្ទាត់ចម្លើយជាមួយនឹងសៀវភៅសិក្សា។ |
| ១ | សំណួរគន្លឹះ និងដំណើរការត្រូវបាន **ផ្ដល់ឱ្យសិស្ស**។ សិស្សពន្យល់បកស្រាយទិន្នន័យស្រាវជ្រាវ ឬពិសោធន៍ និងផ្ដល់សេចក្ដីសន្និដ្ឋានដែលសមហេតុផល។ |
| ២ | សំណួរគន្លឹះត្រូវបាន **ផ្ដល់ឱ្យសិស្ស**។ សិស្សត្រូវ **គិត** និង**រៀបចំ** ដំណើរការ ដើម្បីធ្វើការសង្កេត **កំណត់** ទិន្នន័យ ដែលត្រូវវាស់វែង និង**បកស្រាយ** ទិន្នន័យពិសោធន៍ ឬលទ្ធផលស្រាវជ្រាវដែលសមហេតុផល។ |
| ៣ | បាតុភូតមួយចំនួនត្រូវបានផ្ដល់ឱ្យសិស្ស។ សិស្ស **ធ្វើការបង្កើត** ឬសំយោគបញ្ហា ឬសំណួរគន្លឹះមួយ រួចសិស្សត្រូវ **គិត** និង**រៀបចំ** ដំណើរការដើម្បីធ្វើការសង្កេត **កំណត់** ទិន្នន័យ ដែលត្រូវវាស់វែង និង**បកស្រាយ** ទិន្នន័យស្រាវជ្រាវ ឬពិសោធន៍ និងផ្ដល់សេចក្ដី សន្និដ្ឋាន ដែលសមហេតុផល។ |

(ប្រភព៖ ប្រាក់ ពៅ ឃិន វណ្ណី បាន កក្កដា, វិធីសាស្ត្របង្រៀន, ឆ្នាំ២០១៩)

ដូចដែលបានបង្ហាញនៅក្នុងតារាងខាងលើ សេរីភាព និងការទទួលខុសត្រូវរបស់សិស្សមានការរីកចម្រើនពីកម្រិត ០ ទៅ ៣។ នៅកម្រិត ៣ គេចាត់ទុកថា ជាកម្រិតល្អបំផុតនៃការរិះរក។ ដូច្នេះ គេអាចវាយតម្លៃការបង្រៀនរបស់គ្រូ និងរៀនរបស់សិស្ស ថាវាស្ថិតនៅក្នុងកម្រិត១ ឬនៅកម្រិតណា? បើការរៀន និងបង្រៀនស្ថិតនៅកម្រិត ០ មានន័យថា «គ្មានការរិះរក» ទេ។

ទោះបីជាគេមិនអាចរៀបចំការបង្រៀន និងរៀនតាមបែបរិះរកបានលើគ្រប់មេរៀននៃមុខវិជ្ជាវិទ្យាសាស្ត្រពិត និងវិទ្យាសាស្ត្រសង្គមក៏ដោយ តារាងខាងលើអាចផ្ដល់ជាគំនិត និងជាគោលដៅ ដែលអាចសាកល្បងបាន ដោយអាស្រ័យលើស្ថានភាពជាក់ស្ដែង និងការខិតខំប្រឹងប្រែងរបស់គ្រូបង្រៀន។ ជាមួយ

គ្នានេះដែរក៏ទាក់ទងដល់កម្រិតនៃការយល់ដឹងរបស់សិស្ស បរិស្ថានថ្នាក់រៀន សម្ភារៈបង្រៀន ឬឧបករណ៍ពិសោធន៍ជាដើម។ តែប្រសិនបើការបង្រៀន និងរៀនរបស់អ្នកស្ថិតនៅកម្រិតសូន្យ(០)ជាដំបូងអ្នកអាចសាកល្បងបន្តទៅកម្រិត០១ ឬកម្រិត០២បាន។ តែប្រសិនបើមេរៀនរបស់អ្នកឈានដល់កម្រិត០៣ហើយអ្នកត្រូវបន្តធ្វើការកែលម្អគុណភាព ឬប្រសិទ្ធភាពនៃសកម្មភាពនីមួយៗបន្ថែមទៀត ព្រោះការកែលម្អនេះគឺគ្មានទីបញ្ចប់ឡើយ ពោលគឺក្នុងបំណងធ្វើឱ្យការរៀន និងបង្រៀនរបស់អ្នកកាន់តែមានប្រសិទ្ធភាព និងគុណភាពខ្ពស់បន្ថែមទៀត(ប្រាក់ ពៅ, ឃិន វណ្ណី និង បាន កក្កដា, ឆ្នាំ ២០១៩)។

### ២.២.៧ របៀបអភិវឌ្ឍន៍ការបង្រៀន និងរៀន

### ក.ការយល់ដឹងមុនពេលធ្វើកិច្ចតែងការបង្រៀន

ការបង្រៀនមេរៀនតាមវិធីសាស្ត្របែបរិះរក ចំណុចសំខាន់បំផុតគឺគ្រូបង្រៀនត្រូវជួយសិស្សឱ្យចេះបង្កើតសំណួរ ឬចម្ងល់នៅក្នុងចិត្តរបស់ពួកគេ តាមរយៈការបង្ហាញបាតុភូតធម្មជាតិ ឬព្រឹត្តិការណ៍សង្គមដែលទាក់ទងទៅនឹងជីវភាពរបស់នៅប្រចាំថ្ងៃរបស់សិស្ស ជាជាងប្រាប់អំពីវត្ថុបំណងនៃមេរៀនដោយផ្ទាល់ដល់ពួកគេ។ បន្ទាប់ពីការកំណត់បញ្ហា ឬសំណួរគន្លឹះរួច គ្រូបង្រៀនត្រូវសម្រុះសម្រួលឱ្យសិស្សធ្វើការពិភាក្សាគ្នា អំពីអ្វីដែលពួកគេត្រូវធ្វើការសិក្សាឬសង្កេត និងប្រាប់ពីរបៀបដែលពួកគេត្រូវធ្វើ។ នៅពេលនេះជាតួនាទីរបស់គ្រូ ដូចនេះគ្រូត្រូវបង្កើតបរិយាកាសមួយដែលនាំឱ្យសិស្សអាចចែករំលែកមតិយោបល់រវាងគ្នា និងគ្នាបានដោយសេរី និងដោយសកម្ម។

គ្រូបង្រៀនមិនត្រូវជ្រៀតជ្រែក ឬរំខានដល់ការពិភាក្សារបស់សិស្សឡើយ ប៉ុន្តែត្រូវជួយជម្រុញការគិតរបស់សិស្ស តាមរយៈការបំផុតគំនិតផ្ទុយទៅនឹងគំនិតសិស្ស ឬអាចជាការផ្តល់គំនិតខុសទាំងស្រុងជាដើមដើម្បីឱ្យសិស្សមានប្រតិកម្មក្នុងការគិត និងរិះរក។ ប្រសិនបើការពិភាក្សាត្រូវបានកាច់ចង្កូតដោយគ្រូបង្រៀន នោះសិស្សនឹងពុំអាចយល់បានច្បាស់លាស់ ថាតើហេតុអ្វីបានជាពួកគេត្រូវធ្វើដូច្នោះ នៅពេលគេធ្វើពិសោធន៍ ឬធ្វើការសិក្សាស្រាវជ្រាវ ហើយវានឹងនាំទៅដល់ភាពបរាជ័យ ព្រមទាំងមិនអាចសម្រេចវត្ថុបំណងមេរៀនបានឡើយ។

### ខ.ដំណើការរៀបចំកិច្ចតែងការបង្រៀនបែបរិះរក

នៅក្នុងការរៀបចំកិច្ចតែងការបង្រៀនជា **លំនាំនៃការ**«ធ្វើផែនការបញ្ច្រាស» ហើយត្រូវបានគេប្រើជាញឹកញាប់។ ការធ្វើរបៀបនេះ គ្រូបង្រៀនត្រូវធ្វើការពិចារណាអំពីដំណើការនៃការធ្វើមេរៀនឱ្យបានត្រឹមត្រូវតាមលំដាប់លំដោយៗ នឹងត្រូវចាប់ផ្ដើមពីចំណុចៈ វត្ថុបំណងមេរៀន ⇨ សេចក្ដីសន្និដ្ឋាន ⇨ សកម្មភាព/ពិសោធន៍ ⇨ សំណួរគន្លឹះ ការបង្ហាញបាតុភូតចិត្ត។ នៅក្នុងវិធីសាស្ត្រនេះអាចជួយឱ្យគ្រូបង្រៀនបន្តផ្ដោតអារម្មណ៍ទៅលើវត្ថុបំណងរបស់មេរៀន។

- **ការកំណត់វត្ថុបំណងមេរៀនៈ**

ដំបូងគ្រូបង្រៀនត្រូវយល់ដឹងអំពីវត្ថុបំណងរបស់មេរៀន ឬជំពូកនៃមេរៀនឱ្យច្បាស់លាស់ជាមុនសិន។ បន្ទាប់មកត្រូវធ្វើការពិចារណាអំពីចំណេះដឹង និងជំនាញដែលសិស្សគួរទទួលបាន តាមរយៈមេរៀននីមួយៗ។ គ្រូបង្រៀនត្រូវចងចាំថា ការបង្រៀន និងរៀនកាន់តែមានប្រសិទ្ធភាព កាលណាវត្ថុបំណងនៃមេរៀនដែលបានកំណត់ មានទំនាក់ទំនងទៅនឹងមេរៀនមុន និងមេរៀនដែលត្រូវរៀនបន្ទាប់។ ប្រសិនបើវត្ថុបំណងនៃមេរៀននីមួយៗត្រូវបានកំណត់ដាច់ដោយឡែកៗពីគ្នា ឬគ្មានទំនាក់ទំនងគ្នានោះទេ ឱកាសនៃការសិក្សា ការតាមដានបន្តរបស់សិស្សនឹងត្រូវបាត់បង់ជាក់ជាមិនខានឡើយ។

- **ការកំណត់សំណួរគន្លឹះ**

បន្ទាប់មកទៀត គ្រូបង្រៀនត្រូវគិតអំពីថា តើសំណួរគន្លឹះបែបណាដែលគួរបង្កើតឡើង ដើម្បីឱ្យសិស្សអាចចាប់ផ្ដើមធ្វើសកម្មភាពដូចនឹងអ្វីដែលបានរៀបរាប់ខាងលើ។ សំណួរគន្លឹះនេះត្រូវធ្វើយ៉ាងណាឱ្យច្បាស់ និងងាយយល់បំផុត។ ជាមួយគ្នានេះដែរ ពេលខ្លះគ្រូបង្រៀនអាចលើកជាឧទាហរណ៍បង្ហាញសិស្ស ដូចជាចោទជាសំណួរថា តើការបាត់បង់ពូជសត្វ និងរុក្ខជាតិនៅលើផែនដីមានទំនាក់ទំនងយ៉ាងដូចម្ដេចខ្លះជាមួយនឹងសកម្មភាពរបស់មនុស្ស?

- **ការកំណត់ពីបាតុភូតដែលត្រូវបង្ហាញ**

នៅដំណាក់កាលចុងក្រោយ គ្រូបង្រៀនត្រូវគិតអំពីវិធីដ៏មានប្រសិទ្ធភាពបំផុត ដើម្បីជួយសិស្សឱ្យអាចបង្កើតចម្ងល់ ឬសំណួរគន្លឹះបាននៅក្នុងចិត្តរបស់ពួកគេ។ ចូរអ្នកព្យាយាមរកនឹក និងពិនិត្យមើលរាល់

បាតុភូតនៅជុំវិញខ្លួនរបស់អ្នក រកមើលសៀវភៅវិទ្យាសាស្ត្រពិត សៀវភៅវិទ្យាសាស្ត្រសង្គមផ្សេងៗ និង ស្វែងរកបាតុភូតធម្មជាតិ ដូចជា បាតុភូតរូបឬគីមី ភូមិ ផែនដី ឬបរិស្ថាន ហេតុការណ៍ផ្សេងៗ ឬព្រឹត្តិការណ៍ សង្គម និងរូបភាពគួរឱ្យចាប់អារម្មណ៍នានាផ្សេងទៀត ដើម្បីជួយជម្រុញដល់ការគិតរបស់សិស្សឱ្យកាន់តែ ស៊ីជម្រៅថែមទៀត។ នៅក្នុងឧទាហរណ៍នៃទំនាក់ទំនងរវាងការផុតពូជសត្វ និងរុក្ខជាតិទៅនឹងសកម្មភាព របស់មនុស្សខាងលើ។ មេរៀនអាចចាប់ផ្តើមបានតាមរយៈ ឱ្យសិស្សសង្កេតមើលសកម្មភាពជាក់ស្តែង របស់មនុស្សខាងលើ ទៅលើប្រភេទសត្វ និងរុក្ខជាតិទាំងនោះជាដើម (ប្រាក់ ពៅ, ឃិន វណ្ឌី និង បាន កក្កដា, ឆ្នាំ ២០១៩)។

- **ការកំណត់សេចក្តីសន្និដ្ឋាន និងសកម្មភាពនានា**

ដោយផ្អែកលើវត្ថុបំណងនៃមេរៀនដែលបានកំណត់ខាងលើ គ្រូបង្រៀនត្រូវគិតថា តើ សិស្សនឹងធ្វើសកម្មភាពអ្វី និងត្រូវធ្វើយ៉ាងដូចម្តេច នៅក្នុងដំណើរការសិក្សារបស់ពួកគេ។ ជាឧទាហរណ៍៖ ប្រសិនបើនៅក្នុងវត្ថុបំណងមេរៀន សិស្សអាចពន្យល់បានអំពីទំនាក់ទំនងគ្នារវាងការផុតពូជសត្វ និងរុក្ខ ជាតិ ដោយសកម្មភាពរបស់មនុស្ស នោះសិស្សនឹងត្រូវធ្វើការសិក្សាអំពីទំនាក់ទំនងនេះដោយប្រើប្រាស់ភ ស្តុតាងនានាដើម្បីរកឱ្យឃើញនូវការពិតដែលថា ការផុតពូជសត្វ និងរុក្ខជាតិមានទំនាក់ទំនងទៅនឹង សកម្មភាពរបស់មនុស្ស (ប្រាក់ ពៅ, ឃិន វណ្ឌី និង បាន កក្កដា, ឆ្នាំ ២០១៩)។

### ២.២.៨ គុណសម្បត្តិនៃការប្រើប្រាស់វិធីបង្រៀន និងរៀនបែបរិះរក

នៅក្នុងវីដេអូ និងសេចក្តីថ្លែងសុន្ទរកថារបស់លោក Dr. Tony Wagner[11] បានបញ្ជាក់អំពីជំនាញ ផ្សេងៗគ្នាដែលចាំបាច់សម្រាប់ភាពជោគជ័យរបស់សិស្ស នៅក្នុងយុគ្គសម័យនៃសេដ្ឋកិច្ចសកល។ ជំនាញ ទាំងប្រាំពីរនោះមានដូចជា៖ ជំនាញនៃការគិតស៊ីជម្រៅ ជំនាញដោះស្រាយបញ្ហា ការសហការ និងដឹកនាំ ប្រកបដោយឥទ្ធពល ភាពរហ័សរហួន និងការសម្របសម្រួល គំនិតផ្តួចផ្តើម និងសហគ្រិនភាព ទំនាក់ទំនង ផ្ទាល់ និងលាយលក្ខ័ណអក្សរប្រកដដោយប្រសិទ្ធភាព រួមទាំងការទទួលបាន និងវិភាគព័ត៌មាន និងការ ចង់ចេះចង់ដឹង និងការស្រមើស្រមៃ។ ជាមួយគ្នានេះដែរ Marks (2013) បានពន្យល់ទៀតថា «នៅក្នុង

[11] «7 Skills Students Need for Their Future (2009)»

ថ្នាក់រៀនបែបរិះរក សិស្សរៀន អនុវត្ត ឆ្លុះទៅលើជំនាញទាំងប្រាំពីរនេះនៅក្នុងដំណើរការជាក់ស្តែងដែលពាក់ព័ន្ធនឹងដំណើរការជាច្រើនដែលធ្លាប់ប្រើប្រាស់ពីមុនមក»។

វិធីសាស្ត្របង្រៀន និងរៀនបែបរិះរកគឺជាយុទ្ធសាស្ត្របង្រៀនដែលនាំឱ្យការបង្រៀន និងរៀនផ្សារភ្ជាប់ជាមួយនឹងសិស្ស ជាមួយជំនាញចាំបាច់សម្រាប់ជោគជ័យទៅថ្ងៃអនាគត(Marks, 2013)។ ការសិក្សាស្រាវជ្រាវជាច្រើនត្រូវបានគេធ្វើឡើងលើគុណសម្បត្តិនៃការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនបែបរិះរកនៅក្នុងថ្នាក់រៀន។ ចំពោះ Guido (2017) បានបញ្ជាក់ និងបង្ហាញគុណសម្បត្តិចំនួនប្រាំពីរយ៉ាងនៃការប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនបែបរិះរកផងដែរ ក្នុងនោះមានដូចជា៖ ១) ការពង្រឹងខ្លឹមសារកម្មវិធីសិក្សា ២) ត្រៀមខួរក្បាលសម្រាប់ការរៀន ៣) ជម្រុញការយល់ដឹងស៊ីជម្រៅចំពោះខ្លឹមសារ ៤) ជួយបង្កើតរង្វាន់លើកទឹកចិត្តដល់ការសិក្សារៀនសូត្រ ៥) កសាងគំនិតផ្តួចផ្តើម និងទិសដៅផ្ទាល់ខ្លួន ៦) ចូលរួមសហការស្មើរតែទាំងអស់គ្នាក្នុងថ្នាក់រៀននីមួយៗ និង៧) ផ្តល់នូវការបង្រៀនផ្សេងៗគ្នា។

បើយោងទៅតាម Sockalingam, Rotgans, and Schmidt (2011)នៅពេលសិស្សត្រូវបានផ្តល់ឱកាសដើម្បីដោះស្រាយបញ្ហា នោះពួកគេទទួលបាននូវចំណេះដឹងថ្មី និងការយល់ដឹងថ្មីកាន់តែស៊ីជម្រៅ និងមានវិសាលភាពទូលំទូលាយ។ នៅពេលសិស្សរុករក និងអង្កេត នោះពួកគេមានទទួលខុសត្រូវសម្រាប់ការសិក្សារបស់ពួកគេ ពីព្រោះពួកគេរំពឹថានឹងធ្វើការសម្រេចចិត្ត និងទាញសេចក្តីសន្និដ្ឋាន និងការវិនិច្ឆ័យ (Jonassen, 2000)បានដោយខ្លួនឯង។ ប្រហាក់ប្រហែលគ្នានេះដែរ Hwang and Chang (2011) បានអះអាងថា នៅពេលសិស្សរៀនតាមមធ្យោបាយនៃការស្រាវជ្រាវ និងអង្កេតដែលស្ថិតនៅក្នុងស្ថានភាពជាក់ស្តែង នោះពួកគេបង្កើននូវជំនាញនៃការគិតស៊ីជម្រៅ។

ចំពោះ Goldston et al. (2010) បានអះអាងថា វិធីសាស្ត្របង្រៀន និងរៀនបែបរិះរកចាត់ទុកចំណេះដឹងផ្សេងៗដែលទទួលបានពីការសិក្សារៀនសូត្រ ឱ្យផ្តោតសំខាន់ទៅលើសមត្ថភាពគិតស៊ីជម្រៅ សមត្ថភាពដោះស្រាយបញ្ហា និងសមត្ថភាពទំនាក់ទំនង។ រីឯ Gu et al. (2015) បែរជារកឃើញថា សិស្សដែលចូលរួមអនុវត្តការរៀនបែបរិះរកត្រូវបានរាយការណ៍ថា ការសិក្សាមានប្រសិទ្ធភាពខ្ពស់ការដោះស្រាយ

ទំនាស់ស្ថិតនៅក្នុងអត្រាមួយខ្ពស់ កាត់បន្ថយការភ័យខ្លាចក្នុងការប្រថុយប្រថាន ហើយទំនងជាបន្តការសាកល្បងនូវមធ្យោបាយផ្សេងៗទៀត ដើម្បីភាពជោគជ័យនៅពេលពួកគេបរាជ័យ។

ជាមួយគ្នានេះដែរ Marks (2013) បានសន្និដ្ឋានថា សិស្សដែលមានការចូលរួមយ៉ាងសកម្មក្នុងការរិះរក មិនត្រឹមតែយល់ដឹងបាននូវខ្លឹមសារស៊ីជម្រៅប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងរីកចម្រើននូវទម្លាប់នៃការសិក្សារៀនសូត្រទៀតផង។ Harlen (2013) បានបរិយាយថា ការអភិវឌ្ឍការយល់ដឹង តាមរយៈការពិចារណា និងការគិតផ្ទាល់ខ្លួនរបស់សិស្ស មានអត្ថប្រយោជន៍ជាច្រើនសម្រាប់សិស្សដូចជា៖ ១)ភាពរីករាយ និងពេញចិត្តក្នុងការស្វែងរកនូវអ្វីៗដែលពួកគេចង់ដឹង ២) មើលឃើញចំពោះខ្លួនឯងនូវអ្វីដែលត្រូវធ្វើជាជាងចាំតែគេប្រាប់ ៣) ពេញចិត្ត និងជម្រុញការចង់ចេះចង់ដឹងអំពីពិភពជុំវិញខ្លួនក្នុងពេលជាមួយគ្នា និង៤) អភិវឌ្ឍជាបន្តបន្ទាប់នូវគំនិតប្រកបដោយអំណាចអំពីពិភពជុំវិញខ្លួន។

## ២.២.៩ គុណវិបត្តិនៃការប្រើប្រាស់វិធីបង្រៀន និងរៀនបែបរិះរក

តាមការអង្កេតរបស់អ្នកស្រាវជ្រាវ ការព្រួយបារម្ភដ៏ធំបំផុតរបស់គ្រូបង្រៀនអំពីការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនបែបរិះរកគឺពាក់ព័ន្ធជា«ការបំពេញតម្រូវការស្តង់ដា និងខ្លឹមសារនៅពេលបង្រៀនតាមដំណើរការនៃការរិះរក»។ គ្រូបង្រៀនជាច្រើនបានបញ្ចេញទស្សនៈផ្ទាល់ខ្លួន ព្រមទាំងមានការព្រួយបារម្ភថា សិស្សនឹងមិនអាចរៀនបានទេ តាមរយៈខ្លឹមសារទាំងអស់នោះទេ ពីព្រោះពេលវេលាត្រូវចំណាយទៅលើជំនាញ និងដំណើរការនៃការបង្រៀនច្រើន។

ជាមួយគ្នានេះមានមធ្យោបាយតែមួយគត់ដើម្បីដោះស្រាយបញ្ហានេះគឺត្រូវរៀបចំគម្រោង ឬមេរៀនជុំវិញសំណួរប្រដេញ(Driving Question)ឱ្យបានសមស្របតាមពេលវេលា និងកន្លែង។ នៅក្នុងគម្រោងមួយក្នុងចំណោមគម្រោងជាច្រើន គ្រូបង្រៀនត្រូវអភិវឌ្ឍសំណួរប្រដេញ ដោយសំឡឹងមើលទៅលើហេតុ និងផលនៃបញ្ហាតាមពេលវេលា។ គ្រូបង្រៀនត្រូវបញ្ចូលស្តង់ដាដែលបកស្រាយពីការរុករកដែលបានឆ្លងកាត់ជាច្រើនសតវត្សមកហើយ ដូចជា គំរូពាណិជ្ជកម្ម ការកើនឡើងនៃអាណានិគមន៍ និងការអភិវឌ្ឍសេដ្ឋកិច្ចផ្សេងៗគ្នាជាដើម។ សិស្សត្រូវបានគេដាក់ឱ្យដើរតួជាអ្នករិះរកដោយខ្លួនឯង និងត្រូវស្រាវជ្រាវដើម្បីបំពេញតួនាទី និងផលប៉ះពាល់របស់ខ្លួន។ ការណ៍នេះជាមធ្យោបាយមួយ ដើម្បីធានាថា សិស្សបាន

រៀនពីអ្វីច្រើនជាងខ្លឹមសារដែលពួកគេត្រូវស្រាវជ្រាវទៅទៀត។ ជាមួយគ្នានេះដែរ ពួកគេធ្វើការសំភាសន៍គ្នាទៅវិញទៅមក និងធ្វើការងារជាមួយគ្រូបង្រៀនដើម្បីឆ្លើយសំណួរប្រជេញ( Dr. Tony Wagner )[12]។

[12] «7 Skills Students Need for Their Future ( 2009 )»

# ជំពូកទី៣

# វិធីសាស្ត្រស្រាវជ្រាវ

# ជំពូកទី៣៖ វិធីសាស្ត្រស្រាវជ្រាវ

## ៣.១ ព័ត៌មានទូទៅនៃគម្រោងស្រាវជ្រាវ

តាមលោក Christensen (2011) បានបង្ហាញថា ការសិក្សាស្រាវជ្រាវបែបគុណវិស័យសំដៅលើការប្រើប្រាស់ទិន្នន័យជា ពាក្យពេចន៍ ការសន្និដ្ឋាន និងផ្តោតលើការយល់ដឹងស៊ីជម្រៅលើទិន្នន័យនោះ។ ចំណែកឯការសិក្សាស្រាវជ្រាវនេះវិញគឺផ្តោលើបរិមាណវិស័យ ព្រោះទិន្នន័យត្រូវបានយកទៅវិភាគតាមបែបស្ថិតិ ហើយកម្រងសំណួរសម្រាប់ប្រមូលទិន្នន័យ នឹងដាក់ជូន នាយក/នាយិកា នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀន ដើម្បីបំពេញ និងផ្តល់ចម្លើយទាក់ទងជាមួយប្រធានបទ។

រាល់ការប្រមូលពត៌មាននិងចម្លើយដែលទទួលបានពីការផ្តល់បទសម្ភាសនឹងត្រូវប្រើប្រាស់សម្រាប់ធ្វើវិភាគ និងស្វែងយល់ពីទស្សនៈ និងដំណើរការនៃការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនបែបរិះរកដោយគ្រូបង្រៀន និងបញ្ហាប្រឈមនានានៃការប្រើប្រាស់វិធីសាស្ត្របង្រៀននេះ ជាពិសេសនៅតាមសាលាមធ្យមសិក្សាទុតិយភូមិក្នុងខេត្តកណ្តាល បន្ទាប់ពីពួកគាត់បានទទួលការបណ្តុះបណ្តាល លើការប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនបែបរិះរកពីវិទ្យាស្ថានជាតិអប់រំ(NIE)កន្លងមក។

## ៣.២ ទីកន្លែងសិក្សាស្រាវជ្រាវ

ជាពិតណាស់គ្រូបង្រៀនគ្រប់គ្រឹះស្ថានសិក្សាទាំងអស់មិនថា គ្រឹះស្ថានបឋមសិក្សា ឬគ្រឹះស្ថានមធ្យមសិក្សាបឋមភូមិ គ្រឹះស្ថានមធ្យមសិក្សាទុតិយភូមិ និងគ្រឹះស្ថានឧត្តមសិក្សាឡើយ។ គ្រឹះស្ថានសិក្សាទាំងនោះសុទ្ធតែត្រូវប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនថ្មីៗ ដើម្បីជួយពង្រឹងគុណភាពនៃការបង្រៀន និងការរៀនរបស់សិស្សានុសិស្ស ដើម្បីឱ្យការសិក្សារៀនសូត្រទាំងនោះមានភាពសកម្មរស់រវើក មានការសហការ ចូលរួម និងធ្វើកិច្ចការក្រុមក្នុងដំណើរការរៀន និងបង្រៀនប្រកបដោយប្រសិទ្ធភាពខ្ពស់។ ជាងនេះទៅទៀតគឺដើម្បីរួមចំណែក កសាង អភិវឌ្ឍធនធានមនុស្ស វិស័យអប់រំឱ្យមានគុណភាព ផ្នែកចំណេះដឹង ចំណេះធ្វើ និងមានបំណិនក្នុងការបពេញការងារជាដើម។

ដើម្បីសម្រេចគោលបំណងនេះនេះ ក្រសួងអប់រំ យុវជន និងកីឡាតម្រូវឱ្យគ្រូបង្រៀនមានចំណេះដឹងអំពីវិធីសាស្ត្របង្រៀន និងរៀនថ្មីៗបន្ថែមទៀត សម្រាប់ឱ្យការបង្រៀន និងរៀនរបស់សិក្សានុសិស្សកាន់

តែមានប្រសិទ្ធភាពខ្ពស់ថែមទៀត។ ជាមួយគ្នានេះដែរ វិធីសាស្ត្របង្រៀន និងរៀនបែបរិះរក(IBL)ត្រូវបានវិទ្យាស្ថានជាតិអប់រំធ្វើការបណ្តុះបណ្តាលបន្ត ដល់ប្រធានក្រុមបច្ចេកទេសនៃសាលាមធ្យមសិក្សាទុតិយភូមិនានាក្នុងទូទាំងប្រទេស ស្របតាមកំណែទម្រង់របស់ក្រសួងអប់រំ យុវជន និងកីឡាផងដែរ។ ការប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនបែបរិះរក(IBL)ជាដើមចមនៃការសិក្សាស្រាវជ្រាវនេះ ព្រោះតែវិធីសាស្ត្រនេះត្រូវបានអនុវត្តដោយគ្រូបង្រៀន នៅតាមសាលាវិទ្យាល័យនានា ក្រោយពីទទួលការបណ្តុះបណ្តាលពីវិទ្យាស្ថានជាតិអប់រំរួចមក។

ការសិក្សាស្រាវជ្រាវនេះបានជ្រើសរើសក្រុង/ស្រុកចំនួន៥ ក្នុងចំណោមស្រុក/ក្រុងទាំងអស់១១ នៃខេត្តកណ្តាល។ ក្រុង/ស្រុកទាំងអស់នោះមានដូចជា៖ ក្រុងតាខ្មៅ ស្រុកកោះធំ ស្រុកពញាឮ ស្រុកអង្គស្នួល និងស្រុកកណ្តាលស្ទឹង។

ជាមួយគ្នានេះដែរ អ្នកស្រាវជ្រាវបានជ្រើសរើសសាលាក្នុងស្រុកចំនួន០៥មកធ្វើជាភាគសំណាក និងចំរាញ់យកសាលាមធ្យមសិក្សាទុតិយភូមិចំនួន១៤ នឹងជាសាលាដែលនាយក/នាយិកានាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនមួយចំនួនបានចូលរួមក្នុងវគ្គបណ្តុះបណ្តាលស្តីពី វិធីសាស្ត្របង្រៀ និងរៀនបែបរិះរក ក្រោមការរៀបចំរបស់វិទ្យាស្ថានជាតិអប់រំ។ សាលាមធ្យមសិក្សាទុតិយភូមិដែលបានចូលរួមក្នុងវគ្គទាំងនោះរួមមានដូចជា៖

(១) វិទ្យាល័យ ហ៊ុន សែន សេរីភាព និងវិទ្យាល័យ ហ៊ុន សែនតាខ្មៅស្ថិតនៅក្រុងតាខ្មៅ

(២) វិទ្យាល័យ ហ៊ុន សែន កោះធំ, វិទ្យាល័យ ប៊ុន រ៉ានី ហ៊ុន សែនព្រែកតាដួង និងវិទ្យាល័យ ហ៊ុន សែន សំពៅពូន ស្ថិតនៅស្រុកកោះធំ

(៣) វិទ្យាល័យ ហ៊ុន សែន ព្រះធម្មស្រះ វិទ្យាល័យ ហ៊ុន សែន អូកុង និងវិទ្យាល័យ និងវិទ្យាល័យ ហ៊ុន សែន កោះចិនស្ថិតនៅស្រុកពញាឮ

(៤) វិទ្យាល័យ ហ៊ុន សែន អង្គស្នួល វិទ្យាល័យ ហ៊ុន សែន អង្គពពាយ និងវិទ្យាល័យ ហ៊ុន សែន ថ្នល់ទទឹង ស្ថិតនៅស្រុងអង្គស្នួល និង

(៥) វិទ្យាល័យ ហ៊ុន សែន កំពង់កន្ទួត, វិទ្យាល័យ ព្រែកស្លែង និងវិទ្យាល័យ ប៊ុន រ៉ានីហ៊ុន សែន ដើមឫស្ស ស្ថិតនៅស្រុកកណ្តាលស្ទឹង។

## ៣.៣ ក្រុមគោលដៅ

ការសិក្សាស្រាវជ្រាវនេះ ផ្តោទៅលើនាយក/នាយិកា នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស គ្រូបង្រៀន និងសិស្សានុសិស្ស។ ជាមួយគ្នានេះ អ្នកសិក្សាស្រាវជ្រាវជ្រើសយកលោកគ្រូ-អ្នកគ្រូដែលបង្រៀននៅកម្រិតវិទ្យាល័យតែប៉ុណ្ណោះ ដោយមិនគិតពីក្របខ័ណ្ឌ និងផ្តោតជាសំខាន់ទៅលើវិធីសាស្ត្រនៃការបង្រៀនបែបរិះរក ដែលបានអនុវត្តនៅថ្នាក់ទី១០ ទី១១ និងថ្នាក់ទី១២។

ក្រុមគោលដៅដែលត្រូវចុះប្រមូលទិន្នន័យរួមមាន៖ នាយក/នាយិកាចំនួន១៤នាក់ នាយករង/នាយិការងចំនួន២៨នាក់ ប្រធានក្រុមបច្ចេកទេស៧០នាក់ គ្រូបង្រៀនចំនួន១២៦នាក់។

**តារាងទី៣៖ ក្រុមគោលដៅ**

| ល.រ | ក្រុមគោលដៅ | ចំនួនអ្នកចូលរួម | ស្រី | ផ្សេងៗ |
|---|---|---|---|---|
| ១ | នាយក/នាយិកា | ១៤ នាក់ | ០០ | |
| ២ | នាយករង/នាយិការង | ២៨ នាក់ | ០៤ | |
| ៣ | ប្រធានក្រុមបច្ចេកទេស | ៧០ នាក់ | ១៩ | |
| ៤ | គ្រូបង្រៀន | ១២៦ នាក់ | ៦៥ | |
| សរុប | | ២៣៨ នាក់ | ៨៧ | |

**តារាងទី៤៖ តួនាទីរបស់គ្រូបង្រៀន**

| តួនាទី | ចំនួន | ភាគរយ | ប្រុស | ភាគរយ | ស្រី | ភាគរយ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| នាយក/នាយិកា | ១៤ | ៦% | ១៤ | ១០០% | ០០ | ០% | |
| នាយករង/នាយិការង | ២៨ | ១២% | ២៤ | ៧៨% | ០៤ | ២២% | |
| ប្រធានក្រុមបច្ចេកទេស | ៧០ | ២៩% | ៥១ | ៧៣% | ១៩ | ២៧% | |

| | | | | | | | |
|---|---|---|---|---|---|---|---|
| គ្រូបង្រៀន | ១២៦ | ៥៣% | ៦២ | ៤៩% | ៦៤ | ៥១% | |
| សរុប | ២៣៨ | ១០០% | ១៥១ | ៦៣% | ៨៧ | ៣៧% | |

**តារាងទី៥៖ កម្រិតវប្បធម៌របស់គ្រូបង្រៀន**

| កម្រិតវប្បធម៌ | ចំនួន | ភាគរយ | ប្រុស | ភាគរយ | ស្រី | ភាគរយ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| មធ្យមសិក្សាទុតិយភូមិ | ២៦ | ១១% | ០៨ | ៣១% | ១៨ | ៦៩% | |
| បរិញ្ញាបត្រ | ១៥៥ | ៦៥% | ៩៥ | ៦១% | ៦០ | ៣៩% | |
| បរិញ្ញាបត្រជាន់ខ្ពស់ | ៥៦ | ២៣.៥% | ៤៧ | ៨៤% | ០៩ | ១៦% | |
| បណ្ឌិត | ០១ | ០.៥% | ០១ | ១០០% | ០០ | ០% | |
| **សរុប** | **២៣៨** | **១០០%** | **១៥១** | **៦៣%** | **៨៧** | **៣៧%** | |

**តារាងទី៦៖ បទពិសោធន៍របស់គ្រូបង្រៀន**

| បទពិសោធន៍ | ចំនួន | ភាគរយ | ប្រុស | ភាគរយ | ស្រី | ភាគរយ | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| តិចជាង ៥ ឆ្នាំ | ១៨ | ៨% | ០៥ | ២៨% | ១៣ | ៧២% | |
| ពី៥ឆ្នាំ ដល់ ៩ ឆ្នាំ | ៥២ | ២២% | ២៧ | ៥២% | ២៥ | ៤៨% | |
| ពី ១០ ឆ្នាំ ដល់ ២០ ឆ្នាំ | ១០៦ | ៤៤% | ៧០ | ៦៦% | ៣៦ | ៣៤% | |
| ចាប់ពី២០ ឆ្នាំឡើង | ៦២ | ២៦% | ៤៩ | ៧៩% | ១៣ | ២១% | |
| **សរុប** | **២៣៨** | **១០០%** | **១៤៩** | **៦៣%** | **៨៧** | **៣៧%** | |

**តារាងទី៧៖ គ្រូបង្រៀនបំពេញកម្រងសំណួរតាមឯកទេស**

| ល.រ | មុខវិជ្ជា | ចំនួន | ផ្សេងៗ |
|---|---|---|---|

| | | រួម | ភាគរយ | ប្រុស | ភាគរយ | ស្រី | ភាគរយ | |
|---|---|---|---|---|---|---|---|---|
| ១ | ភាសាអង់គ្លេស | ២២ | ៩% | ១៨ | ៨២% | ០៤ | ១៨% | |
| ២ | ភាសាខ្មែរ | ៣៣ | ១៤% | ១៣ | ៣៩% | ២០ | ៦១% | |
| ៣ | គណិតវិទ្យា | ២៨ | ១២% | ១៨ | ៦៤% | ១០ | ៣៦% | |
| ៤ | រូបវិទ្យា | ២៣ | ១០% | ២២ | ៩៦% | ០១ | ៤% | |
| ៥ | គីមីវិទ្យា | ២៣ | ១០% | ១៤ | ៦១% | ០៩ | ៣៩% | |
| ៦ | ជីវវិទ្យា | ២៧ | ១១% | ១៩ | ៧០% | ០៨ | ៣០% | |
| ៧ | ផែនដីនិងបរិស្ថានវិទ្យា | ១៣ | ៥% | ០៤ | ៣១% | ០៩ | ៦៩% | |
| ៨ | ប្រវត្តិវិទ្យា | ១៨ | ៨% | ១១ | ៦១% | ០៧ | ៣៩% | |
| ៩ | ភូមិវិទ្យា | ១៧ | ៧% | ១១ | ៦៥% | ០៦ | ៣៥% | |
| ១០ | សីលធម៌-ពលរដ្ឋ | ២០ | ៨% | ១១ | ៥៥% | ០៩ | ៤៥% | |
| ១១ | បច្ចេកវិទ្យា | ០៧ | ៣% | ០៥ | ៧១% | ០២ | ២៩% | |
| ១២ | សេដ្ឋកិច្ច | ០៧ | ៣% | ០៥ | ៧១% | ០២ | ២៩% | |
| **សរុប** | | **២៣៨** | **១០០%** | **១៥១** | **៦៣%** | **៨៧** | **៣៧%** | |

**តារាងទី៨៖ គ្រូបង្រៀនបានចូលរួមវគ្គបណ្តុះបណ្តាលវិះរក ដែលរៀបចំដោយ NIE**

| ល.រ | មុខវិជ្ជា | ចំនួន | | | | | ផ្សេងៗ |
|---|---|---|---|---|---|---|---|
| | | រួម | ប្រុស | ភាគរយ | ស្រី | ភាគរយ | |
| ១ | ភាសាអង់គ្លេស | ១៤ | ១១ | ៧៦% | ០៣ | ២៤% | |
| ២ | ភាសាខ្មែរ | ១៤ | ១០ | ៧១% | ០៤ | ២៩% | |
| ៣ | ប្រវត្តិវិទ្យា | ១៤ | ០៩ | ៦៤% | ០៥ | ២៦% | |
| ៤ | ភូមិវិទ្យា | ១៤ | ១០ | ៧១% | ០៤ | ២៩% | |
| ៥ | សីលធម៌-ពលរដ្ឋ | ១៤ | ១០ | ៧១% | ០៤ | ២៩% | |
| សរុប | | ៧០ | ៥៨ | ៨៣% | ២២ | ១៧% | |

តារាងទី៩៖ វិទ្យាល័យ នាយក នាយករង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនក្នុងភាគសំណាក

| ល.រ | ឈ្មោះសាលាវិទ្យាល័យ | នាយក/ នាយិកា | នាយក/ នាយិការង | ប្រធានក្រុម បច្ចេកទេស | គ្រូ បង្រៀន | សរុប |
|---|---|---|---|---|---|---|
| ១ | វិទ្យាល័យ ហ៊ុន សែន សេរីភាព | ០១ | ០២ | ០៥ | ០៩ | ១៧ |
| ២ | វិទ្យាល័យ ហ៊ុន សែន តាខ្មៅ | ០១ | ០២ | ០៥ | ០៩ | ១៧ |
| ៣ | វិទ្យាល័យ ហ៊ុន សែន កោះធំ | ០១ | ០២ | ០៥ | ០៩ | ១៧ |
| ៤ | វិទ្យាល័យ ហ៊ុន សែន ព្រែកតាដួង | ០១ | ០២ | ០៥ | ០៩ | ១៧ |
| ៥ | វិទ្យាល័យ ហ៊ុន សែន សំពៅពូន | ០១ | ០២ | ០៥ | ០៩ | ១៧ |
| ៦ | វិទ្យាល័យ ហ៊ុន សែនព្រះធម្មស្រះ | ០១ | ០២ | ០៥ | ០៩ | ១៧ |
| ៧ | វិទ្យាល័យ ហ៊ុន សែន អូកុង | ០១ | ០២ | ០៥ | ០៩ | ១៧ |
| ៨ | វិទ្យាល័យ ហ៊ុន សែន កោះចិន | ០១ | ០២ | ០៥ | ០៩ | ១៧ |
| ៩ | វិទ្យាល័យ ហ៊ុន សែន អង្គស្នួល | ០១ | ០២ | ០៥ | ០៩ | ១៧ |
| ១០ | វិទ្យាល័យ ហ៊ុន សែន អង្គពពាយ | ០១ | ០២ | ០៥ | ០៩ | ១៧ |
| ១១ | វិទ្យាល័យ ហ៊ុន សែន ថ្នល់ទទឹង | ០១ | ០២ | ០៥ | ០៩ | ១៧ |
| ១២ | វិទ្យាល័យ ហ៊ុន សែនកំពង់កន្ទួត | ០១ | ០២ | ០៥ | ០៩ | ១៧ |
| ១៣ | វិទ្យាល័យប៊ុនរ៉ានីហ៊ុនសែនដើមឫស្ស | ០១ | ០២ | ០៥ | ០៩ | ១៧ |
| ១៤ | វិទ្យាល័យ ព្រែកស្លែង | ០១ | ០២ | ០៥ | ០៩ | ១៧ |
| សរុបរួម | | ១៤ | ២៨ | ៧០ | ១២៦ | ២៣៨ |

## ៣.៤ ទំហំ និងភាគសំណាកនៃការស្រាវជ្រាវ

ភាគសំណាកទាំងអស់គឺស្ថិតនៅក្នុងខេត្តកណ្ដាល និងត្រូវបានជ្រើសរើសក្នុងចំណោមក្រុង/ស្រុកចំនួន០៥គឺ៖ ក្រុងតាខ្មៅ ស្រុកអង្គស្នួល ស្រុកកណ្ដាលស្ទឹង ស្រុកកោះធំ និងស្រុកពញាឮ។ ការជ្រើសរើសនាយក/នាយិកា នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស លោកគ្រូ/អ្នកគ្រូ និងសិស្សានុសិស្សមកធ្វើភាគសំណាកត្រូវធ្វើឡើងដោយចៃដន្យ។ ការស្រាវជ្រាវនេះចែកចេញជាពីរដំណាក់កាលសំខាន់ៗគឺ៖

ដំណាក់កាលទី១៖ ជាការពិនិត្យមើល ការសិក្សាលើឯកសារនានាដែលពាក់ព័ន្ធ និងមានស្រាប់។ នៅក្នុងដំណាក់កាលនេះ អ្នកស្រាវជ្រាវបានព្យាយាមសិក្សា ស្វែងរកឯកសារដែលទាក់ទងនឹងប្រធានបទតាមប្រព័ន្ធអ៊ីនធណែត យូធ្យូប វេបសាយ ទិនានុប្បវត្តិ និងកិច្ចការរបស់អ្នកស្រាវជ្រាវមុនៗមកធ្វើជាអំណះអំណាង ជាទឡ្ហីករណ៍ និងធ្វើជាគោលក្នុងការស្រាវជ្រាវ ដើម្បីឱ្យការសិក្សាស្រាវជ្រាវនេះមានតម្លៃអាចទទួលយកបាន និងធ្វើជាឯកសារយោងផងដែរ។

ដំណាក់កាលទី២៖ ជាការចុះប្រមូលព័ត៌ ឬទិន្នន័យពីអ្នកពាក់ព័ន្ធដោយផ្ទាល់។ ដំណាក់កាលទី២ គឺធ្វើឡើងតាមរយៈ(Online) ដោយសារតែស្ថានភាព និងបញ្ហាប្រឈមនៃការរីករាលកូវីដ១៩ កំពុងតែកើនឡើង ជាពិសេសការបំប្លែងខ្លួនថ្មីនៃមេរោគ Delta នៅក្នុងប្រទេសកម្ពុជាទាំងមូល។ ហេតុដូចនេះហើយទើបអ្នកសិក្សាស្រាវជ្រាវមិនអាចចុះទៅជួបភាគសំណាកដោយផ្ទាល់។

ចំពោះកម្រងសំណួរបានរៀបចំឡើង និងធ្វើជាមូលដ្ឋានក្នុងការប្រមូលព័ត៌មានមានពីរករណីគឺ៖ ករណីទី១៖ ឯកសារត្រូវព្រីនចេញជា Source Copy សម្រាប់ភាគសំណាកទាំងឡាយណាដែលអាចជួបដោយផ្ទាល់ និងករណីទី២៖ ឯកសារត្រូវបានរៀបចំតាមទម្រង់ Google Form សម្រាប់ភាគសំណាកដែលអ្នកសិក្សាជ្រាវស្រាវមិនអាចទៅជួបដោយផ្ទាល់បាន និងសម្រាប់សាលារៀនដែលជ្រើសរើសធ្វើជាកន្លែងចត្តាឡីស័ក។

កម្រងសំណួរបានរៀបចំឡើងសម្រាប់នាយក/នាយិកា នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងលោកគ្រូ/អ្នកគ្រូ ក្នុងគោលបំណងប្រមូលព័ត៌មានជាក់ស្ដែងអំពី «ទស្សនៈរបស់នាយកសាលា

ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀន អំពីការប្រើប្រាស់វិធីសាស្ត្របង្រៀន និងបែបរិះរកនៅសាលាមធ្យមសិក្សាទុតិយភូមិ»។ កម្រងសំណួរផ្តោតជាសំខាន់លើបញ្ហាប្រឈម ការប្រើប្រាស់ និងការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនបែបរិះរក បន្ទាប់ពីពួកគាត់ទទួលបានការបណ្តុះបណ្តាលពីវិទ្យាស្ថានជាតិអប់រំក្នុងឆ្នាំសិក្សា២០២០ នៅសាលាគរុកោលសល្យ និងវិក្រិត្តិការខេត្តតាកែវ លើវិធីសាស្ត្របង្រៀន និងរៀនបែបរិះរករួចមក។

## ៣.៥ វិធីសាស្ត្រស្រាវជ្រាវ

ចំពោះប្រធានបទស្តីពី «ទស្សនៈរបស់គណៈគ្រប់គ្រង ប្រធានក្រុមបច្ចេកទស និងគ្រូបង្រៀនស្តីអំពីការប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនបែបរិះរក នៅសាលាមធម្យមសិក្សាទុតិយភូមិ» ករណីសិក្សាៈ ខេត្តកណ្តាលនេះ។ អ្នកសិក្សាស្រាវជ្រាវបានជ្រើសរើសវិធីសាស្ត្រស្រាវជ្រាវតាមបែបបរិមាណវិស័យដោយពឹងផ្អែកលើ «សំណួរស្រាវជ្រាវនៃប្រធានបទ»នេះជាគោល។

នៅក្នុងការសិក្សាស្រាវជ្រាវបែបគុណវិស័យ អ្នកសិក្សាស្រាវជ្រាវប្រើប្រាស់កម្រងសំណួរជា ទម្រង់បើក ដើម្បីឱ្យនាយក/នាយិកា នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស លោកគ្រូអ្នកគ្រូជួយផ្តល់ចម្លើយ និងបំពេញកម្រងសំណួរ។ បន្ទាប់មកធ្វើការឆ្លុះបញ្ចាំងអំពីការអនុវត្តវិធីសាស្ត្របង្រៀនរបស់លោកគ្រូ/អ្នកគ្រូ នៅតាមសាលារៀនគោលដៅ និងទស្សនវិស័យនានាដែលបានលើកឡើង ដើម្បីកែលម្អកំហុសឆ្គងនានាដែលបានកើតឡើងនៅក្នុងការបង្រៀនរបស់ពួកគាត់ និងដើម្បីធ្វើការផ្សព្វផ្សាយអំពីវិធីសាស្ត្របង្រៀន និងរៀនបែបរិះរកនេះឱ្យមានប្រសិទ្ធភាពខ្ពស់ក្នុងការបង្រៀន និងរៀន។

ចំពោះការសិក្សាស្រាវជ្រាវតាមបែបបរិមាណវិស័យវិញ អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់កម្រងសំណួរជាទម្រង់បិទ ដាក់ជូននាយក/នាយិកា នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស លោកគ្រូ/អ្នកគ្រូ និងសិស្សានុសិស្សបំពេញ សម្រាប់យកមកធ្វើវិភាគ ដោយប្រើប្រាស់កម្មវិធី Excel ដើម្បីរកតម្លៃ និងវិភាគតាមកម្មវិធី SPSS ដើម្បីរកភាគរយនៃការយល់ឃើញ។

## ៣.៦ ការជ្រើសរើសភាគសំណាក

ការសិក្សាស្រាវជ្រាវនេះបានកំណត់យកវិទ្យាល័យចំនួន១៤ ដែលស្ថិតនៅក្រុង/ស្រុកចំនួន០៥ នៃខេត្តកណ្ដាល។ សាលារៀនទាំងអស់នោះរួមមាន៖ វិទ្យាល័យ ហ៊ុន សែន សេរីភាព, វិទ្យាល័យ ហ៊ុន សែន តាខ្មៅ, វិទ្យាល័យ ហ៊ុន សែន កោះធំ, វិទ្យាល័យហ៊ុន សែន ព្រែកតាដួង, វិទ្យាល័យ ហ៊ុន សែន សំពៅពូន, វិទ្យាល័យ ហ៊ុន សែន ព្រះធម្មស្រះ, វិទ្យាល័យ ហ៊ុន សែន អូកុង, វិទ្យាល័យ ហ៊ុន សែន កោះចិន, វិទ្យាល័យ ហ៊ុន សែន អង្គស្នួល, វិទ្យាល័យ ហ៊ុន សែន អង្គពពាយ, វិទ្យាល័យ ថ្នល់ទទឹង, វិទ្យាល័យ ហ៊ុន សែន កំពង់កន្ទួត, វិទ្យាល័យ ប៊ុន រ៉ានីហ៊ុន សែន ដើមឫស្ស និងវិទ្យាល័យ ព្រែកស្លែង។

អ្នកសិក្សាស្រាវជ្រាវបានជ្រើសរើសភាគសំណាក់ដែលពាក់ព័ន្ធរួមមាន៖១)នាយក/នាយិកាចំនួន ១៤នាក់ ២)នាយករង/នាយិការងចំនួន២៨នាក់ ៣) ប្រធានក្រុមបច្ចេកទេសចំនួន៧០នាក់ និង៤) លោកគ្រូ/អ្នកគ្រូចំនួន១២៦នាក់ ។ ភាគសំណាកទាំងអស់ស្ថិតនៅក្នុងក្រុងតាខ្មៅ ស្រុកកោះធំ ស្រុកពញាឮ ស្រុកអង្គស្នួល និងស្រុកកណ្ដាលស្ទឹង។

## ៣.៧ ឧបករណ៍ស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះមានឧបករណ៍ជាច្រើនសម្រាប់យកទៅប្រមូលព័ត៌មាន និងទិន្នន័យ។ ទោះបីយ៉ាងណាក៏ដោយ អ្នកសិក្សាស្រាវជ្រាវត្រូវធ្វើការសិក្សាពីគុណសម្បត្តិ និងគុណវិបត្តិនៃឧបករណ៍ប្រមូលព័ត៌មានទាំងនោះ។ កម្រងសំណួរជាឧបករណ៍ដ៏មានប្រសិទ្ធភាពមួយប្រភេទ ក្នុងការប្រមូលទិន្នន័យពីអ្នកឆ្លើយតប និងមានប្រសិទ្ធភាព(Cohen,Manion,& Morrison,2007)សម្រាប់ធ្វើការស្រាវជ្រាវលើការប្រើប្រាស់វិធីសាស្ត្រក្នុងការបង្រៀន និងរៀន។ កម្រងសំណួរទាំងអស់ចែកចេញជាពីរផ្នែកគឺ៖

(១) ព័ត៌មានទូទៅសម្រាប់នាយក/នាយិកា នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀន

(២) ទស្សនៈពីការប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀន ចំណេះដឹងស្ដីពីវិធីសាស្ត្រនៃការបង្រៀន និងរៀនបែបវិះរក សម្រាប់នាយក/នាយិកា នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀន

### ក.ព័ត៌មានទូទៅសម្រាប់នាយក/នាយិកា នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀន

កម្រងសំណួរសម្រាប់នាយក/នាយិកា នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីឱ្យពួកគាត់ជួយបំពេញ និងឆ្លើយតបអំពីព័ត៌មានផ្ទាល់ បទពិសោធន៍ក្នុងវិស័យអប់រំ។ លើសពីនេះទៅទៀត កម្រងសំណួរបានផ្តោតជាសំខាន់ទៅលើគណៈគ្រប់គ្រង ប្រធានក្រុមបច្ចេកទេស គ្រូបង្រៀន ដែលបានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីវិធីសាស្ត្របង្រៀន និងរៀនបែបបរិះរក ដែលរៀបចំដោយវិទ្យាស្ថានជាតិអប់រំនៅក្នុងខេត្តតាកែវក្នុងឆ្នាំ២០២០។ កម្រងសំណួរមានសំណួរជាទម្រង់បិទ និងទម្រង់បើក។

### ខ.ទស្សនៈសម្រាប់គណៈគ្រប់ ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀន

កម្រងសំណួរសម្រាប់នាយក/នាយិកា នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនត្រូវបានរៀបចំឡើងក្នុងគោលបំណងដើម្បីឱ្យពួកគាត់ជួយបំពេញ និងឆ្លើយតបអំពីស្ថានភាពនៃការអនុវត្ត និងការផ្សព្វផ្សាយបន្តនៃវិធីសាស្ត្របង្រៀន និងរៀនបែបបរិះរក ដែលត្រូវបានគេចាត់ទុកថាជាវិធីសាស្ត្របង្រៀនមួយល្អ មានប្រសិទ្ធភាពខ្ពស់ក្នុងការអនុវត្ត សម្រាប់លោកគ្រូ/អ្នកគ្រូនៃបណ្តាលវិទ្យាល័យនានានៅក្នុងខេត្តកណ្តាលទាំងមូល។ លើសពីនេះទៅទៀត កម្រងសំណួរបានផ្តោតជាសំខាន់ទៅលើប្រធានក្រុមបច្ចេកទេស គ្រូបង្រៀន ដែលបានចូលរួមវគ្គបណ្តុះបណ្តាលស្តីពីវិធីសាស្ត្របង្រៀន និងរៀនបែបបរិះរក ដែលរៀបចំដោយវិទ្យាស្ថានជាតិអប់រំនៅក្នុងខេត្តតាកែវក្នុងឆ្នាំ២០២០។ កម្រងសំណួរមានសំណួរជាទម្រង់បិទ និងទម្រង់បើក ដែលនិយាយអំពីបទពិសោធន៍ក្នុងការដឹកនាំ គ្រប់គ្រង និងជាពិសេសគឺផ្តោតសំខាន់ទៅបទពិសោធន៍ក្នុងការបង្រៀន និងការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនបែបបរិះរក បញ្ហាប្រឈម ការលំបាកនានាដែលកើតមានឡើងក្នុងការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនមួយនេះរបស់លោកគ្រូ/អ្នកគ្រូ។ កម្រងសំណួរនេះមាន២៦សំណួរសំខាន់ៗ។

កម្រងសំណួរទាំងអស់នេះបានរៀបចំឡើងក្នុងគោលបំណង ដើម្បីធ្វើការឆ្លុះបញ្ចាំងពីការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនតាមបែបបរិះរករបស់គ្រូបង្រៀន ដើម្បីធ្វើការវាស់ស្ទង់ពីការប្រើប្រាស់វិធីសាស្ត្រ

បង្រៀន និងរៀនបែបរិះរក ការចូលរួមសកម្មភាពរៀន និងបង្រៀន ការចែករំលែកគំនិតផ្ទាល់ខ្លួន ការតម្រង់ទិសសិស្សឱ្យចូលរួមគិត និងវិភាគ ជួយសិស្សឱ្យគិតស៊ីជម្រៅ កសាង និងពង្រឹងគំនិតរបស់សិស្ស ជួយសិស្សឱ្យរៀបចំផែនការ/ស្រាវជ្រាវ សម្របសម្រួល និងធ្វើការសន្និដ្ឋានរបស់សិស្សជាដើម។ ជាមួយគ្នានេះដែរក៏ឆ្លុះបញ្ចាំងអំពីចំណាប់ចំណូលចិត្តនិងបំណងប្រាថ្នារបស់សិស្សអំពីវិធីសាស្ត្របង្រៀន និងរៀនបែបរិះរក។

កម្រងសំណួរដែលបានរៀបចំឡើងនេះទទួលបានការណែនាំ ពិភាក្សា និងផ្តល់យោបល់ជាប្រចាំពីសាស្ត្រាចារ្យណែនាំ។ ក្រោយពីបានពិគ្រោះយោបល់ជាច្រើនលើកច្រើនសារ និងការណែនាំកែតម្រូវរបស់សាស្ត្រណែនាំរួចមក កម្រងសំណួរនេះត្រូវបានពិនិត្យ និងកែលម្អជាចុងក្រោយនូវអក្ខរាវិរុទ្ធ។ ខ្លឹមសារនៃឧបករណ៍នេះ រៀបចំឡើងដោយយោងទៅលើឯកសារនានាដែលធ្លាប់បានសិក្សាស្រាវជ្រាវកន្លងមក និងឯកសារដែលសាស្ត្រាចារ្យណែនាំផ្តល់ឱ្យ ក៏ដូចជាឯកសារដែលសាស្ត្រាចារ្យណែនាំបានចង្អុលបង្ហាញផងដែរ។ ឯកសារទាំងអស់នោះពាក់ព័ន្ធនឹង «ការប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនបែបរិះរកនៅសាលាមធ្យមសិក្សាទុតិយភូមិ»។

ដើម្បីលើកកម្ពស់ការរៀន និងការបង្រៀន ក៏ដូចជាលើកកម្ពស់គុណភាពអប់រំ និងគុណវុឌ្ឍន៍របស់គ្រូបង្រៀន។ អ្នកសិក្សាស្រាវជ្រាវបានលើកយកប្រធានបទស្រាវជ្រាវពាក់ព័ន្ធនឹងទស្សនៈគណៈគ្រប់គ្រង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀន ស្តីពីការប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនបែបរិះរក នៅសាលាមធ្យមសិក្សាទុតិយភូមិ ដោយផ្តោតជាសំខាន់លើការប្រើប្រាស់ «វិធីសាស្ត្របង្រៀន និងរៀនបែបរិះរក»។

ការសិក្សាស្រាវជ្រាវនេះ តម្រូវឱ្យនាយក/នាយិកា នាយករង/នាយិការង ប្រធានក្រុមបច្ចេកទស និងគ្រូបង្រៀនបំពេញកម្រងសំណួរជាទម្រង់បិទ និងទម្រង់បើក ពាក់ព័ន្ធជាមួយនឹងព័ត៌មានផ្ទាល់ខ្លួន បទពិសោធន៍ក្នុងវិជ្ជាជីវៈ ចំណេះដឹងអំពីវិធីសាស្ត្របង្រៀន និងរៀនបែបរិះរក ស្ថានភាពនៃការអនុវត្ត និងបញ្ហាប្រឈមនានាដែលកើតឡើងក្នុងការបង្រៀន និងរៀន នៅតាមសាលារៀនទាំងនោះ។ ម្យ៉ាងវិញទៀត កម្រងសំណួរទាំងអស់ក៏បានរំលេចអំពីទស្សនវិស័យរបស់នាយក/នាយិកា នាយករង/នាយិការង ប្រធាន

ក្រុមបច្ចេកទេស និងគ្រូបង្រៀន អំពីស្ថានភាពនៃការអនុវត្តវិធីសាស្ត្រនេះ និងលើកឡើងជាអនុសាសន៍កែលម្អទៅលើចំណុចខ្វះខាតទាំងឡាយចំពោះការអនុវត្តរបស់សហការីកន្លងមក។

អ្នកសិក្សាស្រាវជ្រាវតម្រូវឱ្យលោកគ្រូ/អ្នកគ្រូជួយបំពេញព័ត៌មានផ្ទាល់ខ្លួន និងសំណួរស៊ីជម្រៅពាក់ព័ន្ធជាមួយនឹងចំណេះដឹង សមត្ថភាពនៃការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនតាមបែបរិះរក។ សំណួរទាំងមាន២៦សំណួរជាទម្រង់បិទ និង២សំណួរទៀតជាទម្រង់បើក។ កម្រងសំណួរក្នុងផ្នែកនេះរៀបចំឡើងក្នុងគោលបំណង ដើម្បីឱ្យគ្រូបង្រៀនបង្ហាញពីសមត្ថភាព លើការយល់ដឹង និងសមត្ថភាពនៃការប្រើប្រាស់វិធីសាស្ត្របង្រៀន និងបញ្ហាប្រឈមនានាដែលកើតឡើងក្នុងការអនុវត្តវិធីសាស្ត្រនេះ។

## ៣.៨ ការប្រមូលព័ត៌មាន

ក្រោយពីពិនិត្យសម្រេចលើការរៀបចំ និងការប្រើប្រាស់កម្រងសំណួររួចមក អ្នកសិក្សាស្រាវជ្រាវក៏បានទទួលលិខិតឧទ្ទេសនាមពីវិទ្យាស្ថានជាតិអប់រំ សម្រាប់យកទៅប្រើប្រាស់ក្នុងការប្រមូលទិន្នន័យតាមគោលដៅដែលបានកំណត់ ជាពិសេស វិទ្យាល័យទាំង១៤ដែលស្ថិតនៅក្រុង/ស្រុកចំនួន៥នៃខេត្តកណ្តាល ដូចជា៖ ក្រុងតាខ្មៅ ស្រុកកោះធំ ស្រុកពញាឮ ស្រុកអង្គស្នួល និងស្រុកកណ្តាលស្ទឹង។

បន្ទាប់ពីទទួលបានលិខិតឧទ្ទេសនាមផ្លូវការពីវិទ្យាស្ថានជាតិអប់រំរួចមក អ្នកសិក្សាស្រាវជ្រាវបានធ្វើដំណើរទៅជួបថ្នាក់ដឹកនាំ មន្ទីរអប់រំ យុវជន និងកីឡាខេត្ត ដើម្បីសុំកិច្ចសហការ និងដើម្បីប្រមូលព័ត៌មាននានាអំពីស្ថិតិគ្រូបង្រៀននៅតាមវិទ្យាល័យនៅក្នុងក្រុង/ស្រុក។ បន្ទាប់ពីទទួលបានការអនុញ្ញាត និងផ្តល់កិច្ចសហការពីថ្នាក់ដឹកនាំ មន្ទីរអប់រំ យុវជន និង កីឡារួចមក អ្នកសិក្សាស្រាវជ្រាវក៏បន្តចុះទៅតាមវិទ្យាល័យគោលដៅដោយផ្ទាល់ និងធ្វើទំនាក់ទំនងតាមរយៈអនឡាយជាមួយថ្នាក់ដឹកនាំសាលារៀន និងទីតាំងសាលាដែលជាប់ជាកន្លែងធ្វើចត្តាឡីស័ក ដោយសារបញ្ហានៃការរីករាលដាលជំងឺកូវីដ១៩ និងការបំផ្លែងខ្លួនថ្មីដែលមានឈ្មោះថា(Delta)ផងដែរ។ បន្ទាប់មកទៀត អ្នកសិក្សាស្រាវជ្រាវបន្តសុំកិច្ចសហការពីគណៈគ្រប់គ្រងសាលា លោកគ្រូ/អ្នកគ្រូ និងសិស្សានុសិស្ស ដោយបង្ហាញ និងប្រាប់ពីគោលបំណងនៃការចុះទៅប្រមូលព័ត៌មានពីសាលារៀនទាំងនោះ។

បន្ទាប់មកទៀត អ្នកសិក្សាស្រាវជ្រាវចែកកម្រងសំណួរជូន លោកនាយក/លោកស្រីនាយិកា លោកនាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀន ព្រមទាំងសិស្សានុសិស្ស ដើម្បីឱ្យពួកគាត់ជួយបំពេញកម្រងសំណួរទាំងនោះស្របតាមទិដ្ឋភាពនៃការបង្រៀន និងរៀនជាក់ស្តែង នៅតាមសាលារៀនទាំងនោះ។ ការបំពេញកម្រងសំណួរត្រូវបានឡើងដោយផ្ទាល់ (ចំពោះលោកគ្រូ/អ្នកគ្រូដែលមានការប្រាស័យទាក់ទងជិតស្និទ្ធ) និងតាមរយៈអនឡាយភាគច្រើន។ ការបំពេញកម្រងសំណួរដោយផ្ទាល់គឺ ត្រូវធ្វើឡើងចំពោះវិទ្យាល័យគោលដៅតែមួយប៉ុណ្ណោះគឺវិទ្យាល័យ ហ៊ុន សែន អង្គស្នួល ជាសាលាដែលអ្នកសិក្សាស្រាវជ្រាវបង្រៀនផ្ទាល់ តែក៏មានលោកគ្រូ/អ្នកគ្រូមួយចំនួនទៀតនៃវិទ្យាល័យនេះ ត្រូវធ្វើសម្ភាសតាមអនឡាញដែរ ដោយសារតែការរីករាលដាលខ្លាំងនៃកូវីដ១៩នៅក្នុងសហគមន៍ ជាពិសេសDelta។

ការបំពេញកម្រងសំណួរដោយផ្ទាល់ត្រូវចំណាយពេលពី១៥ទៅ ២០នាទីសម្រាប់លោកគ្រូ/អ្នកគ្រូម្នាក់ៗ ក៏ប៉ុន្តែពេលវេលានៃការបំពេញគឺត្រូវធ្វើឡើងផ្សេងៗគ្នា ពីគ្រូបង្រៀនម្នាក់ទៅម្នាក់ទៀត អាស្រ័យលើការណាត់ជួប និងពេលវេលាដែលលោកគ្រូ/អ្នកគ្រូនីមួយៗទំនេរផងដែរ។ ជាមួយគ្នានេះដែរ លោកគ្រូ/អ្នកគ្រូខ្លះក៏បានជួបគ្នានៅសាលា ខ្លះទៀតជួបនៅតាមផ្ទះ ដោយអាស្រ័យទៅលើការអនុញ្ញាតជាក់ស្តែងរបស់ពួកគាត់។ ចំណែកឯសាលាផ្សេងៗទៀត អ្នកសិក្សាស្រាវជ្រាវសុំការអនុញ្ញាតពីគណៈគ្រប់គ្រងសាលារៀន លោកគ្រូ/អ្នកគ្រូ និងសិស្សានុសិស្ស និងត្រូវឱ្យពួកគាត់បំពេញកម្រងសំណួរតាមអនឡាយដោយសារវិបត្តិកូវីដ១៩ បញ្ហាពេលវេលា និងសាលារៀនទាំងអស់នោះនៅឆ្ងាយ។ ការបំពេញកម្រងសំណួរតាមអនឡាយបានរៀបចំជាកម្រងសំណួរទម្រង់ Google Form ដោយឡែកៗពីគ្នា សម្រាប់នាយក/នាយិកា នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស គ្រូបង្រៀន និងសិស្សានុសិស្ស។

ជាមួយគ្នានេះដែរ អ្នកសិក្សាស្រាវជ្រាវបានដាក់កម្រងសំណួរជាទម្រង់ Google Form ជូនទៅដល់នាយកសាលា និងស្នើសុំឱ្យពួកគាត់ជួយបញ្ជូនបន្ត(Forward) ទៅឱ្យក្រុមគ្រូបង្រៀន តាមរយៈក្រុមតេឡេក្រាម(telegram group)។ នាយកមួយចំនួនបានស្នើសុំឱ្យអ្នកសិក្សាស្រាវជ្រាវធ្វើទំនាក់ទំនងដោយផ្ទាល់ទៅកាន់លោកគ្រូ/អ្នកគ្រូរបស់ពួកគាត់រៀងៗខ្លួនតាមរយៈលេខតេឡេក្រាមដែលនាយកសាលាផ្តល់ជូន។

## ៣.៩ ការវិភាគទិន្នន័យ

ទិន្នន័យដែលបានប្រមូលតាមរយៈកម្រងសំណួរដែលធ្វើឡើងនៅក្នុងកម្មវិធី Google Form នឹងត្រូវបញ្ចូលទៅកម្មវិធី Excel បន្ទាប់មកគណនារកភាគរយ និងបញ្ចូលទៅក្នុងកម្មវិធី SPSS ដោយប្រើ Multi response ដើម្បីដឹងអំពីចំនួនអថេរដែលត្រូវបានជ្រើសរើស ប្រៀបធៀបអថេរ រកភាគរយនៃការយល់ឃើញ និងដើម្បីឱ្យការកត់ត្រាទិន្នន័យមានភាពរហ័ស និងមានភាពងាយស្រួលក្នុងការទាញយកព័ត៌មាន រកភាគរយ ដើម្បីបកស្រាយដោយប្រើប្រាស់តាមវិធីសាស្ត្របែបបរិមាណវិស័យ។ រាល់ទិន្នន័យដែលប្រមូលបានទាំងអស់នឹងត្រូវយកមកធ្វើការវិភាគ ធ្វើជាតារាង ជាធាត ឬបកស្រាយពន្យល់ ដោយមានការប្រៀបធៀបពីទស្សនៈនាយក/នាយិកា នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀន។ ការវិភាគផ្អែកទៅលើឯកសារទ្រឹស្តី និងភស្តុតាងដែលមានស្រាប់ អំពីការប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនបែបរិះរកនៅសាលាមធ្យមសិក្សាទុតិយភូមិ។

## ៣.១០ ក្រមសីលធម៌ស្រាវជ្រាវ

ដើម្បីរក្សាក្រមសីលធម៌នៃការស្រាវជ្រាវ ជាបឋម អ្នកសិក្សាស្រាវជ្រាវធ្វើការណែនាំខ្លួន និងប្រាប់ពីគោលបំណងនៃការស្រាវជ្រាវ និងការប្រមូលទិន្នន័យ។ អ្នកស្រាវជ្រាវរក្សាការសម្ងាត់ជូនដល់អ្នកផ្តល់បទសម្ភាស ឬបំពេញទិន្នន័យជាកម្រងសំណួរបិទ និងសំណួរបើក ហើយព័ត៌មានដែលទទួលបានមិនយកទៅប្រើប្រាស់ក្នុងគោលបំណងផ្សេងទៀតឡើយ។ រាល់ព័ត៌មានដែលទទួលបានសុទ្ធតែមានការសុំអនុញ្ញាត និងមានការឯកភាពពីអ្នកចូលរួមផ្តល់សម្ភាស។

ក្នុងដំណើរការនៃការប្រមូលព័ត៌ចែកចេញជាពីរផ្នែកគឺ ការណាត់ជួបដោយផ្ទាល់ និងការណាត់ជួបតាមអនឡាញ។ ការណាត់ជួបដោយផ្ទាល់គឺដើម្បីផ្តល់ជូនកម្រងសំណួរដល់អ្នកផ្តល់សម្ភាសដោយផ្ទាល់។ ចំពោះការណាត់ជួបតាមអនឡាញគឺធ្វើឡើងតាមរយៈទូរស័ព្ទ និងផ្តល់ដំណឹងដល់អ្នកដែលត្រូវសម្ភាសអ្នកពាក់ព័ន្ធជាមុនៗពេលស្នើសុំឱ្យជួយបំពេញកម្រងសំណួរទាំងពីរប្រភេទ។ ការទំនាក់ទំនងនេះ អ្នកស្រាវជ្រាវគោរពទៅតាមបទដ្ឋាននៃការស្រាវជ្រាវ ដោយប្រើប្រាស់ពាក្យសំដីសមរម្យ គោរពតួនាទី ភារកិច្ច

ឋានានុក្រម និងសិទ្ធសេរីភាពរបស់អ្នកផ្តល់បទសម្ភាស ដោយឥរិយាបថទន់ភ្លន់ ប្រកបដោយសីលធម៌ បង្ហាញទឹកមុខញញឹមរាក់ទាក់ និងកាយវិកាទន់ភ្លន់។

# ជំពូកទី៤

# លទ្ធផល និងការពិភាក្សា

# ជំពូកទី៤៖ លទ្ធផល និងការពិភាក្សា

នៅក្នុងជំពូកនេះ អ្នកសិក្សាស្រាវជ្រាវនឹងបង្ហាញពីលទ្ធផលនៃការវិភាគទិន្នន័យ លើប្រធានបទស្តីពី៖ «ទស្សនៈគណៈគ្រប់គ្រង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនស្តីពីការប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនបែបរិះរកនៅសាលាមធ្យមសិក្សាទុតិយភូមិ» ដោយយកខេត្តកណ្តាលធ្វើជាការសិក្សាលើប្រធានបទនេះ។ ជាមួយគ្នានេះដែរ លទ្ធផលនៃការវិភាគទិន្នន័យត្រូវបានស្រាយតាមរយៈ ការបំពេញកម្រងសំណួរលើក្រុមគោលដៅដែលពាក់ព័ន្ធ ដោយក្នុងនោះមានយក/នាយិកា នាយករង/នាយិការង ប្រធានក្រុមបច្ចេកទស និងគ្រូបង្រៀននៃសាលាគោលដៅចំនួន១៤ក្នុងខេត្តកណ្តាល។ ចំពោះលទ្ធផលដែលទទួលបាននឹងត្រូវលើកយកមកពិភាក្សាលើចំណុចសំខាន់ៗនៃការប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនបែបរិះរកនៅក្នុងការបង្រៀន និងរៀន នៅក្នុងចំណោមសាលារៀនជាគោលដៅទាំង១៤ ដូចបានជម្រាបជូនខាងលើ។

## ៤.១ ព័ត៌មានទូទៅអំពីគ្រូ

កិច្ចការស្រាវជ្រាវស្តីពីការប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនបែបរិះរកនៅសាលាមធ្យមសិក្សាទុតិយភូមិនេះបានជ្រើសរើសសាលាសរុបចំនួន១៤ធ្វើជាភាគសំណាក។សាលារៀនទាំងនោះមានដូចជា៖ (១)វិទ្យាល័យ ហ៊ុន សែន សេរីភាព (២)វិទ្យាល័យ ហ៊ុន សែន តាខ្មៅ (៣)វិទ្យាល័យ ហ៊ុន សែន កោះធំ (៤)វិទ្យាល័យ ហ៊ុន សែន ព្រែកតាដួង (៥)វិទ្យាល័យ ហ៊ុន សែន សំពៅពូន (៦)វិទ្យាល័យ ហ៊ុន សែន ព្រះធម្មស្រះ (៧)វិទ្យាល័យ ហ៊ុន សែន អ្នកុង (៨)វិទ្យាល័យ ហ៊ុន សែន កោះចិន (៩)វិទ្យាល័យ ហ៊ុន សែន អង្គស្នួល (១០)វិទ្យាល័យ ហ៊ុន សែន អង្គពពាយ (១១)វិទ្យាល័យ ហ៊ុន សែន ថ្នល់ទទឹង (១២) វិទ្យាល័យ ហ៊ុន សែនកំពង់កន្ទួត (១៣)វិទ្យាល័យ ប៊ុន រ៉ានីហ៊ុន សែន ដើមឫស្ស និង(១៤)វិទ្យាល័យ ហ៊ុន សែន ព្រែកស្លែង។ សាលារៀនទាំង១៤នេះស្ថិតនៅក្នុងក្រុង/ស្រុកចំនួន៥នៃខេត្តកណ្តាលគឺ៖ (១) ក្រុងតាខ្មៅ (២)ស្រុកអង្គស្នួល (៣)ស្រុកកណ្តាលស្ទឹង (៤)ស្រុកកោះធំ និង(៥)ស្រុកពញាឮ។

ជាមួយនេះដែរ ដើម្បីឱ្យការសិក្សាស្រាវជ្រាវនេះកាន់តែមានភាពជឿជាក់ ហេតុនេះហើយទើបក្រុង/ស្រុកទាំងអស់ត្រូវបានបែងចែកជាបីកម្រិតផ្សេងទៀតគឺ៖ (១)តំបន់ប្រជុំជន (២)តំបន់ជនបទ និង

(៣)តំបន់ដាច់ស្រយាល។ ការជ្រើសរើស និងកំណត់ជាតំបន់ទាំង៣ខាងលើ មានគោលបំណងឆ្លុះបញ្ចាំងភាគសំណាកឱ្យកាន់តែមានសុក្រិតភាពបន្ថែមទៀត។ ចំពោះភាគសំណាកដែលបានជ្រើសរើស និងយកមកវិភាគមានគ្រូបង្រៀនចំនួន២៣៨នាក់។ ក្នុងចំណោមគ្រូបង្រៀនចំនួន២៣៨នាក់ មាននាយក/នាយិកា ចំនួន១៤នាក់ នាយករង/នាយិការង២៨នាក់(ស្រី៤នាក់) ប្រធានក្រុមបច្ចេកទេសចំនួន៧០នាក់(១៩នាក់) និងគ្រូបង្រៀនចំនួន១២៦នាក់(ស្រី៦៥នាក់)។

ក្នុងចំណោមគ្រូបង្រៀនចំនួន២៣៨នាក់ មានគ្រូបង្រៀនចំនួន៣៤នាក់បង្រៀននៅតំបន់ទីប្រជុំជន ហើយគ្រូបង្រៀនចំនួន១០២នាក់ បង្រៀននៅតំបន់ទីជនបទ និងគ្រូបង្រៀនចំនួន១០២ផ្សេងទៀតបង្រៀននៅតំបន់ដាច់ស្រយាល។ ក្នុងចំណោមគ្រូបង្រៀនទាំងអស់មានគ្រូបង្រៀនត្រឹមតែ២៦(ស្រី១៨នាក់)ដែលមានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ដោយក្នុងនោះគ្រូបង្រៀន១៥៥នាក់(ស្រី៦០នាក់)មានបរិញ្ញាបត្រ ហើយគ្រូបង្រៀនត្រឹម៥៦នាក់(ស្រី០៩នាក់)មានសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ និងគ្រូបង្រៀន០១នាក់ មានសញ្ញាបត្របណ្ឌិត(ស្រី០នាក់)។

***ដ្យាក្រាមទី១៖*** *ភាគរយគ្រូបង្រៀនដែលបានចូលរួមជាភាគសំណាកក្នុងតំបន់ទាំង៣*




តាមរយៈការស្ទាបស្ទង់មតិយោបល់ក្នុងចំណោមគ្រូបង្រៀនទាំងអស់ គ្រូបង្រៀនបង្រៀនដែលធ្លាប់បានចូលរួមវគ្គបណ្ដុះបណ្ដាលស្ដីពីការប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនបែបរិះរកនៅកម្រិតមធ្យម

សិក្សាទុតិយភូមិនេះ មានចំនួន១៦៨នាក់ ស្មើនឹង ៧០.៦ ភាគរយ និងគ្រូបង្រៀនដែលមិនធ្លាប់ចូលរួមវគ្គបណ្តុះបណ្តាលរួមមាន ៧០នាក់ ស្មើ២៩.៤ភាគរយ។

**ដ្យាក្រាមទី២៖ គ្រូបង្រៀនធ្លាប់ចូលរួម និងមិនធ្លាប់ចូលរួមវគ្គបណ្តុះបណ្តាល**




នៅក្នុងចំណោមវិធីសាស្ត្របង្រៀននានា ដែលលោកគ្រូអ្នកគ្រូជ្រើសរើសយកមកបង្រៀនសិក្សានុសិស្សគឺមិនដូចគ្នាទេ។ ក្នុងចំណោមវិធីសាស្ត្របង្រៀនទាំងនោះ គ្រូបង្រៀនចំនួន២១.២% បានជ្រើសរើសវិធីសាស្ត្របង្រៀន និងរៀនបែបរិះរក(IBL)។ ១៧.១% ជ្រើសរើសវិធីសាស្ត្របង្រៀនបែបសហការ។ គ្រូបង្រៀន១៤.៥% ជ្រើសរើសវិធីសាស្ត្របង្រៀនបែបដោះស្រាយបញ្ហា។ ១៥.១%ជ្រើសរើសវិធីសាស្ត្របង្រៀនបែបពិភាក្សា។ ៨.៧%ជ្រើសរើសវិធីសាស្ត្របង្រៀនបែបផែនទីគំនិត។ ១១.៥% ជ្រើសរើសវិធីសាស្ត្របង្រៀនបែបប្លូម (bloom taxonomy)។ ៦.០%ជ្រើសរើសវិធីសាស្ត្របង្រៀនចង្អុលបង្ហាញ និងគ្រូបង្រៀនចំនួន៥.៩% ជ្រើសរើសវិធីបង្រៀនបែបឧទ្ទេស ឬគ្រូមជ្ឈមណ្ឌល។

តាមរយៈទិន្នន័យខាងលើ គេសង្កេតឃើញថា បើទោះបីជាមានការផ្សព្វផ្សាយទូលំទូលាយស្តីពីវិធីសាស្ត្របង្រៀន និងរៀនបែបរិះរកក៏ដោយ ក៏គ្រូបង្រៀនមួយចំនួននៅតែប្រើប្រាស់វិធីសាស្ត្របង្រៀនបែបប្រពៃណី និងតាមទម្លាប់ចាស់ ហើយក្នុងចំណោមគ្រូបង្រៀនទាំងនោះ ក៏នៅតែប្រើប្រាស់វិធីសាស្ត្របង្រៀនបែបគ្រូមជ្ឈមណ្ឌល និងវិធីឧទ្ទេសជាដើម។ តែទោះបីជាយ៉ាងនេះក៏ដោយ ក៏មានគ្រូបង្រៀនជា

ច្រើនផ្សេងទៀតបានជ្រើសរើសការបង្រៀន និងរៀនបែបរិះរកផងដែរ ជាពិសេសក្រោយពីពួកគាត់បានទទួលការបណ្តុះបណ្តាលពីវិទ្យាស្ថានជាតិអប់រំ។ ម្យ៉ាងវិញទៀតពួកគាត់គិតថាពួកគាត់គួរតែយល់ដឹង និងចេះប្រើប្រាស់វិធីសាស្ត្របង្រៀនផ្សេងៗទៀតក្រៅពីវិធីសាស្ត្របង្រៀន និងរៀនបែបរិះរក(IBL)នេះផងដែរ។

ហេតុនេះហើយ គណៈគ្រប់គ្រង ប្រធានក្រុមបច្ចេកទេស គ្រូបង្រៀន និងអ្នកពាក់ព័ន្ធក្នុងវិស័យអប់រំ គួរតែជម្រុញ និងពង្រីកការប្រើវិធីសាស្ត្របង្រៀន និងរៀនបែបរិះរក(IBL)ឱ្យបានទូលំទូលាយបន្ថែមទៀត ដើម្បីពង្រឹងគុណភាពអប់រំឱ្យស្របតាមកំណែទម្រង់របស់ក្រសួងអប់រំ យុវជន និងកីឡា ក៏ដូចជារួមចំណែកកសាងចំណេះដឹង និងពង្រឹងសមត្ថភាពសិក្សារបស់សិស្សានុសិស្សផងដែរ។

**ដ្យាក្រាមទី៣៖ការជ្រើសរើសវិធីសាស្ត្របង្រៀនផ្សេងៗ**




នៅក្នុងចំណោលភាគសំណាកចំនួន២៣៨នាក់ សុទ្ធតែមានបទពិសោធន៍ខុសៗគ្នា និងបង្រៀនមុខវិជ្ជាខុសៗ។ ជាមួយគ្នានេះដែរ គ្រូបង្រៀនដែលមានបទពិសោធន៍បង្រៀនមុខវិជ្ជារបស់ខ្លួន ចន្លោះពី២០ឆ្នាំឡើងទៅមានចំនួន២៦.៥%។ គ្រូបង្រៀនដែលមានបទពិសោធន៍ពី១០ដល់២០ឆ្នាំមាន៤៤.៥%។

គ្រូបង្រៀនដែលមានបទពិសោធន៍ពី ៥ទៅ៩ឆ្នាំមាន ២១.៨% និងគ្រូបង្រៀនដែលមានបទពិសោធន៍តិចជាង៥ឆ្នាំមាន៧.១%។

ដូចនេះក្នុងចំណោមគ្រូបង្រៀនដែលមានបទពិសោធន៍ និងមានភាគរយ៤៤.៥%ខ្ពស់ជាងគេគឺជាទឡ្ហីករណ៍សំខាន់ក្នុងការពង្រឹកការប្រើប្រាស់វិធីសាស្រ្តបង្រៀន និងរៀនបែបរិះរក និងអាចជាចលករសំខាន់ក្នុងការជម្រុញ និងពង្រឹកសមត្ថភាពលើការប្រើប្រាស់វិធីសាស្រ្តបង្រៀននេះឱ្យកាន់តែមានប្រសិទ្ធភាពបន្ថែមទៀត នៅក្នុងចំណោមសាលាទាំង១៤ ដែលមាននៅក្នុងភាគសំណាក។

**ដ្យាក្រាមទី៤៖ បទពិសោធន៍គ្រូបង្រៀន**




## ៤.២ ទស្សនៈយល់ឃើញអំពីវិធីសាស្រ្តបង្រៀន និងរៀនបែបរិះរក (IBL)

នៅក្នុងផ្នែកនេះ អ្នកសិក្សាស្រាវជ្រាវបានបង្ហាញអំពីទស្សនៈទាក់ទងនឹងវិធីសាស្រ្តបង្រៀន និងរៀនបែបរិះរក(IBL)របស់នាយក/នាយករង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀន។ ជាមួយគ្នានេះដែរ អ្នកសិក្សាស្រាវជ្រាវនឹងធ្វើការសិក្សាលម្អិតទៅលើកម្រងសំណួរដែលនឹងត្រូវសាកសួរ គ្រូបង្រៀនទាំងអស់ដែលមាននៅក្នុងភាគសំណាក។ ចំពោះចម្លើយដែលទទួលបានពីកម្រងសំណួរនឹងបង្ហាញពីទស្សនៈយល់ឃើញអំពីកាប្រើប្រាស់វិធីសាស្រ្តបង្រៀន និងរៀនបែបរិះរក និងគ្របដណ្តប់ទៅលើចំណុចសំខាន់ៗមួយចំនួនដូចជា៖ ១) ការយល់ដឹងពីការប្រើប្រាស់វិធីសាស្រ្តបង្រៀន និងរៀនបែបរិះរក និងវិធីសាស្រ្ត

បង្រៀនផ្សេងទៀតដែលគ្រូបង្រៀនបានប្រើប្រាស់កន្លងមក។ ២)ការអភិវឌ្ឍជំនាញ តួនាទីសិស្ស និងគ្រូបង្រៀន ៣)ការយល់ដឹងអំពីការរៀបចំសិស្សជាក្រុម និង៤)ការយល់ដឹងអំពីការរៀបចំកិច្ចតែងការបង្រៀនជាដើម។

លើសពីនេះទៅទៀត អ្នកសិក្សាស្រាវជ្រាវក៏បានសិក្សាពីទស្សនៈរបស់នាយក/នាយករង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនផងដែរ ជាពិសេសអំពីបញ្ហាប្រឈមនានា ក្នុងការប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនបែបរិះរក សារៈសំខាន់នៃការប្រើប្រាស់វិធីសាស្ត្រនេះ និងស្ថានភាពនៃការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនបែបរិះរកកន្លងមកតាមសាលាគោលដៅទាំង១៤។

ការសិក្សានេះផងដែរ បានធ្វើឡើងក្នុងគោលបំណង ដើម្បីស្វែងយល់ពីទស្សនៈយល់ឃើញ របស់នាយក/នាយិកាសាលារៀន និងនាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀន ថាតើពួកគាត់យល់ឃើញយ៉ាងណាខ្លះចំពោះវិធីសាស្ត្របង្រៀន និងរៀនបែបរិះរកនេះ។ ហេតុផលចម្បងដែលផ្តោតលើសាលាគោលដៅទាំងនោះគឺដើម្បីលើកកម្ពស់ការបង្រៀន និងរៀនឱ្យកាន់តែមានគុណភាព និងប្រសិទ្ធភាព និងឆ្លុះបញ្ចាំងពីការយល់ដឹងរបស់ពួកគាត់ផងដែរ លើកការប្រើប្រាស់វិធីសាស្ត្របង្រៀននេះផងដែរ។ ដោយផ្អែកលើកម្រងសំណួរ និងការជ្រើសរើសចម្លើយត្រឹមត្រូវ លោកគ្រូអ្នកគ្រូអាចជ្រើសរើសទៅតាមកម្រិតយល់ដឹងរបស់ខ្លួនតាមរយៈសំណួរមួយចំនួនដូចខាងក្រោមនេះ៖

### ៤.២.១ ទស្សនៈយល់ឃើញ និងអត្ថន័យនៃវិធីសាស្ត្របង្រៀន

**តារាងទី១០៖ អត្ថន័យនៃវិធីសាស្ត្របង្រៀន**

| ទស្សនៈយល់ឃើញ | ភាគសំណាករួម | សំណាកជ្រើសរើស | % |
|---|---|---|---|
| ១.ជាលក្ខណៈនៃសំណុំគោលការណ៍ និតិវិធី ឬយុទ្ធសាស្ត្រ អនុវត្តដោយគ្រូបង្រៀន ដើម្បីសម្រេចការសិក្សាមួយសមស្របតាមបំណងប្រាថ្នារបស់សិស្ស | 238 | 172 | 42.2% |

| | | | |
|---|---|---|---|
| ២.គឺជាវិធីមួយដើម្បីសំរេចគោលដៅនៃការរៀនសូត្រ | 238 | 95 | 23.3% |
| ៣.គឺជាប្រព័ន្ធនៃសកម្មភាពជាបន្តបន្ទាប់ និងមាន ស ណ្តាប់ធ្នាប់របស់គ្រូ | 238 | 46 | 11.3% |
| ៤.វាជាវិធីនៃសកម្មភាពដែលមានរបៀបរៀបរយនៃមុខវិជ្ជា និង កម្មវត្ថុនៃដំណើរការអប់រំ | 238 | 95 | 23.3% |

តាមរយៈទិន្នន័យក្នុងតារាងខាងលើ អ្នកសិក្សាស្រាវជ្រាវអាចវាយតម្លៃបានថា ទស្សនៈយល់ឃើញរបស់គណៈគ្រប់គ្រងសាលារៀន ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀន លើការយល់ដឹងអំពីវិធីសាស្ត្របង្រៀនគឺមានភាគសំណាកសរុបមានចំនួន១៧២នាក់ ស្មើនឹង៤២.២០% យល់ឃើថា វិធីសាស្ត្របង្រៀនគឺ ជាលក្ខណៈនៃសំណុំគោលការណ៍ និតិវិធី ឬយុទ្ធសាស្ត្រ ដែលអនុវត្តដោយគ្រូបង្រៀន ដើម្បីសម្រេចការសិក្សាមួយសមស្របតាមបំណងប្រាថ្នារបស់សិស្ស។ ចំពោះ នាយក នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស គ្រូបង្រៀនសរុបចំនួន៩៥នាក់ ស្មើនឹង២៣.២០% យល់ឃើថា វិធីសាស្ត្របង្រៀនគឺជាជាវិធីមួយដើម្បីសំរេចគោលដៅនៃការរៀនសូត្រ។ រីឯ ភាគសំណាកសរុប ចំនួន៤៦នាក់ ក្នុងចំណោម២៣៨នាក់ ស្មើនឹង១១.៣០% យល់ឃើញថា វិធីសាស្ត្របង្រៀនគឺជាប្រព័ន្ធនៃសកម្មភាពជាបន្តបន្ទាប់ និងមានសណ្តាប់ធ្នាប់របស់គ្រូបង្រៀន។ ចំពោះនាយក/នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស គ្រូបង្រៀនចំនួនសរុប៩៥នាក់ ក្នុងចំណោម២៣៨នាក់ ស្មើនឹង២៣.៣០% យល់ឃើថា វិធីសាស្ត្របង្រៀនគឺជាវិធីនៃសកម្មភាពដែលមានរបៀបរៀបរយនៃមុខវិជ្ជា និងកម្មវត្ថុនៃដំណើរការអប់រំ។

ដូច្នេះហើយ គេអាចសន្និដ្ឋានបានថា ទស្សនៈយល់ឃើញរបស់គណៈគ្រប់គ្រងសាលារៀន ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនអំពីអត្ថន័យនៃវិធីសាស្ត្របង្រៀនដោយផ្តោតជាសំខាន់លើ*លក្ខណៈនៃសំណុំគោលការណ៍ និតិវិធី ឬយុទ្ធសាស្ត្រ អនុវត្តដោយគ្រូបង្រៀន ដើម្បីសម្រេចការសិក្សាមួយសមស្របតាមបំណងប្រាថ្នារបស់សិស្ស។*

### ៤.២.២ ទស្សនៈយល់ឃើញពីអត្ថន័យនៃវិធីសាស្ត្របង្រៀន និងរៀនបែបរិះរក

**តារាងទី១១៖ អត្ថន័យនៃវិធីសាស្ត្របង្រៀន និងរៀនបែបរិះរក**

| ទស្សនៈយល់ឃើញ | ភាគសំណាករួម | ភាគសំណាកជ្រើសរើស | % |
|---|---|---|---|
| ១.ការបង្រៀន និងរៀនតាមរយៈសំណួរស្រាវជ្រាវ | 238 | 167 | 15.1% |
| ២.សិស្សរៀនបែបសហការ និងធ្វើការងារជាក្រុម | 238 | 154 | 13.9% |
| ៣.គ្រូជាអ្នកសម្របសម្រួល | 238 | 148 | 13.4% |
| ៤.គ្រូបង្រៀន សិស្សចាំតែធ្វើតាម | 238 | 7 | 0.6% |
| ៥.សិស្សរៀនស្រាវជ្រាវដោយខ្លួនឯង | 238 | 132 | 11.9% |
| ៦.គ្រូបង្កើតបាតុភូតមុនពេលបង្រៀន | 238 | 92 | 8.3% |
| ៧.ការបង្រៀន និងរៀនដែលមានបង្កើតសំណួរគន្លឹះ | 238 | 134 | 12.1% |
| ៨.ការបង្រៀន និងរៀនដែលមានរៀបចំផែនការ/សកម្មភាពស្រាវជ្រាវ | 238 | 115 | 10.4% |
| ៩.មានការវិភាគវាយតម្លៃ/សន្និដ្ឋានដោយសិស្ស | 238 | 157 | 14.2% |

តាមរយៈទិន្នន័យក្នុងតារាងខាង អ្នកសិក្សាស្រាវជ្រាវអាចវាយតម្លៃបានថា ទស្សនៈយល់ឃើញរបស់គណៈគ្រប់គ្រងសាលារៀន ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនទៅលើ« វិធីសាស្ត្របង្រៀន និងរៀនបែបរិះរក» ក្នុងចំណោម២៣៨នាក់ ស្មើនឹង១៥.១០% យល់ឃើញថា *វិធីសាស្ត្របង្រៀន និងរៀនបែបរិះរក* គឺការបង្រៀន និងរៀនតាមរយៈសំណួរស្រាវជ្រាវ។ ភាគសំណាកចំនួន១៥៤នាក់ ក្នុងចំណោម២៣៨នាក់ស្មើនឹង១៣.៩០% យល់ឃើញថា*វិធីសាស្ត្របង្រៀន និងរៀនបែបរិះរក* គឺសិស្សរៀនបែបសហការ និងធ្វើ

ការងារជាក្រុម។ ភាគសំណាកសរុបចំនួន១៤៨នាក់ ក្នុងចំណោម២៣៨នាក់ ស្មើនឹង១៣.៤០% យល់ឃើថា វិធីសាស្ត្របង្រៀន និងរៀនបែបរិះរក*គឺ គ្រូជាអ្នកសម្របសម្រួល។*ក្នុងចំណោម នាយក នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស លោកគ្រូបង្រៀនចំនួន០៧នាក់ ក្នុងចំណោម២៣៨នាក់ ស្មើនឹង ០.៦០% យល់ឃើថា វិធីសាស្ត្របង្រៀន និងរៀនបែបរិះរក គឺជាអ្នកគ្រូបង្រៀន *សិស្សចាំតែធ្វើតាម*។ រីឯ នាយក នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនចំនួន១៣២នាក់ ក្នុងចំណោម ២៣៨នាក់ ស្មើនឹង១១.៩០% យល់ឃើថា វិធីសាស្ត្របង្រៀន និងរៀនបែបរិះរក គឺជា*វិធីសាស្ត្រមួយដែលសិស្សរៀនស្រាវជ្រាវដោយខ្លួនឯង*។ នាយក នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស គ្រូបង្រៀន ចំនួន៩២នាក់ (ក្នុងចំណោម២៣៨នាក់) ស្មើនឹង៨.៣០% យល់ឃើថា *វិធីសាស្ត្របង្រៀន និងរៀនបែបរិះរក*គឺជាវិធីសាស្ត្រមួយដែលគ្រូជាអ្នកបង្កើតបាតុភូតមុនពេលបង្រៀន។ នាយក នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស គ្រូបង្រៀនចំនួន១៣៤នាក់ (ក្នុងចំណោម២៣៨នាក់) ស្មើនឹង១២.១០% យល់ឃើថា *វិធីសាស្ត្របង្រៀន និងរៀនបែបរិះរក*គឺជាវិធីសាស្ត្រមួយដែលការបង្រៀន និងរៀន តាមរយៈការបង្កើតសំណួរគន្លឹះ។ នាយក នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស គ្រូបង្រៀនចំនួន១១៥នាក់ (ក្នុងចំណោម២៣៨នាក់) ស្មើនឹង១០.៤០% យល់ឃើថា *វិធីសាស្ត្របង្រៀន និងរៀនបែបរិះរក*គឺជាវិធីសាស្ត្រមួយដែលការបង្រៀន និងរៀនដែលមានរៀបចំផែនការ/សកម្មភាពស្រាវជ្រាវ។ នាយក នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស គ្រូបង្រៀនចំនួន១៥៧នាក់ (ក្នុងចំណោម២៣៨នាក់) ស្មើនឹង ១៤.២០% យល់ឃើថា *វិធីសាស្ត្របង្រៀន និងរៀនបែបរិះរក*គឺជាវិធីសាស្ត្រមួយដោយមានការវិភាគវាយតម្លៃ/សន្និដ្ឋានដោយសិស្ស។

ដូច្នេះ យើងអាចសន្និដ្ឋានបានថា ការបង្ហាញពីទស្សនៈយល់ឃើញរបស់គណៈគ្រប់គ្រងសាលា ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនទៅលើនិយមន័យ«វិធីសាស្ត្របង្រៀន និងរៀនបែបរិះរក» មានលក្ខណៈប្រហាក់ប្រហែលគ្នា ដែលអាចឱ្យអ្នកសិក្សាស្រាវជ្រាវវាយតម្លៃបានថា វិធីសាស្ត្របង្រៀន និងរៀនបែបរិះរកគឺការបង្រៀន និងរៀនតាមរយៈសំណួរស្រាវជ្រាវ ការបង្កើតសំណួរគន្លឹះ ដោយគ្រូបង្រៀនជាអ្នក

បង្កើតបាតុភូត និងជាការរៀនបែបសហការដោយមានគ្រូបង្រៀនជាអ្នកសម្របសម្រួល ចំណែកសិស្សជាអ្នករៀបចំផែនការស្រាវជ្រាវ វាយតម្លៃ ឬធ្វើសេចក្តីសន្និដ្ឋានដោយខ្លួនឯង។

**៤.២.៣ ទស្សនៈយល់ឃើញលើការអភិវឌ្ឍជំនាញនៅក្នុងវិធីសាស្ត្របង្រៀន និងរៀនបែបរិះរក**

**តារាងទី១២៖ការអភិវឌ្ឍជំនាញដល់សិស្សតាមវិធីសាស្ត្របង្រៀន និងរៀនបែបរិះរក**

| ទស្សនៈយល់ឃើញ | ភាគសំណាករួម | ភាគសំណាកជ្រើសរើស | % |
|---|---|---|---|
| ១.ជំនាញដោះស្រាយបញ្ហា បង្កើតថ្មី និងច្នៃប្រឌិត | 238 | 193 | 26.3% |
| ២.ជំនាញគិតស៊ីជម្រៅ វិភាគ និងវាយតម្លៃ | 238 | 185 | 25.0% |
| ៣.ជំនាញស្រាវជ្រាវ | 238 | 182 | 23.8% |
| ៤.ជំនាញទំនាក់ទំនង (សហការ/ធ្វើការក្រុម) | 238 | 171 | 13.0% |
| ៥.ជំនាញក្នុងការធ្វើផែនការ | 238 | 167 | 11.9% |

តាមរយៈតារាងខាងលើ អ្នកសិក្សាស្រាវជ្រាវសង្កេតឃើញថា ទស្សនៈយល់ឃើញរបស់គណៈគ្រប់គ្រងសាលារៀន ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនទៅលើ «ការអភិវឌ្ឍជំនាញនៅក្នុងវិធីសាស្ត្របង្រៀន និងរៀនបែបរិះរក»បានបង្ហាញថា នាយក នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនសរុបចំនួន១៩៣នាក់ ក្នុងចំណោម២៣៨នាក់ ស្មើនឹង២៦.៣០% យល់ឃើថា វិធីសាស្ត្របង្រៀន និងរៀនបែបរិះរកគឺ*បានផ្តល់ឱ្យសិស្សនូវការអភិវឌ្ឍជំនាញនៃការដោះស្រាយបញ្ហា ការបង្កើតថ្មី និងការច្នៃប្រឌិត*។ រីឯ នាយក នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនចំនួន១៨៥នាក់ ក្នុងចំណោម២៣៨នាក់ ស្មើនឹង២៥.០% យល់ឃើថា វិធីសាស្ត្របង្រៀន និងរៀនបែបរិះរកគឺ*បានផ្តល់ឱ្យសិស្សនូវការអភិវឌ្ឍជំនាញនៃការគិតស៊ីជម្រៅ វិភាគ និងវាយតម្លៃ*។

ចំពោះនាយក នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនចំនួន១៨២នាក់ ក្នុងចំណោម២៣៨នាក់ស្មើនឹង២៣.៨០% យល់ឃើញថា*វិធីសាស្ត្របង្រៀន* និងរៀនបែបរិះរកគឺ*បានផ្តល់ឱ្យសិស្សនូវការអភិវឌ្ឍជំនាញធ្វើការស្រាវជ្រាវ*។ ចំណែកចំនួន១៧១នាក់ក្នុងចំណោម២៣៨នាក់ ស្មើ១៣.០% យល់ឃើញថា វិធីសាស្ត្របង្រៀន និងរៀនបែបរិះរក គឺ*បានផ្តល់ឱ្យសិស្សនូវការអភិវឌ្ឍជំនាញក្នុងការធ្វើទំនាក់ទំនង(សហការក្រុម/ធ្វើការក្រុម)*។ ចំពោះ នាយក នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស គ្រូបង្រៀនចំនួន១៦៧នាក់ ក្នុងចំណោម២៣៨នាក់ ស្មើនឹង១១.៩០% យល់ឃើញថា វិធីសាស្ត្របង្រៀន និងរៀនបែបរិះរក គឺ*បានផ្តល់ឱ្យសិស្សនូវការអភិវឌ្ឍជំនាញក្នុងការធ្វើផែនការ។*

ដូច្នេះហើយ យើងអាចសន្និដ្ឋានបានថា ការផ្តល់ជាទស្សនៈយល់ឃើញរបស់គណៈគ្រប់គ្រងសាលា ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនទៅលើ «ការអភិវឌ្ឍជំនាញ» មានលក្ខណៈមិនដូចគ្នាទេ ប៉ុន្តែជំនាញមួយចំនួនមានលក្ខណៈប្រហែលប្រហែលគ្នា។ ជំនាញដែលគ្រូបង្រៀនពុំសូវផ្តល់សារៈសំខាន់មានដូចជា ជំនាញក្នុងការធ្វើផែន និងជំនាញទំនាក់ទំនង ហើយជំនាញដែលមានលក្ខណៈសំខាន់មានដូចជា ជំនាញនៃការដោះស្រាយបញ្ហា ជំនាញនៃការគិតស៊ីជម្រៅ និងជំនាញស្រាវជ្រាវជាដើម។

តាមលក្ខខ័ណ្ឌខាងលើនេះអាចឱ្យអ្នកសិក្សាស្រាវជ្រាវធ្វើការសន្និដ្ឋានបានថា ជំនាញដែលអាចអភិវឌ្ឍដល់សិស្សនៅក្នុងករណីដែលគ្រូបង្រៀនប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនតាមបែបរិះរកគឺមានដូចជា ជំនាញដោះស្រាយបញ្ហា ជំនាញការគិតស៊ីជម្រៅ ជំនាញស្រាវជ្រាវ ជំនាញផ្នែកទំនាក់ទំនង និងជំនាញនៃការធ្វើផែនការជាដើម។

### ៤.២.៤ ទស្សនៈយល់ឃើញលើជំហាននៃការរៀន និងបង្រៀន តាមវិធីសាស្ត្របង្រៀន និងរៀនតាមបែបរិះរក

**តារាងទី១៣៖ ការប្រើប្រាស់ជំហាននៃការបង្រៀន និងរៀនតាមបែបរិះរក**

| ទស្សនៈយល់ឃើញ | ភាគសំណាករួម | ភាគសំណាកជ្រើសរើស | % |
|---|---|---|---|
| ១.បង្កើតបាតុភូត | 238 | 106 | 13.6% |

| | | | |
|---|---|---|---|
| ២.កំណត់វត្ថុបំណង/បញ្ហា | 238 | 200 | 25.6% |
| ៣.បង្កើតសំណួរគន្លឹះ/សម្មតិកម្ម | 238 | 196 | 25.1% |
| ៤.ផែនការ/ប្រមូលទិន្នន័យ | 238 | 117 | 15.0% |
| ៥.វិភាគទិន្នន័យ/ទាញសេចក្ដីសន្និដ្ឋាន | 238 | 163 | 20.8% |

យោងតាមរយៈតារាងខាងលើ អ្នកសិក្សាស្រាវជ្រាវអាចវាយតម្លៃបានថា ទស្សនៈយល់ឃើញរបស់គណៈគ្រប់គ្រងសាលារៀន ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនទៅលើ «ជំហានដែលត្រូវប្រើប្រាស់នៅក្នុងវិធីសាស្ត្របង្រៀន និងរៀនបែបរិះរក» គឺមាននាយក នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនចំនួន១០៦នាក់ ក្នុងចំណោម២៣៨នាក់ ដែលស្មើនឹង១៣.៦០% បានជ្រើសរើសជំហានទី១ ស្ដីអំពីការបង្កើតបាតុភូត។ ចំពោះនាយក នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនចំនួន២០០នាក់ ក្នុងចំណោម២៣៨នាក់ ស្មើនឹង២៥.៦០% បានជ្រើសរើសជំហានទី២ ដែលទាក់ទងជាមួយការកំណត់វត្ថុបំណងឬបញ្ហា។ រីឯនាយក នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនចំនួន១៩៦នាក់ ក្នុងចំណោម២៣៨នាក់ ស្មើនឹង២៥.១០% បានជ្រើសរើសជំហានទី៣ដែលទាក់ទងជាមួយការបង្កើតសំណួរគន្លឹះឬសម្មតិកម្ម។ ចំណែក នាយក នាយករង/នាយិការង ប្រធានក្រុមបច្ចេក ទេស និងគ្រូបង្រៀនចំនួន១១៧នាក់ ក្នុងចំណោម២៣៨នាក់ ស្មើនឹង១៥.០០% បានជ្រើសរើសជំហានទី៤ ដែលទាក់ទងជាមួយការធ្វើផែនការ/ប្រមូលទិន្នន័យ។ ដោយឡែក នាយក នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនចំនួន១៦៣នាក់ ក្នុងចំណោម២៣៨នាក់ ស្មើនឹង២០.៨០% បានជ្រើសរើសជំហានទី៥ ទាក់ទងជាមួយ វិភាគទិន្នន័យ ឬទាញសេចក្ដីសន្និដ្ឋាន។

ហេតុដូចមាននៅក្នុងអំណះអំណាងខាងលើ យើងអាចសន្និដ្ឋានបានថា ការផ្ដល់ជាទស្សនៈយល់ឃើញរបស់គណៈគ្រប់គ្រងសាលា ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនទៅលើ«ជំហាននៃការបង្រៀននៅក្នុងវិធីសាស្ត្របង្រៀ និងរៀនបែបរិះរក» មានលក្ខណៈខុសគ្នាមួយចំនួន ហើយលោកនាយក នាយក

រង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនបានចូលរួមជ្រើសរើសចម្លើយមានភាគរយខ្ពស់បំផុតគឺ២៥.៦០% ផ្តោតលើការកំណត់វត្ថុបំណង/បញ្ហា។ នេះមានន័យថា ការកំណត់វត្ថុបំណងមានសារៈសំខាន់ណាស់នៅក្នុងការបង្រៀន ដោយប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនបែបរិះរក។ គ្រូបង្រៀនត្រូវយល់ច្បាស់លាស់អំពីវត្ថុបំណងមេរៀន ដើម្បីរៀបចំកិច្ចតែងការបង្រៀនឱ្យបានត្រឹមត្រូវ និងដើម្បីដឹងពីគោលបំណងមេរៀន ក៏ដូចជាតម្រូវការជាក់ស្តែងរបស់សិស្សានុសិស្ស។ នាយក នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនចូលជ្រើសរើសកម្រងសំណួរមានភាគរយទាបបំផុតគឺ១៣.៦០%។ នេះមានន័យថាពួកគាត់មិនបានយល់ច្បាស់លាស់អំពីសារៈសំខាន់នៃការកំណត់បាតុភូតនៅក្នុងវិធីសាស្ត្របង្រៀន និងរៀនតាមបែបរិះរកឡើយ។

តាមលក្ខខ័ណ្ឌនេះអាចឱ្យអ្នកសិក្សាស្រាវជ្រាវធ្វើការសន្និដ្ឋានបានថា ការប្រើប្រាស់ជំហាននៃការបង្រៀនតាមវិធីសាស្ត្របង្រៀន និងរៀនបែបរិះរកមានលក្ខណៈមួយចំនួនដូចជាៈ ១)ការបង្កើតបាតុភូត ២) ការកំណត់វត្ថុបំណង/បញ្ហា ៣) បង្កើតសំណួរគន្លឹះ/សម្មតិកម្ម ៤)ការធ្វើផែនការ/ប្រមូលទិន្នន័យ និង ៥) វិភាគទិន្នន័យ/ទាញសេចក្តីសន្និដ្ឋាន។

នៅក្នុងចំណោមជំហាននៃការបង្រៀន និងរៀនទាំងនេះ លោកនាយក នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនមានការយល់ឃើញមិនដូចគ្នាទេអំពីសារៈសំខាន់នៃការប្រើប្រាស់ជំហាននីមួយៗ ពោលគឺដោយអាស្រ័យលើកម្រិតយល់ដឹងរបស់ពួកម្នាក់ៗ។

### ៤.២.៥ ទស្សនៈយល់ឃើញលើដំណើរការបង្រៀន និងរៀនបែបរិះរក

នៅក្នុងដំណើរការបង្រៀនតាមវិធីសាស្ត្របង្រៀន និងរៀនបែបរិះរកត្រូវបានអនុវត្តដោយផ្អែកលើកត្តាសំខាន់មួយចំនួនដូចជាៈ ក)ទស្សនៈយល់ឃើញចំពោះការបង្កើតបាតុភូត/ព្រឹត្តិការណ៍។ ខ) ទស្សនៈយល់ឃើញចំពោះការបង្កើតសំណួរគន្លឹះ។ គ)ទស្សនៈយល់ឃើញចំពោះធ្វើផែនការ/ប្រមូលទិន្នន័យ / តេស្តសម្មតិកម្ម/ពិសោធន៍។ ឃ) ទស្សនៈយល់ឃើញចំពោះវិភាគ/ទាញសេចក្តីសន្និដ្ឋាន និង ង)ទស្សនៈយល់ឃើញទៅលើការរៀបចំសិស្សជាក្រុម។

#### ក) ទស្សនៈយល់ឃើញអំពីការបង្កើតបាតុភូតឬព្រឹត្តិការណ៍

តារាងទី១៤៖ ទស្សនៈយល់ឃើញចំពោះការបង្កើតបាតុភូត/ព្រឹត្តិការណ៍

| ទស្សនៈយល់ឃើញ | ភាគសំណាករួម | ភាគសំណាកជ្រើសរើស | % |
|---|---|---|---|
| ១. វត្ថុបំណងមេរៀន | 238 | 183 | 23.7% |
| ២. ខ្លឹមសារមេរៀន | 238 | 161 | 20.9% |
| ៣. សង្កេតបាតុភូតធម្មជាតិ | 238 | 119 | 15.4% |
| ៤. សង្កេតព្រឹត្តិការណ៍សង្គម | 238 | 114 | 14.8% |
| ៥. អង្កេតរូបភាព/វីដេអូដែលទាក់ទង | 238 | 131 | 17.0% |
| ៦. ប្រាប់ពីវត្ថុបំណងមេរៀនដោយផ្ទាល់ | 238 | 54 | 7.0% |
| ៧. ផ្សេងៗ... | 238 | 9 | 1.2% |

តាមទិន្នន័យបង្ហាញក្នុងតារាង អ្នកសិក្សាអាចវាយតម្លៃបានថា ទស្សនៈយល់ឃើញរបស់គណៈគ្រប់គ្រង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនលើដំណើការនៃការបង្រៀន និងការប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនបែបរិះរក ទាក់ទងជាមួយការបង្កើតបាតុភូត ឬព្រឹត្តិការណ៍គឺត្រូវមានលក្ខណៈសមស្របតាមវត្ថុបំណងមេរៀន ខ្លឹមសារមេរៀន ការសង្កេតព្រិត្តិការណ៍សង្គម ការអង្កេតរូបភាពឬវីដេអូ ឬគ្រូបង្រៀនអាចប្រាប់ពីវត្ថុបំណងដោយផ្ទាល់។

នៅក្នុងចំណោមទទ្បីករណ៍ខាងលើមានគណៈគ្រប់គ្រង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនចំនួន១៨៣នាក់ក្នុងចំណោម២៣៨នាក់ ស្មើនឹង២៣.៧០% យល់ឃើញថា ការបង្កើតបាតុភូតឬព្រឹត្តិការណ៍គឺត្រូវផ្តោតលើវត្ថុបំណងមេរៀនជាកត្តាសំខាន់។ តែចំពោះនាយក នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនចំនួន១៦១នាក់ ក្នុងចំណោម២៣៨នាក់ ស្មើនឹង២០.៩០% បានសង្កត់ធ្ងន់លើ *ខ្លឹមសារមេរៀន* ទៅវិញ។ រីឯ នាយក នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀន

ចំនួន១១៩នាក់ ក្នុងចំណោម២៣៨នាក់ ស្មើនឹង១៥.៤០% បានសង្កត់ធ្ងន់លើការ*សង្កេតបាតុភូតធម្មជាតិ* ហើយចំនួន១១៤នាក់ ក្នុងចំណោម២៣៨នាក់ ស្មើនឹង១៤.៨០% ទៀតបានជ្រើសរើស និងឱ្យតម្លៃលើការ*សង្កេតព្រឹត្តិការណ៍សង្គម*។ ចំពោះនាយក នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនចំនួន១៣១នាក់ ក្នុងចំណោម២៣៨នាក់ ស្មើនឹង១៧.០០% បានផ្ដោតលើការ *សង្កេតរូបភាព ឬវីដេអូដែលទាក់ទងជាមួយមេរៀន*។ ចំពោះនាយក នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនចំនួន៥៤នាក់ ក្នុងចំណោម២៣៨នាក់ ស្មើនឹង៧.០០% បានសង្កត់ធ្ងន់លើការប្រាប់ពី*វត្ថុបំណងមេរៀនដោយផ្ទាល់ទៅវិញ*។

ដូច្នេះគេអាចធ្វើសេចក្ដីសន្និដ្ឋានបានថា ការបង្ហាញពីទស្សនៈយល់ឃើញរបស់គណៈគ្រប់គ្រង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនទៅលើដំណើរការនៃការបង្រៀនដែលទាក់ទងជាមួយការបង្កើតបាតុភូតឬព្រឹត្តិការណ៍សង្គមមានលក្ខណៈខុសគ្នាខ្លាំង ពីព្រោះនាយក នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនមួយចំនួនបានចូលរួមជ្រើសរើសចម្លើយលើបញ្ហានេះមានភាគរយខ្ពស់បំផុតត្រឹមតែ២៣.៧០%ប៉ុណ្ណោះជាមួយនឹងការកំណត់វត្ថុបំណង ឬកំណត់បញ្ហា។ ចំណែកចម្លើយដែលទាបបំផុតគឺមានត្រឹម៧.០០%។ តាមរយៈទឡ្ហីករណ៍នេះមានន័យថា ពួកគាត់បានផ្ដល់អាទិភាពខ្លាំងទៅការបង្កើតបាតុភូតឬព្រឹត្តិការណ៍សង្គម ក្នុងការកំណត់វត្ថុបំណងមេរៀន ពោលគឺគ្រូបង្រៀនត្រូវជ្រើសរើសបាតុភូតទាំងឡាយណាដែលស៊ីចង្វាក់គ្នាជាមួយនឹងវត្ថុបំណងមេរៀនឬខ្លឹមសារមេរៀន។ ម្យ៉ាងវិញទៀត ពួកគាត់បានផ្ដល់តម្លៃកម្រិតទាបទៅលើការប្រាប់ពីវត្ថុបំណងមេរៀនដោយផ្ទាល់ ដោយមិនទាមទារ ឬចាំបាច់ក្នុងការចូលរួមបង្កើតបាតុភូតឬព្រឹត្តិការណ៍សង្គមអ្វីឡើយ។

លើសពីនេះទៅទៀត គណៈគ្រប់គ្រងសាលា ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនយល់ឃើញថា ការបង្កើតបាតុភូត ឬព្រឹត្តិការណ៍ត្រូវមានទំនាក់ទំនងយ៉ាងជិតស្និតជាមួយនឹងការសង្កេតព្រឹត្តិការណ៍សង្គម ឬការសង្កេតបាតុភូមសង្គម ព្រមទាំងសង្កេតរូបភាព ឬវីដេអូទាំងឡាយណាដែលជាប់ពាក់ព័ន្ធជាមួយខ្លឹមសារមេរៀនផងដែរ។

តាមលក្ខខ័ណ្ឌនេះអាចឱ្យអ្នកស្រាវជ្រាវធ្វើការសន្និដ្ឋានបានថា ការបង្កើតបាតុភូត ឬព្រឹត្តិការណ៍ក្នុងដំណើការនៃការបង្រៀនតាមវិធីសាស្ត្របង្រៀន និងរៀនបែបរិះរកគឺជាប់ពាក់ព័ន្ធនឹងលក្ខខណ្ឌមួយចំនួនដូចជា៖ ១)ការកំណត់វត្ថុបំណងមេរៀន ២)ត្រូវអាស្រ័យលើខ្លឹមសារមេរៀន ៣)ការសង្កេតបាតុភូតធម្មជាតិ ៤)សង្កេតព្រឹត្តិការណ៍សង្គម និង៥)ការអង្កេតរូបភាពឬវីដេអូដែលជាប់ពាក់ព័ន្ធ។

**ខ.ទស្សនៈយល់ឃើញអំពីការបង្កើតសំណួរគន្លឹះ**

**តារាងទី១៥៖ ទស្សនៈយល់ឃើញពីការបង្កើតសំណួរគន្លឹះ**

| ទស្សនៈយល់ឃើញ | ភាគសំណាករួម | ភាគសំណាក ជ្រើសរើស | % |
|---|---|---|---|
| ១. ទាក់ទងវត្ថុបំណងមេរៀន | 238 | 184 | 26.0% |
| ២. ទាក់ទងខ្លឹមសារមេរៀន | 238 | 185 | 26.1% |
| ៣. ទាក់ទងប្រធានបទនៃការស្រាវជ្រាវ | 238 | 184 | 26.0% |
| ៤. សេចក្តីសន្និដ្ឋាន និងវត្ថុបំណងត្រូវឆ្លុះបញ្ចាំងគ្នា | 238 | 156 | 22.0% |

ផ្អែកលើតារាងទិន្នន័យខាងលើ អ្នកស្រាវជ្រាវអាចវាយតម្លៃថា ទស្សនៈយល់ឃើញរបស់គណៈគ្រប់គ្រងសាលារៀន ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនលើដំណើការនៃការបង្រៀន និងរៀនបែបរិះរកតាមរយៈការបង្កើតសំណួរគន្លឹះគឺមានលោកនាយក នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនចំនួន១៨៤នាក់ ក្នុងចំណោម២៣៨នាក់ ស្មើនឹង២៦.០០% បានជ្រើសរើស និងផ្តោតជាសំខាន់*ទាក់ទងជាមួយការកំណត់វត្ថុបំណងមេរៀន* ។ ជាមួយគ្នានេះដែរ នាយក នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនចំនួន១៨៥នាក់ ក្នុងចំណោម២៣៨នាក់ ស្មើនឹង២៦.១០% បានជ្រើសរើស និងផ្តោតសំខាន់ *ទាក់ទងជាមួយខ្លឹមសារមេរៀន*។ ចំណែក នាយក នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស គ្រូបង្រៀនចំនួន១៨៤នាក់ ក្នុងចំណោម២៣៨នាក់ ស្មើនឹង២៦.០០% បាន

ជ្រើសរើស និងផ្ដោតជាសំខាន់លើ*ប្រធានបទស្រាវជ្រាវ*។ រីឯ នាយក នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនចំនួន១៥៦នាក់ ក្នុងចំណោម ២៣៨នាក់ ស្មើនឹង២២.០០% បានសង្កត់ធ្ងន់លើ *សេចក្ដីសន្និដ្ឋាន និងវត្ថុបំណងផ្ទុះបញ្ចាំងគ្នា*។

តាមរយៈទិន្នន័យខាងលើនេះយើងអាចសន្និដ្ឋានបានថា ទស្សនៈយល់ឃើញរបស់គណៈគ្រប់គ្រង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនទៅលើ ដំណើរការនៃការបង្រៀនក្នុងដំណាក់កាលនៃការបង្កើតសំណួរគន្លឹះគឺមានលក្ខណៈប្រហាក់ប្រហែលគ្នា និងគម្លាតគ្នាតិចតួចបំផុត ពីព្រោះលោកនាយក នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនបានចូលរួមជ្រើសរើសចម្លើយមាន២៦.១០ % ខ្ពស់ជាងគេទាក់ទងដល់ការកំណត់វត្ថុបំណងមេរៀន និងមានចំនួន ២២.០០% ទាបជាគេទាក់ទងជាមួយសេចក្ដីសន្និដ្ឋាន និងវត្ថុបំណងមេរៀនដែលផ្ទុះបញ្ចាំងគ្នា។

ក្នុងន័យនេះ ការបង្កើតសំណួរគន្លឹះនៅក្នុងការបង្រៀន និងរៀនបែបរិះរកមានសារៈសំខាន់ខ្លាំងណាស់សម្រាប់ដំណើរការនៃការបង្រៀននេះ។ ជាមួយគ្នានេះដែរ គ្រូបង្រៀនត្រូវបង្កើតសំណួរគន្លឹះដោយផ្អែកលើលក្ខខណ្ឌទាំងអស់ខាងលើ និងត្រូវទាក់ទងជាមួយកត្តាមួយចំនួនដូចជា៖ ១)សំណួរគន្លឹះត្រូវទាក់ទងវត្ថុបំណងមេរៀន ២)សំណួរគន្លឹះត្រូវទាក់ទងជាមួយខ្លឹមសារមេរៀន ៣) សំណួរគន្លឹះត្រូវទាក់ទងជាមួយប្រធានបទនៃការស្រាវជ្រាវ និង ៤)សេចក្ដីសន្និដ្ឋាន និងវត្ថុបំណងមេរៀនត្រូវផ្ទុះបញ្ចាំងគ្នាទៅវិញទៅមកជាចាំបាច់។

**គ.ទស្សនៈអំពីការធ្វើផែនការ/ប្រមូលទិន្នន័យ/តេស្តសម្មតិកម្ម/ពិសោធន៍**

**តារាងទី១៦៖ ធ្វើផែនការ/ប្រមូលទិន្នន័យ/តេស្តសម្មតិកម្ម/ពិសោធន៍**

| ទស្សនៈយល់ឃើញ | ភាគសំណាករួម | ភាគសំណាកជ្រើសរើស | % |
|---|---|---|---|
| ១. ឱ្យសិស្សប្រមូលព័ត៌មាន | 238 | 191 | 21.9% |
| ២. ឱ្យសិស្សស្វែងរកភស្តុតាង | 238 | 165 | 18.9% |
| ៣. សិស្សចែករំលែកព័ត៌មាន/ភស្តុតាង | 238 | 160 | 18.3% |

| | | | |
|---|---|---|---|
| ៤. សិស្សជ្រើសរើសចម្លើយត្រឹមត្រូវ | 238 | 118 | 13.5% |
| ៥. សិស្សបដិសេធចម្លើយដែលខុស | 238 | 53 | 6.1% |
| ៦.គ្រូសម្របសម្រួល/សំយោគលទ្ធផល | 238 | 187 | 21.4% |

តាមតារាងទិន្នន័យខាងលើ អ្នកសិក្សាស្រាវជ្រាវអាចអះអាងថា ទស្សនៈយល់ឃើញរបស់គណៈគ្រប់គ្រងសាលារៀន ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនលើដំណើរការបង្រៀន និងរៀនបែបរិះរក ដែលជាប់ទាក់ទងជាមួយការធ្វើផែនការ/ការប្រមូលទិន្នន័យ/តេស្តសម្មតិកម្ម/ពិសោធន៍ មានអ្នកផ្តល់ចម្លើយចំនួន១៩១នាក់ ក្នុងចំណោម២៣៨នាក់ ស្មើនឹង២១.៩០% បានជ្រើសរើស និងផ្តោតជាសំខាន់លើចំណុចនៃការរៀបចំសិស្សដោយផ្តល់លទ្ធភាព *ឱ្យសិស្សជាអ្នកប្រមូលទិន្នន័យ*។ ចំពោះនាយក នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនចំនួន១៦៥នាក់ ក្នុងចំណោម២៣៨នាក់ ស្មើនឹង១៨.៩០%យល់ថា *សិស្សជាអ្នកស្វែងរកកស្តុតាងដោយខ្លួនឯង*។ រីឯនាយក នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនចំនួន១៦០នាក់ ក្នុងចំណោម២៣៨នាក់ ស្មើនឹង១៨.៣០%បានអះអាងថា *សិស្សជាអ្នកចែករំលែកព័ត៌មាន ជាអ្នកផ្តល់ឬចែករំលែកភស្តុតាងគ្នា* ។ ចំពោះលោកនាយក នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនចំនួន១១៨នាក់ ក្នុងចំណោម២៣៨នាក់ ស្មើនឹង១៣.៥០%បានផ្តល់ជាទឡ្ហីករណ៍ថា *សិស្សជាអ្នកជ្រើសរើសចម្លើយត្រឹមត្រូវដោយខ្លួនឯង* ហើយនៅក្នុងចំណោមនោះដែរក៏មានភាគសំណាក៥៣នាក់ ក្នុងចំណោម២៣៨នាក់ ស្មើនឹង៦.១០% បានផ្តល់ជម្រើសលើទឡ្ហីករណ៍លើចំណុចនោះថា«សិស្សជាអ្នកបដិសេធចម្លើយដែលខុស»។ រីឯ នាយក នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនចំនួន១៨៧នាក់ក្នុងចំណោម២៣៨នាក់ស្មើនឹង២១.៤០%បានជ្រើសរើសការបង្រៀន និងរៀនដោយមានគ្រូបង្រៀនជាអ្នក*សម្របសម្រួល និងជាអ្នកសំយោគលទ្ធផល*។

តាមរយៈអំណះអំណាងខាងលើ យើងអាចសន្និដ្ឋានបានថាទស្សនៈយល់ឃើញរបស់គណៈគ្រប់គ្រងសាលារៀន ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនលើ«ដំណើរការនៃការបង្រៀននៅក្នុងការដំណាក់

កាលនៃការធ្វើផែនការ/ប្រមូលទិន្នន័យ/តេស្តសម្មតិកម្ម/ពិសោធន៍ នៅក្នុងវិធីសាស្ត្របង្រៀន និងរៀនបែបរិះរក»មានលក្ខណៈខុសគ្នា និងមានគម្លាតគ្នាខ្លាំង ពីព្រោះលោកនាយក នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនបានចូលរួមជ្រើសរើសចម្លើយដែលមានភាគរយខ្ពស់បំផុតគឺ២១.៩០% (ឱ្យសិស្សប្រមូលព័ត៌មាន) និងទាបបំផុតគឺ ៦.១០%(បដិសេធចម្លើយដែលខុស)។ នេះមានន័យថា នៅក្នុងដំណាក់កាលនេះការប្រមូលព័ត៌មានមានសារៈខ្លាំងណាស់ និងជាការងាររបស់សិស្សខ្លួនឯង ក្នុងការស្វែងរកភស្តុតាង អំណះអំណាង ជ្រើសរើសចម្លើយដែលត្រឹមត្រូវ និងឆ្លើយតបទៅនឹងប្រធានបទនៃការស្រាវជ្រាវក៏ដូចជាសំណួរគន្លឹះនៃមេរៀន។

ចំពោះបញ្ហានេះពួកគាត់យល់ឃើញថា ការធ្វើផែនការ/ការប្រមូលទិន្នន័យ/ការធ្វើតេស្តសម្មតិកម្ម ឬពិសោធន៍គឺគ្រូបង្រៀនត្រូវផ្អែកលើលក្ខខណ្ឌខាងក្រោម៖១)ឱ្យជាសិស្សប្រមូលព័ត៌មាន ២)សិស្សជាអ្នកស្វែងរកស្តុតាង ៣) សិស្សជាអ្នកចែករំលែកព័ត៌មានឬភស្តុតាងដែលបានរកឃើញ ៤)សិស្សអាចជ្រើសរើសចម្លើយត្រឹមត្រូវ និង៥)គ្រូជាអ្នកសម្របសម្រួលក្នុងដំណើរការនេះដោយសន្តិវិធី។

**ឃ.ទស្សនៈយល់ឃើញលើការវិភាគ និងទាញសេចក្តីសន្និដ្ឋាន**

**តារាងទី១៧៖ ការវិភាគ និងទាញសេចក្តីសន្និដ្ឋាន**

| ទស្សនៈយល់ឃើញ | ភាគសំណាករួម | ភាគសំណាកជ្រើសរើស | % |
|---|---|---|---|
| ១. សិស្សជាអ្នកបកស្រាយ/វិភាគព័ត៌មាន | 238 | 166 | 19.0% |
| ២. សិស្សជ្រើសរើសចម្លើយផ្អែកលើសំណួរគន្លឹះ | 238 | 169 | 19.4% |
| ៣.សិស្សជ្រើសរើសចម្លើយផ្អែកលើវត្ថុបំណងមេរៀន | 238 | 126 | 14.4% |
| ៤. សិស្សបដិសេធចម្លើយដែលខុស | 238 | 62 | 7.1% |
| ៥. គ្រូសម្របសម្រួល | 238 | 151 | 17.3% |

| | | | |
|---|---|---|---|
| ៦. គ្រូសំយោគ ឬផ្តល់ព័ត៌មានត្រឡប់ | 238 | 198 | 22.7% |

នៅក្នុងតារាងខាងលើគេអាចវាយតម្លៃបានថា ទស្សនៈយល់ឃើញរបស់គណៈគ្រប់គ្រងសាលារៀន ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនទៅលើដំណើការនៃការបង្រៀន និងរៀនបែបរិះរកតាមរយៈ« **ការវិភាគ/ទាញសេចក្តីសន្និដ្ឋាន**» មាននាយក នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនចំនួន១៦៦នាក់ក្នុងចំណោម២៣៨នាក់ស្មើនឹង១៩.០០%បានកំណត់ថា*សិស្សជាអ្នកបកស្រាយ ឬជាអ្នកវិភាគព័ត៌មាន*។ ចំណែកភាគសំនាកចំនួន១៦៩នាក់ក្នុងចំណោម២៣៨នាក់ ស្មើនឹង១៩.៤០% បានអះអាងថា*សិស្សជាអ្នកជ្រើសរើសចម្លើយដោយខ្លួនឯង និងត្រូវផ្អែកលើសំណួរគន្លឹះ* ។ ចំពោះនាយក នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនចំនួន១២៦នាក់ក្នុងចំណោម២៣៨នាក់ ស្មើនឹង១៤.៤០%បានបញ្ជាក់ថា*សិស្សជាអ្នកជ្រើសរើសចម្លើយ និងផ្អែកលើវត្ថុបំណងមេរៀន*។ រីឯនាយក នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនចំនួន៦២នាក់ក្នុងចំណោម២៣៨នាក់ ស្មើនឹង៧.១០%បានបង្ហាញថា*សិស្សជាអ្នកបដិសេធចម្លើយដែលខុស*។ ចំណែកនាយក នាយករង ឬនាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនចំនួន១៥១នាក់ក្នុងចំណោម២៣៨នាក់ស្មើនឹង១៧.៣០% បានបញ្ជាក់ថា*គ្រូបង្រៀនជាអ្នកសម្របសម្រួលនៅក្នុងដំណើរការនៃការបង្រៀន និងរៀននេះ*។ នាយក នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស គ្រូបង្រៀនចំនួន១៩៨នាក់ ក្នុងចំណោម២៣៨នាក់ ស្មើនឹង២២.៧០%គិតថា*សិស្សជាអ្នកបកស្រាយឬជាអ្នកវិភាគព័ត៌មាន* ។

តាមរយៈពំនោលខាងលើគេអាចសន្និដ្ឋានបានថា ទស្សនៈយល់ឃើញរបស់គណៈគ្រប់គ្រង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនលើដំណើរនៃការបង្រៀន ដែលស្ថិតនៅក្នុងដំណាក់កាលនៃ«**ការវិភាគឬទាញសេចក្តីសន្និដ្ឋាន**»នេះពុំសូវមានលក្ខណៈខុសទាំងស្រុងឡើយ លើកលែងតែការបដិសេធចម្លើយដែលមិនត្រឹមត្រូវប៉ុណ្ណោះដែលមានគម្លាតគ្នាខ្លាំង ពីព្រោះ នាយក នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនបានចម្លើយលើបញ្ហានេះមានភាគរយខ្ពស់បំផុតត្រឹម២២.៧០% (គ្រូសំយោគ ឬផ្តល់ព័ត៌មានត្រឡប់) និងទាបបំផុតមានត្រឹម៧.១០% (បដិសេធចម្លើយដែលខុស)។

នេះមានន័យថា នៅក្នុងដំណាក់កាលនេះ ការសំយោគ និងការផ្តល់ព័ត៌មានត្រឡប់មានសារៈខ្លាំងណាស់ និងជាការងាររបស់សិស្ស ហើយដើម្បីបង្ហាញពីសមត្ថភាពរបស់ពួកគេក៏ដូចជាការយល់ដឹងរបស់ពួកគេទៅលើខ្លឹមសារមេរៀន ប្រធានបទនៃការស្រាវជ្រាវ ហើយបន្ទាប់មកគ្រូបង្រៀនត្រូវធ្វើសំយោគដើម្បីបញ្ជាក់អំពីចំណុចខ្លាំង និងខ្សោយ ចំណុចខ្វះ និងចំណុចដែលត្រូវកែលម្អ។

ទោះបីជាយ៉ាងណា នាយក នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនយល់ឃើញអំពីការវិភាគឬទាញសេចក្តីសន្និដ្ឋានថាមានលក្ខណៈផ្សេងៗគ្នា និងស្រមទៅតាមកម្រិតនៃការយល់ដឹងរបស់ខ្លួនម្នាក់ៗផងដែរ។

**ង.ទស្សនៈយល់ឃើញពីការរៀបចំក្រុមពិភាក្សា**

**តារាងទី១៨៖ការរៀបចំសិស្សជាក្រុមពិភាក្សា**

| ទស្សនៈយល់ឃើញ | ភាគសំណាករួម | ភាគសំណាកជ្រើសរើស | % |
|---|---|---|---|
| ១.សិស្សខ្សោយ មធ្យម បង្គួរ | 238 | 8 | 3.3% |
| ២.សិស្សខ្សោយ មធ្យម ពូកែ | 238 | 15 | 6.1% |
| ៣.មធ្យម បង្គួរ  ពូកែ | 238 | 2 | .8% |
| ៤.សិស្សចម្រុះ | 238 | 211 | 86.5% |
| ៥.ផ្សេងៗ... | 238 | 8 | 3.3% |

តាមរយៈទិន្នន័យដែលមាននៅក្នុងតារាង អ្នកស្រាវជ្រាវអាចសន្និដ្ឋានបានថាទស្សនៈយល់ឃើញរបស់គណៈគ្រប់គ្រងសាលារៀន ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនទៅលើដំណើរការនៃការបង្រៀន និងរៀនបែបរិះរកទាក់ទងជាមួយ**ការរៀបចំក្រុមសិស្សពិភាក្សាគឺ**មានលក្ខណៈជាក្រុមចម្រុះ។ ជាមួយគ្នានេះដែរ នាយក នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនចំនួន០៨នាក់ក្នុងចំណោម ២៣៨នាក់ ស្មើនឹង៣.៣០% បានដាក់ក្រុម*សិស្សខ្សោយ មធ្យម និងល្អបង្គួរជាមួយគ្នា* ។ នាយក នាយក

រង/នាយិការង ប្រធានក្រុមបច្ចេកទេស គ្រូបង្រៀនចំនួន១៥នាក់ផ្សេងទៀត ស្មើនឹង៦.១០% បានរៀបចំជ្រើសរើស*សិស្សខ្សោយ មធ្យម ពូកែដាក់នៅក្នុងក្រុមជាមួយគ្នា*។ ចំណែកនាយក នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស គ្រូបង្រៀនចំនួន០២នាក់ ស្មើនឹង០.៨០%បានរៀបចំសិស្ស *មធ្យម ល្អបង្គួរ* និង *ពូកែនៅក្នុងក្រុមជាមួយគ្នា*។ ចំពោះ នាយក នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនចំនួន២១១នាក់ក្នុងចំណោម២៣៨នាក់ ស្មើនឹង៨៦.៥០%បានអះអាងថា ពួកគាត់រៀបចំសិស្សដោយដាក់ពួកគេឱ្យរៀនជាមួយក្នុងស្ថានភាពជា*សិស្សចម្រុះ*។ រីឯ នាយក នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស គ្រូបង្រៀនចំនួន០៨នាក់ក្នុងចំណោម២៣៨នាក់ស្មើនឹង៣.៣០%មិនបានបញ្ជាក់ច្បាស់លាស់បីបញ្ហារៀបចំក្រុមសិស្សពិភាក្សានេះឡើយ។

ដូច្នេះយើងអាចសន្និដ្ឋានបានថា ទស្សនៈយល់ឃើញរបស់គណៈគ្រប់គ្រង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនលើដំណើរការនៃការបង្រៀន និងរៀនតាមបែបរិះក ដោយ**រៀបចំក្រុមសិស្សពិភាក្សាគឺ**មានលក្ខណៈខុសគ្នា ប៉ុន្តែគ្រូបង្រៀនភាគច្រើនបានរៀបចំក្រុមសិស្សបានត្រឹមត្រូវ ដូចជារៀបចំសិស្សជាក្រុមចម្រុះជាដើម។ ជាមួយគ្នានេះដែរ មាននាយក នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនដែលបានរៀបចំសិស្សជាក្រុមចម្រុះមានចំនួន៨៦.៥០%ខ្ពស់ជាងគេ និងទាបជាងគេ០.៨០% (មធ្យម ល្អបង្គួរ ពូកែ)។

នេះមានន័យថា នៅក្នុងដំណាក់កាលនេះ គ្រូបង្រៀនមានការយល់ដឹងខ្ពស់អំពីរបៀបរៀបចំក្រុមសិស្ស។ ម្យ៉ាងទៀតពួកគាត់គិតថា ការរៀបចំក្រុមដែលល្អប្រសើរបំផុតគឺតាមបែបចម្រុះ ពីព្រោះគេមិនត្រូវទុកចោលសិស្សណាម្នាក់ដោយមិនបានឱ្យចូលរួមនោះទេ។ សិស្សគ្រប់រូបត្រូវតែចូលរួមសកម្មភាពក្នុងការពិភាក្សាក្រុមតាមការចាត់តាំងរបស់គ្រូបង្រៀន។ ទោះបីយ៉ាងណា នាយក នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនយល់ឃើញថា បញ្ហានេះមានលក្ខណៈខុសគ្នាបន្តិចបន្តួចទៅតាមកម្រិតនៃការយល់ដឹងរបស់ខ្លួន។

### ៤.២.៦ ទស្សនៈយល់ឃើញពីការរៀបចំកិច្ចតែងការបង្រៀន នៅក្នុងវិធីសាស្ត្របង្រៀន និងរៀនបែបរិះក

**តារាងទី១៩៖ ទស្សនៈអំពីការរៀបចំកិច្ចតែងការបង្រៀន តាមមេរៀនIBL**

| ទស្សនៈយល់ឃើញ | ភាគសំណាករួម | ភាគសំណាកជ្រើសរើស | % |
|---|---|---|---|
| ១.យល់ដឹងខ្លឹមសារមេរៀន | 238 | 185 | 17.8% |
| ២.យល់ដឹងពីវត្ថុបំណងមេរៀន | 238 | 198 | 19.1% |
| ៣.យល់ដឹងសមត្ថភាពចំណេះដឹងសិស្ស | 238 | 134 | 12.9% |
| ៤.យល់ដឹងរបៀបប្រើប្រាស់ជំហានទាំង៥របស់IBL | 238 | 188 | 18.1% |
| ៥.យល់ដឹងរបៀបរៀបចំសិស្សជាក្រុម | 238 | 126 | 12.1% |
| ៦.យល់ដឹងបាតុភូតឬព្រឹត្តិការណ៍សង្គមក្នុងការបង្កើតសំណួរគន្លឹះ | 238 | 111 | 10.7% |
| ៧.យល់ពីបាតុភូតឬព្រឹត្តិការណ៍សង្គមទាក់ទងជីវភាពរស់នៅប្រចាំថ្ងៃរបស់សិស្ស | 238 | 97 | 9.3% |

តាមរយៈទិន្នន័យនៅក្នុងតារាងបង្ហាញឱ្យឃើញថា ទស្សនៈយល់ឃើញរបស់គណៈគ្រប់គ្រងសាលារៀន ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀននៅក្នុងដំណើការនៃការរៀបចំកិច្ចតែងការបង្រៀនតាមវិធីសាស្រ្តបង្រៀន និងរៀនបែបរិះរក មាននាយក នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនចំនួន១៨៥នាក់ក្នុងចំណោម២៣៨នាក់ ស្មើនឹង១៧.៨០%បានបញ្ជាក់ថា ដើម្បីរៀបចំកិច្ចតែងការបានត្រូវ*យល់ដឹងពីខ្លឹមសារមេរៀន*។ ចំណែកភាគសំណាកចំនួន១៩៨នាក់ ក្នុងចំណោម២៣៨នាក់ ស្មើនឹង១៩.១០%បានអះអាងថាត្រូវ*យល់ដឹងពីវត្ថុបំណងមេរៀន។* ចំណែកនាយក នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនចំនួន១៣៤នាក់ ក្នុងចំណោម២៣៨នាក់ ស្មើនឹង១២.៩០% បានផ្តល់ជាចម្លើយថា គ្រូបង្រៀនត្រូវ*យល់ដឹងពីសមត្ថភាព និងចំណេះដឹងសិស្សជាចាំបាច់។* រីឯនាយក

នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនចំនួន១៨៨នាក់ក្នុងចំណោម២៣៨នាក់ស្មើនឹង១៨.១០%បានពោលថា គ្រូបង្រៀនត្រូវ *យល់ដឹងរបៀបប្រើប្រាស់ជំហានទាំង៥របស់IBL* ព្រោះវាជាផែនទីបង្ហាញផ្លូវនៅក្នុងការបង្រៀន និងដើម្បីសម្រេចវត្ថុបំណងមេរៀនបាន។ ចំពោះនាយក នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនចំនួន១២៦នាក់ ក្នុងចំណោម២៣៨នាក់ ស្មើនឹង១២.១០%បានបញ្ជាក់ពីការ *យល់ដឹង និងរបៀបរៀបចំសិស្សជាក្រុមទៅវិញ។* នាយក នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនចំនួន១១១នាក់ ក្នុងចំណោម២៣៨នាក់ ស្មើនឹង១០.៧០% បានបញ្ជាក់ថាការរៀបចំកិច្ចតែងការបង្រៀនត្រូវ *យល់ដឹងពីបាតុភូត ឬព្រឹត្តិការណ៍សង្គមក្នុងការបង្កើតសំណួរគន្លឹះ ព្រោះសំណួរគន្លឹះជាចំណុចសំខាន់នៃការរៀន និងបង្រៀន។* ចំណែកនាយក នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនចំនួន៩៧នាក់ក្នុងចំណោម២៣៨នាក់ ស្មើនឹង៩.៣០%បានបញ្ជាក់ថា គ្រូបង្រៀនត្រូវ *យល់ដឹងពីបាតុភូត ឬព្រឹត្តិការណ៍សង្គមដែលទាក់ទងនឹងជីវភាពរស់នៅប្រចាំថ្ងៃរបស់សិស្ស។*

បើដូចនេះគេអាចសន្និដ្ឋានបានថា ទស្សនៈយល់ឃើញរបស់គណៈគ្រប់គ្រងសាលារៀន ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនលើ«ការរៀបចំកិច្ចតែងការបង្រៀន ក្នុងវិធីសាស្ត្របង្រៀន និងរៀនបែបរិះរក»ពុំមានលក្ខណៈខុសគ្នាខ្លាំងនោះទេ ពីព្រោះនាយក នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនបានចូលរួមផ្តល់ចម្លើយមានភាគរយខ្ពស់បំផុតត្រឹម១៨.១០% និងត្រូវយល់ដឹងពីជំហានទាំងប្រាំរបស់IBL និងទាបបំផុតគឺ 9.30% តែត្រូវ *យល់ដឹងពីបាតុភូតឬព្រឹត្តិការណ៍សង្គមទាក់ទងជីវភាពរស់នៅប្រចាំថ្ងៃរបស់សិស្ស*។

នេះមានន័យថាពួកគាត់បានឱ្យតម្លៃខ្ពស់ទៅលើជំហានទាំងប្រាំរបស់IBL ដែលជាចំណុចរួមនៃដំណើរការបង្រៀន និងរៀនរបស់IBL។ ទោះបីជាយ៉ាងណាក៏ដោយ ពួកគាត់គិតថាត្រូវមានធាតុផ្សំបន្ថែមទៀតដើម្បីឱ្យការរៀបចំកិច្ចតែងការបង្រៀនមួយឱ្យបានល្អប្រសើរ ពោលគឺគ្រូបង្រៀនត្រូវយល់ដឹងអំពីខ្លឹមសាមេរៀន យល់ដឹងអំពីវត្ថុបំណងមេរៀនបានច្បាសលាស់ យល់ដឹងអំពីសមត្ថភាពរបស់សិស្ស យល់ដឹង

អំពីការរៀបចំក្រុមពិភាក្សារបស់សិស្ស និងត្រូវយល់ដឹងបាតុភូតឬព្រឹត្តិការណ៍សង្គមក្នុងការបង្កើតសំណួរគន្លឹះ និងយល់ដឹងពីបាតុភូត ឬព្រឹត្តិការណ៍សង្គមទាក់ទងជីវភាពរស់នៅប្រចាំថ្ងៃរបស់សិស្សផងដែរ។

**៤.២.៧ ទស្សនៈយល់ឃើញពីសារៈសំខាន់នៃការប្រើប្រាស់វិធីសាស្រ្តបង្រៀន និងរៀនបែបរិះរក**

**តារាងទី២០៖ សារៈសំខាន់នៃការបង្រៀន និងរៀនតាមបែបរិះរក**

| ទស្សនៈយល់ឃើញ | ភាគសំណាករួម | ភាគសំណាកជ្រើសរើស | % |
|---|---|---|---|
| ១.ដឹងអំពីសកម្មភាពដែលត្រូវបង្រៀន | 238 | 124 | 12.2% |
| ២.ដឹងអំពីរបៀបនៃការបង្រៀនចំពោះមុខវិជ្ជាផ្សេងៗគ្នា | 238 | 73 | 7.2% |
| ៣.ផ្លាស់ប្តូរបច្ចេកទេសតាមដំណាក់កាលនៃសកម្មភាព | 238 | 109 | 10.8% |
| ៤.ដឹងអំពីមធ្យោបាយមានប្រសិទ្ធភាពក្នុងការផ្តល់ព័ត៌មាន | 238 | 71 | 7.0% |
| ៥.ជួយគ្រូក្នុងការប្រមើលមើលទៅលើកម្មវិធីសិក្សាទាំងមូល | 238 | 79 | 7.8% |
| ៦.យល់ដឹងបាតុភូត/ព្រឹត្តិការណ៍សង្គមក្នុងការបង្កើតសំណួរគន្លឹះ | 238 | 128 | 12.6% |
| ៧.ដឹងអំពីលំនាំនៃការរៀននិងបង្រៀន | 238 | 116 | 11.5% |
| ៨.ងាយស្រួលក្នុងការរៀបចំកិច្ចតែងការបង្រៀន | 238 | 135 | 13.3% |
| ៩.អាចសម្រេចវត្ថុបំណងមេរៀន | 238 | 178 | 17.6% |

យោងតាមទិន្នន័យដូចមាននៅក្នុងតារាងខាងលើអ្នកសិក្សាស្រាវជ្រាវសង្កេតឃើញថា ទស្សនៈយល់ឃើញរបស់គណៈគ្រប់គ្រងសាលារៀន ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនទៅលើ «សារៈសំខាន់នៃការប្រើប្រាស់វិធីសាស្រ្តបង្រៀន និងរៀនបែបរិះរកគឺមាន នាយក នាយករង/នាយិការង ប្រធានក្រុម

បច្ចេកទេស និងគ្រូបង្រៀនចំនួន១២៤នាក់ ក្នុងចំណោម២៣៨នាក់ ស្មើនឹង១២.២០% បានបញ្ជាក់ថាគ្រូបង្រៀនត្រូវយល់ *ដឹងអំពីសកម្មភាពដែលខ្លួនត្រូវបង្រៀន*។ ជាមួយគ្នានេះដែរ នាយក នាយករង ឬនាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនចំនួន៧៣នាក់ ក្នុងចំណោម២៣៨នាក់ ស្មើនឹង៧.២០% បានបង្ហាញឱ្យដឹងថាសារៈសំខាន់នៃការប្រើប្រាស់វិធីសាស្ត្រនេះគឺត្រូវ *ដឹងអំពីរបៀបនៃការបង្រៀនចំពោះមុខវិជ្ជាផ្សេងៗគ្នា*» រីឯភាគសំណាកចំនួន១០៩នាក់ ក្នុងចំណោម២៣៨នាក់ស្មើនឹង១០.៨០%បានផ្តោតជាសំខាន់លើការ *ផ្លាស់ប្តូរបច្ចេកទេសនៃការរៀន និងបង្រៀនឱ្យស្របទៅតាមដំណាក់កាលនៃសកម្មភាពនីមួយៗ*។ ចំពោះ នាយក នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនចំនួន៧១នាក់ ក្នុងចំណោម២៣៨នាក់ ស្មើនឹង៧.០០% គិតថាសារៈសំខាន់នៃការប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនបែបរិះរកគឺត្រូវ *ដឹងអំពីមធ្យោបាយនានាដែលមានប្រសិទ្ធភាពក្នុងការផ្តល់ព័ត៌មាន*។ ចំណែក នាយក នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនចំនួន៧៩នាក់ផ្សេងទៀត ក្នុងចំណោម២៣៨នាក់ស្មើនឹង៧.៨០%បានអះអាងថា សារៈសំខាន់នៃការប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀននេះគឺ *ជួយគ្រូបង្រៀនឱ្យចេះប្រមើលមើលទៅលើកម្មវិធីសិក្សាទាំងមូល*។ រីឯ នាយក នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនចំនួន១២៨នាក់ ក្នុងចំណោម២៣៨នាក់ ស្មើនឹង១២.៦០% មានយោបល់ថាគ្រូបង្រៀនត្រូវ *យល់ដឹងបាតុភូតឬព្រឹត្តិការណ៍សង្គមក្នុងការបង្កើតសំណួរគន្លឹះ*។ ជាមួយគ្នានេះដែរ នាយក នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនចំនួន១១៦នាក់ ក្នុងចំណោម២៣៨នាក់ស្មើនឹង១១.៥០% អះអាងថា គ្រូបង្រៀនត្រូវ *ដឹងអំពីលំនាំនៃការរៀន និងបង្រៀន* ទើបអាចឱ្យការប្រើប្រាស់វិធីសាស្ត្រនេះមានប្រសិទ្ធភាព។ ចំណែក នាយក នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនចំនួន១៣៥នាក់ ស្មើនឹង១៣.៣០% បានបញ្ជាក់ថា សារៈសំខាន់នៃការប្រើប្រាស់វិធីសាស្ត្រ*គឺងាយស្រួលក្នុងការរៀបចំកិច្ចតែងការបង្រៀន*។ ដោយឡែក នាយក នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនចំនួន១៧៨នាក់ ស្មើនឹង១៧.៦០% យល់ងថាសារៈសំខាន់នៃការប្រើប្រាស់វិធីសាស្ត្រគឺ*អាចសម្រេចវត្ថុបំណងមេរៀនបាន*។

ហេតុនេះហើយ យើងអាចសន្និដ្ឋានបានថា ទស្សនៈយល់ឃើញរបស់គណៈគ្រប់គ្រងសាលា ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនទៅលើ«សារៈសំខាន់នៃការប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនបែបរិះរក» ពុំមានលក្ខណៈខុសគ្នាខ្លាំងនោះទេ ពីព្រោះលោកនាយក នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនបានជ្រើសរើសចម្លើយដែលមានភាគរយខ្ពស់បំផុតគឺ១៣.៣០% ជាពិសេសទាក់ទងជាមួយភាព«ងាយស្រួលក្នុងការរៀបចំកិច្ចតែងការបង្រៀន» និងមានភាគរយទាបបំផុតគឺ ៧.០០ % ដែលនិយាយទាក់ទងជាមួយទឡ្ហីករណ៍ថា គ្រូបង្រៀនត្រូវ«*ដឹងពីមធ្យោបាយដ៏មានប្រសិទ្ធភាពក្នុងការបង្រៀនសិស្ស*»។ នេះមានន័យថា ការប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនបែបរិះរកមានសារៈសំខាន់ច្រើន។ ម៉្យាងទៀត វិធីសាស្ត្រនេះជម្រុញ និងជួយសិស្សឱ្យស្រូបយកព័ត៌មាន ជម្រុញឱ្យមានការចង់ចេះចង់ដឹង ព្រមទាំងចេះរបៀបរបបនៃការសិក្សាស្រាវជ្រាវ ការវិភាគ និងការប្រមូលទិន្នន័យ ពាក់ព័ន្ធជាមួយប្រធានបទនៃការសិក្សា តាមរយៈសកម្មភាព និងកិច្ចការក្រុមដែលសិស្សត្រូវធ្វើការរិះរក អំពីអ្វីៗដែលមាននៅជុំវិញខ្លួនរបស់គេនោះ។ ការរៀនតាមវិធីសាស្ត្រនេះសិស្សានុសិស្សអាចធ្វើការអភិវឌ្ឍ ធ្វើការស្វែងយល់មានការគិតស៊ីជម្រៅ និងមានជំនាញទំនាក់ទំនងជាដើម។ ការប្រើប្រាស់ជំនាញ និងពុទ្ធិរបស់សិស្សជាបន្តបន្ទាប់មិនត្រឹមតែជួយសិស្សឱ្យរៀនបាននៅក្នុងថ្នាក់ប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងអាចជួយសិស្សឱ្យចេះរស់នៅប្រកបដោយភាពថ្លៃថ្នូរទៀតផង។ មិនតែប៉ុណ្ណោះ ការប្រើប្រាស់វិធីសាស្ត្រនេះអាចជម្រុញ និងបង្កើតបាននូវភាពជាម្ចាស់ មានភាពម្ចាស់ការ មានការស្រឡាញ់ ចង់សិក្សារៀនសូត្រ និងចេះសម្របខ្លួនទៅតាមបរិយាកាសសង្គមផងដែរ។

ពាក់ព័ន្ធនឹងសារៈសំខាន់នៃការប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនបែបរិះរក ត្រូវបានអ្នកសិក្សាស្រាវជ្រាវលើកឡើងជាសំណួរថា តើវិធីសាស្តនៃការបង្រៀន និងរៀនបែបរិះរកមានសារៈសំខាន់បែបណា។ គ្រូបង្រៀនភាគច្រើនបាននិយាយថា វិធីសាស្ត្រនេះគឺមានសារៈសំខាន់ខ្លាំង ពីព្រោះគ្រូបង្រៀនអាចស្វែងយល់ និងយល់ដឹងអំពីសកម្មភាពដែលត្រូវបង្រៀន និងអាចយល់ដឹងអំពីរបៀបបង្រៀនលើមុខវិជ្ជាផ្សេងៗទៀត។

លើសពីនេះទៅទៀត វិធីសាស្ត្របង្រៀននេះ ធ្វើឱ្យគ្រូបង្រៀនដឹងអំពីដំណើរការបង្រៀន និងរៀន ងាយស្រួលក្នុងការរៀបចំកិច្ចតែងការបង្រៀន ងាយស្រួលរៀបចំក្រុមពិភាក្សា សិស្សមានសកម្មភាពរស់រវើក សិស្សចេះគិតបែបស៊ីជម្រៅ និងចេះសិក្សាស្រាវជ្រាវដោយខ្លួនឯង ព្រមទាំងរំពឹងថា ក្រោយពីសិក្សារួចសិស្សនឹងទទួលបានលទ្ធផលល្អប្រសើរ ប្រសិនបើគ្រូបង្រៀនអនុវត្តវិធីសាស្ត្រនេះបានត្រឹមត្រូវ និងមានការចូលរួមពីសិស្សផងដែរនោះ។

### ៤.២.៨ ទស្សនៈយល់ឃើញពីស្ថានភាពនៃការប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនបែបរិះរក

#### ក) ទស្សនៈយល់ឃើញរបស់នាយក នាយករង/នាយិការងលើស្ថានភាពនៃការប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនបែបរិះរក (IBL)

ពាក់ព័ន្ធនឹងទស្សនៈយល់ដឹងរបស់នាយក/នាយិកា នាយករង/នាយិការងសាលារៀន អ្នកសិក្សាស្រាវជ្រាវបានលើកឡើងនូវសំណួរអំពីស្ថានភាពនៃការប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនបែបរិះរកដល់ **លោកនាយក នាយករង/នាយិការង អំពីការប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនបែបរិះរក(IBL) នៅតាមសាលារៀនរបស់ពួកគាត់**។ លោកនាយក/នាយិកា និងនាយករងភាគច្រើនបានមើលឃើញថា ការអនុវត្ត និងការប្រើប្រាស់វិធីសាស្ត្របង្រៀននេះគឺនៅមិនទាន់បានទូលំទូលាយនោះទេ ដោយសារកង្វះការបណ្តុះបណ្តាល និងការបំប៉នបន្ថែម។

ដូចនេះមានន័យថា មានគ្រូបង្រៀនតិចតួចប៉ុណ្ណោះដែលធ្លាប់បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលស្តីពីវិធីសាស្ត្របែបរិះរកនេះកន្លងមក ចំណែកគ្រូបង្រៀនមួយចំនួនទៀតមិនទាន់ចេះប្រើប្រាស់វិធីសាស្ត្រនេះនៅឡើយទេ។ មួយវិញទៀត គ្រូបង្រៀនដែលមានមនសិកា មានឆន្ទៈពិតប្រាកដក្នុងការអនុវត្ត និងប្រើប្រាស់វិធីសាស្ត្រនេះក៏នៅមានតិចតួចបំផុតដោយសារកង្វះការលើកទឹកចិត្តទាំងផ្នែកសំភារៈសិក្សា និងថវិកាជាដើម។ ជាមួយគ្នានេះដែរ នាយក/នាយិកា នាយករង/នាយិការងមួយចំនួនក៏បានលើកឡើងអំពីបញ្ហាខ្វះកិច្ចសហការគ្នារវាងគណៈគ្រប់គ្រងសាលារៀន ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនផងដែរ។ មិនត្រឹមតែប៉ុណ្ណោះ ក្រសួងអប់រំ យុវជន និងកីឡាក៏មិនបានកំណត់វិធីសាស្ត្រមួយណាដែលល្អប្រសើរសម្រាប់ការរៀន និងបង្រៀននៅឡើយដែរ ពោលគឺក្រសួងអប់រំ យុវជន និងកីឡា គ្រាន់តែជម្រុញឱ្យមាន

ការប្រើប្រាស់វិធីសាស្ត្របង្រៀនថ្មីៗ តែក៏ពុំទាន់បានចុះបង្ហាត់បង្ហាញឱ្យបានគ្រប់សាលារៀន នៅទូទាំងប្រទេស និងធ្វើការតាមដានលើការអនុវត្ត និងប្រើប្រាស់វិធីសាស្ត្រនេះឱ្យបានត្រឹមត្រូវនៅឡើយដែរ។

លើសពីនេះទៅទៀត កម្មវិធីសិក្សាថ្នាក់ជាតិក៏មិនបានតម្រូវឱ្យ និងត្រូវតែអនុវត្តការបង្រៀនដោយប្រើប្រាស់វិធីសាស្ត្រនៃការបង្រៀន និងរៀនបែបរិះរកនេះទាំងស្រុងដែរ ចំណែកកម្មវិធីសិក្សាគ្រាន់តែជាកម្មវិធីសិក្សា រីឯការអនុវត្ត និងប្រើប្រាស់វិធីសាស្ត្របង្រៀនរបស់គ្រូបង្រៀននៅតែមានលក្ខណៈផ្សេងៗពីគ្នានៅឡើយ។

**ខ.ទស្សនៈយល់ឃើញរបស់ប្រធានក្រុមបច្ចេកទេសពីស្ថានភាពនៃការប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនបែបរិះរក (IBL)**

ពាក់ព័ន្ធនឹងទស្សនៈយល់ដឹងរបស់ប្រធានក្រុមបច្ចេកទេស អ្នកសិក្សាស្រាវជ្រាវបានលើកឡើងនូវសំណួរដូចជានាយក/នាយិកា នាយករង/នាយិការងផងដែរលើបញ្ហានេះ។ ដោយផ្អែកលើសំណួរខាងលើ ប្រធានក្រុមបច្ចេកទេសភាគច្រើនបានមើលឃើញ មិនសូវជាខុសពីនាយក និងនាយករងប៉ុន្មាននោះទេ។ ពួកគាត់យល់ថា ការអនុវត្ត និងការប្រើប្រាស់វិធីសាស្ត្របង្រៀននេះគឺមិនទាន់បានទូលំទូលាយនោះទេ ដោយសារតែខ្វះការបណ្តុះបណ្តាល ព្រោះមានគ្រូបង្រៀនតិចតួចតែប៉ុណ្ណោះដែលធ្លាប់បានចូលរួមវគ្គបណ្តុះបណ្តាលកន្លងមក ចំណែកលោកគ្រូអ្នកគ្រូមួយចំនួនធំទៀតមិនបានទទួលការបណ្តុះបណ្តាល និងមិនចេះប្រើប្រាស់វិធីសាស្ត្រនេះនៅឡើយ។

មួយវិញទៀត គ្រូបង្រៀនដែលមានមនសិកា មានឆន្ទៈពិតប្រាកដក្នុងការអនុវត្ត និងប្រើប្រាស់វិធីសាស្ត្របង្រៀននេះគឺមានតិចតួចបំផុត។ មូលហេតុគឺបណ្តាលមកពីខ្វះការលើកទឹកចិត្ត ដោយខ្វះទាំងផ្នែកសំភារៈសិក្សា និងថវិកាជាដើម។ ជាមួយគ្នានេះដែរ គ្រូបង្រៀនមួយចំនួនទៀតក៏បានលើកឡើងអំពីកង្វះកិច្ចសហការគ្នា រវាងគណៈគ្រប់គ្រងសាលារៀន ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនផងដែរ។ មិនត្រឹមតែប៉ុណ្ណោះ ក្រសួងអប់រំ យុវជន និងកីឡា ក៏មិនបានកំណត់យកវិធីសាស្ត្រណាមួយជាយាន្ត សម្រាប់ការរៀន និងបង្រៀនដែរ ពោលគឺក្រសួងគ្រាន់តែជម្រុង តែពុំមានការចុះបង្ហាញ និងតាមដានពីការអនុវត្ត

វិធីសាស្ត្រនេះឱ្យបានត្រឹមត្រូវនៅឡើយដែរ។ លើសពីនេះទៀតកម្មវិធីសិក្សាថ្នាក់ជាតិក៏មិនបានតម្រូវឱ្យគ្រូបង្រៀនត្រូវតែអនុវត្តការបង្រៀនសិស្សដោយប្រើប្រាស់វិធីសាស្ត្រនៃការបង្រៀន និងរៀនបែបរិះរកនោះទេ។

**គ. ទស្សនៈយល់ឃើញរបស់គ្រូបង្រៀនអំពីស្ថានភាពនៃការប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនបែបរិះរក (IBL)**

ពាក់ព័ន្ធទស្សនៈយល់ឃើញរបស់គ្រូបង្រៀនជាមួយនឹងសំណួរស្តីពីស្ថានភាណនៃការប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនបែបរិះរក។ គ្រូបង្រៀនភាគច្រើនមើលឃើញថាវាមិនខុសពីគណៈគ្រប់គ្រងសាលារៀន និងប្រធានក្រុមបច្ចេកទេសប៉ុន្មានឡើយ។ ពួកគាត់យល់ឃើញថា ការអនុវត្ត និងការប្រើប្រាស់វិធីសាស្ត្របង្រៀននេះគឺមិនទាន់ទូលំទូលាយ ដោយសារតែខ្វះការបណ្តុះបណ្តាលបន្ថែម ហើយមានគ្រូបង្រៀនតិចតួចប៉ុណ្ណោះដែលធ្លាប់បានចូលរួមក្នុងវគ្គបណ្តុះបណ្តាលកន្លងមក ហើយគ្រូបង្រៀនមួយចំនួនធំមិនចេះប្រើប្រាស់វិធីសាស្ត្រនេះទេ។

មួយវិញទៀត គ្រូបង្រៀនដែលមានមនសិកា មានឆន្ទៈពិតប្រាកដក្នុងការអនុវត្ត និងប្រើប្រាស់វិធីសាស្ត្រនេះគឺមានតិចតួច ដោយសារតែមិនមានការលើកទឹកចិត្តទាំងផ្នែកសំភារៈសិក្សា និងថវិកាជាដើម។ ចំណែកគ្រូបង្រៀនមួយចំនួនទៀតបានលើកឡើងអំពីកង្វះការសហការគ្នា រវាងគណៈគ្រប់គ្រង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនផងដែរ។ មិនត្រឹមតែប៉ុណ្ណោះ ក្រសួងអប់រំ យុវជន និងកីឡា មិនបានកំណត់វិធីសាស្ត្រមួយណាដែលល្អប្រសើរជាគេក្នុងការបង្រៀនសិស្សដែរ ពោលគឺក្រសួងគ្រាន់តែជម្រុញឱ្យប្រើប្រាស់លើវិធីសាស្ត្រនេះ តែពុំមានការចុះបង្ហាញ និងតាមដានពីការអនុវត្តវិធីសាស្ត្រនេះឱ្យបានត្រឹមត្រូវឡើយ។

លើសពីនេះ ទៀត កម្មវិធីសិក្សាថ្នាក់ជាតិក៏មិនបានតម្រូវត្រូវតែអនុវត្តការបង្រៀនសិស្សដោយប្រើប្រាស់វិធីសាស្ត្រនៃការបង្រៀន និងរៀនបែបរិះរកនោះទេ កម្មវិធីសិក្សាគ្រាន់តែជាកម្មវិធីសិក្សា រីឯការអនុវត្តរបស់គ្រូផ្សេង។

**ឃ)ការប្រៀបធៀបទស្សនៈគណៈគ្រប់គ្រង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនលើការប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនបែបរិះរក**

បើយើងប្រៀបធៀបទស្សនៈយល់ឃើញ រវាងគណៈគ្រប់គ្រងសាលា ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនពុំសូវមានលក្ខណៈខុសគ្នាប៉ុន្មានឡើយ ហើយអ្នកសិក្សាស្រាវជ្រាវក៏សង្កេបឃើញបញ្ហានេះដូចមានបង្ហាញនៅក្នុងតារាងក្រោម៖

**តារាងទី២១៖ ទស្សនៈយល់ឃើញរវាងគណៈគ្រប់គ្រងសាលា ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀន**

| គណៈគ្រប់គ្រង | ប្រធានក្រុមបច្ចេកទេស | គ្រូបង្រៀន |
|---|---|---|
| – ការប្រើប្រាស់មិនទាន់បានទូលំទូលាយ<br>– គ្រូបង្រៀនភាគច្រើនមិនចេះប្រើប្រាស់វិធីសាស្ត្រនេះទេ<br>– គ្រូបង្រៀនមួយចំនួនគ្មានឆន្ទៈក្នុងការប្រើប្រាស់<br>– កង្វះវគ្គបណ្តុះបណ្តាល<br>– ពុំមានអ្នកឯកទេសផ្នែកវិធីសាស្ត្របង្រៀនឱ្យបានច្បាស់លាស់<br>– គ្រូបង្រៀនភាគច្រើនៗធ្វើការងារទៅតាមទម្លាប់របស់ខ្លួនពីមុខៗមក | – វិធីសាស្ត្រនេះប្រើមិនបានទូលំទូលាយ<br>– កង្វះការលើកទឹកចិត្ត<br>– ភាពមិនស៊ីចង្វាក់គ្នារវាងនាយកសាលា ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀន<br>– កម្មវិធីសិក្សាមិនតម្រូវឱ្យដាច់ខាតត្រូវតែប្រើប្រាស់<br>– គ្រូបង្រៀនភាគច្រើនមិនចង់ធ្វើការស្រាវជ្រាវបន្ថែម<br>– ការប្រើប្រាស់វិធីសាស្ត្របង្រៀនច្រើនធ្វើទៅតាមទម្លាប់តៗគ្នា | – គ្រូបង្រៀនភាគច្រើនមិនចេះប្រើប្រាស់វិធីសាស្ត្រនេះទេ និងមិនបានទូលំទូលាយ<br>– ការបណ្តុះបណ្តាលបានទៅដល់តែគ្រូបង្រៀនមួយចំនួនតូចតែប៉ុណ្ណោះ<br>– គ្រូបង្រៀនដែលមានមនសិកាក្នុងការអនុវត្តវិធីសាស្ត្រនេះឱ្យបានទូលំទូលាយនិងបានប្រើតិចតួចប៉ុណ្ណោះ<br>– ក្រសួងអប់រំ យុវជន និងកីឡាមិនបានកំណត់ឱ្យប្រើតែវិធីសាស្ត្រនេះដាច់ខាតក្នុងការបង្រៀនសិស្សទេ<br>– កង្វះការលើទឹកចិត្តឱ្យប្រើប្រាស់ឱ្យបានទូលំទូលាយ |

### ៤.២.៩ ទស្សនៈយល់ឃើញលើបញ្ហាប្រឈម ក្នុងការប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនបែបរិះរករបស់គណៈគ្រប់គ្រង និងគ្រូបង្រៀន

#### ក) ទស្សនៈ និងខ្លឹមសាររួមនៃបញ្ហាប្រឈមក្នុងការប្រើប្រាស់វិធីសាស្ត្រ IBL

ការប្រើប្រាស់វិធីសាស្ត្របង្រៀនថ្មីៗតែងកើតមានបញ្ហាប្រឈម សម្រាប់គ្រូបង្រៀនជាក់ជាមិនខាន ។ ចំណែកការប្រើប្រាស់វិធីបង្រៀន និងរៀនបែបរិះរកក៏មានបញ្ហាប្រឈមកើតឡើងចំពោះគណៈគ្រប់គ្រងសាលាផងដែរ។ ហេតុនេះហើយ ទើបអ្នកសិក្សាស្រាវជ្រាវលើកជាសំណួរឡើង ដើម្បីស្វែងយល់អំពីបញ្ហាប្រឈមក្នុងការប្រើប្រាស់វិធីបង្រៀន និងរៀនបែបរិះរក(IBL)នេះ។ ចំពោះបញ្ហានេះគ្រូបង្រៀនភាគច្រើនបានលើកឡើងថា ពួកគាត់តែងជួបប្រទះបញ្ហាប្រឈមនៅក្នុងការអនុវត្ត ព្រោះតែកង្វះចំណេះដឹងមូលដ្ឋាន ទៅលើខ្លឹមសារមេរៀន ក៏ដូចជាគរុកោសល្យ ការគ្រប់គ្រងថ្នាក់រៀន និងការរៀបចំកិច្ចតែងការបង្រៀន និងការៀបចំរចនាសម្ព័ន្ធផ្សេងៗទៀតលើវិធីសាស្ត្រនេះ។ បញ្ហាទាំងនេះបានជះឥទ្ធិពលទៅលើការអនុវត្ត និងភាពជោគជ័យចំពោះការសិក្សារបស់សិស្ស។

គ្រូបង្រៀនមួយចំនួនទៀតបានត្អូញត្អែថា ពួកគាត់មិនចេះប្រើប្រាស់វិធីសាស្ត្រនេះ ហើយក៏មិនទៅសួរអ្នកណាដែរពីព្រោះមិនសូវមានអ្នកចេះ និងធ្លាប់បានប្រើប្រាស់វិធីសាស្ត្រនេះនៅក្នុងសាលារបស់គាត់។ ចំពោះគ្រូបង្រៀនមួយចំនួនផ្សេងទៀតបាននិយាយថា ពួកគាត់មានភាពស្ទាក់ស្ទើរក្នុងការប្រើប្រាស់វិធីសាស្ត្រនេះ ពីព្រោះពួកគាត់មិនសូវយល់ និងភ័យខ្លាចបង្រៀនមិនបានល្អដល់សិស្សានុសិស្ស។ រីឯគ្រូបង្រៀនមួយចំនួនទៀតបានលើកឡើងថា សិស្សរបស់គាត់មានភាពអៀនខ្មាសច្រើន ក្នុងការបញ្ចេញមតិយោបល់ សិស្សមិនសូវចូលចិត្តការងារពិភាក្សាក្រុម ហើយថ្នាក់រៀននីមួយៗមានសិស្សចម្រុះខ្លាំង ព្រមទាំងខ្វះសម្ភារៈសិក្សា ខ្វះពេលវេលាក្នុងការសិក្សាស្រាវជ្រាវផងដែរ។

តាមរយៈចម្លើយដែលទទួលបានពីគ្រូបង្រៀន គេអាចវាយតម្លៃបានថា ពួកគាត់ជួបប្រទះបញ្ហាប្រឈមធំចំនួនបីយ៉ាងគឺ៖ (១) ខ្វះចំណេះដឹងមូលដ្ឋានលើខ្លឹមសារ និងគរុកោសល្យ (២)បញ្ហាក្នុងការគ្រប់គ្រងថ្នាក់រៀន និង(៣)ពិបាករៀបចំកិច្ចតែងការបង្រៀនបែបរិះរក។

*១) ចំណេះដឹងមូលដ្ឋានលើខ្លឹមសារ និងគរុកោសល្យ៖* នៅក្នុងចំណុចនេះត្រូវបានបែងចែកចេញជាពីរផ្នែកគឺ ចំណេះដឹងលើខ្លឹមសារ និងចំណេះផ្នែកគរុកោសល្យនៃវិធីសាស្រ្តបង្រៀន និងរៀនបែបរិះរក។ ចំពោះចំណេះដឹងលើខ្លឹមសារលើការសិក្សាស្រាវជ្រាវនេះសំដៅទៅលើការយល់ដឹងស៊ីជម្រៅ លើខ្លឹមសារដែលអនុញ្ញាតឱ្យគ្រូបង្រៀនភ្ជាប់ទំនាក់ទំនង សួរសំណួរដែលបានត្រៀមទុកមួយចំនួន ការសួរសំណួរដោយមានទំនុកចិត្ត ឬសួរសំណួរដែលមានប្រសិទ្ធភាពដោយផ្អែកលើចំណេះដឹងមូលដ្ឋានអំពីខ្លឹមសារមេរៀន។

នៅក្នុងចំណុចនេះ គ្រូបង្រៀនត្រូវបានសាកសួរ ដើម្បីឱ្យរាយការណ៍អំពីទំនុកចិត្តរបស់សិស្ស ទៅលើការយល់ដឹងអំពីខ្លឹមសារដែលជាផ្នែកមួយនៃការវិភាគ។ រីឯចំណេះដឹងគរុកោសល្យបានពិចារណាទៅលើការប្រើប្រាស់វិធីសាស្រ្ត យុទ្ធសាស្រ្ត និងជំនាញរួម ដោយផ្តោតទៅលើការបង្រៀនបែបរិះរក។ ចំណេះដឹងគរុកោសល្យត្រូវបានវាស់ស្ទង់តាមរយៈកម្រងសំណួរ និងការសាកសួរផ្ទាល់មាត់ តាមទូរសព្ទដៃ អំពីបច្ចេកទេសនៃការបង្រៀន ការរៀបចំថ្នាក់រៀន ការរៀបចំសិស្សជាក្រុម ការយល់ដឹងអំពីកិច្ចតែងការបង្រៀន និងចំណេះដឹងអំពីចិត្តសាស្រ្តរបស់សិស្សានុសិស្ស ទៅតាមដំណាក់កាល និងវ័យរបស់ពួកគេផងដែរ។

*២) ការគ្រប់គ្រងថ្នាក់រៀន៖* នៅពេលសួរសំណួរ អំពីបញ្ហាប្រឈមនៃការគ្រប់គ្រងថ្នាក់រៀន លោកគ្រូអ្នកគ្រូជាច្រើនបានរាយការណ៍អំពីបញ្ហាប្រឈមដែលពួកគាត់បានជួបប្រទះ ឬបញ្ហានានាដែលរំពឹងទុកថានឹងជួបប្រទះ។ បញ្ហាប្រឈមទាំងនោះរួមមាន វិន័យ ការរក្សាសិស្សឱ្យបន្តកិច្ចការជាប្រចាំ និងការពង្រឹងឥរិយាបថរបស់សិស្ស លើការសិក្សាដូចជា ការគ្រប់គ្រងកិច្ចការ ការធ្វើផែនការ ការចាត់ចែង ការជម្រុញ និងការវាយតម្លៃការងារក្រុម។ ចំពោះបញ្ហានេះមានគ្រូបង្រៀនមួយចំនួនតូច ត្អូញត្អែអំពីបញ្ហាប្រឈមក្នុងការគ្រប់គ្រងឥរិយាបថសិស្ស និងការរក្សាសិស្សឱ្យបន្តកិច្ចការជាប្រចាំ ជាពិសេសបញ្ហាប្រឈមដែលកើតឡើងក្នុងថ្នាក់រៀនគឺដោយសាសិស្សមានចំនួនច្រើន និងលើសនិយាមកំណត់ជាដើម។

*៣) ការរៀបចំកិច្ចតែងការបង្រៀនបែបរិះរក៖* ចំពោះចំណេះដឹងពាក់ព័ន្ធនឹងការរៀបចំកិច្ចតែងការបង្រៀននេះមានគ្រូបង្រៀនមួយចំនួនធំមិនបានយល់ដឹងអំពីរបៀបរៀបចំ ឬត្រូវធ្វើកិច្ចតែងការបង្រៀន

បែបណា ដើម្បីឱ្យសមស្របតាមវិធីសាស្ត្រនៃការបង្រៀន និងរៀនបែបរិះរកនោះទេ។ ពួកគាត់មួយចំនួនមិនបានយល់ច្បាស់អំពីដំណាក់កាលនៃការរៀបចំកិច្ចតែងការបង្រៀនបែបរិះរកឡើយ។

ចំពោះដំណាក់កាលនៃការរៀបចំកិច្ចតែងការនេះរួមមាន៖ ១)ការយល់ច្បាស់ពីវត្ថុបំណងមេរៀន ២) ចេះកំណត់បញ្ហា ឬបង្កើតសម្មតិកម្មបានត្រឹមត្រូវ ៣)យល់ខ្លឹមសារមេរៀនច្បាស់លាស់ ៤)ចេះធ្វើផែនការ ឬពិសោធន៍ ៥)ចេះអង្កេត ឬវាស់វែងលទ្ធផល ៦) ចេះវិភាគឬសំយោគ និង៧) ចេះវាយតម្លៃ/បង្កើតគំនិតថ្មី។

លើសពីនេះទៅទៀត គ្រូបង្រៀនមួយចំនួនមិនយល់ពីការបង្កើតបាតុភូតឬព្រឹត្តិការណ៍សង្គមដែលពាក់ព័ន្ធជាមួយនឹងជីវភាពរស់នៅប្រចាំថ្ងៃរបស់សិស្សឡើយ។ ហេតុនេះហើយទើបពួកគាត់ទាំងអស់ស្នើសុំជំនួយ ផ្នែកបណ្តុះបណ្តាល និងឯកសារពាក់ព័ន្ធផ្សេងៗទៀត។

**ខ) ទស្សនៈអំពីបញ្ហាប្រឈមក្នុងការអនុវត្ត និងការប្រើប្រាស់ IBL**

**តារាងទី២២៖ បញ្ហាប្រឈមក្នុងការអនុវត្ត និងការប្រើប្រាស់ IBL**

| គណៈគ្រប់គ្រង | ប្រធានក្រុមបច្ចេកទេស | គ្រូបង្រៀន |
|---|---|---|
| – គ្រូភាគច្រើនមិនចេះប្រើប្រាស់វិធីសាស្ត្រនេះ<br>– ពុំមានសម្ភារៈឧបទ្ទេសគ្រប់គ្រាន់សម្រាប់គ្រូយកទៅប្រើប្រាស់<br>– សិស្សច្រើននៅក្នុងថ្នាក់រៀន<br>– បរិយាកាសថ្នាក់ពុំមានផាសុកភាព | – ខ្វះសម្ភារៈបង្រៀន និងរៀន<br>– ថ្នាក់រៀនមិនអំណោយផល<br>– សិស្សមានភាពចម្រុះ<br>– ព្រួយបារម្ភណ៍អំពីការគ្រប់គ្រងសិស្ស<br>– សិស្សពុំសូវយកចិត្តទុកដាក់ក្នុងការពិភាក្សាក្រុម<br>– សិស្សមានភាពរុញរានៅពេលឡើងធ្វើបទបង្ហាញ | – ថ្នាក់រៀនធំ កង្វះសម្ភារៈឧបទ្ទេស<br>– ថ្នាក់រៀនពុំមានផាសុកភាព<br>– មិនចេះប្រើប្រាស់វិធីសាស្ត្រ<br>– មិនដឹងសួរអ្នកណាដែលយល់ដឹងច្បាស់លាស់<br>– ពុំមានពេលសិក្សាស្រាវជ្រាវ<br>– សិស្សច្រើនក្នុងថ្នាក់រៀននីមួយៗ |

| | | |
|---|---|---|
| – ការប្រើប្រាស់វិធីសាស្ត្រតាមទម្លាប់ចាស់មានភាពងាយស្រួលជាង | | – សិស្សភាគច្រើនមានការអៀនខ្មាសក្នុងការបញ្ចេញយោបល់<br>– ព្រួយបារម្ភណ៍អំពីវិន័យសិស្សនៅពេលអនុវត្តIBL<br>– ស្ទាក់ស្ទើរខ្លាចបង្រៀនមិនបានល្អ<br>– សិស្សពុំសូវយកចិត្តទុកដាក់ពេលពិភាក្សាក្រុម |

## ៤.៣ ការពិភាក្សាលើលទ្ធផលនៃការស្រាវជ្រាវ

ឆ្លងតាមការបកស្រាយពីទស្សនៈយល់ឃើញរបស់គណៈគ្រប់គ្រងសាលារៀន ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀននៅក្នុងវិទ្យាល័យគោលដៅទាំងដប់បួននៃក្រុង/ស្រុកចំនួនប្រាំ នៃខេត្តកណ្ដាល អ្នកសិក្សាស្រាវជ្រាវទទួលបានលទ្ធផលដូចខាងក្រោម៖

### ៤.៣.១ ការពិភាក្សាលើទស្សនៈយល់ឃើញរបស់គណៈគ្រប់គ្រង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនអំពីស្ថានភាពនៃការប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនតាមបែបរិះរក

យោងតាមទិន្នន័យនៃការសិក្សាស្រាវជ្រាវបានបង្ហាញថា ទស្សនៈយល់ឃើញរបស់នាយក នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀន មានលក្ខណៈប្រហាក់ប្រហែលគ្នា។ ដូចនេះអាចធ្វើការវាយតម្លៃជារួមថា៖

ការប្រើប្រាស់វិធីសាស្ត្រនេះមិនទាន់បានទូលំទូលាយ ព្រោះគ្រូបង្រៀនចំនួន ២៩.៤០% មិនចេះប្រើប្រាស់វិធីសាស្ត្រនេះទេ ដោយសារមិនទាន់បានទទួលការបណ្តុះបណ្តាលនៅឡើយ។ ចំពោះគ្រូបង្រៀនចំនួន៧០.៦០%ទទួលការបណ្តុះបណ្តាលពីវិទ្យាស្ថានជាតិអប់រំលើវិធីសាស្ត្របង្រៀន និងរៀន

បែបរិះរក ប៉ុន្តែកង្វះការសហការរវាងគណៈគ្រប់គ្រងសាលា ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀន។ គ្រូបង្រៀនដែលមានមនសិកាក្នុងការអនុវត្តវិធីសាស្ត្រនេះមានតិចតួចប៉ុណ្ណោះ។ កម្មវិធីសិក្សាមិនបានតម្រូវឱ្យអនុវត្តទេ ដោយកង្វះការលើទឹកចិត្តឱ្យប្រើប្រាស់វិធីសាស្ត្រនេះឱ្យបានទូលំទូលាយក្នុងចំណោមសាលាទាំងនោះ

**៤.៣.២ ការពិភាក្សាពីទស្សនៈយល់ឃើញរបស់គណៈគ្រប់គ្រង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនលើបញ្ហាប្រឈមនៃការប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនតាមបែបរិះរក**

យោងតាមទិន្នន័យនៃការសិក្សាស្រាវជ្រាវបានបង្ហាញថា ទស្សនៈយល់ឃើញរបស់នាយក នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនលើបញ្ហាប្រឈមក៏មានលក្ខណៈប្រហាក់ប្រហែលគ្នាដែរក្នុងការប្រើប្រាស់វិធីសាស្ត្របង្រៀននេះ។ ហេតុនេះហើយគេអាចធ្វើការវាយតម្លៃបានថា៖

- គ្រូមួយចំនួនមិនចេះប្រើប្រាស់វិធីសាស្ត្របង្រៀននេះទេ
- កង្វះសម្ភារៈឧបទ្ទេស
- ពុំមានពេលសិក្សាស្រាវជ្រាវ
- ស្នាក់ស្ទើរខ្លាចបង្រៀនមិនបានល្អ
- មានសិស្សច្រើនក្នុងថ្នាក់រៀននីមួយៗ និងបរិយាកាសថ្នាក់រៀនពុំមានផាសុកភាព
- សិស្សពុំសូវចូលរួមក្នុងការពិភាក្សាក្រុម ដោយសារសិស្សភាគច្រើនមានការអៀនខ្មាសក្នុងការបញ្ចេញមតិយោបល់
- សិស្សមានលក្ខណៈចម្រុះខ្លាំង
- ព្រួយបារម្ភណ៍អំពីវិន័យសិស្សនៅពេលអនុវត្តIBL និងមិនដឹងសួរអ្នកណា នៅពេលបង្រៀនវិធីសាស្ត្រ IBL មិនកើត ឬមិនបានល្អ

សរុបសេចក្តីមក ទស្សនៈយល់ឃើញរបស់គណៈគ្រប់គ្រង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនពីការប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនបែបរិះរកនៅសាលាមធ្យមសិក្សាទុតិយភូមិ នៅក្នុងចំណោមសាលាគោលដៅទាំង១៤ នៃខេត្តកណ្តាល មានលក្ខណៈសមស្របជាមួយព្រឹត្តិបត្រស្រាវជ្រាវរបស់វិទ្យាស្ថាន

ជាតិអប់រំ ដែលរៀបចំដោយ លោក នី សុពុទ្ធី លោកស្រី ខែក សំណាង លោក នី រដ្ឋា លោកស្រី ឈូក ណាស្រស់ និងលោកស្រីប៊ុន សុផានី ក្រោមប្រធានបទ «ការអនុវត្ត និងការលើកទឹកចិត្ត ចំពោះវិធីសាស្ត្របង្រៀន និងរៀនតាមបែបរិះរក (IBL) របស់គ្រូវិទ្យាសាស្ត្រនៅវិទ្យាល័យក្នុងប្រទេសកម្ពុជា» ឆ្នាំសិក្សា ២០១៩-២០២០។ ព្រឹត្តិបត្រស្រាវជ្រាវនោះបានលើកឡើងថា «*ការស្រាវជ្រាវនេះបានរកឃើញថា មានគ្រូតែ៤២%ប៉ុណ្ណោះធ្លាប់បានអនុវត្តវិធីសាស្ត្របង្រៀនបែបIBL ហើយការអនុវត្តIBLរបស់គ្រូបង្រៀននៅជួបបញ្ហាប្រឈមជាច្រើន ដោយក្នុងនោះរួមមានដូចជា ពេលវេលាក្នុងការរៀបចំ កង្វះខាតសម្ភារបង្រៀន សមត្ថភាពលើវិធីសាស្ត្របង្រៀន និងសមត្ថភាពសិស្សនៅមានកម្រិត ដែលទាមទារនូវការលើកទឹកចិត្តខ្ពស់ និងជួយជ្រោមជ្រែងបន្ថែមទៀត។ ជាមួយគ្នានេះដែរ ការផ្ដល់អត្ថប្រយោជន៍ ឬលើកទឹកចិត្តគ្រូបង្រៀន ក្រៅពីប្រាក់បៀវត្សប្រចាំខែ ដូចជាទទួលបានប្រាក់ម៉ោងលើស ទទួលបានលិខិតសរសើរពីសាលា ទទួលបានការកោតសរសើរនៅក្នុងអង្គប្រជុំ ការជប់លៀងបន្តិចបន្តួចរួមគ្នា ដំណើរកំសាន្តរួមគ្នា ឬការផ្ដល់ឱកាសចូលរួមវគ្គបំប៉ន ឬសិក្ខាសាលាគឺ ជាសកម្មភាពលើកទឹកដែលគ្រូបង្រៀន និងនាយកសាលាធ្លាប់បានផ្ដល់ឱ្យនាពេលកន្លងមក។*»

# ជំពូកទី៥

# សេចក្តីសន្និដ្ឋាន និងសំណូមពរ

# ជំពូកទី៥៖ សេចក្ដីសន្និដ្ឋាន និងសំណូមពរ

## ៥.១ សេចក្ដីសន្និដ្ឋាន

ឆ្លងតាមទិន្នន័យដែលបានមកពីការវិភាគ លើកម្រងសំណួរទាក់ទងទៅនឹងគោលគំនិតសំខាន់ៗរបស់ប្រធានបទស្ដីពី «ទស្សនៈគណៈគ្រប់គ្រង ប្រធានក្រុមបច្ចេកទស និងគ្រូបង្រៀនពីការប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនបែបវិះរក នៅសាលាមធ្យមសិក្សាទុតិភូមិ» ដែលបានជ្រើសរើសខេត្តកណ្ដាលជាភាគសំណាកនេះ និងតាមរយៈកម្រងសំណួរ ដែលបានចោទសួរនៅតាមសាលាគោលដៅទាំង១៤ នៃក្រុង/ស្រុកចំនួន៥ នាំឱ្យអ្នកសិក្សាស្រាវជ្រាវផ្ដោតលើសេចក្ដីសន្និដ្ឋានមួយចំនួនដូចខាងក្រោម៖

### ៥.១.១ ទស្សនៈយល់ឃើញលើអត្ថន័យនៃវិធីសាស្ត្របង្រៀន

ត្រង់ចំណុចនេះឃើញថា អ្នកសិក្សាស្រាវជ្រាវអាចធ្វើការសន្និដ្ឋានអំពីទស្សនៈយល់ឃើញរបស់នាយកសាលា នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនថា ទស្សនៈយល់ឃើញរបស់ពួកគាត់មានភាពខុសគ្នាពាក់ព័ន្ធជាមួយនឹងអត្ថន័យនៃបញ្ញត្តិ«**វិធីសាស្ត្របង្រៀន**» មានចំនួន42.20% ខ្ពស់ជាងគេ និងទាបបំផុតមានចំនួន11.30%។

ក្នុងចំណោមនាយក នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនចំនួន 42.20% យល់ឃើញថា «**វិធីសាស្ត្របង្រៀន**» គឺជាជាលក្ខណៈនៃសំណុំគោលការណ៍ និតិវិធី ឬយុទ្ធសាស្ត្រ អនុវត្តដោយគ្រូបង្រៀន ដើម្បីសម្រេចការសិក្សាមួយសមស្របតាមបំណង និងសេចក្ដីប្រាថ្នារបស់សិស្ស។ រីឯចំនួននាយក នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនចំនួន ១១.៣០% យល់ឃើញថា «**វិធីសាស្ត្របង្រៀន**» គឺជាប្រព័ន្ធនៃសកម្មភាពជាបន្តបន្ទាប់ និងមានសណ្ដាប់ធ្នាប់របស់គ្រូបង្រៀន។

តាមលក្ខខណ្ឌខាងលើនេះ អ្នកសិក្សាស្រាវជ្រាវអាចសន្និដ្ឋានបានថា អត្ថន័យសំខាន់ជាងគេនៃពាក្យថា «**វិធីសាស្ត្របង្រៀន**» គឺជាជាលក្ខណៈនៃសំណុំគោលការណ៍ និតិវិធី ឬយុទ្ធសាស្ត្រ ដែលអនុវត្តដោយគ្រូបង្រៀន ក្នុងគោលបំណងធ្វើឱ្យសម្រេចការសិក្សាមួយសមស្របតាមការចង់បានរបស់សិស្ស។

### ៥.១.២ ទស្សនៈយល់ឃើញលើអត្ថន័យនៃវិធីសាស្ត្របង្រៀ និងរៀនបែបវិះរក

នៅត្រង់ចំណុចនេះអ្នកសិក្សាស្រាវជ្រាវសង្កេតឃើញថា ទស្សនៈយល់ឃើញរបស់នាយកសាលា នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនអំពី «**វិធីសាស្ត្របង្រៀន និងរៀនបែបរិះរក**» បានបង្ហាញឱ្យឃើញថាមិនសូវមានភាពខុសគ្នាប៉ុន្មាននោះទេ ពីព្រោះចំនួននាយកសាលា នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនបានចូលរួមផ្តល់ចម្លើយលើបញ្ហានេះមានអត្រាភាគរយខ្ពស់បំផុតគឺ 15.1% និងទាបបំផុតគឺ 0.6%។ តែទោះបីជាយ៉ាងនេះក៏ដោយ គ្រូបង្រៀនភាគច្រើនយល់ឃើញថា វិធីសាស្ត្របង្រៀន និងរៀនបែបរិះរកគឺជាវិធីសាស្ត្រមួយល្អ ព្រោះសិស្សានុសិស្សរៀនតាមរយៈសំណួរស្រាវជ្រាវ ជាការរៀនតាមបែបសហការ ធ្វើការងារជាក្រុម និងសិស្សធ្វើការស្រាវជ្រាវដោយខ្លួនឯង ប៉ុន្តែក៏មានគ្រូបង្រៀនមួយចំនួនយល់ច្រឡំអំពីអត្ថន័យនៃវិធីសាស្ត្រនៃការបង្រៀន និងរៀនបែបរិះរកផងដែរ ព្រោះពួកគាត់យល់ឃើញថា វិធីសាស្ត្របង្រៀន និងរៀនតាមបែបរិះរកគឺជាវិធីសាស្ត្រមួយដែលគ្រូបង្រៀនជាអ្នកអនុវត្ត ហើយសិស្សចាំតែធ្វើតាម។ ហេតុនេះហើយ វាមិនមានភាពខុសគ្នាប៉ុន្មាននោះទេ ពោលគឺវាមានលក្ខណៈដូចជាវិធីសាស្ត្រផ្សេងទៀតដែរ។

### ៥.១.៣ ទស្សនៈយល់ឃើញលើការអភិវឌ្ឍជំនាញនៅក្នុងវិធីសាស្ត្របង្រៀន និងរៀនបែបរិះរក

បើផ្អែកតាមទស្សនៈរបស់នាយក នាយករង/នាយិការង ប្រធានបច្ចេកទេស និងគ្រូបង្រៀនពាក់ព័ន្ធជាមួយនឹងចំណុចអភិវឌ្ឍជំនាញក្នុងវិធីសាស្ត្របង្រៀន និងរៀនបែបរិះរកសម្រាប់សិស្សានុសិស្សដែលសំខាន់ជាងគេគឺអភិវឌ្ឍជំនាញផ្នែកដោះស្រាយបញ្ហា ជំនាញក្នុងការគិតស៊ីជម្រៅ ជំនាញស្រាវជ្រាវជំនាញទំនាក់ទំង និងជំនាញក្នុងការធ្វើផែនការ។ តែទោះបីជាយ៉ាងណាក៏ដោយ នាយក នាយករង/នាយិការង ប្រធានបច្ចេកទេស និងគ្រូបង្រៀនក៏បានជ្រើសរើសជំនាញបន្ថែមផ្សេងៗទៀតផងដែរ។ ជំនាញទាំងនោះមានដូចជា ជំនាញក្នុងការធ្វើផែនការ ឬការស្រាវជ្រាវ បង្កើតភាពម្ចាស់ការ ទំនាក់ទំនង សហការ ឬការធ្វើការក្រុម លើកកម្ពស់ការរៀនតាមបែបស្រាវជ្រាវ តាមរយៈវិភាគ វាយតម្លៃ និងសន្និដ្ឋានដោយសិស្សខ្លួនឯង។

### ៥.១.៤ ទស្សនៈយល់ឃើញអំពីជំហាននៃការប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនបែបរិះរក

តាមទស្សនៈរបស់នាយក នាយករង/នាយិការង ប្រធានបច្ចេកទេស និងគ្រូបង្រៀនពាក់ព័ន្ធជាមួយជំហានទាំង៥នៃការប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនបែបរិះរកគឺពួកគាត់ឱ្យតម្លៃទៅលើជំហាននីមួយៗមិនដូចគ្នាគ្នា។ នៅក្នុងជំហានទី១ស្តីពីការបង្កើតបាតុភូតមានចំនួន 13.6%។ នៅក្នុងជំហានទី២ស្តីពីការកំណត់វត្ថុបំណងឬបញ្ហាមាន 25.6%។ នៅក្នុងជំហានទី៣ស្តីពីការបង្កើតសំណួរគន្លឹះឬសម្មតិកម្មមានចំនួន 25.1%។ នៅក្នុងជំហានទី៤ស្តីពីការធ្វើផែនការឬប្រមូលទិន្នន័យមានចំនួន15.0% និងនៅក្នុងជំហានទី៥ស្តីពីការវិភាគទិន្នន័យឬទាញសេចក្តីសន្និដ្ឋានមានចំនួន20.8%។ នៅក្នុងចំណោមជំហានទាំង៥នេះ ជំហានដែលសំខាន់ជាងគេគឺ ការកំណត់វត្ថុបំណងឬបញ្ហាមានចំនួន 25.6%ខ្ពស់ជាងគេ។

តាមរយៈការកំណត់ និងជ្រើសរើសជំហានដូចបានជម្រាបជូនខាងលើអាចបញ្ជាក់បានថា នាយក នាយករង/នាយិការង ប្រធានបច្ចេកទេស និងគ្រូបង្រៀនមានការយល់ដឹងខ្ពស់អំពីរបៀបនៃការប្រើប្រាស់វិធីសាស្ត្របង្រៀន និងបែបរិះរកនេះ។

**៥.១.៥ ទស្សនៈយល់ឃើញលើដំណើរការបង្រៀន ប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនបែបរិះរក**

ការសិក្សាស្រាវជ្រាវដែលបានធ្វើឡើងតាមរយៈកម្រងសំណួរ ជាមួយនាយក នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀន ដែលប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនបែបរិះរក។ ដំណើរការបង្រៀនទាំងនោះផ្អែកលើ ការបង្កើតបាតុភូត ឬព្រឹត្តិការណ៍ ការបង្កើតសំណួរគន្លឹះ ការធ្វើផែនការប្រមូលទិន្នន័យ តេស្តសម្មតិកម្ម ឬធ្វើពិសោធន៍ និងវិភាគឬទាញសេចក្តីសន្និដ្ឋាន។ ដោយឡែកការរៀបចំក្រុមក៏ត្រូវបានគេចាត់ទុកថាស្ថិតនៅក្នុងដំណើរការនៃការបង្រៀន និងរៀនតាមបែបរិះរកផងដែរ ពីព្រោះគ្រូបង្រៀនត្រូវយល់ដឹងឱ្យបានច្បាស់លាស់អំពីការរៀបចំក្រុមដែលមានលក្ខណៈត្រឹមត្រូវ និងអាចឱ្យគ្រប់គ្នាទទួលបានឱកាសរៀនសូត្រស្មើៗគ្នា និងដូចៗគ្នា។

ចំពោះការរៀបចំក្រុមពិភក្សាបានត្រឹមត្រូវគឺត្រូវមានលក្ខណៈចម្រុះគ្នាពោលគឺត្រូវដាក់សិស្សលាយបញ្ចូលគ្នា ដោយឱ្យសិស្សខ្សោយចូលក្រុមជាមួយសិស្សមធ្យម សិស្សដែលមាននិទ្ទេសល្អបង្គួរ សិស្សដែលមាននិទ្ទេសល្អ និងសិស្សដែលមាននិទ្ទេសល្អណាស់ជាដើម។

### ៥.១.៦ ទស្សនៈយល់ឃើញលើការរៀបចំកិច្ចតែងការបង្រៀនក្នុងវិធីសាស្ត្របង្រៀន និងរៀនបែបរិះរក

បើផ្អែកតាមទស្សនៈ និងការយល់ឃើញរបស់នាយក នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀន។ ដើម្បីរៀបចំកិច្ចតែងការបង្រៀនមួយបានល្អប្រសើរគឺ ត្រូវមានសមាសធាតុចូលរួមមួយចំនួនដូចជា៖ ត្រូវយល់ដឹងខ្លឹមសារមេរៀន យល់ដឹងពីវត្ថុបំណងមេរៀន យល់ដឹងពីសមត្ថភាពចំណេះដឹងរបស់សិស្ស យល់ដឹងរបៀបប្រើប្រាស់ជំហានទាំង៥របស់IBL យល់ដឹងរបៀបរៀបចំសិស្សជាក្រុម យល់ដឹងបាតុភូត ឬព្រឹត្តិការណ៍សង្គមក្នុងការបង្កើតសំណួរគន្លឹះ និងត្រូវយល់ពីបាតុភូត ឬព្រឹត្តិការណ៍សង្គមទាក់ទងជីវភាពរស់នៅប្រចាំថ្ងៃរបស់សិស្ស។

ទោះបីជាយ៉ាងណាក៏ដោយ នាយកសាលា នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនបានឱ្យតម្លៃផ្សេងៗគ្នាទៅតាមការយល់ឃើញរបស់ខ្លួនលើបញ្ហានេះ។ ការយល់ដឹងខ្លឹមសារមេរៀនមានចំនួន 17.8% ការយល់ដឹងពីវត្ថុបំណងមេរៀនមាន19.1% ការយល់ដឹងសមត្ថភាពចំណេះដឹងសិស្សមាន12.9% ការយល់ដឹងរបៀបប្រើប្រាស់ជំហានទាំង៥របស់IBLមាន18.1% ការយល់ដឹងរបៀបរៀបចំសិស្សជាក្រុមមានចំនួន12.1% ការយល់ដឹងពីបាតុភូត ឬព្រឹត្តិការណ៍សង្គមក្នុងការបង្កើតសំណួរគន្លឹះមានចំនួន 10.7% និងត្រូវយល់ពីបាតុភូត ឬព្រឹត្តិការណ៍សង្គមទាក់ទងជាមួយជីវភាពរស់នៅប្រចាំថ្ងៃរបស់សិស្សមានចំនួន 9.3%។

### ៥.១.៧ ទស្សនៈយល់ឃើញពីសារៈសំខាន់នៃវិធីសាស្ត្របង្រៀន និងរៀនបែបរិះរក

វិធីសាស្ត្របង្រៀនមានសារៈសំខាន់ណាស់ចំពោះគ្រូបង្រៀនសម្រាប់យកទៅប្រើប្រាស់ ឬអនុវត្តជាមួយសិស្សានុសិស្សផ្ទាល់។ សារៈសំខាន់នៃការប្រើប្រាស់វិធីសាស្ត្របង្រៀនទាំងនោះមានដូចជា ១)ត្រូវយល់ដឹងអំពីសកម្មភាពដែលត្រូវបង្រៀន ២)ត្រូវយល់ដឹងអំពីរបៀបនៃការបង្រៀនចំពោះមុខវិជ្ជាផ្សេងៗគ្នា ផ្លាស់ប្តូរបច្ចេកទេសតាមដំណាក់កាលនៃសកម្មភាព ៣)ត្រូវយល់ដឹងអំពីមធ្យោបាយមានប្រសិទ្ធភាពក្នុងការផ្តល់ព័ត៌មាន ៤)ជួយគ្រូបង្រៀនក្នុងការប្រមើលមើលទៅលើកម្មវិធីសិក្សាទាំងមូល ៥)ត្រូយល់ដឹង

បាតុភូត/ព្រឹត្តិការណ៍សង្គមក្នុងការបង្កើតសំណួរគន្លឹះ ៦ )ត្រូវដឹងអំពីលំនាំនៃការរៀន និងបង្រៀន ៧ )មានភាពងាយស្រួលក្នុងការរៀបចំកិច្ចតែងការបង្រៀន និងអាចសម្រេចវត្ថុបំណងមេរៀនបាន។

### ៥.១.៨ ទស្សនៈយល់ឃើញពីស្ថានភាពនៃការប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនបែបរិះរក

តាមរយៈកម្រងសំណួរដែលបានដាក់ជូន នាយក នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនបំពេញ អំពីស្ថានភាពនៃការប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនបែបរិះរក ពួកគាត់បានបង្ហាញការយល់ឃើញរបស់ខ្លួនដូចមាននៅក្នុងកថាខណ្ឌខាងក្រោម៖

- ការប្រើប្រាស់វិធីសាស្ត្រនេះមិនទាន់បានទូលំទូលាយ
- គ្រូបង្រៀនភាគច្រើនមិនចេះប្រើប្រាស់វិធីសាស្ត្របង្រៀននេះទេ
- គ្រូបង្រៀនមួយចំនួនគ្មានឆន្ទៈក្នុងការប្រើប្រាស់វិធីសាស្ត្របង្រៀននេះទេ
- កង្វះវគ្គបណ្តុះបណ្តាលលើការប្រើប្រាស់វិធីសាស្ត្របង្រៀននេះ
- ពុំមានអ្នកឯកទេសផ្នែកវិធីសាស្ត្របង្រៀន និងរៀនឱ្យបានច្បាស់លាស់
- គ្រូបង្រៀនភាគច្រើនធ្វើការងារទៅតាមទម្លាប់របស់ខ្លួនពីមុខមក និងធ្វើតៗគ្នា

### ៥.១.៩ ទស្សនៈយល់ឃើញលើបញ្ហាប្រឈមនៃការប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនបែបរិះរក

តាមរយៈកម្រងសំណួរដែលបានដាក់ឱ្យ នាយក នាយករង/នាយិការង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនបំពេញអំពី **បញ្ហាប្រឈមក្នុងការប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនបែបរិះរកនេះ** ពួកគាត់បានបង្ហាញនូវទស្សនៈផ្ទាល់ខ្លួនថា៖

- កង្វះសម្ភារៈបង្រៀន និងរៀន
- ថ្នាក់រៀនមិនអំណោយផល និងសិស្សមានភាពចម្រុះ
- ព្រួយបារម្ភណ៍អំពីការគ្រប់គ្រងសិស្ស
- សិស្សពុំសូវយកចិត្តទុកដាក់ក្នុងការពិភាក្សាក្រុម
- សិស្សមានភាពរុញរានៅពេលឡើងធ្វើបទបង្ហាញ

## ៥.២ សំណូមពរ

### ៥.២.១ សាលារៀន

- សូមពិនិត្យតាមដានចំពោះគ្រូបង្រៀនដែលអសកម្ម អវត្តមានច្រើនដង និងត្រូវចាត់វិធានការតាមនិតិវិធីរដ្ឋបាលឱ្យបានសមស្រប និងមានប្រសិទ្ធភាព និងអាចទទួលយកបាន
- សូមពិនិត្យតាមដានចំពោះប្រធានក្រុមបច្ចេកទេស ដែលបានចូលរួមវគ្គបណ្ដុះបណ្ដាលក្រោមការរៀបចំរបស់វិទ្យាស្ថានជាតិអប់រំ ស្ដីពីវិធីសាស្ត្របង្រៀន និងរៀនបែបរិះរកនេះដែលមិនបានផ្សព្វផ្សាយបន្តដល់គ្រូបង្រៀនដទៃទៀត
- សូមពិនិត្យតាមដាន ការអនុវត្ត និងប្រើប្រាស់វិធីសាស្ត្របង្រៀនរបស់ប្រធានក្រុមបច្ចេកទេសថាបានចែករំលែកដល់គ្រូបង្រៀននៅក្នុងសាលារៀនមានប្រសិទ្ធភាពកម្រិតណា
- ប្រធានក្រុមបច្ចេកទេសត្រូវពិនិត្យទៅលើសមាជិកក្រុមរបស់ខ្លួន ទៅតាមថ្នាក់នីមួយៗជាប្រចាំអំពីការងារបង្រៀនរបស់ពួកគាត់ និងត្រូវកែលម្អរចំណុចខ្វះខាត និងដោះស្រាយបញ្ហាប្រឈមនានាដែលរាំងស្ទះដល់ការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនបែបរិះ ដើម្បីឱ្យវាប្រព្រឹត្តិទៅបានដោយរលូន
- បង្កើតឱ្យមានថ្នាក់និទស្សន៍ឱ្យទៀងទាត់ក្នុងឆ្នាំសិក្សានីមួយៗ
- ពិនិត្យមើលទៅលើការប្រើប្រាស់សម្ភារឧបទេសរបស់គ្រូបង្រៀន
- ពិនិត្យមើលទៅលើការពង្រឹងវិន័យ សណ្ដាប់ធ្នាប់គ្រូ និងសិស្ស
- គណៈគ្រប់គ្រងបែងចែកកាលវិភាគដល់បុគ្គលិកបង្រៀនឱ្យមានតម្លាភាព និងស្របតាមឯកទេស និងគុណវុឌ្ឍរបស់គ្រូបង្រៀន
- ពិនិត្យតាមដានទៅលើដំណើរការបង្រៀន និងរៀន ដោយប្រើប្រាស់កិច្ចតែងការបង្រៀនឱ្យបានខ្ជាប់ខ្ជួន និងស្របតាមវិធីសាស្ត្របង្រៀន និងរៀនបែបរិះរក
- ការរៀបចំប្រជុំបច្ចេកទស ដោយតម្រូវឱ្យមានការដោះស្រាយបញ្ហា និងចម្ងល់នានាពាក់ព័ន្ធនឹងបច្ចេកទេសនៃការបង្រៀន និងរៀនឱ្យមានប្រសិទ្ធភាពខ្ពស់

- រៀបចំសម្ភារៈឧបទេសសម្រាប់ដំណើរការបង្រៀន និងរៀនឱ្យបានគ្រប់មុខវិជ្ជា
- គួរជម្រុញ និងទឹកចិត្តសិស្សានុសិស្សឱ្យចូលរួមសិក្សាឱ្យបានទៀងទាត់

### ៥.២.២ ក្រសួងអប់រំ យុវជន និងកីឡា

- សូមបើកវគ្គបណ្តុះបណ្តាលស្តីពីវិធីសាស្ត្របង្រៀ និងរៀនបែបរិះរកឱ្យបានគ្រប់សាលារៀន
- សូមពង្រឹងគោលការណ៍ សកម្មភាពអធិការកិច្ចផ្ទៃក្នុង និងផ្ទៃក្រៅឱ្យបានច្បាស់លាស់ទាក់ទងជាមួយវិធីសាស្ត្របង្រៀ និងរៀនបែបរិះរកនេះ
- ស្នើសុំកុំព្យូទ័រប្រើប្រាស់ឱ្យបានគ្រប់គ្រាន់ដើម្បីគាំទ្រដំណើរការបង្រៀ និងរៀនបែបរិះរក
- សូមរៀបចំបោះពុម្ពសៀវភៅវិធីសាស្ត្រនៃការបង្រៀន និងរៀនបែបរិះរក រួចបន្តផ្សព្វផ្សាយទៅដល់វិទ្យាល័យនានានៅក្នុងខេត្ត និងនៅក្នុងក្របខ័ណ្ឌទូទាំងប្រទេស
- សូមបណ្តុះបណ្តាលគ្រូឧទ្ទេសថ្នាក់ជាតិ ថ្នាក់ខេត្ត និងគ្រូឧទ្ទេសប្រចាំសាលាសម្រាប់ពង្រឹងវិធីសាស្ត្របង្រៀន និងរៀនបែបរិះរក
- សូមផ្សព្វផ្សាយការបង្រៀន និងរៀនតាមប្រព័ន្ធអេឡិចត្រូនិកដល់លោកគ្រូ/អ្នកគ្រូដែលមិនទាន់ចេះប្រើប្រាស់វិធីសាស្ត្របង្រៀ និងរៀនបែបរិះរកឱ្យបានទូលំទូលាយ
- វិទ្យាស្ថានជាតិអប់រំគួរតែបន្តយន្តការតាមដាន លើការអនុវត្តវិធីសាស្ត្របង្រៀន និងរៀនបែបរិះរក ដែលស្ថិតនៅក្នុងដែនសមត្ថកិច្ច និងការបណ្តុះបណ្តាលរបស់ខ្លួនឱ្យបានទៀតទាត់
- សូមរៀបចំឱ្យមានការប្រឡងប្រណាំង និងប្រគួទប្រជែង **«ការបង្រៀនល្អ»** ដើម្បីលើកទឹកចិត្តដល់គ្រូបង្រៀនដែលមានស្នារតីខ្ពស់ក្នុងមុខវិជ្ជាជីវៈរបស់ខ្លួន

### ៥.២.៣ មន្ទីរអប់រំ យុវជន និងកីឡាខេត្ត និងការិយាល័យអប់រំ យុវជន និងកីឡាស្រុក

- សូមចូលរួមអនុវត្តអធិការកិច្ចផ្ទៃក្នុងដោយយកចិត្តទុក ដើម្បីជួយពង្រឹងការរៀន និងបង្រៀនកាន់តែមានប្រសិទ្ធភាព និងគុណភាពទាក់ទងជាមួយវិធីសាស្ត្របង្រៀ និងរៀនបែបរិះរក
- សូមវាយតម្លៃលើការងារអធិការកិច្ចផ្ទៃក្នុង រកឱ្យឃើញនូវចំណុចខ្វះខាត ដើម្បីកែលម្អឱ្យមានប្រសិទ្ធភាព

- សូមបើកវគ្គបំប៉នលើការប្រើប្រាស់«វិធីសាស្ត្របង្រៀន និងរៀនបែបរិះរក»ដល់សាលានានាក្នុងដែនសមត្ថកិច្ចរបស់ខ្លួនឱ្យបានញឹកញាប់ក្នុងឆ្នាំសិក្សានីមួយៗ

### ៥.២.៤ សំណូមពរសម្រាប់អ្នកសិក្សាជំនាន់ក្រោយៗ

ការសិក្សាស្រាវជ្រាវលើប្រធានបទស្តីពី «ទស្សនៈគណៈគ្រប់គ្រង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនលើការប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនបែបរិះរកនៅសាលាមធ្យមសិក្សាទុតិយភូមិ» ដែលជ្រើសរើសខេត្តកណ្តាលជាភាគសំណាកនេះគឺមិនទាន់មានលក្ខណៈគ្រប់ជ្រុងជ្រោយនៅឡើយទេ ពីព្រោះការសិក្សានេះធ្វើឡើងតែនៅក្នុងក្រុង/ស្រុកចំនួន៥នៃខេត្តកណ្តាលប៉ុណ្ណោះ។

ហេតុនេះហើយ ទើបលទ្ធផលនៃការសិក្សាស្រាវជ្រាវនេះមិនអាចធ្វើការឆ្លុះបញ្ចាំងបានពីស្ថានភាពជាក់ស្តែង និងគ្របដណ្តប់ទាំងស្រុងទូទាំងខេត្ត និងទូទាំងប្រទេសកម្ពុជាបាននោះទេ។ ម្យ៉ាងវិញទៀត អ្នកសិក្សាស្រាវជ្រាវបានផ្តោតតែទៅលើវិធីសាស្ត្របង្រៀន និងរៀនបែបរិះរកប៉ុណ្ណោះ។ ដោយសារមូលហេតុដូចនេះហើយ ទើបអ្នកសិក្សាស្រាវជ្រាវទាមទារ និងសំណូមពរដល់អ្នកសិក្សាក្រោយៗ សូមបន្តពង្រីកភាគសំណាក និងធ្វើការស្រាវជ្រាវលើប្រធានបទនេះឱ្យកាន់តែមានលក្ខណៈជាក់លាក់ និងសុក្រឹត្យថែមទៀត។

# ឯកសារយោង

## ក. ឯកសារជាភាសាខ្មែរ


ក្រសួងអប់រំ យុវជន និងកីឡា (១៩៩៨) *ប្រវត្តិក្រសួងអប់រំ យុវជន និងកីឡា ផ្នែកទី១ និងទី២. ភ្នំពេញ*

ក្រសួងអប់រំ យុវជន និងកីឡា (២០១៣) *គោលនយោបាយស្តីពីគ្រូបង្រៀន . ភ្នំពេញ*

ក្រសួងអប់រំ យុវជន និងកីឡា(២០១៥)*ផែនការគោលស្តីពីការអភិវឌ្ឍសមត្ថភាពក្នុងវិស័យអប់រំឆ្នាំ២០១៤-២០១៨. ភ្នំពេញ*

ក្រសួងអប់រំ យុវជន និងកីឡា(២០១៦)*ផែនការសកម្មភាពស្តីពីធនធានមនុស្សក្នុងវិស័យអប់រំ. ភ្នំពេញ*

ក្រសួងអប់រំ យុវជន និងកីឡា (២០១៨) *ក្របខណ្ឌគន្លងអាជីពគ្រូបង្រៀន. ភ្នំពេញ*

ក្រសួងអប់រំ យុវជន និងកីឡា (២០២០) *ព្រឹត្តិបត្រស្រាវជ្រាវអប់រំរបស់វិទ្យាស្ថានជាតិអប់រំ ឆ្នាំសិក្សា ២០១៩-២០២០*

ជួន ណាត (២០០៨) *វចនានុក្រមសម្តេចព្រះសង្ឃរាជ្យ, បោះពុម្ពដោយពុទ្ធសាសនបណ្ឌិត,២០០៨*

បណ្ឌិត នី រដ្ឋា, ២០២១ *«តួនាទី និងភារកិច្ចរបស់នាយកសាលា» នៅក្នុងមុខវិជ្ជា៖ ការគ្រប់ការបំពេញភារកិច្ចក្នុងសាលារៀន*

ប៉ូ ប៊ុន្នន  ឡុច ចាន់ថន និងឃិន វណ្ណី (២០១៩-២០២០) *វិធីសាស្ត្របង្រៀន, វិទ្យាស្ថានជាតិអប់រំ*

រាជរដ្ឋាភិបាលកម្ពុជា (២០១៨) *យុទ្ធសាស្ត្រចតុកោលដំណាក់កាលទី៥ ២០១៨-២០២៣. ភ្នំពេញ*

វិទ្យាស្ថានជាតិអប់រំ (២០២០) *ស្ថិតិការចូលរួមវគ្គបណ្តុះបណ្តាលរបស់លោកគ្រូ/អ្នកគ្រូតាមសាលាមធ្យមសិក្សានីមួយៗផ្តល់*

ឡុច ចាន់ថន, ឃិន វណ្ណី(២០២១) *ទស្សនវិជ្ជាអប់រំ, គ្រឹះស្ថានបោះពុម្ព៖ ឡឹក ជំនោរ,ភ្នំពេញ*

## ខ.ឯកសារជាភាសាបរទេស

Alain, G. ( 2019 ) Journal of Inquiry & Action in Education ( Inquiry-Based Learning: Student

Ian C. B ( 2014 ) Simplifying Inquiry Instruction

Great School Partnership ( 2021 ) *The Glossary of Education Reform*

Lena Ballone, D. ( 2004 ) *The 5Es Instructional Model: A Learning Cycle Approach for Inquiry-Base Science Teaching*

Oxford Advanced Learner. ( 2020 ) English Dictionary

Rita Mei-Ching, Ng. ( 2009 ) Journal of College and Character: What did Confucius Teach ?

Rajagopalan, I. ( 2019 ) *International Journal of Education* ( Concept of Teaching ).

Samuel, W ( 2017 ) *Essential Teaching Methods for Education and Behavioral*

Sharon, F. *( 2015 ) Focus on Inquiry*

Teacher's Challenges and Perceptions.

William, U. ( 2000 ) *Anatomy of a Crisis, Education, Development, and the State in Cambodia, 1953-1998*

# ឧបសម្ព័ន្ធ
## កម្រងសំណួរ

សម្រាប់គណៈគ្រប់គ្រង ប្រធានក្រុមបច្ចេកទេស គ្រូបង្រៀន

ខ្ញុំបាទឈ្មោះ ធឿង យន ជានិស្សិតបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៃវិទ្យាស្ថានជាតិអប់រំ។ ខ្ញុំបាទធ្វើការស្រាវជ្រាវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់លើប្រធានៈ «ទស្សនៈគណៈគ្រប់គ្រង ប្រធានក្រុមបច្ចេកទេស និងគ្រូបង្រៀនស្តីការប្រើប្រាស់វិធីបង្រៀន និងរៀនបែបរិះរក នៅសាលាមធ្យមសិក្សាទុតិយភូមិក្នុងខេត្តកណ្តាល»។

ដូចបានជម្រាបជូនខាងលើ សូមគ្រូបង្រៀន ជួយផ្តល់ចម្លើយ កម្រងសំណួរស្រាវជ្រាវនេះ ដើម្បីឈ្វេងយល់ពីស្ថានភាពនៃការប្រើប្រាស់វិធីសាស្ត្របង្រៀន និងរៀនបែបរិះរក ដែលបណ្តុះបណ្តាលដោយវិទ្យាស្ថានជាតិអប់រំ ក្នុងគោលបំណងលើកកម្ពស់ការប្រើប្រាស់វិធីសាស្ត្របង្រៀននេះ និងអភិវឌ្ឍការអប់រំនៅក្នុងប្រទេសកម្ពុជា។

សូមលោក-លោកស្រីជួយផ្តល់ចម្លើយតាមស្ថានភាពពិតជាក់ស្តែង ហើយរាល់ចម្លើយរបស់លោក-លោកស្រី នឹងរក្សាជាការសម្ងាត់ដោយពុំមានផលប៉ះពាល់ដល់លោក-លោកស្រីឡើយ។ សូមគោរពថ្លែងអំណរគុណចំពោះកិច្ចសហការ និងការចំណាយពេលវេលារបស់លោក-លោកស្រី ក្នុងការបំពេញកម្រងសំណួរនេះ។

សូមលោក-លោកស្រីបំពេញចម្លើយឬគូសសញ្ញា (✓) ក្នុងប្រអប់ ☐ ចម្លើយណាមួយ ដែលត្រូវនឹងស្ថានភាពជាក់ស្តែងរបស់លោក-លោកស្រី៖

ឈ្មោះវិទ្យាល័យ៖........................................................................

មុខវិជ្ជាឯកទេស៖........................................................................

១) ភេទ៖ ☐ ប្រុស ☐ ស្រី

២) មុខងារ/តួនាទី៖ ☐ នាយក ☐ នាយករង ☐ ប្រធានក្រុមបច្ចេកទេស ☐ គ្រូបង្រៀន

៣) កម្រិតវប្បធម៌៖ □ មធ្យមសិក្សាទុតិយភូមិ □ បរិញ្ញាបត្រ □ បរិញ្ញាបត្រជាន់ខ្ពស់ □ បណ្ឌិត

៤) បទពិសោធន៍ការងារ៖ □តិចជាង៥ឆ្នាំ □ពី៥ ទៅ៩ឆ្នាំ □ពី១០ ទៅ២០ឆ្នាំ □ លើសពី២០ឆ្នាំ

៥) តើលោក-លោកស្រី ធ្លាប់ចូលរួមវគ្គបណ្តុះបណ្តាលវិធីបង្រៀន និងរៀនបែបរិះរកទេ?

1) នាយក □ ធ្លាប់ □ មិនធ្លាប់

2) នាយករង □ ធ្លាប់ □ មិនធ្លាប់

3) ប្រធានក្រុម □ ធ្លាប់ □ មិនធ្លាប់

4) គ្រូបង្រៀន □ ធ្លាប់ □ មិនធ្លាប់

៦)តើលោកគ្រូ/អ្នកគ្រូគិតថា វិធីសាស្ត្របង្រៀនជាអ្វី?

□ជាលក្ខណៈនៃសំណុំគោលការណ៍ និតិវិធី ឬយុទ្ធសាស្ត្រ អនុវត្តដោយគ្រូបង្រៀន ដើម្បីសម្រេចការសិក្សាមួយសមស្របតាមបំណងប្រាថ្នារបស់សិស្ស

□គឺជាវិធីមួយដើម្បីសំរេចគោលដៅនៃការរៀនសូត្រ

□គឺជាប្រព័ន្ធនៃសកម្មភាពជាបន្តបន្ទាប់ និងមានសណ្តាប់ធ្នាប់របស់គ្រូ

□វាជាវិធីនៃសកម្មភាពដែលមានរបៀបរៀបរយនៃមុខវិជ្ជា និងកម្មវត្ថុនៃដំណើរការអប់រំ

៧)តើគ្រូបង្រៀនមានទស្សនៈយល់ឃើញដូចម្តេចអំពីសារៈសំខាន់នៃវិធីសាស្ត្របង្រៀននិងរៀនបែបរិះរិក?

□ដឹងអំពីសកម្មភាពដែលត្រូវបង្រៀន □ដឹងអំពីរបៀបនៃការបង្រៀនចំពោះមុខវិជ្ជាផ្សេងៗគ្នា □ផ្លាស់ប្តូរបច្ចេកទេសតាមដំណាក់កាលនៃសកម្មភាព □ដឹងអំពីមធ្យោបាយមានប្រសិទ្ធភាពក្នុងការផ្តល់ព័ត៌មាន □ជួយគ្រូក្នុងការប្រមើលមើលទៅលើកម្មវិធីសិក្សាទាំងមូល □ដឹងអំពីលំនាំនៃការរៀននិងបង្រៀន □ងាយស្រួលក្នុងការរៀបចំកិច្ចតែងការបង្រៀន □អាចសម្រេចវត្ថុបំណងមេរៀន □សិស្សទទួលបានចំណេះដឹងស្របតាមវត្ថុបំណងមេរៀន

៨)តើគ្រូបង្រៀនធ្លាប់បានប្រើប្រាស់វិធីសាស្ត្រទាំងនេះដែរឬទេ?

□វិធីបង្រៀន និងរៀនបែបរិះរក □វិធីបង្រៀនបែបឧទ្ទេស □វិធីបង្រៀន និងរៀនតាមគំរូ៥អ៊ី

□វិធីបង្រៀន និងរៀនបែបសហការ □វិធីបង្រៀន និងរៀនបែបដោះស្រាយបញ្ហា □វិធីបង្រៀន និងរៀនបែបពិភាក្សា □វិធីបង្រៀន និងរៀនបែបផែនទីគំនិត □វិធីបង្រៀនបែបចង្អុលបង្ហាញ □វិធីបង្រៀន និងរៀនបែបប្លមតាក់សូណូមី

៩) តើគ្រូបង្រៀនមានទស្សនៈយល់ឃើញដូចម្តេចអំពីវិធីសាស្ត្របង្រៀន និងរៀនបែបរិះរក?

□ការបង្រៀន និងរៀនតាមរយៈសំណួរស្រាវជ្រាវ □សិស្សរៀនបែបសហការ និងធ្វើការងារជាក្រុម □គ្រូជាអ្នកសម្របសម្រួល□គ្រូបង្រៀន សិស្សចាំតែធ្វើតាម □សិស្សរៀនស្រាវជ្រាវដោយខ្លួនឯង □គ្រូបង្កើតបាតុភូតមុនពេលបង្រៀន □ការបង្រៀន និងរៀនដែលមានបង្កើតសំណួរគន្លឹះ □ការបង្រៀន និងរៀនដែលមានរៀបចំផែនការ/សកម្មភាពស្រាវជ្រាវ □មានការវិភាគវាយតម្លៃ/សន្និដ្ឋានដោយសិស្ស

១០) តើគ្រូបង្រៀនមានទស្សនៈយល់ឃើញដូចម្តេចអំពីអភិវឌ្ឍជំនាញដល់សិស្សនៅពេលប្រើប្រាស់បង្រៀន និងរៀនបែបរិះរក(IBL)?

□ ដោះស្រាយបញ្ហា□គិតស៊ីជម្រៅ□វិភាគ/វាយតម្លៃ□ធ្វើផែនការ/ស្រាវជ្រាវ□ច្នៃប្រឌិត/បង្កើតថ្មី □ បង្កើតភាពម្ចាស់ការ □បង្កើនការចូលរួមសហការ/ធ្វើការងារក្រុម □លើកកម្ពស់ការរៀនបែបស្រាវជ្រាវ □ទាំងអស់ខាងលើ

១១) តើគ្រូបង្រៀនមានទស្សនៈយល់ឃើញដូចម្តេចអំពីវិធីបង្រៀនដែលទាក់ទងនឹងវិធីសាស្ត្របង្រៀន និងរៀនបែបរិះរក(IBL)?

□វិធីបង្រៀនបែបសហការ □វិធីបង្រៀនបែបសិស្សមជ្ឈមណ្ឌល □វិធីបង្រៀនបែបគ្រូមជ្ឈមណ្ឌល □វិធីបង្រៀនបែបស្ថាបនា □វិធីបង្រៀនបែបសកម្ម □វិធីបង្រៀនបែបអកម្ម □វិធីបង្រៀនបែបប្រពៃណីនិយម □វិធីបង្រៀនតាមគំរូ៥អ៊ី

១២) តើគ្រូបង្រៀនមានទស្សនៈយល់ឃើញដូចម្តេចអំពីការប្រើប្រាស់ជំហាននៅក្នុងវិធីសាស្ត្របង្រៀន និងរៀនបែបរិះរិក(IBL)?

□បង្កើតបាតុភូត □កំណត់វត្ថុបំណង/បញ្ហា □បង្កើតសំណួរគន្លឹះ/សម្មតិកម្ម

□ធ្វើផែនការ/ប្រមូលទិន្នន័យ/តេស្តសម្មតិកម្ម/ពិសោធន៍ □វិភាគទិន្នន័យ/ទាញសេចក្ដីសន្និដ្ឋាន

១៣) តើការបង្រៀនផ្អែកលើជំហានទាំង៥នៃវិធីបង្រៀន និងរៀនបែបរិះរកសិស្សទទួលបានលទ្ធផលបែបណា?

□យល់ច្បាស់វត្ថុបំណងមេរៀន □ចេះកំណត់បញ្ហា/បង្កើតសម្មតិកម្មបានត្រឹមត្រូវ □យល់ខ្លឹមសារមេរៀនច្បាស់លាស់ □ចេះធ្វើផែនការ/ពិសោធន៍ □ចេះអង្កេត/វាស់វែងលទ្ធផល □ចេះវិភាគ/សំយោគ □ចេះវាយតម្លៃ/បង្កើតគំនិតថ្មី

១៤) វិធីបង្រៀននិងរៀនបែបរិះរក (IBL) គឺជាវិធីសាស្ត្រស្ថិតនៅក្នុងគោលវិធីអ្វី?

□សិស្សមជ្ឈមណ្ឌល □គ្រូមជ្ឈមណ្ឌល □ទាំងពីរខាងលើ □ ផ្សេងៗ....................

១៥)តើការបង្កើត«បាតុភូត/ព្រឹត្តិការណ៍»ក្នុងការបង្រៀននិងរៀនបែបរិះរកផ្អែកកត្តាអ្វីខ្លះ?

□វត្ថុបំណងមេរៀន □ខ្លឹមសារមេរៀន □សង្កេតបាតុភូតធម្មជាតិ □សង្កេតព្រឹត្តិការណ៍សង្គម □អង្កេតរូបភាព/វីដេអូដែលទាក់ទង □ប្រាប់អំពីវត្ថុបំណងមេរៀនដោយផ្ទាល់ □ផ្សេងៗ...........

១៦) តើ«សំណួរគន្លឹះ»ត្រូវបង្កើតឡើងយ៉ាងដូចម្ដេច?

□ទាក់ទងវត្ថុបំណងមេរៀន □ទាក់ទងខ្លឹមសារមេរៀន □ទាក់ទងប្រធានបទនៃការស្រាវជ្រាវ □សេចក្ដីសន្និដ្ឋាននិងវត្ថុបំណងមេរៀនត្រូវឆ្លុះបញ្ចាំងគ្នា □ចម្លើយទាំងអស់ខាងលើ

១៧) ក្នុងដំណាក់កាល«ធ្វើផែនការ/ប្រមូលទិន្នន័យ/តេស្តសម្មតិកម្ម/ពិសោធន៍»គ្រូរៀបចំដំណើការរៀននិងបង្រៀនយ៉ាងដូចម្ដេច?

□ឱ្យសិស្សធ្វើការជាក្រុម □ចែកតួនាទីទទួលខុសត្រូវ □ឱ្យសិស្សប្រមូលព័ត៌មាន □ឱ្យសិស្សស្វែងរកភស្តុតាង □ឱ្យសិស្សចែករំលែកព័ត៌មាន/ភស្តុតាង □ឱ្យសិស្សរៀបចំធ្វើពិសោធន៍ □ឱ្យសិស្សរៀបចំបកស្រាយ/វិភាគទិន្ន័យ □ឱ្យសិស្សធ្វើសេចក្ដីសន្និដ្ឋានរួមគ្នា □គ្រូសម្របសម្រួល/សំយោគលទ្ធផល

១៨) ក្នុងដំណាក់កាល«វិភាគ/ទាញសេចក្ដីសន្និដ្ឋាន»គ្រូនិងសិស្សមានតួនាទីធ្វើអ្វីខ្លះ?

□សិស្សជាអ្នកបង្ហាញភស្តុតាង □សិស្សជាអ្នកបកស្រាយ/វិភាគព័ត៌មាន □សិស្សជ្រើសរើសចម្លើយផ្អែកលើសំណួរគន្លឹះ □សិស្សជ្រើសរើសចម្លើយផ្អែកលើវត្ថុបំណងមេរៀន □សិស្សបដិសេធចម្លើយដែលខុស □គ្រូសម្របសម្រួល □គ្រូសំយោគ/ផ្តល់ព័ត៌មានត្រឡប់

១៩) តើលោកគ្រូ/អ្នកគ្រូមានទស្សនៈបែបណាចំពោះមុនការធ្វើកិច្ចតែងការបង្រៀនបែបរិះរក?

□យល់ដឹងខ្លឹមសារមេរៀន□យល់ដឹងពីវត្ថុបំណងមេរៀន□យល់ដឹងសមត្ថភាពចំណេះដឹងសិស្ស □យល់ដឹងរបៀបប្រើប្រាស់ជំហានទាំង៥របស់IBL □យល់ដឹងរបៀបរៀបចំសិស្សជាក្រុម □យល់ដឹងបាតុភូត/ព្រឹត្តិការណ៍សង្គមក្នុងការបង្កើតសំណួរគន្លឹះ □យល់ពីបាតុភូត/ព្រឹត្តិការណ៍សង្គមទាក់ទងជីវភាពរស់នៅប្រចាំថ្ងៃរបស់សិស្ស

២០) តើដំណើរការរៀបចំកិច្ចតែងការបង្រៀន និងរៀនបែបរិះរកមានលក្ខណៈបែបណា?

□កំណត់បាតុភូតដែលត្រូវបង្ហាញ □កំណត់វត្ថុបំណងមេរៀនឱ្យបានជាក់លាក់ □រៀបចំ/កំណត់សំណួរគន្លឹះ □រៀបចំលទ្ធផលរំពឹងទុកពីការស្រាវជ្រាវ/ប្រមូលទិន្នន័យរបស់សិស្ស □រៀបចំពន្យល់/បកស្រាយ/វិភាគ/ទាញសេចក្តីសន្និដ្ឋាន □រៀបចំផ្តល់ព័ត៌មានត្រឡប់ □ដាក់ឱ្យសិស្សពិភាក្សាអំពីអ្វីដែលត្រូវសង្កេត □ឱ្យសិស្សចែករំលែកមតិយោបល់រវាងគ្នា □គ្រូជាអ្នកសម្របសម្រួល

២១) តើគ្រូបង្រៀនគួរមានចំណេះដឹងបន្ថែមអ្វីខ្លះក្រៅពីចំណេះដឹង IBL?

□ចំណេះដឹងព័ត៌មានវិទ្យា(ICT)□ចំណេះដឹងភាសាបរទេស □ចំណេះដឹងអំពីវិធីសាស្ត្របង្រៀន □ចំណេះដឹងចិត្ត-គរុកោសល្យ □ចំណេះដឹងសីលធម៌វិជ្ជាជីវៈ □ចំណេះដឹងទូទៅ □ផ្សេងៗ........................................

២២) តើវិធីបង្រៀន និងរៀនបែបរិះរកអាចប្រើប្រាស់ចំពោះសិស្សប្រភេទណាខ្លះ?

□សិស្សខ្សោយ □សិស្សមធ្យម □សិស្សបង្គួរ □សិស្សពូកែ □សិស្សគ្រប់ប្រភេទ

២៣) តើលោកគ្រូ/អ្នកគ្រូរៀបចំក្រុមសិស្សពិភាក្សាយ៉ាងដូចម្តេចពេលបង្រៀនIBL?

□ សិស្សខ្សោយ មធ្យម បង្គួរ□សិស្សខ្សោយ មធ្យម ពូកែ□សិស្ស មធ្យម បង្គួរ ពូកែ□សិស្សចម្រុះ

☐ ផ្សេងៗ.............................

២៤) តើលោកគ្រូ/អ្នកគ្រូយល់ឃើញបែបណាអំពីការប្រើប្រាស់វិធីបង្រៀន និងរៀនបែបរិះរក(IBL)នៅតាមសាលារបស់លោកគ្រូ/អ្នកគ្រូ?

.......................................................................................................................

.......................................................................................................................

.......................................................................................................................

.......................................................................................................................

.......................................................................................................................

២៥) តើលោកគ្រូ/អ្នកគ្រូយល់ឃើញបែបណាអំពីបញ្ហាប្រឈមចំពោះការប្រើប្រាស់វិធីបង្រៀន និងរៀនបែបរិះរក(IBL)?

.......................................................................................................................

.......................................................................................................................

.......................................................................................................................

.......................................................................................................................

.......................................................................................................................

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា

លេខ: ១៤៣៥ អយក.នទន

# លិខិតឧទ្ទេសនាម

យោង ៖ - លិខិតលេខ៣៣៦២ អយក.វជអ ចុះថ្ងៃទី០៩ ខែកក្កដា ឆ្នាំ២០១៩។

- បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។
- ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៨ និងទី៩ ឆ្នាំសិក្សា២០២០-២០២១ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០២១។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជាគ្រូដឹកនាំគោល និងគ្រូដឹកនាំរង សម្រាប់ការសរសេរនិក្ខេបបទរបស់និស្សិតបង់ថ្លៃថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៨ ឆ្នាំសិក្សា២០១៩-២០២១ ដែលបានទទួលការបណ្តុះបណ្តាលនៅវិទ្យាស្ថានជាតិអប់រំ៖

| ល.រ | គ្រូដឹកនាំបង្គោល | គ្រូដឹកនាំរង | ប្រធានបទស្រាវជ្រាវ | និស្សិត |
|---|---|---|---|---|
| ១ | លោកបណ្ឌិត ឈាង សង្វាត | លោក សៀង វិសនា | គំរូនៃភាពជាអ្នកដឹកនាំគ្រប់គ្រងសាលារៀនរបស់នាយកមធ្យមសិក្សាទុតិយភូមិក្រោមគម្រោងកែលម្អការអប់រំមធ្យមសិក្សាក្នុងខេត្តបន្ទាយមានជ័យ | លោក ចាន់ សុភាព |
| ២ | ឯកឧត្តមបណ្ឌិត ទី ខាំប៉ូលី | លោក សៀង វិសនា | ពង្រឹងការបង្រៀនរបស់គ្រូ តាមរយៈការអភិវឌ្ឍវិធីសាស្ត្របង្រៀន មុខវិជ្ជាជីវវិទ្យា ករណីសិក្សាស្រុករំដួលខេត្តស្វាយរៀង | លោក ជឹម សំហៃ |
| ៣ | លោក ឡុច ចាន់ថន | លោកបណ្ឌិត នី រដ្ឋា | ទស្សនៈនាយកសាលា និងប្រធានក្រុមបច្ចេកទេសស្តីពីការប្រើប្រាស់វិធីសាស្ត្របង្រៀននៅសាលាមធ្យមសិក្សាទុតិយភូមិ .ករណីសិក្សាសាលាវិទ្យាល័យដែលបណ្តុះបណ្តាលដោយវិទ្យាស្ថានជាតិអប់រំនៅខេត្តកណ្តាល. | លោក ធឿង យន |
| ៤ | លោកបណ្ឌិត នូវ វីរ៉ា | លោក ចាន់ ធឿន | ការចូលរួមរបស់សហគមន៍ក្នុងការលើកកម្ពស់លទ្ធផលសិក្សារបស់សិស្សនៅមធ្យមសិក្សាទុតិយភូមិក្នុងខេត្តស្វាយរៀង | លោក ផាន់ សំអាត |

| | | | | |
|---|---|---|---|---|
| ៥ | លោក<br>ប៉ូ បុន្នន | ឯកឧត្តមបណ្ឌិត<br>សៀង សុវណ្ណា | សមត្ថភាពនាយកសាលាបឋមសិក្សាក្នុងការអនុវត្តផែនការប្រតិបត្តិប្រចាំឆ្នាំ ករណីសិក្សាក្នុងរាជធានីភ្នំពេញ | លោក មូល ម៉ង់ |
| ៦ | លោកស្រី<br>ប៊ិន សុផានី | លោកបណ្ឌិត<br>ឈាង សង្វាត | ការអនុវត្តការគ្រប់គ្រង របស់នាយកសាលាមធ្យមសិក្សាទុតិយភូមិ ធៀបនឹងការគ្រប់គ្រងសាលារៀនដោយផ្អែកលើលទ្ធផល(SBM) នៅស្រុកស្វាយជ្រំ ខេត្តស្វាយរៀង | លោក រស់ សារ៉ាង |
| ៧ | លោក<br>លន លីណា | លោកបណ្ឌិត<br>នី រដ្ឋា | ស្ថានភាពការគ្រប់គ្រងបរិស្ថានសាលារៀន នៅមធ្យមសិក្សាទុតិយភូមិនៅក្នុងខេត្តព្រៃវែង | លោក រឹម សារាត់ |
| ៨ | លោកបណ្ឌិត<br>កាង ស៊ិងឆាង | លោក<br>ម៉ែន សុខសុន្ទី | ការយល់ឃើញរបស់គ្រូទៅលើភាពជាអ្នកដឹកនាំបង្ហាត់បង្រៀននៅសាលា WESTERN ក្នុងរាជធានីភ្នំពេញ | ល.ស ស៊ា គីមលី |
| ៩ | លោកបណ្ឌិត<br>ឈូក ច័ន្ទឆាយា | លោក<br>ចាប រតនា | ការដឹកនាំគ្រប់គ្រងថ្នាក់រៀនរបស់គ្រូឧទ្ទេសមុខវិជ្ជាសីលធម៌-ពលរដ្ឋវិជ្ជា នៅមជ្ឈមណ្ឌលគរុកោសល្យភូមិភាគខេត្តកណ្តាល | ល.ស សុខ ផល្លី |
| ១០ | លោក<br>ឌី បុណ្ណា | ឯកឧត្តមបណ្ឌិត<br>សៀង សុវណ្ណា | ប្រសិទ្ធភាពនៃការអនុវត្តរបាយការណ៍អធិការកិច្ចតាមកាលកំណត់របស់សាលារៀន ៖ករណីសិក្សាខេត្តឧត្តរមានជ័យ | លោក អ៊ឹម សានី |
| ១១ | លោកបណ្ឌិត<br>អាន វ៉ូប្រាវ | លោក<br>លន លីណា | ទស្សនៈរបស់គ្រូបង្រៀននៅកម្រិតមធ្យមសិក្សាបឋមភូមិចំពោះការអនុវត្តការសិក្សាពីចម្ងាយនៅរាជធានីភ្នំពេញ | លោក សំ ហាន |

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអនុវត្តការងារឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ៧កើត ខែបឋមាសាឍ ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**
- -អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- -ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី " ដើម្បីជ្រាបជាព័ត៌មាន"
- -គ្រប់អង្គភាពក្រោមឱវាទក្រសួងអយក ដែលមានការពាក់ព័ន្ធ " ដើម្បីជ្រាបជាព័ត៌មាន"
- -សាមីខ្លួន " ដើម្បីអនុវត្ត"
- -កាលប្បវត្តិ
- -ឯកសារ រ៉ៃអ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ២៤០៩ អយក.ទំ.ស

ថ្ងៃ[illegible] ខែ[illegible] ឆ្នាំឆ្លូវ ត្រីស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០២១

**ជម្រាបមក**
**លោក លោកស្រី ប្រធានមន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត**

**កម្មវត្ថុ៖** ការចុះប្រមូលទិន្នន័យ ដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៨។

**យោង៖** -លិខិតលេខ១៤៣៤ អយក.ឧទន ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១។
-លិខិតលេខ១៤៣៥ អយក.ឧទន ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០២១។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាបជូន **លោក លោកស្រី ប្រធាន** ជ្រាបថា៖ និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៨ ចំនួន៣១នាក់ ត្រូវបានអនុញ្ញាតឱ្យចុះប្រមូលទិន្នន័យនៅតាមរាជធានី-ខេត្តនានាតាមប្រព័ន្ធអនឡាញ ដើម្បីសរសេរនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចាប់ពីថ្ងៃទី០៥ ខែកក្កដា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី៣១ ខែសីហា ឆ្នាំ២០២១។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម **លោក លោកស្រី ប្រធាន** ជួយសម្រួល និងសហការដល់ការចុះប្រមូលទិន្នន័យខាងលើតាមការគួរ។

សូម **លោក លោកស្រី ប្រធាន** ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ។

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

**ចម្លងជូន៖**
- អគ្គនាយកដ្ឋានរដ្ឋបាលនិងហិរញ្ញវត្ថុ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី
- សាលារាជធានី ខេត្តពាក់ព័ន្ធ

"ដើម្បីជូនជ្រាបជាព័ត៌មាន"
- កាលប្បវត្តិ
- ឯកសារ វិទ្យាស្ថានជាតិអប់រំ

អាគារលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
វិទ្យាល័យ ហ៊ុន សែន អង្គស្នួល

ខ្ញុំបាទឈ្មោះ **ឡឿង ឃន** ជាគ្រូបង្រៀននៃវិទ្យាល័យ **ហ៊ុន សែន** អង្គស្នួល និងជានិស្សិតបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៃវិទ្យាស្ថានជាតិអប់រំ។

**សូមគោរពជូន**
**លោកប្រធានមន្ទីរអប់រំ យុវជន និងកីឡា ខេត្តកណ្ដាល**

**ជាទីគោរពដ៏ខ្ពង់ខ្ពស់!**

**កម្មវត្ថុ:** ការប្រមូលទិន្នន័យ ដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៨ នៃវិទ្យាស្ថានជាតិអប់រំ

**យោង:** -លិខិតលេខ ២៤០៩ អយក.វជអ ចុះថ្ងៃ សុក្រ៧កើត ខែទុតិយសាឍ ឆ្នាំឆ្លូវ ទោស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ២០២១ របស់ក្រសួងអប់រំ យុវជន និងកីឡា

-លិខិតលេខ ១៤៣៥ អយក. ឧទន ចុះថ្ងៃ ពុធ៧កើត ខែបឋមសាឍ ឆ្នាំឆ្លូវ ទោស័ក ព.ស ២៥៦៥ ត្រូវនឹងថ្ងៃទី ១៦ ខែមិថុនា ឆ្នាំ២០២១ របស់ក្រសួងអប់រំ យុវជន និងកីឡា

តតាមកម្មវត្ថុ និងយោងខាងលើ សូមលោកប្រធានអនុញ្ញាតឱ្យខ្ញុំបាទជានិស្សិតបរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៨ នៃវិទ្យាស្ថានជាតិអប់រំចុះប្រមូលទិន្នន័យតាមប្រព័ន្ធអនឡាញនៅតាមវិទ្យាល័យចំនួន១៤ នៅក្នុងក្រុង/ស្រុកចំនួន៥ នៃខេត្តកណ្ដាលចាប់ពីថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ២០២១ ដល់ថ្ងៃទី ៣១ ខែសីហា ឆ្នាំ២០២១ ក្នុងគោលបំណងដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សាសម្រាប់ឆ្នាំសិក្សា២០១៩-២០២១។ វិទ្យាល័យគោលដៅនៃការសិក្សាស្រាវជ្រាវមានដូចជា៖

| ល.រ | ឈ្មោះសាលា | ស្រុក/ក្រុង | ល.រ | ឈ្មោះសាលា | ស្រុក/ក្រុង |
|---|---|---|---|---|---|
| ១ | វិទ្យាល័យ ហ៊ុន សែន សេរីភាព | តាខ្មៅ | ៨ | វិទ្យាល័យ ហ៊ុន សែន កោះចិន | ពញាឮ |
| ២ | វិទ្យាល័យ ហ៊ុន សែន តាខ្មៅ | តាខ្មៅ | ៩ | វិទ្យាល័យ ហ៊ុន សែន អង្គស្នួល | អង្គស្នួល |
| ៣ | វិទ្យាល័យ ហ៊ុន សែន កោះធំ | កោះធំ | ១០ | វិទ្យាល័យ ហ៊ុន សែន អង្គពពាយ | អង្គស្នួល |
| ៤ | វិទ្យាល័យ ហ៊ុន សែន ព្រែកតាជ្រូង | កោះធំ | ១១ | វិទ្យាល័យ ថ្នល់ទទឹង | អង្គស្នួល |
| ៥ | វិទ្យាល័យ ហ៊ុន សែន សំពៅពូន | កោះធំ | ១២ | វិទ្យាល័យ ហ៊ុន សែនកំពង់កន្ទួត | កណ្ដាលស្ទឹង |
| ៦ | វិទ្យាល័យ ហ៊ុន សែន ព្រះធម្មស្រះ | ពញាឮ | ១៣ | វិទ្យាល័យ ប៊ុន រ៉ានីហ៊ុន សែន ដើមឬស្ស | កណ្ដាលស្ទឹង |
| ៧ | វិទ្យាល័យ ហ៊ុន សែន អ្នកុង | ពញាឮ | ១៤ | វិទ្យាល័យ ព្រែកស្លែង | កណ្ដាលស្ទឹង |

អាស្រ័យដូចបានជម្រាបជូនខាងលើ សូមលោកប្រធានមេត្តាជួយសម្រួល និងសហការដល់ការចុះប្រមូលទិន្នន័យតាមការគួរ។

សូម **លោកប្រធាន** មេត្តាទទួលនូវការរាប់អាន និងសេចក្ដីគោរពខ្ពង់ខ្ពស់ពីខ្ញុំ។

ថ្ងៃចន្ទ២រោច ខែទុតិយសាឍ ឆ្លូវ ត្រីស័ក ព.ស២៥៦៥
អង្គស្នួល,ថ្ងៃទី ២៦ ខែកក្កដា ឆ្នាំ២០២១
ហត្ថលេខាសាម៉ីខ្លួន

**ឡឿង ឃន**

<u>សូមគោរពជូនភ្ជាប់មកជាមួយនូវ៖</u>
- តារាងទិន្នន័យ ចំនួន ០១ ច្បាប់

លេខ [illegible]
បានឃើញ និង [illegible]
ថ្ងៃ [illegible] ខែ [illegible] ឆ្នាំ [illegible] ព.ស២៥៦៥
[illegible] ថ្ងៃ [illegible] ខែ [illegible] ឆ្នាំ ២០២១
**ប្រធានមន្ទីរអប់រំ យុវជន និងកីឡា ខេត្តកណ្ដាល**

**ចេង_សំអ៊ុល**